# កច្ចាយនូបត្ថម្ភកៈ

# ១

Kaccāyanūpatthambhaka

បោះពុម្ពចែកជាធម្មទាន

ព.ស. ២៥៥៨ គ.ស. ២០១៥

Printed for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org
Website:http://www.budaedu.org
Mobile Web: m.budaedu.org
**This book is strictly for free distribution, it is not to be sold.**
សម្រាប់ចែកជាធម្មទាន

# សេចក្តីយល់ឃើញ

របស់ព្រះសិរីសម្មតិវង្ស (អែម) ចាងហ្វាងសាលាបាឡីជាន់ខ្ពស់ ។

សៀវភៅកច្ចាយនូបត្ថម្ភកៈ ដែលព្រះសាសនសោភ័ណ (ជួន-ណាត) ចាងហ្វាងរងសាលាបាលីជាន់ខ្ពស់ បានដកស្រង់យកសេចក្តីពីគម្ពីរវិធីមូលដទៃជាច្រើនមករៀបរៀង ជាបែបវេយ្យា-ករណ៍ សម្រាប់រៀនភាសាបាឡី ជាគ្រឿងជំនួយជួយការសិក្សាមូលកច្ចាយនៈឲ្យបានងាយឡើង ជាការចម្រើនក្នុងព្រះពុទ្ធសាស-នា ឧបមាដូច បុគ្គលតាក់តែងប្រទីបផ្ងាលាអុចបំភ្លឺដល់អ្នកស្រុកដែលស្ថិតនៅ ក្នុងទីងងឹតឲ្យបានភ្លឺច្បាស់រាល់គ្នា កុលបុត្រដែលសិក្សាក្នុងព្រះពុទ្ធសាសនា បើគ្មានបែបផែននឹងរៀនសូត្រហើយដូចជាទីងងឹតមិនដឹងគិតដូចម្តេចនឹងយល់បាន បើបានសៀវភៅកច្ចាយនូបត្ថម្ភកៈនេះហើយ មុខជានឹងបានភ្លឺចម្រើនវិជ្ជាខាងភាសាបាឡីនេះជាឆាប់ងាយនឹងរៀនទន្ទេញចេះចាំស្ទាត់បាន មិន

បាច់ទន្ទេញមេសូត្រដូចជាន់មុនក៏បាន គ្រាន់តែទន្ទេញបែបនេះឲ្យចាំស្ទាត់ហើយក៏អាចនឹងដឹងខុសត្រូវក្នុងវិធីប្រែ និងសូត្រធម៌ជាភាសាបាឡីត្រឹមត្រូវទៅបាន ។ ព្រោះខ្ញុំបានឲ្យភិក្ខុ-សាមណេរសិក្សារៀនសូត្របែបនេះជាយូរឆ្នាំមកហើយ ឃើញថារៀនទៅឆាប់យល់ឆាប់ចេះមែន ខ្ញុំមានសេចក្តីសង្ឃឹមថាការរៀនសូត្រក្នុងព្រះពុទ្ធសាសនានឹងរុងរឿងឡើងដោយពិត ។

សូមចម្រើនសព្ទសាធុការពរ ដល់ព្រះសាសនសោភ័ណ (ជួន-ណាត) ចាងហ្វាងរងសាលាបាឡីជាន់ខ្ពស់ ដែលបានរៀបរៀងកច្ចាយនូបត្ថម្ភកៈ ឲ្យកើតឡើងដោយកម្លាំងព្យាយាមរបស់លោក ឲ្យបានសេចក្តីសុខសេចក្តីចម្រើនគ្រប់ជំពូកក្នុងព្រះពុទ្ធ-សាសនាតរៀងទៅ ។

# គាថាមុខ

បែបរៀនភាសាបាឡីនេះ ខ្ញុំបានរៀបរៀងហើយស្រេច តាំងពីកាលពុទ្ធសករាជ ២៤៥២ គ្រិស្តសករាជ ១៩១០ ខ្ញុំបានសន្មតឈ្មោះបែបរៀននេះថា "កច្ចាយនូបត្ថម្ភកៈ" ប្រែថា "វេយ្យាករណ៍ជាជំនួយកច្ចាយនៈ" គឺជាបែបសម្រាប់រៀនអមជាមួយនឹងកច្ចាយនបករណ៍ ជាបែបសម្រាប់នាំមុខការសិក្សាបាឡីភាសាក្នុងគម្ពីរកច្ចាយនៈឲ្យងាយយល់ ជាងការសិក្សាចំពោះកច្ចាយនបករណ៍សុទ្ធ ។

កច្ចាយនូបត្ថម្ភកៈនេះ ចែកជានិទ្ទេសមាន ៧ យ៉ាងតាមឈ្មោះកច្ចាយនបករណ៍ គឺ

១- អក្ខរវិធីនិទ្ទេស សម្តែងអំពី សមញ្ញាភិធាន គឺ អក្ខរវិធី និង សន្ធិ បែបតអក្សរក្នុងបាឡីភាសា ។

២- នាមនិទ្ទេស សម្តែងអំពី នាមសព្ទ ព្រមទាំង លិង្គ, វចនៈ, វិភត្តិ, ការន្ត, សំខ្យាសព្ទ និង អព្យយសព្ទ ។

៣- សមាសនិទ្ទេស សម្ដែងអំពីកិច្ចរបស់សមាស និង ឈ្មោះរបស់សមាស តាមលំដាប់ ដោយសង្ខេប ។

៤- តទ្ធិតនិទ្ទេស សម្ដែងអំពីឈ្មោះតទ្ធិត ព្រមទាំងបច្ច័យ តាមលំដាប់ក្នុងកច្ចាយនបករណ៍ ។

៥- អាខ្យាតនិទ្ទេស សម្ដែងអំពី វិភត្តិ (អាខ្យាត), កាល, បទ, វចនៈ, បុរិសៈ, ធាតុ, វាចកៈ, បច្ច័យ និង បែបបំបែកធាតុ រៀបរៀងជារបៀប តាមលំដាប់ តែជាសង្ខេបណាស់ ។

៦- កិតកនិទ្ទេស សម្ដែងអំពី នាមកិតកៈ និង កិរិយាកិតកៈ ព្រមទាំង សាធនៈ, វិភត្តិ (នាម), វចនៈ, កាល, ធាតុ, វាចកៈ និង បច្ច័យ ដោយសង្ខេប ។

៧- ឧណាទិនិទ្ទេស សម្ដែងអំពីបច្ចេកបច្ច័យខ្លះ ដែល ប្លែកគ្នាអំពីបច្ច័យក្នុងកិតកនិទ្ទេស ព្រមទាំងឧទាហរណ៍ដោយ សង្ខេប ។

បន្ទាប់អំពីឧណាទិនិទ្ទេសទៅ ខ្ញុំបានរៀបរៀងរូបសិទ្ធិ គឺ វិធីតាំងតួសម្រេចរូបសព្ទបាឡី តាមលទ្ធិវេយ្យាករណបណ្ឌិត

អំពីបូរាណ ទុកជាបែបដោយឡែក សម្រាប់កុលបុត្រអ្នកសិក្សាកច្ចាយនបករណ៍ តែបែបរូបសិទ្ធិនោះមិនរាប់បញ្ចូលជានិទ្ទេសក្នុងកច្ចាយនូបត្ថម្ភកៈនេះទេ ។

លុះបានរៀបរៀងបែបរៀនបាឡីនេះស្រេចហើយ ខ្ញុំបានបង្រៀនល្បងមើល គឺបានឲ្យអ្នករៀនទន្ទេញបែបនេះឲ្យចាំមាត់ដោយអន្លើ ៗ ចំពោះតែត្រង់ណាដែលត្រូវទន្ទេញឲ្យចាំនោះ ហើយខ្ញុំបង្រៀនកច្ចាយនបករណ៍ផង យកបែបក្នុងកច្ចាយនូ-បត្ថម្ភកៈនេះមកអធិប្បាយពន្យល់ផ្សំជាជំនួយផង ក៏ឃើញមានសេចក្ដីចម្រើនដោយឆាប់រហ័ស ជាងការបង្រៀនកច្ចាយនប-ករណ៍សុទ្ធ ។

លុះដល់មកពុទ្ធសករាជ ២៤៥៧ គ្រិស្តសករាជ ១៩១៥ លោកគ្រូព្រះមហាវិមលធម្ម (ព្រហ្មបណ្ឌិតោ) នាមដើម (ថោង) ចាងហ្វាងសាលាបាឡី បានអនុញ្ញាតយល់ព្រមឲ្យបញ្ចូលបែបកច្ចាយនូបត្ថម្ភកៈនេះ ក្នុងការបង្រៀនសិស្សសម្រាប់ថ្នាក់មូលវិជ្ជា គឺថ្នាក់ឆ្នាំទី ១, ក្នុងសាលាបាឡី ។ ឯការបង្រៀនក្នុងថ្នាក់នោះ

ក៏គង់មិនបោលកច្ចាយនបករណ៍ទេ ប៉ុន្តែយកបែបក្នុងកច្ចាយនូ-បត្ថម្ភកៈនេះមកសរសេរនឹងក្ដារ (តាប្លូ) ឲ្យអ្នករៀនចម្លងហើយអាចារ្យបានអធិប្បាយពន្យល់ជាជំនួយកច្ចាយនៈដរាប ។ ចាប់ដើមតាំងពីឆ្នាំនោះមក បែបកច្ចាយនូបត្ថម្ភកៈនេះក៏ផ្សាយចេញជាសៀវភៅច្រើនចប់ ដោយសារអ្នករៀនចេះតែសរសេរចម្លង ត ៗ រៀងរាល់ឆ្នាំមក ទាំងសេចក្ដីចម្រើននៃការសិក្សាបាឡីភាសាសោត ក៏ចេះតែលូតលាស់ឡើងដោយលំដាប់ឆាប់រហ័សជាងអំពីដើម ។

លុះដល់មកពុទ្ធសករាជ ២៤៦៦ គ្រិស្តសករាជ ១៩២៤ ខ្ញុំបានរៀបរៀងអក្ខរវិធីនិទ្ទេស និងនាមនិទ្ទេស ជាបែប ១ យ៉ាងទៀតផ្សេងច្រើនអន្លើអំពីបែបមុន ហើយខ្ញុំបានឆ្លៀតបង្រៀនភិក្ខុសាមណេរនៅទីកុដិលំនៅរបស់ខ្ញុំក្នុងវេលាយប់ ៗ បង្រៀនចំពោះតែកច្ចាយនូបត្ថម្ភកៈសុទ្ធ មិនបាច់បង្រៀនកច្ចាយនបករណ៍ គឺឲ្យអ្នករៀនចាប់ទន្ទេញបែបនោះតែម្ដង មិនបាច់ឲ្យទន្ទេញមេ-សូត្រឡើយ ។ លុះបង្រៀនតាមបែបនេះទៅ ក៏ឃើញមានសេចក្ដីចម្រើនឆាប់ជាងពីមុនដោយច្រើន គឺកាលបើអ្នករៀន

បានទន្ទេញបែបក្នុងកច្ចាយនូបត្ថម្ភកៈចាំស្ទាត់រត់មាត់ហើយ ខ្ញុំបង្រៀនដោយអធិប្បាយពន្យល់បែបទាំងនោះ ព្រមទាំងសម្ពន្ធផង ត្រឹមតែ ៣ ខែឬ ៤ ខែប៉ុណ្ណោះ (តាមដោយអ្នករៀនមានប្រាជ្ញាខ្លាំងនិងខ្សោយ) ក៏ចប់កច្ចាយនូបត្ថម្ភកៈទាំង ៧ និទ្ទេស ហើយបានស្ទង់កម្លាំងចំណេះរបស់អ្នករៀនទៅ ឃើញមានផ្លូវយល់ជ្រៅទូលាយច្រើន មិនសូវទើសទាក់ប៉ុន្មាន ទាំងសេចក្ដីឈ្លាសវៃក៏សឹងមានក្រាស់ក្រែល ។

ដល់មកក្នុងពុទ្ធសករាជ ២៤៧៤ គ្រិស្តសករាជ ១៩៣២ នេះព្រះរាជបណ្ណាល័យមានសេចក្ដីត្រូវការនឹងបោះពុម្ពកច្ចានយនូ-បត្ថម្ភកៈនេះ ដើម្បីនឹងផ្សាយចេញជាប្រយោជន៍ដល់ការសិក្សាភាសាបាឡី ។ ខ្ញុំក៏បានខំប្រឹងផ្ទៀងផ្ទាត់បែបរៀននេះថែមម្ដងទៀត បានផ្លាស់អក្ខរវិធីនិទ្ទេស និងនាមនិទ្ទេស យកតាមបែបដែលខ្ញុំរៀបរៀងលើកខាងក្រោយ ព្រោះឃើញថាជាបែបមានទំនងស្រួលរៀនជាងបែបដែលខ្ញុំបានរៀបរៀងជាន់មុន ។ ឯបែបតាំងពីសមាសនិទ្ទេសរៀងទៅដល់ឧណាទិនិទ្ទេស ខ្ញុំនឹងរៀបចំឲ្យបានស្រួលជាងទំនងមុននោះមិនទាន់ គ្រាន់តែថែមថយខ្លះ

បន្តិចបន្តួចដោយអន្លើ ៗ ពីព្រោះព្រះរាជបណ្ណាល័យមានសេចក្តីត្រូវការដោយប្រញឹកប្រញាប់ពេក ។

ខ្ញុំមានសេចក្តីស្តាយជាបំផុត ដោយហេតុមិនបានដាក់សម្ពន្ធនិទ្ទេស "វិធីសម្តែងអំពីបែបសម្ពន្ធ" មកក្នុងកច្ចាយនូបត្ថម្ភកៈនេះផង ពីព្រោះរៀបចំក្នុងកាលនេះមិនទាន់ ។ ប៉ុន្តែខ្ញុំមានបំណងមាំថា តទៅខាងមុខបើជីវិតសង្ខារព្រមទាំងដំណើរប្រព្រឹត្តទៅនៃករជកាយរបស់ខ្ញុំតាំងនៅដោយប្រពៃ ល្មមឆ្លៀតខំប្រឹងបាន ខ្ញុំនឹងរៀបចំសម្ពន្ធនិទ្ទេសនោះតទៅទៀត ហើយនឹងរៀបរៀងឲ្យជានិទ្ទេសទី ៨ ជាលំដាប់អំពីឧណាទិនិទ្ទេសទៅ ។ មិនត្រឹមតែប៉ុណ្ណោះឡើយ បើតទៅខាងមុខមានទំនងនិងឱកាសដ៏សមគួរ នោះខ្ញុំនឹងរៀបរៀងវេយ្យាករណ៍សម្រាប់រៀនភាសាបាឡីមួយយ៉ាងទៀត ឲ្យមានបែបវិសេសងាយរៀនឆាប់ចេះជាងបែបនេះ ទុកជាសម្បត្តិដ៏ឧត្តមក្នុងព្រះពុទ្ធសាសនាតរៀងទៅ ។

កច្ចាយនូបត្ថម្ភកៈនេះ កាលដែលខ្ញុំបានរៀបរៀងផ្ទៀងផ្ទាត់ជាន់ក្រោយបំផុតនេះស្រេចហើយ លោកគ្រូព្រះសិរីសម្មតិវង្ស

(វជិរបញ្ញោ) នាមដើម (អែម) ចាងហ្វាងសាលាបាឡីជាន់ខ្ពស់សព្វថ្ងៃនេះ លោកបានជួយពិនិត្យថែមទៀត ដោយសេចក្តីព្យាយាមអស់ពីព្រះទ័យរបស់លោកហើយបានយល់ឃើញថា ជាបែបរៀនដ៏ត្រឹមត្រូវ ឥតមានទាស់ឆ្គងឡើយ ពីព្រោះលោកក៏បានពេញព្រះទ័យនឹងកច្ចាយនូបត្ថម្ភកៈនេះ បានណែនាំឲ្យអស់សិស្សានុសិស្សរបស់លោកសិក្សាតាមបែបនេះយូរឆ្នាំមកហើយ ។

ដោយអំណាចកម្លាំងព្យាយាម ដែលខ្ញុំបានរៀបរៀងកច្ចាយនូបត្ថម្ភកៈនេះ សូមឲ្យព្រះពុទ្ធសាសនារុងរឿងប្រហែលដូចកាលព្រះអរហំសម្មាសម្ពុទ្ធជាបរមគ្រូគង់ព្រះជន្មនៅ, ទាំងកុលបុត្រដែលបានសិក្សាគម្ពីរនេះ ក៏សូមឲ្យបរិបូណ៌ដោយចំណេះវិជ្ជាដ៏ដុះដាលលូតលាស់ចម្រើន ក្នុងធម៌វិន័យព្រះពុទ្ធសាសនាឲ្យបានរាល់គ្នាសព្វកាលវេលារៀងទៅហោង ។

វត្តឧណ្ណាលោម ក្រុងភ្នំពេញនៅថ្ងៃចន្ទ ១ រោចខែមាឃ ឆ្នាំមមែ ត្រីស័ក ពុទ្ធសករាជ ២៤៧៤ ត្រូវនឹងថ្ងៃ ២២ ខែហ្វេវ្រិយេរ គ្រិស្តសករាជ ១៩៣២ ។

ព្រះសាសនសោភ័ណ (ជោតញ្ញាណោ) ជ. ណាត
ចាងហ្វាងរងសាលាបាឡីជាន់ខ្ពស់

# អក្សរសង្ខេប

## ប្រើក្នុងកច្ចាយនូបត្ថម្ភកៈ អក្ខរវិធីនិទ្ទេសនិងនាមនិទ្ទេស

| | | |
|---|---|---|
| អា | គឺ | អាលបនៈ |
| ឥ. | គឺ | ឥត្ថីលិង្គ |
| ឯក. | គឺ | ឯកវចនៈ |
| ឧ. | គឺ | ឧទាហរណ៍ |
| ច. | គឺ | ចតុត្ថី |
| ឆ. | គឺ | ឆដ្ឋី |
| ត. | គឺ | តតិយា |
| ទ. | គឺ | ទាំងឡាយ |
| ទុ. | គឺ | ទុតិយា |
| នបុំ. | គឺ | នបុំសកលិង្គ |
| ប. | គឺ | បឋមា |
| បញ្ច. | គឺ | បញ្ចមី |
| បុំ. | គឺ | បុំលិង្គ |
| បុំ. ឥ. | គឺ | បុំលិង្គនិងឥត្ថីលិង្គ |
| ពហុ. | គឺ | ពហុវចនៈ |
| ស. | គឺ | សត្តមី |

# គ្រឿងសម្គាល់

+ សម្គាល់ថា 〝និង〞 ឬថា 〝ហើយនិង〞 > សម្គាល់ថា 〝ជា〞 ឬថា 〝ទៅជា〞 ដូចជា អ + ត > ឯ ឲ្យថា អ, និង ត ជា ឯ. ឬថា អ ហើយនិង ត ទៅជា ឯ, < សម្គាល់ថា 〝មកពី〞 ដូចជា ឯ < អ + ត ឲ្យថា ឯ មកពី អ និង ត ។ ឯគ្រឿងសម្គាល់ឯទៀតក្រៅពីនេះ មិនបាច់នាំមកពន្យល់ក្នុងទីនេះទេ ពីព្រោះសុទ្ធតែមានទំនងងាយយល់ អ្នករៀនក៏ច្រើនធ្លាប់បានប្រើរៀងមកហើយ ។

# បញ្ជីមាតិកា

## អក្ខរវិធីនិទ្ទេសជី ១


| មាតិកានុក្រម | ទំព័រ |
|---|---|
| អក្ខរៈ | ៣ |
| សរៈ | ៤ |
| ព្យញ្ជនៈ | ៥ |
| និគ្គហិត | ៧ |
| ឋាននៃអក្ខរៈ | ៨ |
| ករណៈនៃអក្ខរៈ | ១០ |
| ឃោសាឃោសៈ | ១០ |
| អក្ខរប្បភេទ | ១៣ |
| សិថិលនិងធនិត | ១៣ |
| ទីឃៈនិងរស្សៈ | ១៧ |
| គរុនិងលហុ | ១៨ |
| និគ្គហិតនិងវិមុត្ត | ១៩ |
| សម្ពន្ធៈនិងវវត្ថិតៈ | ១៩ |
| ព្យញ្ជនសំយោគ | ១៩ |
| សន្ធិ | ២៣ |
| សន្ធិ ៣ យ៉ាង | ២៣ |
| សន្ធិកិរិយោបករណ៍ ៨ យ៉ាង | ២៤ |
| សរសន្ធិ | ២៤ |
| លោបោ | ២៥ |
| អាទេសោ | ២៨ |
| អាគមោ | ៣០ |

ទំព័រ
វិការោ .......................................................................... ៣១
បកតិ ............................................................................ ៣៣
ទីឃោ ............................................................................ ៣៣
រស្សោ ........................................................................... ៣៥
ព្យញ្ជនសន្ធិ ...................................................................... ៣៦
លោបោ .......................................................................... ៣៦
អាទេសោ......................................................................... ៣៧
អាគមោ .......................................................................... ៣៩
បកតិ............................................................................. ៤០
សំយោគោ........................................................................ ៤១
និគ្គហិតសន្ធិ..................................................................... ៤១
លោបោ .......................................................................... ៤២
អាទេសោ......................................................................... ៤២
អាគមោ .......................................................................... ៤៤
បកតិ............................................................................. ៤៥
អធិប្បាយឈ្មោះសន្ធិ ........................................................... ៤៦
បែបកាត់បទសរសន្ធិ ........................................................... ៤៨

## នាមនិទ្ទេសទី ២

នាម ............................................................................. ៥១
នាមសព្ទ.......................................................................... ៥១
នាមនាម.......................................................................... ៥១
សាធារណនាម ................................................................... ៥២
អសាធារណនាម.................................................................. ៥២

ទំព័រ

គុណនាម ........................................................................ ៥៣
បកតិគុណនាម .............................................................. ៥៣
វិសេសគុណនាម ........................................................ ៥៤
អតិវិសេសគុណនាម........................................................ ៥៤
សព្វនាម ........................................................................ ៥៥
លិង្គ ............................................................................. ៥៦
ជាតិលិង្គ........................................................................ ៥៧
សម្មតិលិង្គ ..................................................................... ៥៨
នាមសព្ទមានលិង្គផ្សេងគ្នា..................................................... ៥៩
នាមនាមជាឯកលិង្គិកៈ............................................................ ៦០
នាមនាមជាទ្វិលិង្គិកៈ................................................................ ៦១
នាមនាមមានមូលសព្ទតែ ១... ជាទ្វិលិង្គិកៈ.......................... ៦១
គុណនាមជាតិលិង្គិកៈ......................................................... ៦៣
វចនៈ ............................................................................ ៦៤
បែបប្រើវចនៈ ................................................................ ៦៥
វិភត្តិ ............................................................................ ៦៨
អាយតនិបាត ................................................................. ៦៩
ពាក្យប្រែរបស់វិភត្តិ ........................................................ ៧០
អត្ថរបស់អាយតនិបាត ................................................... ៧១
ការន្ត ........................................................................... ៨៨
វិធីបំបែកនាមសព្ទ ........................................................ ៨៩
រូបសិទ្ធិ ........................................................................ ៨៩
អការន្តបុំលិង្គ.................................................................. ៩០
ឥការន្តបុំលិង្គ ................................................................ ៩៣
ឦការន្តបុំលិង្គ................................................................. ៩៧

| | |
|---|---|
| | ទំព័រ |
| ឧការន្តបុំលិង្គ | ១០០ |
| ឱការន្តបុំលិង្គ | ១០៣ |
| អាការន្តឥត្ថីលិង្គ | ១០៤ |
| ឥការន្តឥត្ថីលិង្គ | ១០៧ |
| ឦការន្តឥត្ថីលិង្គ | ១១១ |
| ឧការន្តឥត្ថីលិង្គ | ១១៤ |
| ឱការន្តឥត្ថីលិង្គ | ១១៦ |
| អការន្តនបុំសកលិង្គ | ១១៧ |
| ឥការន្តនបុំសកលិង្គ | ១២០ |
| ឧការន្តនបុំសកលិង្គ | ១២១ |
| បកិណ្ណកសព្ទ | ១២៣ |
| ព្រហ្ម | ១២៤ |
| អត្ត | ១២៦ |
| សខ | ១២៩ |
| រាជ | ១៣២ |
| ភគវន្តុ | ១៣៦ |
| អរហន្ត | ១៤១ |
| ភវន្ត | ១៤២ |
| សត្ថុ | ១៤៥ |
| បិតុ | ១៤៨ |
| មាតុ | ១៥០ |
| មនោគណសព្ទ | ១៥២ |
| កម្ម | ១៥៧ |
| គោ | ១៦០ |
| សំខ្យាសព្ទ | ១៦៥ |

ទំព័រ

វិធីរាប់បកតិសំខ្យា ............................................................... ១៦៦
សេចក្តីពន្យល់ដោយសង្ខេប (ក្នុងបកតិសំខ្យា) ...................... ១៧៥
វិធីផ្សំឧត្តរសព្ទជាមួយនឹងសំខ្យាសព្ទ.................................... ១៨១
វិធីផ្សំអធិកសព្ទជាមួយនឹងសំខ្យាសព្ទ ................................... ១៨៤
វិធីផ្សំឧត្តរនិងអធិកលាយគ្នា ................................................ ១៨៦
រូបសិទ្ធិដោយសង្ខេប (ក្នុងបកតិសំខ្យា) .................................. ១៨៧
បកតិសំខ្យាប្រើជានាមនាម .................................................... ១៨៩
បកតិសំខ្យាមានលិង្គនិងវចនៈផ្សេងគ្នា................................... ១៩២
វិធីបំបែកបកតិសំខ្យា............................................................. ១៩៥
បែបបំបែកឯកសព្ទ ................................................................. ១៩៥
បែបបំបែកទ្វិសព្ទ ................................................................... ១៩៦
ឧភនិងឧភយ .......................................................................... ១៩៨
បែបបំបែកតិសព្ទ ................................................................... ១៩៩
បែបបំបែកចតុសព្ទ ................................................................. ២០១
បែបបំបែកបញ្ចសព្ទ ................................................................ ២០៤
បែបបំបែកឯកូនវីសសព្ទ......................................................... ២០៦
បែបបំបែកឯកូនវីសតិសព្ទ.................................................... ២០៦
បែបបំបែកឯកូនសដ្ឋីសព្ទ ...................................................... ២០៧
បូរណសំខ្យា ........................................................................... ២០៧
វិធីរាប់បូរណសំខ្យា ................................................................ ២០៩
បូរណសំខ្យាអាស្រ័យបច្ច័យ .................................................. ២១២
វិធីបំបែកបូរណសំខ្យា ........................................................... ២១៤
សព្វនាម ................................................................................. ២១៥
បុរិសសព្វនាម ........................................................................ ២១៦

ទំព័រ
បែបបំបែកតសព្ទក្នុងលិង្គទាំង ៣ ........................................ ២២៤
គុម្ពសព្ទទាំង ២ លិង្គបំបែកតែបែបមួយ ................................ ២៣១
អម្ហសព្ទទាំង ២ លិង្គបំបែកតែបែបមួយ.................................. ២៣២
វិសេសនសព្ទនាម ............................................................... ២៣៤
បែបបំបែកយសព្ទ ............................................................. ២៣៦
បែបបំបែកកឹសព្ទ .............................................................. ២៤១
បែបប្រើកឹសព្ទ.................................................................... ២៤៣
វិសេសនសព្ទនាម-និយម...................................................... ២៤៥
បែបបំបែកឯតសព្ទ.............................................................. ២៤៧
បែបបំបែកឥមសព្ទ ........................................................... ២៤៨
បែបបំបែកអមុសព្ទ ............................................................ ២៥៣
អព្យយសព្ទ........................................................................ ២៥៨
ឧបសគ្គ ............................................................................ ២៥៩
បែបប្រើឧបសគ្គ.................................................................. ២៦១
ឧទាហរណ៍សង្ខេប (ក្នុងពួកឧបសគ្គ).................................... ២៦៣
និបាត ............................................................................... ២៧០
បច្ច័យ (ក្នុងពួកនិបាត) ........................................................ ២៨៥

---

# អក្ខរាវិធីនិក្ខេស ទី ១

កច្ចាយនទូបត្ថម្ភកៈ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្សការថ្វាយបង្គំចំពោះព្រះដ៏មានជោគ

ជាអរហន្ត សម្មាសម្ពុទ្ធ ព្រះអង្គនោះ ។

## អក្ខរវិធីនិទ្ទេសទី ១

### សមញ្ញាភិធាន

អត្ថោអក្ខរសញ្ញាតោ សេចក្ដីនៃពាក្យទាំងពួង ជនទាំងឡាយនឹងកំណត់ដឹងបាន ក៏ព្រោះអាស្រ័យអក្ខរៈ កាលបើអក្ខរៈវិបត្តិប្រែប្រួលឃ្លៀងឃ្លាតហើយ, អ្នកណានឹងអាចចូលចិត្តសេចក្ដីថាជាអ្វីបាន? ព្រោះហេតុនោះ សេចក្ដីយល់ស្ទាត់ឈ្លាសវៃក្នុងអក្ខរវិធី ជាហេតុនាំឲ្យមានឧបការៈច្រើន ។

### អក្ខរៈ

[១] ពាក្យដែលហៅថា "អក្ខរៈ" ឬ "អក្សរ" នោះ អ្នកប្រាជ្ញទាំងឡាយគ្រប់ប្រទេស លោកសំដៅយកហេតុពីរយ៉ាងមករួម

ឲ្យឈ្មោះ គឺ សូរសំឡេងដែលលាន់ឮប្រាកដឡើង ១, ស្នាម
គំនូសជាតួរាងដែលល្មមកំណត់ចំណាំបានតាមការស្រួល ១,
ទាំងពីរយ៉ាងនេះរួមមកហៅតែពាក្យ ១ ម៉ាត់ថា"អក្ខរៈ" ឬ "អក្សរ"
ឬ ហៅថា "វណ្ណៈ" ក៏បាន ។

អក្ខរៈសម្រាប់ប្រើក្នុងបាឡីភាសា មាន ៤១ តួគឺ អអា ឥឦ
ឧឩ ឯឱ ៨ តួនេះហៅថា "សរៈ" (ស្រៈ), កខ គឃ ង, ចឆ
ជឈ ញ, ដឋ ឌឍ ណ, តថ ទធ ន, បផ ពភ ម, យរលវ
សហឡ ំ ៣៣ នេះហៅថា "ព្យញ្ជនៈ" ។

## សរៈ

[២] សរៈ ប្រែថា " រឮក" ឬថា "បញ្ចេញសំឡេង" គឺអក្ខរៈ
ដែលនាំព្យញ្ជនៈឲ្យចេញសូរលាន់ឮផង បញ្ចេញសូរលាន់ឮ
តាមរំពងរបស់ព្យញ្ជនៈផង ហៅថា សរៈ (ស្រៈ) ។ ស្រៈទាំង
៨ តួនោះហៅថា "និស្ស័យ" ប្រែថា "អក្ខរៈជាទីអាស្រ័យនៃ
ព្យញ្ជនៈ" ។ ស្រៈនោះចែកជា ២ យ៉ាង គឺជា រស្សៈ ១ យ៉ាង, ជា
ទីឃៈ ១ យ៉ាង, ស្រៈដែលមានសូរខ្លីរហ័សរួសរាន់ មាន ៣ តួគឺ
អ ឥ ឧ ហៅថារស្សៈ "ខ្លី" ឧ. អភិរមតុ, ឥមតុ, បរិចរតិ ។

ស្រៈដែលមានសូរវែងមាន ៥ តួគឺ អា ឦ ឩ ឯ ឱ ហៅថា ទីឃៈ "វែង" ឧ. ភាគី, ថូបោ, ទេវោ, ប៉ុន្តែស្រៈទីឃៈ ៣ តួគឺ អា ឯ ឱ នេះ កាលបើមានព្យញ្ជនៈតម្រួតគ្នាពីរតួនៅខាងចុង ក៏ បែជាមានសូរខ្លីដូចជារស្សៈទៅវិញ ឧ. ស្វាក្ខាតោ, អាត្តំ, ឯត្តកំ, ឱដ្ឋោ, ខេត្តំ, មេត្តា, សេដ្ឋី, សេយ្យោ, សោត្ថិ ។ ស្រៈបើចែក ចេញជាគូមាន ៣ គូគឺ អអា ហៅថា "អវណ្ណៈ" ជាគូ ១, ឥឦ ហៅថា "ឥវណ្ណៈ" ជាគូ ១, ឧឩ ហៅថា "ឧវណ្ណៈ" ជាគូ ១ ។ ស្រៈ ២ តួគឺ ឯឱ នេះជាស្រៈឥតគូ ហៅថា សំយុត្តសរៈ ប្រែថា "ស្រៈផ្សំ" ពីព្រោះផ្សំស្រៈ ៣ តួ រួមគ្នាឲ្យកើតបានជាស្រៈ ១ តួគឺ អ និង ឥ ផ្សំចូលគ្នាកើតបានជា ឯ. អ និង ឧ ផ្សំចូលគ្នាកើត បានជា ឱ. ព្រោះហេតុនោះ បានជាស្រៈទាំង ២ តួនេះជា ទ្វិ-ដ្ឋានជៈ (មើលទៅក្នុងខាងមុខត្រង់លេខ ៥ ) ។

## ព្យញ្ជនៈ

[៣] អក្ខរៈ ៣៣ តួក្រៅពីស្រៈ ឈ្មោះថា ព្យញ្ជនៈ ប្រែថា "អក្សរធ្វើនូវសេចក្តីឲ្យប្រាកដ" ។ ព្យញ្ជនៈទាំង ៣៣ តួនោះ

ហៅថា និស្សិត ប្រែថា "អក្សរលុះតែអាស្រ័យនូវស្រៈផងទើបចេញសូរបាន" ។ សេចក្តីថា ព្យញ្ជនៈទាំងអស់ លុះតែអាស្រ័យនឹងស្រៈផងទើបអាចចេញសំឡេងបាន ប៉ុន្តែមានអំណាចអាចនាំស្រៈដែលខ្លួនអាស្រ័យនោះ ឲ្យលាន់ឮសូរតាមរំពងរបស់ខ្លួនផងដែរ ហើយធ្វើនូវសេចក្តីឲ្យច្បាស់ប្រាកដឡើងផង, ឯស្រៈពិតជាចេញសំឡេងតាមទំនើងខ្លួនឯងបានមែន ប៉ុន្តែនឹងអាចធ្វើសេចក្តីឲ្យច្បាស់លាស់ ថាជាអ្វីដោយខ្លួនឯងទាំងអស់នោះពុំបានឡើយ ដូចជាភាសាបាឡីថា "វិហារោ" ឬដូចជាភាសាយើងថា "ទៅណា" បើប្រសិនជាសរសេរសុទ្ធតែស្រៈថា "ិ ា ោ "ឬថា" ៅ-ា" ដូច្នេះ នឹងយកសេចក្តីថាជាអ្វីក៏ពុំបានលុះតែដាក់ព្យញ្ជនៈរួមចូលជាមួយផង នោះទើបដាក់ប្រាកដថា "វិហារោ" ថា "ទៅណា" ដូច្នេះឡើងបាន ។

ព្យញ្ជនៈទាំង ៣៣ តួនោះចែកជា ២ ពួក គឺ វគ្គៈ ១ ពួក អវគ្គៈ ១ ពួក ។ វគ្គៈ ចែកចេញទៅទៀតជា ៥ ពួកដូច្នេះ គឺ កខគឃង ៥ តួនេះហៅថា កវគ្គៈ ចឆជឈញ ៥ តួនេះហៅថា

ចវគ្គៈ ជបឋឈណ ៥ តួនេះហៅថា ជវគ្គៈ តថទធន ៥ តួនេះហៅថា តវគ្គៈ បផពភម ៥ តួនេះហៅថា បវគ្គៈ ។ ព្យញ្ជនៈទាំង ២៥ តួនេះជាពួក ៗ តាមឋានករណៈ និងវិធីតម្រួតគ្នា ដែលនឹងមាននិយាយទៅក្នុងខាងមុខត្រង់លេខ ៥, ៦ និងលេខ ១៤, ព្រោះហេតុនោះទើបបានឈ្មោះថា វគ្គៈប្រែថា "ព្យញ្ជនៈមានពួក" ឬថា "ព្យញ្ជនៈប្រព្រឹត្តទៅតាមពួក" ។

ព្យញ្ជនៈ ៨ តួ គឺ យរលវសហឡ º នេះ ហៅថា អវគ្គៈប្រែថា "ព្យញ្ជនៈឥតពួក" ពីព្រោះមិនមានពួកតាមឋានករណៈឡើយ ឬហៅថា សេសវគ្គៈ ក៏បាន ប្រែថា "ព្យញ្ជនៈ មានពួកដ៏សេស គឺ សល់ក្រៅពីពួក" ។

## និគ្គហិត

[៤] ព្យញ្ជនៈគឺ º នេះ ហៅថា និគ្គហិត ប្រែថា "ព្យញ្ជនៈស្ថិតនៅអាស្រ័យនឹងស្រៈរស្សៈ" ឬហៅថា អនុសារៈ ប្រែថា "ព្យញ្ជនៈបញ្ចេញសំឡេង (នាសិកជៈ) តាមលំនាំស្រៈ" ។ ក្នុងភាសាបាឡីនិគ្គហិតអាស្រ័យបានតែនឹងស្រៈរស្សៈ ៣តួ គឺ អ ឥ ឧ

ប៉ុណ្ណោះ ឯក្នុងភាសាសំស្រ្កឹត និគ្គហិតអាស្រ័យនឹងស្រៈទីឃៈ មានស្រៈអាជាដើមក៏បាន បញ្ចេញសំឡេងតាមសមគួរដល់លំនាំស្រៈដែលខ្លួនអាស្រ័យនោះ ។ សំឡេងរបស់និគ្គហិតនោះនឹងមាននិយាយទៅក្នុងខាងមុខត្រង់លេខ ៧ ។

## ឋានៃអក្ខរៈ

[៥] ទីតាំងដែលកើតសំឡេងនៃអក្ខរៈ ហៅថា "ឋាន" មាន ៦ យ៉ាងគឺ កណ្ឋោ ក, តាលុ ពិតាន, មុទ្ធា ក្បាល, ទន្តោ ធ្មេញ, ឱដ្ឋោ បបូរមាត់, នាសិកា ច្រមុះ ។

បណ្ដាអក្ខរៈទាំងអស់នោះអក្ខរៈខ្លះកើតក្នុងឋានមួយ ខ្លះកើតក្នុងពីរឋាន ដូច្នេះគឺ អអា កខគឃង, ហ ៨ តួនេះកើតក្នុងក ហៅថា កណ្ឋជៈ, ឥឦ, ចឆជឈញ, យ ៨ តួនេះកើតក្នុងពិតាន គឺក្រអូមមាត់ ហៅថាតាលុជៈ,ដឋឌឍណ, រឡ ៧ តួនេះកើតក្នុងក្បាល ហៅថា មុទ្ធជៈ, តថទធន. លស ៧ តួនេះកើតត្រង់ប្រទល់ធ្មេញ ហៅថា ទន្តជៈ, ឧឩ, បផពភម ៧ តួនេះកើតត្រង់ប្រទល់បបូរមាត់ហៅថាឱដ្ឋជៈ,និគ្គហិតកើតក្នុងច្រមុះហៅថានាសិកជៈ។

អក្ខរៈទាំងអម្បាលនេះ, លើកតែព្យញ្ជនៈជា វគ្គន្តៈ "ទីបំផុតវគ្គ" ៥ តួ គឺ ង, ញ, ណ, ន, ម និងសំយុត្តសរៈពីរតួ គឺ ឯឱ និងព្យញ្ជនៈប៉ែកខាងអវគ្គៈពីរតួ គឺ វ, ហ នេះចេញ, សុទ្ធតែកើតក្នុងឋានមួយ (ហៅថា ឯកដ្ឋានជៈ) ។ ឯព្យញ្ជនៈទីបំផុតវគ្គទាំង ៥ តួ គឺ ង, ញ, ណ, ន, ម នេះជាទ្វិដ្ឋានជៈ "កើតក្នុងពីរឋាន" គឺ កើតតាមឋានរបស់ខ្លួន ៗ និងច្រមុះ ហៅថា សកដ្ឋាននាសិកជៈ ។ សំយុត្តសរៈទាំងពីរតួជាទ្វិដ្ឋានជៈ គឺស្រៈ ឯ កើតក្នុងកនិងពិតាន ហៅថា កណ្ឋតាលុជៈ ពីព្រោះស្រៈឯនេះកើតមកអំពីស្រៈអ ដែលជាកណ្ឋជៈ និងស្រៈឥដែលជាតាលុជៈ, ស្រៈ ឱ កើតក្នុង ក និងប្រទល់បបូរមាត់ ហៅថា កណ្ឋោដ្ឋជៈ ពីព្រោះស្រៈ ឱ កើតមកអំពីស្រៈអ ដែលជាកណ្ឋជៈ និងស្រៈឧ ដែលជា ឱដ្ឋជៈ (មើលក្នុងខាងដើមត្រង់លេខ ២) ។ "វ" ជាទ្វិដ្ឋានជៈ កើតត្រង់ប្រទល់ធ្មេញ និងប្រទល់បបូរមាត់ ហៅថា ទន្តោដ្ឋជៈ ។ "ហ" បើផ្សំចូលនឹងព្យញ្ជនៈ ៨ តួ គឺ ញ, ណ, (ន), ម, យ, ល, វ, ឡ ដូចជា តញ្ហិ, តណ្ហា, តម្ហា, មយ្ហំ, វុល្ហំ, ជិវ្ហា, វុឡ្ហំ ដូច្នេះ លោកពោលថាកើតក្នុងទ្រូង ហៅថា ឧរជៈ, បើ

មិនផ្សំចូលនឹងព្យញ្ជនៈទាំងនោះទេ ក៏នៅជាកណ្ឋជៈ ដូចបាននិយាយមករួចហើយ, ព្រោះហេតុនោះ "ហ" ជួនណាជាកណ្ឋជៈ ជួនណាជាឱរជៈ ។

## ករណៈ នៃ អក្ខរៈ

[៦] ដំណើរឬលំនាំដែលធ្វើនូវសំឡេងនៃអក្ខរៈទាំងនោះហៅថា "ករណៈ" មាន ៤ យ៉ាង គឺ ជិវ្ហាមជ្ឈំ ត្រង់ពាក់កណ្ដាលអណ្ដាត, ជិវ្ហោបគ្គំ ឲ្យរលាស់ចុងអណ្ដាតចូល, ជិវ្ហគ្គំ ត្រង់ចុងអណ្ដាត, សកដ្ឋានំ តាមឋានរបស់ខ្លួនស្រាប់ ។ ជិវ្ហាមជ្ឈំ ជាករណៈរបស់អក្ខរៈដែលជាតាលុជៈ, ជិវ្ហោបគ្គំ ជាករណៈរបស់អក្ខរៈដែលជាមុទ្ធជៈ, ជិវ្ហគ្គំ ជាករណៈរបស់អក្ខរៈដែលជាទន្តជៈ, សកដ្ឋានំ ជាករណៈរបស់អក្ខរៈឯទៀតទាំងប៉ុន្មានក្រៅអំពីអក្ខរៈដែលជា តាលុជៈ, មុទ្ធជៈ, ទន្តជៈ ។

## ឃោសាឃោសៈ

[៧] ព្យញ្ជនៈទាំងអស់ មានវិធីចែកមួយយ៉ាងទៀតតាមសំឡេងជា២ចំណែកគឺព្យញ្ជនៈដែលមានសំឡេងគឹកកង ហៅថា

"ឃោសៈ" ជាចំណែក ១. ព្យញ្ជនៈដែលមានសំឡេងមិនគឹកកង ហៅថា "អឃោសៈ" ជាចំណែក ១ ។ នឹងសម្ដែងអំពីអឃោសៈមុនតាមលំដាប់អក្ខរៈ ដូចសេចក្ដីតទៅនេះ ។

ព្យញ្ជនៈទី ១ ទី ២ ក្នុងវគ្គទាំង ៥ គឺ កខ, ចឆ, ដឋ, តថ, បផ និងព្យញ្ជនៈជាអវគ្គៈ ១ តួគឺ ស, ១១ តួនេះជា អឃោសៈ ប្រែថា "អក្ខរមានសំឡេងមិនគឹកកង" ។ ព្យញ្ជនៈ ទី ៣ ទី ៤ ទី ៥ ក្នុងវគ្គទាំង ៥ គឺ គឃង, ជឈញ, ឌឍណ, ទធន, ពភម នឹងព្យញ្ជនៈជាអវគ្គៈ ៦ តួគឺ យរលវហឡ រួមជា ២១ តួនេះជា ឃោសៈ ប្រែថា " អក្ខរៈមានសំឡេងគឹកកង" ។

និគ្គហិតគឺ ◌ំ នេះ តាមលទ្ធិខាងភាសាសំស្ក្រឹត រាប់បញ្ចូលក្នុងពួកឃោសៈ, តាមលទ្ធិខាងភាសាបាឡីដែលប្រើក្នុងពុទ្ធសាសនាលោកចាត់ថាជា ឃោសាឃោសវិមុត្ត ប្រែថា"អក្ខររួចផុតចាកឃោសៈនិងអឃោសៈ"គឺមិនមែនជាឃោសៈ ឬអឃោសៈឡើយពីព្រោះនិគ្គហិតនោះជាព្យញ្ជនៈសម្រាប់អាស្រ័យតែនឹងស្រៈរស្សៈសុទ្ធ៣ តួគឺ អ ឥ ឧ ជា "អំ ឥំ ឧំ" ឬក៏អាស្រ័យនឹង

ព្យញ្ជនៈដែលអាស្រ័យនឹងស្រៈនិស្ស័យជារស្សៈ៣ តួដូចយ៉ាង "តំ តឹ តុំ" ជាដើម ។ និគ្គហិតនោះ បើពោលជា "អនុនាសិកន្តៈ" បញ្ចេញសំឡេងដូចមានអក្សរ "ង" ប្រកបខាងចុង ឧ. យំ, តំ, អគ្គឹ, វធុំ(១) បើពោលជា "មការន្ត" បញ្ចេញសំឡេងដូចមានអក្សរ "ម" ប្រកបខាងចុង ឧ. យម៍, តម៍, អគ្គិម៍, វធុម៍,(២) ( មើលក្នុងខាងដើមត្រង់លេង ៤ ) ។

ចំណែកខាងស្រៈ តាមលទ្ធិខាងភាសាសំស្ក្រឹតថា ស្រៈទាំងអស់ជាឃោសៈ, តែឯលទ្ធិខាងភាសាបាឡីសម្រាប់ប្រើក្នុងពុទ្ធ-សាសនា មិនមានបង្គាប់ថាជាឃោសៈ ឬ ជាអឃោសៈឡើយ ។ គួរនឹងឲ្យចូលចិត្តថា ទោះខាងភាសាបាឡីក៏ដោយ ស្រៈសុទ្ធទាំង ៨ តួ គឺស្រៈដែលមិនអាស្រ័យនឹងព្យញ្ជនៈទេ ហៅថា "ស្រៈពេញតួ" នោះក៏ជាឃោសៈដែរ(?) ។ ពីព្រោះជាអក្សរមានសំឡេងគឹកកងតាមធម្មតារបស់ខ្លួនស្រាប់ ។

---

១ មើលថា: យ័ង, ត័ង, អគ្គិង, វធុង ។ ២ មើលថា: យ័ម, ត័ម, អគ្គិម, វធុម ។ ទោះសរសេរថា យំ, តំ, អគ្គឹ, វធុំ ដូច្នេះក្តី បើពោលជា មការន្ត ក៏គង់បញ្ចេញសំឡេងដូចមានអក្សរ ម, ប្រកបខាងចុងដូច្នោះដែរ ។

## អក្ខរប្បភេទ

[៨] ចំណែកជាគូ ៗ របស់អក្ខរៈដែលមានសំឡេងផ្សេងគ្នាគឺគូនៃអក្ខរៈដែលមានសូរជាទំនាស់នឹងគ្នា ហៅថា "អក្ខរប្បភេទ" ៗ នោះ បើរាប់ជាគូមាន ៥ គូ បើរាប់រាយមាន ១០ យ៉ាងគឺ សិថិល, ធនិត, ទីឃៈ, រស្សៈ, គរុ, លហុ, និគ្គហិត, វិមុត្ត, សម្ពន្ធៈ, វវត្ថិតៈ ។

## សិថិល និង ធនិត

[៩] ព្យញ្ជនៈទី ១ និងទី ៣ ក្នុងវគ្គទាំង ៥ គឺ កគ, ចជ, ដឌ, តទ, បព ១០ តួនេះ ហៅថា សិថិល ប្រែថា "ធូរ" ព្រោះជាព្យញ្ជនៈមានសំឡេងធូរខ្សោយ ។ ព្យញ្ជនៈទី ២ និងទី ៤ ក្នុងវគ្គទាំង ៥ គឺ ខឃ, ឆឈ, ឋឍ ថធ, ផភ ១០ តួនេះ ហៅថា ធនិត ប្រែថា "តឹង" ព្រោះជាព្យញ្ជនៈមានសំឡេងតឹងខ្លាំង ។

ព្យញ្ជនៈជាសិថិល ចែកចេញជា ២ ពួកគឺ កចដតប ៥ តួនេះជាពួក ១ ហៅថា សិថិល-អឃោសៈ, គជឌទព ៥ តួនេះ

ជាពួក ១ ហៅថា សិថិល-ឃោសៈ ។ ចំណែកខាងព្យញ្ជនៈជាធនិតក៏បែកចេញជា ២ ពួកដែរគឺ ខឆឋថផ ៥ តួនេះជាពួក ១ ហៅថា ធនិត-អឃោសៈ, ឃឈឍធភ ៥ តួនេះជាពួក ១ ហៅថា ធនិត-ឃោសៈ ។

ព្យញ្ជនៈជាសិថិលនិងធនិតទាំង ២០ តួនោះ មានសំឡេងធូរ-តឹងជាងគ្នាតាមលំដាប់ដូចនេះគឺ

*ក)* សិថិល-អឃោសៈ (កចដតប) មានសំឡេងធូរខ្សោយជាងព្យញ្ជនៈទាំងអស់,

*ខ)* ធនិត-អឃោសៈ (ខឆឋថផ) មានសំឡេងតឹងខ្លាំងជាងសិថិល-អឃោសៈ (កចដតប),

*គ)* សិថិល-ឃោសៈ (គជឌទព) មានសំឡេងលាន់ខ្លាំងជាងធនិត-អឃោសៈ (ខឆឋថផ),

*ឃ)* ធនិត-ឃោសៈ (ឃឈឍធភ) មានសំឡេងតឹងខ្លាំងជាងសិថិល-ឃោសៈ (គជឌទព) ។

បើនិយាយដោយអធិប្បាយ ជាសេចក្តីទូលាយឲ្យងាយចំណាំនោះ អ្នកសិក្សាត្រូវសង្កេតដូច្នេះថា អក្សរ "ខ" មានសំឡេងតឹងខ្លាំងជាង "ក", "គ" មានសំឡេងលាន់ខ្លាំងជាង "ខ", "ឃ" មានសំឡេងតឹងខ្លាំងជាង "គ", យ៉ាងនេះជាលំដាប់គ្នារៀងដល់ "ភ", ព្រោះ "ក" និង "ហ" ផ្សំគ្នាជាសំឡេងមួយ បង្កើតបានជា "ខ" ។ ល ។ "ព" និង "ហ" ផ្សំគ្នាជាសំឡេងមួយ បង្កើតបានជា "ភ", ពីព្រោះព្យញ្ជនៈជាធនិតទាំង ១០ តួ កើតមកអំពីព្យញ្ជនៈជាសិថិលទាំង ១០ តួ ដែលមានសំឡេងផ្សំនឹងអក្សរ "ហ" លាយចូលផង គឺ ធនិត-អឃោសៈកើតមកអំពីសិថិល-ឃោសៈ និង ហ[១] កើតតាមលំដាប់គូរបស់ខ្លួន ៗ ដូចមានរបៀបរៀបរៀងជាខ្នង់សង្កាត់ ជាបែបឲ្យងាយយល់ខាងក្រោយនេះ ។

---

១ ព្រោះហេតុនេះបានជាវេយ្យាករណបណ្ឌិតទាំងឡាយក្នុងប្រទេសខ្លះព្រមព្រៀងគ្នាកំណត់ឈ្មោះត្រង់អក្សរ សិថិល ឲ្យហៅថា "អក្សរឥតសំឡេងហ" ត្រង់អក្សរធនិតឲ្យហៅថាអក្សរមានសំឡេងហ" ។

## សិថិលផ្សំនឹង "ហ" បង្កើតជាធនិត

| សិថិល | សិថិលនិង-ហ | បង្កើតជាធនិត | សំឡេងធនិត |
|---|---|---|---|
| ក | ក + ហ | ខ | ក្ហ[១] |
| គ | គ + ហ | ឃ | គ្ហ |
| ច | ច + ហ | ឆ | ច្ហ |
| ជ | ជ + ហ | ឈ | ជ្ហ |
| ដ | ដ + ហ | ឋ | ដ្ហ |
| ឌ | ឌ + ហ | ឍ | ឌ្ហ |
| ត | ត + ហ | ថ | ត្ហ |
| ទ | ទ + ហ | ធ | ទ្ហ |
| ប | ប + ហ | ផ | ប្ហ |
| ព | ព + ហ | ភ | ព្ហ |

អក្សរ "ហ" ជា កណ្ឋជៈ តាមឋាន-ករណៈរបស់ខ្លួនក៏ពិតមែន ប៉ុន្តែដល់មកផ្សំនឹងអក្សរ សិថិល ដែលមានឋាន-ករណៈ

១ បើអ្នកសិក្សាចង់សង្កេតសំឡេងអក្សរធនិតទាំងនេះឲ្យប្រាកដនោះ ត្រូវថាផ្ដួលសំឡេងពីអក្សរ សិថិល ទៅផ្សំនឹងអក្សរ "ហ" សម្រួលសំឡេងសិនថា ក-ហា=ក្ហ(ខ). ។ល។ ព-ហា=ព្ហ (ភ) គឺជម្រាលសំឡេងពី "ក" ទៅ "ហ" ។ល។ ពី "ព" ទៅ "ហ" ហើយសឹមក្រសោបឆក់ផ្ដាច់សំឡេងអក្សរទាំងពីរតួឲ្យទៅជាសំឡេងតែមួយ ។ ទំនងនេះជាការងាយក្នុងដំណើរសង្កេតសំឡេង សិថិល និងធនិត ។

ត្រូវគ្នានឹងខ្លួនក្តី ផ្សេងគ្នាពីខ្លួនក្តី ក៏គ្រាន់តែជាជំនួយនាំអក្សរសិថិលនោះឲ្យក្លាយទៅជាអក្សរធនិត មានសំឡេងតឹងខ្លាំងជាងប្រក្រតីដើមរបស់ខ្លួនប៉ុណ្ណោះ ឯឋាន-ករណៈរបស់អក្សរទាំងនោះ ក៏នៅនឹងប្រាកដតាមកំណើតរបស់ខ្លួន ៗ ដូចដែល អក្សរ "ហ" មិនមែនទាញសំឡេងឲ្យក្លាយមកតាមអំណាចខ្លួនទេ ពីព្រោះអក្សរធនិតទាំងនោះ សឹងមានសំឡេងអក្សរសិថិលដែលជាគូនឹងខ្លួន ជាប្រធានដឹកនាំឲ្យមានសំឡេងទៀងទាត់តាមឋាន-ករណៈរបស់ខ្លួន ៗ ស្រាប់ហើយ ។

អក្ខរៈឯទៀតក្រៅអំពីអក្សរទាំង ២០ តួនោះ គឺស្រៈ ៨ តួ ព្យញ្ជនៈជាវគ្គន្តៈ ៥ តួ, ព្យញ្ជនៈប៉ែកខាងអវគ្គៈ ៨ តួ រួមជា ២១ តួនេះ បានជាមិនរាប់បញ្ចូលក្នុងពួកសិថិល-ធនិតនោះ ពីព្រោះជាអក្ខរៈមានសំឡេងដោយឡែក ឥតមានកំណត់អំពីសំឡេងធូរតឹងតាមលំដាប់គូឡើយ ។

ឃោសៈ និង អឃោសៈ

[១០] ស្រៈមានសំឡេងវែង ៥ តួ ទោះប្រើជាស្រៈពេញតួចេញសំឡេងតាមទំនើងខ្លួនឯងជា អា ឦ ឩ ឯ ឱ យ៉ាងនេះក្តី

ទោះប្រើជាស្រៈនិស្ស័យរួមជាមួយនឹងព្យញ្ជនៈ ដូចជា ញាតី, កូបាលោ, សេនា យ៉ាងនេះក្តី ហៅថា ទីឃៈ មានសំឡេងវែង ។ ស្រៈមានសំឡេងខ្លី ៣ តួ ទោះប្រើជាស្រៈពេញតួចេញសំឡេងតាមទំនើងខ្លួនឯងជា អ ឥ ឧ យ៉ាងនេះក្តី ទោះប្រើជាស្រៈនិស្ស័យរួមជាមួយនឹងព្យញ្ជនៈ ដូចជា បរិសតុ យ៉ាងនេះក្តី ហៅថា រស្សៈមានសំឡេងខ្លី (មើលក្នុងខាងដើមត្រង់លេខ ២) ។

## គរុ និង លហុ

[១១]ស្រៈទីឃៈនិងស្រៈរស្សៈ ដែលមានព្យញ្ជនៈតម្រួតគ្នានៅខាងចុង ឬដែលមាននិគ្គហិតអាស្រ័យផង ដូចជា អាការោ, ពុទ្ធំ, សម្មាសម្ពុទ្ធោ, តស្សា យ៉ាងនេះ ហៅថា គរុ[១] ប្រែថា ធ្ងន់, យូរ″ ។ ស្រៈរស្សៈដែលមិនមានព្យញ្ជនៈតម្រួតគ្នានៅខាងចុង ឬដែលមិនមាននិគ្គហិតអាស្រ័យផងទេ ដូចជា បរិសតុ យ៉ាងនេះ ហៅថា លហុ[២] ប្រែថា ‶ស្រាល, រហ័ស″ ។

---

១ គរុ និយាយដោយសង្ខេបមាន ៣ យ៉ាងគឺ ទីឃគរុ ១ សំយោគគរុ ១ និគ្គហិតគរុ ១, និយាយដោយពិស្តារមាន ៥ យ៉ាងគឺ ថែម បាទាទិគរុ ១ បាទន្តគរុ ១ មកទៀតផ្សំនឹងគរុ ៣ យ៉ាងខាងដើម រួមជា ៥ យ៉ាង (លោកអាចារ្យគួរពន្យល់សិស្សឲ្យចូលចិត្តផងចុះ) ។

២ លហុនិងរស្សៈជារូបតែមួយ ប៉ុន្តែបើកាលណានិយាយអំពីវែងខ្លី ហៅថា រស្សៈ បើនិយាយអំពីធ្ងន់ ស្រាល ហៅថា លហុ ។ ទីឃៈឬនិគ្គហិតនិងគរុក៏មានន័យដូចគ្នានឹងន័យនេះដែរ ។

## និគ្គហិត និង វិមុត្ត

[១២] និគ្គហិតនោះ បាននិយាយក្នុងខាងដើមត្រង់លេខ ៤, លេខ ៧ រួចហើយ ក្នុងទីនេះនឹងនិយាយតែអំពីវិមុត្ត ។ អក្ខរៈដែលវេលាសូត្រ ត្រូវបង្ហើបមាត់ឲ្យហើបលើសជាងប្រក្រតីបន្តិច ដូចជា បាណា, ថេរោ, ឱវាទោ, ឯសា ញត្តិ យ៉ាងនេះ ហៅថា វិមុត្ត ប្រែថា " បង្ហើបមាត់បញ្ចេញសំឡេង " ។

## សម្ពន្ធៈ និង វវត្ថិតៈ

[១៣] បទសន្ធិ ដូចជា តត្រាយមាទិ, តត្ថេវ យ៉ាងនេះ ហៅថា សម្ពន្ធៈ ប្រែថា "បទដែលចងភ្ជាប់" ។ បទដែលកាត់ញែកចេញអំពីបទសន្ធិ ដូចជា តត្រ អយំ អាទិ, តត្ថ ឯវ យ៉ាងនេះ ហៅថា វវត្ថិតៈ ប្រែថា " បទញែក " ។

## ព្យញ្ជនសំយោគ

[១៤] ព្យញ្ជនៈដែលតម្រួតគ្នា ហៅថា "ព្យញ្ជនសំ-យោគ " ។ វិធីដែលតម្រួតគ្នានោះដូច្នេះគឺ បណ្ដាព្យញ្ជនៈក្នុង

វគ្គទាំង ៥ នោះ ព្យញ្ជនៈទី ១ ត្រូវតម្រួតលើតួឯងនិងលើព្យញ្ជនៈទី ២ ព្យញ្ជនៈទី ៣ ត្រូវតម្រួតលើតួឯងនិងលើព្យញ្ជនៈទី ៤, តាមលំដាប់វគ្គរបស់ខ្លួន ៗ ព្យញ្ជនៈទី ៥ ត្រូវតម្រួតលើព្យញ្ជនៈទាំង ៤ តួក្នុងវគ្គរបស់ខ្លួន ៗ បាន លើកតែ "ង" មួយចេញដែលនឹងតម្រួតលើតួឯងពុំបាន (ពីព្រោះក្នុងភាសាបាឡីមិនមានវិធីប្រើ) ឯព្យញ្ជនៈ ៤ តួក្រៅពី "ង" អាចនឹងតម្រួតលើតួឯងបាន ។ ចំណែកខាងព្យញ្ជនក្នុងអវគ្គៈ ៣ តួ គឺ យ ល ស នេះ តម្រួតលើតួឯងបាន ។

ព្យញ្ជនៈដែលតម្រួតគ្នា ដូចនិយាយមកហើយខាងលើនេះ ព្យញ្ជនៈតួលើគ្រាន់តែជាតួប្រកបរបស់អក្សរ ដែលនៅពីខាងដើមខ្លួន គឺថា តួលើនោះមិនបញ្ចេញសំឡេងផ្សំនឹងព្យញ្ជនៈតួក្រោមផងទេ ហើយមិនមានស្រៈរាំងខាំងសំឡេងឡើយ ឯព្យញ្ជនៈតួក្រោមជាអក្សរបញ្ចេញសំឡេងតាមលំនាំស្រៈ ដែលខ្លួនអាស្រ័យផងនោះ ដូចជាពាក្យថា "សក្កា" សូរឮថា "កា" នេះគឺ សូរតួ "ក" ខាងក្រោម ឯតួ "ក" ខាងលើគ្រាន់តែជាអក្សរប្រកបឲ្យ

តួ "ស" ខាងដើមមានសំឡេងធ្ងន់ថា "ស័ក" តួ "ក" ខាងក្រោមដែលអាស្រ័យនឹងស្រៈ "អា" ក៏បញ្ចេញសំឡេងថា "កា" គឺឲ្យថា "ស័ក-កា" ។

សេចក្ដីដែលនិយាយមកនេះ គឺ ចំពោះព្យញ្ជនៈដែលមានកំណត់ត្រូវតម្រួតគ្នាតាមលំដាប់វគ្គ និងតម្រួតគ្នាលើតួឯង ។ នៅមានវិធីតម្រួតផ្សេងពីនេះទៅទៀត គឺ ព្យញ្ជនៈជាវគ្គតម្រួតគ្នាលើព្យញ្ជនៈជាអវគ្គៈឬក៏ព្យញ្ជនៈជាអវគ្គៈតម្រួតគ្នាលើព្យញ្ជនៈជាអវគ្គៈតួផ្សេងគ្នា ដូចជា បញ្ហោ, តណ្ហា, អន្ទាយ, អម្ហាកំ, មយ្ហំ, ជិវ្ហា, រុឡ្ហា, អគ្យាគារំ, តត្រ, កត្វា, ទិស្វា ជាដើមនោះ ខ្ញុំមិននាំមកអធិប្បាយក្នុងទីនេះទេ (ពីព្រោះកុំឲ្យអ្នកសិក្សាដំបូងធុញទ្រាន់) ទុកឱកាសឲ្យលោកអាចារ្យអ្នកបង្រៀន អធិប្បាយពន្យល់សិស្សដែលពេញចិត្តសេចក្ដីពិស្ដារក្នុងការសិក្សាផងចុះ ។

# សន្ធិ

[១៥] ក្នុងបាឡីភាសា មានវិធីតបទ តអក្ខរៈ ភ្ជាប់ជាមួយនឹងអក្ខរៈ ដូចជា "តត្ថ ឯវ" តភ្ជាប់ជា "តត្ថេវ" ជាដើម ហៅថា "សន្ធិ" ។ សន្ធិនោះជាឧបការដល់វិធីតែងឆន្ទ ឬការពោលស្រួលមាត់ប៉ុណ្ណោះឯង ។

វិធីត (សន្ធិ) នោះសម្តែងដោយលក្ខណៈមាន ២ យ៉ាង គឺ

១- តសព្ទដែលមានវិភត្តិភ្ជាប់នឹងសព្ទដែលមានវិភត្តិដូចគ្នា ឧ. ចត្តារោ + ឥមេ តភ្ជាប់ជា ចត្តារោមេ,

២- តសព្ទដែលលុបវិភត្តិចេញខ្លះតាមវិធីសមាស ឧ. កត + ឧបការោ តភ្ជាប់ជា កតូបការោ ។

សន្ធិ សម្តែងដោយឈ្មោះដែលជាប្រធាននៃវិធីតមាន ៣ យ៉ាង គឺ

១- សរសន្ធិ តដោយសរៈ (ស្រៈ)

២- ព្យញ្ជនសន្ធិ តដោយព្យញ្ជនៈ

៣- និគ្គហិតសន្ធិ តដោយនិគ្គហិត ។

## សន្ធិកិរិយោបករណ៍

ប្រភេទជាគ្រឿងទំនុកបម្រុងដល់វិធីតសន្ធិ ហៅថា សន្ធិកិ-រិយោបករណ៍ មាន ៨ យ៉ាងគឺ

១- លោបោ លុប គឺបំបាត់តួអក្សរចេញ,

២- អាទេសោ អាទេស គឺផ្លាស់តួអក្សរ,

៣- អាគមោ ចុះអាគម គឺចុះតួអក្សរថែម,

៤- វិការោ វិការៈ គឺផ្លាស់ស្រៈធ្វើជាស្រៈឲ្យប្លែកចាករូបដើម

៥- បកតិ ប្រក្រតី គឺធ្វើឲ្យគង់រូបនៅដូចដែល,

៦- ទីឃោ ទីឃៈ គឺធ្វើស្រៈខ្លីឲ្យជាស្រៈវែង,

៧- រស្សោ រស្សៈ គឺធ្វើស្រៈវែងឲ្យជាស្រៈខ្លី,

៨- សំយោគោ សំយោគ គឺតម្រួតតួព្យញ្ជនៈ ។

## សរសន្ធិ

ក្នុងសរសន្ធិ មានសន្ធិកិរិយោបករណ៍ ៧ គឺ ក្នុងសន្ធិកិរិ-យោបករណ៍ទាំង ៨ នោះ លើកតែសំយោគោ ១ ចេញ ក្រៅពីនោះនៅទាំងអស់ ។

[១៦] លោបោ លុប, គឺលុបស្រៈ ១ តួចេញទុកឲ្យនៅតែ ១ តួ ហៅថា សរលោបសន្ធិ "តដោយលុបស្រៈ" មាន ២ យ៉ាងគឺ

ក) លុបស្រៈខាងដើមចេញ ហើយតភ្ជាប់នឹងស្រៈខាងចុង ហៅថា បុព្វសរលោបសន្ធិ "តដោយលុបស្រៈខាងដើម"

ខ) លុបស្រៈខាងចុងចេញ ហើយតភ្ជាប់នឹងស្រៈខាងដើម ហៅថា បរសរលោបសន្ធិ "តដោយលុបស្រៈខាងចុង" ។

ស្រៈទីបំផុតរបស់សព្ទខាងដើម ហៅថា ស្រៈខាងដើម ស្រៈសុទ្ធគឺស្រៈពេញតួ ដែលនៅជាខាងដើមបំផុតនៃសព្ទខាងចុង ហៅថា ស្រៈខាងចុង ដូចជា ឥធ + អាគតោ, ធ ជាស្រៈ អ ហៅថា ស្រៈខាងដើម, អា ហៅថា ស្រៈខាងចុង, ត្រូវលុបស្រៈ អ របស់ ធ ចេញ ហើយត ធ ភ្ជាប់នឹង អា ជា ឥធាគតោ ។ ឯវិធីលុបស្រៈនោះ លុះតែស្រៈទាំង ២ នៅផ្ទាល់ប្រទល់គ្នាមិនមានព្យញ្ជនៈនៅរាំងត្រង់ចន្លោះកណ្ដាលនោះទើបលុបបាន បើមានព្យញ្ជនៈនៅរាំងត្រង់ចន្លោះនោះនឹងលុបពុំបានឡើយ ។

បុព្វសរលោបសន្ធិ តដោយលុបស្រះខាងដើមដូច្នេះគឺ យស្ស + ឥន្ទ្រិយានិ ជា យស្សិន្ទ្រិយានិ, នោហិ + ឯតំ ជា នោហេតំ, សព្វ + ឦតិយោ ជា សព្វីតិយោ, តេន + អាកា-រេន ជា តេនាការេន, សមេតុ + អាយស្មា ជា សមេតាយស្មា, តយោ + អស្សុ ជា តយស្សុ, តថា + អាគតោ ជា តថាគតោ ។

ដែលលុបស្រះខាងដើមហើយតភ្ជាប់នឹងស្រះខាងចុងតែម្តង មិនបាច់មានវិធីអ្វីតទៅទៀតដូចនិយាយខាងលើនោះ បាន ចំពោះតែស្រះខាងដើមជា រស្សៈ, ស្រះខាងចុងជា ទីឃៈ ដូច នោ-ហិ+ ឯតំ ជាដើម ឬស្រះខាងចុងជា គរុ ដូច យស្ស + ឥន្ទ្រិយានិ ជាដើម ឬក៏ស្រះទាំងពីរខាងដើមនិងខាងចុងសុទ្ធតែជាទីឃៈ ដូច តថា + អាគតោ ជាដើមនោះដែរ ទើបលុបបាន, បើស្រះទាំង ពីរសុទ្ធតែជា រស្សៈ ជា លហុ ហើយមានរូបស្មើគ្នា ដែលហៅ ថា "សវណ្ណៈ" គឺ អនិងអ ឥនិងឥ, ឧនិងឧ នោះ កាលបើ លុបស្រះខាងដើមចេញហើយ នឹងប្រើវិធីត្រឹមតែលុបស្រះខាង ដើមប៉ុណ្ណោះ ហើយតភ្ជាប់តែម្តងជាការស្រេចនោះពុំបានឡើយ

ត្រូវប្រើវិធីតាមដំណើរ ទីឃសន្ធិខាងមុខត្រង់លេខ ២១ នោះវិញទើបបាន គឺត្រូវលុបស្រៈខាងដើមហើយ ទីឃៈស្រៈខាងចុងឲ្យជាស្រៈវែង គឺ ទីឃៈ ស្រៈអជាអា, ឥជាឦ, ឧជាឩ ដូច្នេះ អ + អ, តត្រ + អយំ ជា តត្រាយំ, ឥ + ឥ, វុច្ចតិ + ឥតិ ជា វុច្ចតីតិ, ឧ + ឧ, ពហុ + ឧបការោ ជា ពហូបការោ[១] ។

បើស្រៈទាំងពីរតួជាស្រៈមានរូបមិនស្មើគ្នា ដែលហៅថា "អសវណ្ណៈ" គឺ អនិងឥ អានិងឥ, អនិងឧ, អានិងឧ, ឥនិងអ, ឥនិងឧ ជាដើមនោះ បើស្រៈទាំងពីរតួជា រស្សៈ ជាលហុ ដូចគ្នានឹងប្រើវិធីលោបសន្ធិ គ្រាន់តែលុបស្រៈខាងដើមហើយតភ្ជាប់តែម្តងមិនបាច់ទីឃៈស្រៈខាងចុងក៏បានខ្លះ ដូចជា អ, ឥ, តត្រ + ឥមេ ជា តត្រិមេ, អ + ឧ, តត្រ + ឧបាយោ ជា តត្រុបាយោ, ឥ + អ, ចតូហិ + អបាយេហិ ជា ចតូហបាយេហិ, ឥ + ឧ, បញ្ចហិ + ឧបាលិ ជា បញ្ចហុបាលិ ។

---

១ ដែលទីឃៈយ៉ាងនេះ ជាវិធីធ្វើតាមដំណើរសន្ធិ តែនឹងបានកំណាត់តាមបែបនេះជាការដាច់ខាតនោះក៏មិនមែនទេ បើមិនបាច់ទីឃៈស្រៈខាងចុងគ្រាន់តែលុបស្រៈខាងដើមហើយតភ្ជាប់តែម្តង តាមដំណើរលោបសន្ធិជាពហុបការោ ដូច្នេះក៏គង់ប្រើបាន តាមគួរដល់ការប្រកប ។

បើស្រៈជា អស្សវណ្ណៈ ខាងដើមជា ទីឃៈ ខាងចុងជា រស្សៈ ជាលហុ ត្រូវលុបស្រៈខាងដើមចេញហើយទីឃៈស្រៈខាងចុងតាមដំណើរ ទីឃសន្ធិខាងមុខ ត្រង់លេខ ២១ ដូចជា អា + ឥ, សទ្ធា + ឥធ ជា សទ្ធីធ, អា + ឧ, តថា + ឧបមំ ជា តថូបមំ ។

បរសរលោបសន្ធិ តដោយលុបស្រៈខាងចុង ដូច្នេះ គឺ ចត្តារោ + ឥមេ ជា ចត្តារោមេ, សីហោ + ឥវ ជា សីហោវ, មាតា + ឥតិ ជា មាតាតិ, សោ + ឥទានិ ជា សោទានិ, តេ + អបិ ជា តេបិ ។ បើមាននិគ្គហិតនៅខាងដើមប្រទល់គ្នា នឹងស្រៈខាងចុង, ត្រូវលុបស្រៈខាងចុងចេញហើយផ្លាស់និគ្គហិតធ្វើជា "ន" ដូច្នេះ អភិនន្ទំ + ឥតិ ជា អភិនន្ទុន្តិ (មើលទៅក្នុងខាងមុខត្រង់លេខ ២៩) ។

[១៧] អាទេសោ ផ្លាស់តួអក្សរ, គឺផ្លាស់ស្រៈធ្វើជាព្យញ្ជនៈ ហៅថា សរាទេសសន្ធិ "តដោយផ្លាស់ស្រៈ (ធ្វើជាព្យញ្ជនៈ) មាន ២ យ៉ាងគឺ

*ក)* ផ្លាស់ស្រៈខាងដើមធ្វើជាព្យញ្ជនៈហើយតភ្ជាប់ ហៅថា បុព្វសរាទេសសន្ធិ "តដោយផ្លាស់ស្រៈខាងដើម",

ខ) ផ្លាស់ស្រះខាងចុងធ្វើជាព្យញ្ជនៈហើយតភ្ជាប់ ហៅថា បរសរាទេសសន្ធិ "តដោយផ្លាស់ស្រះខាងចុង" ។

បុព្វសរាទេសសន្ធិ តដោយផ្លាស់ស្រះខាងដើម ដូច្នេះ គឺ បើមានស្រះ ឥ ឬស្រះ ឯ នៅខាងដើម ហើយមានស្រះណាមួយ នៅខាងចុង ត្រូវផ្លាស់ស្រះ ឥ ឬ ឯ ខាងដើមនោះធ្វើជា "យ", បើព្យញ្ជនៈដែលស្រះខាងដើមអាស្រ័យផងនោះ តម្រួតគ្នាជាសទិ-សសំយោគ ពីរតួ ត្រូវលុបមួយតួចេញទុកតែមួយតួ (តាមវិធី ព្យញ្ជនលោបសន្ធិខាងមុខត្រង់លេខ ២៣) ឧ. ផ្លាស់ ឥ ជា "យ", វុត្តិ+អស្ស ជា វុត្យស្ស, អគ្គិ + អគារំ ជា អគ្យាគារំ ។ ផ្លាស់ ឯ ជា "យ", តេ + អស្ស ជា ត្យស្ស, មេ + អយំ ជា ម្យាយំ, តេ + អហំ ជា ត្យាហំ ។ (គ្យា, ម្យា, ត្យា, ធ្វើ តាមវិធីទីឃសន្ធិខាងមុខត្រង់លេង ២១) ។ បើមានស្រះ ឧ ឬ ស្រះ ឱ នៅខាងដើម ហើយមានស្រះណាមួយនៅខាងចុង, ត្រូវ ផ្លាស់ស្រះ ឧ ឬ ឱ ខាងដើមនោះធ្វើជា "វ" ឧ. ផ្លាស់ ឧ ជា "វ" ពហុ + អាពាធោ ជា ពហ្វាពាធោ, ចក្ខុ + អាបាថំ ជា ចក្ខ្វាបាថំ,

វត្តុ + ឯត្ថ ជា វត្តេត្ថ ។ ផ្លាស់ ឱ ជា "វ", អថខោ + អស្ស ជា អថខ្វស្ស, សោ + អស្ស ជា ស្វស្ស, ពោគោ + អត្ថិ ជា ពោគ្វត្ថិ ។

បរសរាទេសសន្ធិ តដោយផ្លាស់ស្រៈខាងចុង ដូច្នេះ គឺបើមានស្រៈទីឃៈនៅខាងដើម ហើយមាន ឯវ សព្ទនៅខាងចុង ត្រូវផ្លាស់ ឯ របស់ ឯវសព្ទ ដែលជាស្រៈខាងចុងនោះធ្វើជា "រ" ហើយរស្សៈស្រៈខាងដើមឲ្យជាស្រៈខ្លី (តាមវិធីរស្សសន្ធិខាងមុខត្រង់លេខ ២២) ឧ. យថា + ឯវ ជា យថរិវ, តថា + ឯវ ជា តថរិវ ។

[១៨] អាគមោ ចុះអាគម, គឺចុះស្រៈថែមហើយតភ្ជាប់ ហៅថា សរាគមសន្ធិ "តដោយចុះស្រៈថែម", ស្រៈដែលចុះមកនោះហៅថា អាគម "អក្សរចុះថែម" ។ ឯវិធីចុះអាគមនោះដូច្នេះ គឺ បើមានស្រៈ ឱ នៅខាងដើម ហើយមាន ព្យញ្ជនៈនៅខាងចុង ត្រូវលុបស្រៈ ឱ នោះចេញហើយចុះ "អ" អាគមត្រង់កន្លែងស្រៈ ឱ នោះ ឧ. សោ + សីលវា ជា ស សីលវា, សោ + បញ្ញវា ជា ស បញ្ញវា, ឯសោ + ធម្មោ ជា ឯស ធម្មោ ។ បើមានស្រៈ

អ នៅខាងដើម ហើយមានព្យញ្ជនៈនៅខាងចុង, ត្រូវលុបស្រៈ អ នោះចេញហើយចុះ "ឱ" អាគមត្រង់កន្លែងស្រៈ អ នោះ ។. បរ + សហស្សំ ជា បរោសហស្សំ, សរទ + សតំ ជា សរទោសតំ ។ (អាគមក្នុងសរាគមសន្ធិនេះមានតែពីរតួគឺ អ និង ឱ ប៉ុណ្ណោះ) ។

[១៩] វិការោ វិការៈ, គឺផ្លាស់ស្រៈធ្វើជាស្រៈឲ្យប្លែកចាករូបដើម ហៅថា វិការសន្ធិ "តដោយធ្វើឲ្យប្លែកចាកភាពដើម" មាន ២ យ៉ាងគឺ

ក) ផ្លាស់ស្រៈខាងដើមធ្វើជាស្រៈឲ្យប្លែកចាកភាពដើមហៅថា បុព្វវិការសន្ធិ "តដោយវិការៈស្រៈខាងដើម" ។

ខ) ផ្លាស់ស្រៈខាងចុងធ្វើជាស្រៈឲ្យប្លែកចាកភាពដើម ហៅថា បរវិការសន្ធិ "តដោយវិការៈស្រៈខាងចុង" ។

បុព្វវិការសន្ធិ តដោយវិការៈស្រៈខាងដើម ដូច្នេះគឺ បើមានស្រៈជា អស្សវណ្ណៈ ប្រទល់គ្នា គឺស្រៈ ឥ ឬ ឧ នៅខាងដើម ហើយមានស្រៈណាមួយនៅខាងចុង, ត្រូវផ្លាស់ ឥ ធ្វើជា ឯ, ឧ

ធ្វើជា ឱ ហើយលុបស្រះខាងចុងចេញ (តាមវិធីបរសរលោបសន្ធិខាងដើមត្រង់លេង ១៦) ឧ ផ្លាស់ ឥ ជា ឯ, មុនិ + អាលយោ ជា មុនេលយោ ។ ផ្លាស់ ឧ ជា ឱ, សុ+អត្ថិ ជា សោត្ថិ ។

បរវិការសន្ធិ តដោយវិការៈស្រះខាងចុង ដូច្នេះគឺ បើមានស្រះជា អស្សវណ្ណៈ ប្រទល់គ្នា គឺស្រះ ឥ ឬ ឧ នៅខាងចុង ហើយមានស្រះណាមួយនៅខាងដើម, ត្រូវផ្លាស់ ឥ ធ្វើជា ឯ, ឧ ធ្វើជា ឱ ហើយលុបស្រះខាងដើមចេញ (តាមវិធីបុព្វសរលោបសន្ធិខាងដើមត្រង់លេខ ១៦) ឧ. ផ្លាស់ ឥ ជា ឯ, ពន្ធុស្ស + ឥវ ជា ពន្ធុស្សេវ, សមណស្ស + ឥទំ ជា សមណស្សេទំ ។ ផ្លាស់ ឧ ជា ឱ, ន + ឧបេតិ ជា នោបេតិ, ន + ឧបាយោ ជា នោបាយោ, អន + ឧទកំ ជា អនោទកំ ។

អ្នកសិក្សាត្រូវកំណត់ចាំថា សរាទេសសន្ធិ តដោយវិធីផ្លាស់ស្រះធ្វើជាព្យញ្ជនៈ គឺ ផ្លាស់ ឥ ជា "យ", ផ្លាស់ ឧ ជា "វ", ផ្លាស់ ឯ របស់ឯវសព្ទធ្វើជា "រិ" ឯវិការសន្ធិនេះ តដោយ

វិធីផ្លាស់ស្រៈធ្វើជាស្រៈ ទោះផ្លាស់ស្រៈខាងដើមក្ដីខាងចុងក្ដី មានវិធីតែ ២ យ៉ាងគឺផ្លាស់ ឥ ជា ឯ, ផ្លាស់ ឧ ជា ឱ, ប៉ុណ្ណោះ ជាការងាយចំណាំ ។

[២០] បកតិ ប្រក្រតី គឺទុកស្រៈឲ្យគង់រូបតាមប្រក្រតីដើម ហៅថា សរបកតិសន្ធិ "តដោយទុកស្រៈឲ្យនៅតាមប្រក្រតីដើម" ឧ. កោ + ឥមំ. គួរនឹងលុបស្រៈ ឥ ខាងចុងហើយតភ្ជាប់ជា កោមំ តាមដំណើរសរលោបសន្ធិ, មិនធ្វើដូច្នោះ បែរជាទុកស្រៈ ឥ ខាងចុងឲ្យនៅជា កោ ឥមំ ដូចដែលទៅវិញ ។ បើមានស្រៈនៅខាងដើម មានព្យញ្ជនៈនៅខាងចុង ឧ. មនោ + បុព្វង្គមា, គួរនឹងលុបស្រៈ ឱ ខាងដើមចេញហើយតភ្ជាប់ជា មនបុព្វង្គមា, មិនធ្វើដូច្នោះ បែរជាទុកស្រៈ ឱ ឲ្យនៅជា មនោបុព្វង្គមា[១] ដូចដែលទៅវិញ ។

[២១] ទីឃោ ទីឃៈ, គឺធ្វើស្រៈខ្លីឲ្យជាស្រៈវែង ហៅថា ទីឃសន្ធិ "តដោយទីឃៈ" មាន ២ យ៉ាងគឺ

---

១ ចូរមើលក្នុងនាមនិទ្ទេសទី ២ ខាងមុខ ត្រង់មនោគណាសព្ទ លេខ ៨៦ ។

ក) តដោយធ្វើស្រះខ្លីខាងដើមឲ្យជាស្រះវែង ហៅថា បុព្វ-ទីឃសន្ធិ "តដោយទីឃៈស្រះខាងដើម" ,

ខ) តដោយធ្វើស្រះខ្លីខាងចុងឲ្យជាស្រះវែង ហៅថា បរ-ទីឃសន្ធិ "តដោយទីឃៈស្រះខាងចុង" ។

បុព្វទីឃសន្ធិ តដោយទីឃៈស្រះខាងដើម ដូច្នេះគឺ បើស្រះទាំង ២ ខាងជា អស្សវណ្ណៈ ប្រទល់គ្នា ហើយសុទ្ធតែជារស្សៈ ជាលហុដូចគ្នា, ត្រូវលុបស្រះខាងចុងចេញហើយទីឃៈស្រះខាងដើមឲ្យជាស្រះវែង ឧ. កឹសុ + ឥធ ជា កឹសូធ, សាធុ + ឥតិ ជា សាធូតិ ។ បើមានព្យញ្ជនៈនៅខាងចុង, ក៏ត្រូវទីឃៈស្រះខាងដើមបានខ្លះ ឧ. មុនិ + ចរេ ជា មុនីចរេ, រមតិ + មនោ ជា រមតីមនោ ។

បរទីឃសន្ធិ តដោយទីឃៈស្រះខាងចុង ដូច្នេះគឺ ស្រះទាំង ២ ខាងដែលប្រទល់គ្នានោះ ទោះជា សវណ្ណៈ ក្តី ជា អស្សវណ្ណៈក្តី,កាលបើលុបស្រះខាងដើមចេញហើយ បើស្រះខាងចុងជារស្សៈជាលហុ នោះត្រូវទីឃៈស្រះខាងចុងឲ្យជាស្រះវែង ឧ.សទ្ធា + ឥធ ជា សទ្ធីធ, ច + ឧភយំ ជា ចូភយំ, តត្រ + អភិរតី ជា តត្រាភិរតី,

អគ្យ + អគារំ ជា អគ្យាគារំ, ម្យ + អឃំ ជា ម្យាឃំ, ត្យ + អហំ ជា ត្យាហំ ។ (មើលសរលោបសន្ធិខាងដើមត្រង់លេខ ១៦) ។

[២២] វស្សោ វស្សៈ, គឺ ធ្វើស្រៈវែងឲ្យជាស្រៈខ្លី ហៅថា វស្សសន្ធិ "តដោយរស្សៈ" មាន ២ យ៉ាង គឺ

*ក)* រស្សៈដោយវិធីផ្លាស់ស្រៈ ឯ របស់ឯវសព្ទធ្វើជា "រិ" (តាមន័យក្នុងសរាទេសសន្ធិខាងដើមត្រង់លេខ ១៧) ឬចុះ "គ" អាគម (តាមន័យក្នុងព្យញ្ជនាគមសន្ធិខាងមុខត្រង់លេខ ២៥) សិន ហើយទើបរស្សៈស្រៈខាងដើមឲ្យជាស្រៈខ្លី ហៅថា សនិទ្ទេសវស្សសន្ធិ "តដោយវិធីមានផ្លាស់ស្រៈសិនហើយទើបរស្សៈ" ឧ. យថា + ឯវ ជា យថរិវ, តថា + ឯវ ជា តថរិវ, បា + ឯវ ជា បគេវ ។

*ខ)* បើមានព្យញ្ជនៈនៅខាងចុង ត្រូវរស្សៈស្រៈខាងដើមឲ្យជាស្រៈខ្លី ហៅថា អនិទ្ទេសវស្សសន្ធិ "តដោយវិធីគ្រាន់តែរស្សៈស្រៈខាងដើម ឥតមានផ្លាស់ស្រៈផងឡើយ ឧ. ភោវាទី + នាម ជា ភោវាទិនាម, ញាតី-ភិ ជា ញាតិភិ, ព្រហ្មចារី-សុ ជា ព្រហ្មចារិសុ ។

## ព្យញ្ជនសន្ធិ

ក្នុងព្យញ្ជនសន្ធិ មានសន្ធិកិរិយោបករណ៍ ៥ គឺ លោបោ ១ អាទេសោ ១ អាគមោ ១ បកតិ ១ សំយោគោ ១ ។

[២៣] លោបោ លុប គឺ លុបព្យញ្ជនៈដែលតម្រួតគ្នា ១ តួចេញ ទុកឲ្យនៅលាតតែ ១ តួហើយតភ្ជាប់ ហៅថា ព្យញ្ជន-លោបសន្ធិ "តដោយលុបព្យញ្ជនៈ" ។ វិធីលុបព្យញ្ជនៈនោះដូច្នេះ គឺ កាលបើមាននិគ្គហិតនៅខាងដើម មានស្រៈនៅខាងចុងប្រទល់គ្នានឹងនិគ្គហិត គឺ ប្រទល់ត្រង់ចន្លោះបទទាំង ២ លុះលុបស្រៈខាងចុងនោះចេញហើយ បើព្យញ្ជនៈខាងចុងបន្ទាប់ស្រៈដែលលុបហើយនោះតម្រួតគ្នាពីរតួ ត្រូវលុបមួយតួចេញ ទុកឲ្យនៅលាតតែមួយតួ ឧ. ឯវំ + អស្ស ជា ឯវំស, បុប្ផំ + អស្សា ជា បុប្ផំសា ។

បើព្យញ្ជនៈតម្រួតគ្នា ៣ តួ ត្រូវលុបព្យញ្ជនៈដែលមានរូបស្មើគ្នា គឺ ព្យញ្ជនៈដែលតម្រួតលើតួឯងមួយតួចេញ ឧ. វុត្យ + អស្ស ជា វុត្យស្ស, អគ្ព្យ + អគារំ ជា អគ្យាគារំ ។ ប៉ុន្តែបើព្យញ្ជនៈ

តម្រួតគ្នា ៣ តួជា អសទិសសំយោគ ដូចជា ចក្ខាបាចំ, វត្តេត្ថ យ៉ាងនេះត្រូវទុកទាំង ៣ តួបាន ។ (មើលក្នុងខាងដើមត្រង់ លេខ ១៧ និងលេខ ២១) ។

[២៤] អាទេសោ ផ្លាស់តួអក្សរ គឺផ្លាស់ព្យញ្ជនៈធ្វើជា ព្យញ្ជនៈ ហើយតភ្ជាប់ ហៅថា ព្យញ្ជនាទេសសន្ធិ "តដោយ ផ្លាស់ព្យញ្ជនៈ" ។ វិធីផ្លាស់ព្យញ្ជនៈនោះដូច្នេះ គឺ បើមាន "តិ" នៅខាងដើម ហើយមានស្រៈនៅខាងចុង, ត្រូវផ្លាស់ "តិ" ជា "ច" ឧ. ឥតិ + ឯវំ ជា ឥច្ចេវំ, បតិ + អាគមិ ជា បច្ចាគមិ, បតិ + ឧត្តរិត្វា ជា បច្ចុត្តរិត្វា (តម្រួត "ច" ជា "ច្ច" តាមវិធី សំយោគសន្ធិខាងមុខត្រង់លេខ ២៧) ។

បើមានព្យញ្ជនៈនៅខាងចុង ត្រូវផ្លាស់ "ធ" ជា "ទ" ក៏បានខ្លះ ឧ. ឯកំ + ឥធ + អហំ ជា ឯកមិទាហំ[១] (មើល ទីឃសន្ធិខាងដើមត្រង់លេខ ២១ និងនិគ្គហិតាទេសសន្ធិខាង មុខត្រង់លេខ ២៩) ។

---

១ បើតាមសណ្ដាប់សន្ធិ ជា ឯកមិធាហំ ក៏បាន ។

-៣៨-

ផ្លាស់ដូចមានរបៀបខាងក្រោយនេះក៏បាន

ផ្លាស់ ធ ជា ហ ឧ. សាធុ + ទស្សនំ ជា សាហុទស្សនំ,

ផ្លាស់ ទ ជា ត ឧ. សុគទោ ជា សុគតោ,

ផ្លាស់ ត ជា ដ ឧ. ទុក្កតំ ជា ទុក្កដំ,

ផ្លាស់ ត ជា ធ ឧ. គន្តព្វោ ជា គន្ធព្វោ,

ផ្លាស់ ត ជា ត្រ ឧ. អត្តជោ ជា អត្រជោ,

ផ្លាស់ គ ជា ក ឧ. កុលុបគោ ជា កុលុបកោ,

ផ្លាស់ រ ជា ល ឧ. មហាសារោ ជា មហាសាលោ,

ផ្លាស់ យ ជា ជ ឧ. គវយោ ជា គវជោ,

ផ្លាស់ វ ជា ព ឧ. កុវតោ ជា កុព្វតោ[១]

ផ្លាស់ យ ជា ក ឧ. សយំ ជា សកំ,

ផ្លាស់ ដ ជា យ ឧ. និដំ ជា និយំ,

ផ្លាស់ ត ជា ក ឧ. និយតោ ជា និយកោ,

---

១ តម្រួត ព ជា ព្វ ។

ផ្លាស់ ត ជា ច ឧ. ភតោ ជា ភច្ចោ[១]

ផ្លាស់ ប ជា ផ ឧ. និប្បតិ ជា និប្ផតិ[២] ។

ទោះមានស្រះក្តីព្យញ្ជនៈក្តីនៅខាងចុង ត្រូវផ្លាស់បានដូចខាងក្រោយនេះគឺ ផ្លាស់ អភិ ជា អព្ភ ឧ. អភិ + ឧគ្គច្ឆតិ ជា អព្ភុគ្គច្ឆតិ ។ ផ្លាស់ អធិ ជា អជ្ឈ ឧ. អធិ + ឱកាសោ ជា អជ្ឈោកាសោ ។ ផ្លាស់ អវ ជា ឱ ឧ. អវ + នទ្ធា ជា ឱនទ្ធា ។

[២៥] អាគមោ ចុះអាគម, គឺចុះព្យញ្ជនៈថែមហើយតភ្ជាប់ហៅថា ព្យញ្ជនាគមសន្ធិ "តដោយចុះព្យញ្ជនៈថែម", ព្យញ្ជនៈដែលចុះមកនោះ ហៅថា អាគម "អក្សរចុះថែម" ។ អាគមនោះមាន ១០ តួគឺ យ, វ, ម, ទ, ន, ត, រ, ឡ, ហ, គ ។ អាគមទាំង ១០ តួនេះ បើលុះតែមានស្រះនៅខាងចុងនោះទើបចុះបានដូចមានរបៀបខាងក្រោយនេះ ។

យៈ យថា + ឥទំ ជា យថាយិទំ,

វៈ ភន្តា + ឧទិក្ខតិ ជា ភន្តាវុទិក្ខតិ,

---

១. តម្រួត ច ជា ច្ច ។ ២. ផ្លាស់ ប តួក្រោមគឺជើង ប ជា ផ ហើយដាក់ក្រោម ប ជា ប្ផ តាមវិធីសំយោគសន្ធិខាងមុខត្រង់លេខ ២៧ ។

| | | | |
|---|---|---|---|
| ម: | លហុ + ឯស្សតិ | ជា | លហុមេស្សតិ, |
| ទ: | អត្ត + អត្ថំ | ជា | អត្តទត្ថំ, |
| ន: | ឥតោ + អាយតិ | ជា | ឥតោនាយតិ, |
| ត: | អជ្ជ + អគ្គេ | ជា | អជ្ជតគ្គេ, |
| រ: | សព្ភិ + ឯវ | ជា | សព្ភិរេវ, |
| ឡ: | ឆ + អាយតនំ | ជា | ឆឡាយតនំ, |

ហ: សុ + ឧជុ ជា សុហុជុ, សុ+ ឧដ្ឋិតំ ជា សុហុដ្ឋិតំ,

គ: បា + ឯវ ជា បគេវ, អតិប្បា+ខោ ជា អតិប្បគោខោ។

[២៦] បកតិ ប្រក្រតី គឺ ទុកព្យញ្ជនៈឲ្យគង់រូបនៅដូចដែល ហៅថា ព្យញ្ជនបកតិសន្ធិ "តដោយទុកព្យញ្ជនៈឲ្យនៅតាមប្រក្រតីដើម" ឧ. សាធុ + ទស្សនំ, គួរនឹងផ្លាស់ ធ ជា ហ (តាមវិធីព្យញ្ជនាទេសសន្ធិខាងដើមត្រង់លេខ ២៤) ឲ្យជា សាហុទស្សនំ, មិនផ្លាស់ដូច្នោះ បែរជាទុកឲ្យគង់រូបនៅជា សាធុទស្សនំ តាមប្រក្រតីដើមដូចដែលទៅវិញ ។

[២៧] សំយោគោ សំយោគ, គឺ តម្រួតព្យញ្ជនៈតាមលំដាប់វគ្គ (តាមវិធីព្យញ្ជនសំយោគខាងដើមត្រង់លេខ ១៤) ។ ហៅថា សំយោគសន្ធិ "តដោយតម្រួតព្យញ្ជនៈ" មាន ២ យ៉ាងគឺ

*ក)* សទិសសំយោគសន្ធិ "តដោយតម្រួតព្យញ្ជនៈដែលមានរូបស្មើគ្នា" គឺតម្រួតដោយតួឯង ឧ. វចន + កមោ ជា វចនក្កមោ, ឥធ + បមាទោ ជា ឥធប្បមាទោ, មហ + ពលំ ជា មហព្ពលំ ។

*ខ)* អសទិសសំយោគសន្ធិ "តដោយតម្រួតព្យញ្ជនៈដែលមានរូបមិនស្មើគ្នា" គឺ តម្រួតដោយព្យញ្ជនៈតួផ្សេងគ្នា ប៉ុន្តែតាមលំដាប់វគ្គ ឧ. ន + ខមតិ ជា នក្ខមតិ, បឋម + ឈានំ ជា បឋមជ្ឈានំ, ចត្តារិ + ឋានានិ ជា ចត្តារិដ្ឋានានិ, មហ + ផលំ ជា មហប្ផលំ ។

## និគ្គហិតសន្ធិ

ក្នុងនិគ្គហិតសន្ធិ មានសន្ធិកិរិយោបករណ៍ ៤ គឺ លោ-បោ ១ អាទេសោ ១ អាគមោ ១ បកតិ ១ ។

[២៨] លោបោ លុប គឺ លុបនិគ្គហិតចេញហើយត ភ្ជាប់ ហៅថា និគ្គហិតលោបសន្ធិ "តដោយលុបនិគ្គហិត" ។ វិធីលុបនិគ្គហិតនោះដូច្នេះ គឺ ទោះមានស្រះក្តី ព្យញ្ជនៈក្តី នៅខាងចុង, ត្រូវលុបនិគ្គហិតដែលនៅខាងដើមបានខ្លះ ឧ. តាសំ + អ-ហំ ជា តាសាហំ (ទីឃៈ អ ជា អា ដោយទីឃសន្ធិខាងដើមត្រង់លេខ ២១), វិទូនំ + អគ្គំ ជា វិទូនគ្គំ, អរិយសច្ចានំ + ទស្សនំ ជា អរិយសច្ចាន ទស្សនំ, ពុទ្ធានំ + សាសនំ ជាពុទ្ធាន សា-សនំ, ពាលានំ + សំសារោ ជា ពាលាន សំសារោ ។

[២៩] អាទេសោ អាទេស គឺ ផ្លាស់និគ្គហិតធ្វើជាព្យញ្ជនៈហើយតភ្ជាប់ ហៅថា និគ្គហិតាទេសសន្ធិ "តដោយផ្លាស់និគ្គហិត" ។ វិធីផ្លាស់និគ្គហិតនោះដូច្នេះគឺ បើមានស្រះនៅខាងចុងអំពីមុខនិគ្គហិត, ត្រូវផ្លាស់និគ្គហិតធ្វើជា "ម" ឬជា "ទ" ឧ. តំ + អហំ ជា តមហំ, ឥទំ + អវោច ជា ឥទម-វោច, ឯតំ + អវោច ជា ឯតទវោច, យំ + ឥទំ ជា យទិទំ ។

បើមាន "ឯ" ឬ "ហ" នៅខាងចុង ត្រូវផ្លាស់និគ្គហិតធ្វើជា "ញ" បានខ្លះ ឧ. បច្ចត្តំ + ឯវ ជា បច្ចត្តញ្ញេវ, តំ + ឯវ

ជា តញ្ញោវ (តម្រួត ញ ជាពីរតួតាមវិធីសំយោគសន្ធិខាងដើម ត្រង់លេខ ២៧), ឯវំ + ហិ ជា ឯវញ្ហិ, តំ + ហិ ជា តញ្ហិ ។

បើមាន "យ" នៅខាងចុង. ត្រូវផ្លាស់និគ្គហិតព្រមទាំង "យ" នោះធ្វើជា "ញ" បានខ្លះ ឧ. សំ + យោគោ ជា សញ្ញោ-គោ, សំ + យោជនំ ជា សញ្ញោជនំ (តម្រួត ញ ដូចន័យមុន) ។

បើមានព្យញ្ជនៈនៅខាងចុង ផ្លាស់និគ្គហិតធ្វើជាវគ្គន្ត-ព្យញ្ជនៈទាំង ៥ តួ គឺ ង, ញ, ណ, ន, ម តាមដំណើរព្យញ្ជនៈខាងចុងក៏បាន ផ្លាស់ដូចរបៀបខាងក្រោយនេះ

ផ្លាស់និគ្គហិតជា "ង" ឧ. តំ + ការុណិកំ ជា តង្ការុណិកំ សំខារា ជា សង្ខារា, សមថំ + គតោ ជា សមថង្គតោ, សំឃោ ជា សង្ឃោ ។

ផ្លាស់និគ្គហិតជា "ញ" ឧ. ធម្មំ + ចរេ ជា ធម្មញ្ចរេ, សំ + ឆិន្នោ ជា សញ្ឆិន្នោ, ចិរំ + ជីវតុ ជា ចិរញ្ជីវតុ, អគ្គឹ + ឈាបេសិ ជា អគ្គិញ្ឈាបេសិ, សំ + ញាបេសិ ជា សញ្ញាបេសិ ។

ផ្លាស់និគ្គហិតជា "ណ" ឧ. សំ + ឋិតិ ជា សណ្ឋិតិ, សំ + ឋាតិ ជា សណ្ឋាតិ ។

ផ្លាស់និគ្គហិតជា "ន" ឧ. សំសារំ + តរតិ ជា សំសារន្តរតិ, អមតំ + ទទោ ជា អមតន្ទទោ, ជុតឹ + ធរោ ជា ជុតិន្ធរោ, តំ + និព្ពុតំ ជា តន្និព្ពុតំ ។

ផ្លាស់និគ្គហិតជា "ម" ឧ. ចិរំ + បវាសឹ ជា ចិរម្បវាសឹ, សំ + ផុដ្ឋោ ជា សម្ផុដ្ឋោ, តំ + ពុទ្ធំ ជា តម្ពុទ្ធំ, ឧទ្ធំ + ភាគេ ជា ឧទ្ធម្ភាគេ, តំ + មេ ជា តម្មេ ។

បើមាន "អំ" នៅខាងចុង, ផ្លាស់និគ្គហិតជា "ល" ក៏បាន ឧ. បុគ្គំ + អំ ជា បុគ្គលំ ។

បើមាន "ល" នៅខាងចុង ផ្លាស់និគ្គហិតជា "ល" ក៏បាន ឧ. បុំ + លិង្គំ ជា បុល្លិង្គំ, សំ + លបនា ជា សល្លបនា, សំ + លក្ខ-ណា ជា សល្លក្ខណា, សំ + លក្ខេសិ ជា សល្លក្ខេសិ ។

[៣០] អាគមោ ចុះអាគម, គឺចុះនិគ្គហិតថែម ហៅថា និគ្គហិតាគមសន្ធិ "តដោយចុះនិគ្គហិតថែម", និគ្គហិត ដែល ចុះមកនោះ ហៅថា អាគម "អក្សរចុះថែម" ។ វិធីចុះអាគមនោះ ដូច្នេះគឺ ទោះមានស្រៈក្តី ព្យញ្ជនៈក្តី នៅខាងចុង ត្រូវចុះនិគ្គហិត

(º) ថែមមក ឧ. ចក្ខុ + ឧទបាទិ ជា ចក្ខុំឧទបាទិ, អវ + សិរោ ជា អវំសិរោ ។

[៣១] បកតិ ប្រក្រតី, គឺធ្វើនិគ្គហិតឲ្យគង់រូបនៅដូចដែល ហៅថា និគ្គហិតបកតិសន្ធិ "តដោយទុកនិគ្គហិតឲ្យនៅតាម ប្រក្រតីដើម" ឧ. សមចំ + គតោ, ធម្មំ + ចរេ, តំ + និព្វុតំ, តំ + ពុទ្ធំ, គួរនឹងផ្លាស់និគ្គហិតជា ង, ញ, ន, ម (តាមវិធីនិគ្គហិតាទេស-សន្ធិខាងដើមត្រង់លេខ ២៩) ឲ្យជា សមចង្គតោ, ធម្មញ្ចរេ, តន្និព្វុតំ, តម្ពុទ្ធំ មិនផ្លាស់ដូច្នោះ បែរជាទុកឲ្យគង់រូបនៅជា សមចំ គតោ, ធម្មំ ចរេ, តំ និព្វុតំ, តំ ពុទ្ធំ តាមប្រក្រតីដើមដូចដែលទៅវិញ ។

(បកតិសន្ធិទាំង ៣ យ៉ាងគឺ សរបកតិសន្ធិក្តី ព្យញ្ជន-បកតិសន្ធិក្តី និគ្គហិតបកតិសន្ធិក្តី បើនឹងមិនបាច់រាប់បញ្ចូល ក្នុងពួកសន្ធិកិរិយោបករណ៍ក៏សឹងតែបាន ពីព្រោះមិនមានវិធី ផ្លាស់ប្រែអ្វីឲ្យប្លែកអំពីទំនងដើមឡើយ, ប៉ុន្តែ ក្នុងគម្ពីរសព្ទ-សាស្ត្រទាំងឡាយ មានសម្តែងឈ្មោះជាកំណត់ថា "បកតិសន្ធិ"

ស្រេចមកហើយ អ្នកសិក្សាក៏គួរតែរៀនសង្កេតឲ្យស្គាល់ ដើម្បីជាគ្រឿងប្រដាប់ប្រាជ្ញាក្នុងការសិក្សាភាសាបាឡី) ។

## អធិប្បាយឈ្មោះសន្ធិ

[៣២] សន្ធិទាំងអស់ដូចបាននិយាយមកហើយនោះ កាលបើតភ្ជាប់ជា សម្ពន្ធៈ ហើយ ក្នុងតំណ (សន្ធិ) នីមួយ ៗ នោះ មានឈ្មោះតែមួយយ៉ាងក៏មាន, មានឈ្មោះពីរ ឬ បីយ៉ាងក៏មាន, បើច្រើនតំណ មានឈ្មោះច្រើនតាមសង្កាត់ទៅក៏មាន ដូចជា យស្សិន្ទ្រិយានិ, នោ ហេតំ, ចត្តារោមេ, សោទានិ (សរលោបសន្ធិ), កឹសូធ, សាធូតិ, សទ្ធីធ, តត្រាយំ (ទីឃសន្ធិ), ត្យស្ស, ចក្ខ្វាបាថំ (សរាទេសសន្ធិ), សន្ធិយ៉ាងនេះហៅថា មានឈ្មោះតែមួយយ៉ាង ពីព្រោះមានវិធីតដោយសន្ធិកិរិយោបករណ៍តែមួយយ៉ាងក៏ជាការស្រេច ។ ដូចជា ឥច្ចេវំ[១],

---

១ សន្ធិនេះ តាមលទ្ធិវេយ្យាករណបណ្ឌិតខ្លះ ឲ្យឈ្មោះជា ៣ យ៉ាង គឺ ព្យញ្ជនាទេសសន្ធិ, សទិសសំយោគសន្ធិ, ថែមឲ្យឈ្មោះថា បុព្វសរលោបសន្ធិ ១ ទៀតជា ៣ យ៉ាង ពីព្រោះកាលដែលផ្លាស់ "តិ" ជា "ច" រួចហើយ ឲ្យតម្រួត ច ជា ២ តួ ហើយឲ្យលុបស្រៈ អ របស់ ច្ច ហើយទើបនាំ ច្ច ទៅតភ្ជាប់នឹង ឯ ជា ច្ចេ ។ ដែលឲ្យឈ្មោះត្រឹមតែ ២ យ៉ាងនោះ ពីព្រោះមិនប្រើវិធីលុបស្រៈឡើយ ។

កុព្វតោ នេះ មានឈ្មោះពីរយ៉ាង គឺ ព្យញ្ជនាទេសសន្ធិ និង សទិ-សសំយោគសន្ធិ ពីព្រោះមានវិធីតដោយសន្ធិកិរិយោបករណ៍ពីរយ៉ាង ។ ដូចជា អគ្យាគារំ នេះ មានឈ្មោះបីយ៉ាង គឺ សរាទេសសន្ធិ, ព្យញ្ជនលោបសន្ធិ និង បរទីឃសន្ធិ ពីព្រោះមានវិធីតដោយសន្ធិកិរិយោបករណ៍ដល់បីយ៉ាង ។ ម្យ៉ាងទៀត បើបទដែលតមានច្រើនសង្កាត់ភ្ជាប់គ្នាតាំងពី ២ សង្កាត់ជាដើមទៅ នោះក្នុងសង្កាត់មួយ ៗ ក៏មានឈ្មោះតាមវិធីតនោះដែរ ដូចជា តត្រ + អយំ + អាទិ តភ្ជាប់ជា តត្រាយមាទិ, តត្រ + អភិ-រតឹ + ឥច្ឆេយ្យ តភ្ជាប់ជា តត្រាភិរតិមិច្ឆេយ្យ នេះ មានឈ្មោះពីរយ៉ាង គឺ បរទីឃសន្ធិ និង និគ្គហិតាទេសសន្ធិ ។ ឥតិ + ឯវំ + អតិ + អន្តំ + នមស្សនេយ្យំ តភ្ជាប់ជា ឥច្ចេវមច្ចន្តនមស្ស-នេយ្យំ នេះ មានសន្ធិច្រើនឈ្មោះ គឺមានព្យញ្ជនាទេសសន្ធិ ២, មាន សទិសសំយោគសន្ធិ ២, មាននិគ្គហិតាទេសសន្ធិ ១, (បើប្រើវិធីលុបស្រៈ អ របស់ ច្ច, ម, ច្ច ផង មាន បុព្វសរ-លោបសន្ធិ ៣), មាន និគ្គហិតលោបសន្ធិ ១ តាមសង្កាត់បទ និងវិធីតភ្ជាប់ដោយលើក ៗ ។

អ្នករៀនចូរចំណាំបទសន្ធិ ដូចបាននិយាយមកប៉ុណ្ណោះជាដើម ឲ្យយល់ជាក់ទុកជាមេគំនិត ហើយគួរប្រើយោបល់សង្កេតបទសន្ធិឯទៀត ៗ ក្រៅពីនេះដែលប្រទះនៅមុខ ហើយចូរកំណត់ឲ្យឈ្មោះតាមដំណើរសន្ធិកិរិយោបករណ៍ ដែលបាននិយាយមកហើយនោះចុះ ។

## បែបកាត់បទសរសន្ធិ

[៣៣] ស្រះដែលតភ្ជាប់ជាសន្ធិ ហើយមានទំនងឲ្យពិបាកសង្កេតបន្តិចដែរ (ដោយអន្លើ ៗ) ដូចជាសន្ធិមានដើមថា ឧបាសកាតិ, បុត្តាតិ, ភិក្ខូតិនេះ មានទំនងឲ្យកាត់បទបានពីរយ៉ាង គឺកាត់ជា ឧបាសក + ឥតិ, បុត្ត + ឥតិ តាមដំណើរ បុព្វទីឃសន្ធិក៏បាន, កាត់ជា ឧបាសកា + ឥតិ, បុត្តា + ឥតិ, ភិក្ខូ + ឥតិ តាមដំណើរ បរសរលោបសន្ធិ ក៏បាន ។ បានជាមានទំនងឲ្យកាត់បទពីរបែបយ៉ាងនេះ ពីព្រោះត្រូវកាត់លៃតាមដំណើរសេចក្ដីព្រមទាំងដំណើរប្រយោគផង ។ ព្រោះហេតុនោះ អ្នកសិក្សាត្រូវសង្កេតសេចក្ដីព្រមទាំងដំណើរប្រយោគផង ទើបនឹងងាយយល់បែបកាត់បទសរសន្ធិនេះ ៚

អក្ខរវិធីនិទ្ទេសទី ១ ចប់ដោយសង្ខេបតែប៉ុណ្ណោះ ។

# នាមនិទ្ទេស ទី ២

## នាមនិទ្ទេស ទី ២

### នាម

[៣៤] អ្វីទាំងពួងក្នុងលោក ទោះមានវិញ្ញាណក្តី ឥតវិញ្ញាណក្តី ដែលមានឈ្មោះសម្រាប់ហៅបាន ដូចពាក្យថា "មនុស្ស, សត្វ, ដី, ទឹក, ភ្លើង, ខ្យល់, អាកាស" ជាដើម ហៅថា នាម ប្រែថា "ឈ្មោះ" ។

### នាមសព្ទ

[៣៥] សំឡេង គឺ សម្តីដែលលាន់ចេញមកចំពោះនាមនោះ ដូចពាក្យថា បុរិស "ប្រុស", ឥត្ថី "ស្រី" ជាដើម ហៅថា នាមសព្ទប្រែថា "សំឡេងគឺសម្តីសម្តែងនូវឈ្មោះ" ។ នាម-សព្ទនោះចែកចេញជាបីយ៉ាង គឺ នាមនាម ១, គុណនាម ១, សព្វនាម ១ ។

### នាមនាម

[៣៦] នាមដែលជាឈ្មោះចំពោះអ្វីទាំងពួង ទោះមានរូបក្តី ឥតរូបក្តី ដូចពាក្យថា "មនុស្ស, សត្វ, ស្រែ, ស្រុក,

ឈើ, ភ្នំ, ទាន, សីល, ឈាន, សមាបត្តិ″ ជាដើម ហៅថា នាមនាម, មានពីរយ៉ាង គឺ សាធារណនាម ១, អសាធារណនាម ១ ។

## សាធារណនាម

[៣៧] នាមដែលគ្រាន់តែសម្តែងឈ្មោះតែនៅសាធារណៈទូទៅទៀតបាន ដូចពាក្យថា "មនុស្ស, ដែន, ក្រុង″ ជាដើម គ្រាន់តែមានពាក្យឲ្យសង្កេតបានថាជានាម តែនៅមិនទាន់ប្រាកដនៅឡើយ ព្រោះថាតាមតែមនុស្សជាតិណា ក៏ហៅថា មនុស្សទាំងអស់ តាមតែដែនណា, ក្រុងណា, ក៏ហៅថា ដែន, ថាក្រុងទាំងអស់ ។ នាមដែលនៅសាធារណៈទូទៅទៀតបានដូច្នេះ ហៅថា សាធារណនាម ។

## អសាធារណនាម

[៣៨] នាមដែលសម្តែងឈ្មោះប្រាកដ មិនសាធារណៈទូទៅទៀតបាន ហៅថា អសាធារណនាម ដូចពាក្យថា "ភិក្ខុ-ពុទ្ធរក្ខិត, សាមណេរ-សង្ឃរក្ខិត, នាយ-ធម្មបាល, ដែន-កម្ពុជា,

ក្រុង-សាវត្ថី" ជាដើម ។ ភិក្ខុ, សាមណេរ, នាយ, ដែន, ក្រុង, ជា សាធារណនាម, ពុទ្ធរក្ខិត, សង្ឃរក្ខិត, ធម្មបាល, កម្ពុជា, សាវត្ថី ជា អសាធារណនាម ។

## គុណនាម

[៣៩] នាមដែលសម្ដែងលក្ខណៈរបស់នាមនាមណាមួយ សម្រាប់សម្គាល់ឲ្យដឹងថានាមនាមនោះ ល្អឬអាក្រក់, ធំឬតូច, ខ្ពស់ឬទាប ជាដើម ដូចពាក្យថា "ខ្មៅ, ស, វែង, ខ្លី, ក្រាស់, ស្ដើង, ជ្រៅ, រាក់, មានប្រាជ្ញា, ឥតប្រាជ្ញា, ស្លូត, កាច" ជាដើម ហៅថា គុណនាម ។ គុណនាមនោះចែកចេញទៅទៀត ជា ៣ យ៉ាង គឺ បកតិគុណនាម ១, វិសេសគុណនាម ១, អតិវិសេស-គុណនាម ១ ។

## បកតិគុណនាម

[៤០] គុណនាមដែលសម្ដែងលក្ខណៈ មិនមានវិសេសប្លែកជាងប្រក្រតីរបស់ខ្លួនឡើយ គ្រាន់តែសម្ដែងឲ្យដឹងលក្ខណៈស្មោះ ៗ តាមធម្មតារបស់ខ្លួនប៉ុណ្ណោះ ដូចពាក្យថា កាឡ

"ខ្មៅ" ឱទាត "ស", មហន្ត "ធំ", ខុទ្ទក "តូច", បញ្ញវន្ត "មានប្រាជ្ញា", ពាល "ល្ងង់" ជាដើម ហៅថា បកតិគុណនាម ។

## វិសេសគុណនាម

[៤១] គុណនាមដែលសម្ដែងលក្ខណៈវិសេស ប្លែកជាងប្រក្រតី តែមិនសម្ដែងលក្ខណៈថ្លៃថ្លាណាស់ ឬថយថោកណាស់នោះទេ គ្រាន់តែសម្ដែងឲ្យដឹងថាប្លែកជាងធម្មតា ដូចពាក្យថា កាឡតរ "ខ្មៅប្លែក, ខ្មៅជាង" ឱទាតតរ "សប្លែក សជាង" មហន្តតរ "ធំប្លែក ធំជាង", ខុទ្ទកតរ "តូចប្លែក តូចជាង", បញ្ញវន្តតរ "មានប្រាជ្ញាប្លែក, មានប្រាជ្ញាជាង, ពាល្យតរ "ល្ងង់ប្លែក, ល្ងង់ជាង" ជាដើម ហៅថា វិសេសគុណនាម ។

## អតិវិសេសគុណនាម

[៤២] គុណនាមដែលសម្ដែងលក្ខណៈវិសេសប្លែកបំផុត គឺថាបើ ល្អ ឬ អាក្រក់ ជាដើម ក៏ ល្អ ឬ អាក្រក់ បំផុត ដូចពាក្យថា អតិកាឡ ឬ អតិវិយកាឡ "ខ្មៅណាស់, ខ្មៅពេក

ណាស់″, អច្ចោទាត ឬ ឱទាតតម ‶សណាស់, សពេក, សបំផុត សក្បុស, សស្គុស″, មហន្តតម ‶ធំបំផុត, ធំបណ្ដាច់, ធំចំបង″, អតិខុទ្ទក ឬ អតិវិយខុទ្ទក ‶តូចណាស់, តូចពេកណាស់″, មេធិដ្ឋ ″មានប្រាជ្ញាជាបំផុត″, ពាល្យតម ‶ល្ងង់បំផុត″ ជាដើម ហៅថា អតិវិសេសគុណនាម ។

## សព្វនាម

[៤៣] នាមដែលសម្រាប់ប្រើជំនួស ឬប្រើជាជំនួយនាមនាមដែលពោលចេញឈ្មោះរួចមកហើយ ដើម្បីនឹងមិនឲ្យថែមពាក្យជញ្ជាន់ស្លាញខ្ជាន់ ៗ ដដែល ៗ ហៅថា សព្វនាម, មាន ២ យ៉ាង គឺ បុរិសសព្វនាម ១, វិសេសនសព្វនាម ១ ។

សព្វនាមដែលប្រើជំនួសឈ្មោះមនុស្ស សត្វ ឬ អ្វីមួយដោយចំពោះ ដូចពាក្យថា ‶ព្រះអង្គ, លោក, គេ, គាត់, វា, អ្នក, នាង, ឯង, ខ្ញុំ, អញ, យើង″ ជាដើម (តាមពាក្យខ្ពស់, កណ្ដាល, ទាប) ហៅថា បុរិសសព្វនាម ។

សព្វនាមដែលប្រើជាជំនួយនាមនាម ដោយលំនាំជាវិសេ-សនៈ (មានទំនងប្រហែលគ្នានឹងគុណនាម) ដូចពាក្យថា "នេះ, នោះ, នុ៎ះ (ហ្នឹង), ឯណា, ណា, ឯនោះ (ឯណោះ), ទាំងពួង", ជាដើម ហៅថា វិសេសនសព្វនាម ។ (សព្វនាមទាំងពីរយ៉ាងនេះ នឹងមានសេចក្ដីសម្ដែងទៅក្នុងខាងមុខ ត្រង់លេខ ១១១ និងលេខ ១១៥) ។

## លិង្គ

[៤៤] ភេទជាគ្រឿងសម្រាប់សម្គាល់នាមសព្ទ ដែលប្រព្រឹត្តទៅដោយអាការៈប្លែក ៗ គ្នា ហៅថា លិង្គ ។ លិង្គនោះក្នុងភាសាបាឡីមានបីយ៉ាង គឺ បុំលិង្គំ "ភេទប្រុស" ១, ឥត្ថីលិង្គំ "ភេទស្រី" ១, នបុំសកលិង្គំ "មិនមែនភេទប្រុសមិនមែនភេទស្រី" ១ ។

លិង្គទាំងបីយ៉ាងនេះ កាលបើកំណត់ដោយកំណើតនិងសន្មតិ មានឈ្មោះបែកចេញទៀតជាពីរយ៉ាង គឺ ជាតិលិង្គ ១, សម្មតិលិង្គ ១ ។

## ជាតិលិង្គ

[៤៥] លិង្គដែលកំណត់ដោយភេទប្រុស ឬភេទស្រី ឬមិនមែនភេទប្រុសមិនមែនភេទស្រី តាមកំណើតតាមភេទពិត ហៅថា ជាតិលិង្គ ដូចពាក្យមានដើមថា បុរិសោ "ប្រុស", ហត្ថី "ដំរីឈ្មោល", កុក្កុដោ "មាន់ឈ្មោល" នេះជាបុំលិង្គ ព្រោះមានកំណើតមានភេទជាមនុស្សប្រុស, ជាសត្វឈ្មោល ទាំងស្រះទីបំផុតសព្ទក៏ជាបុំលិង្គស្រាប់ ។ ឥត្ថី "ស្រី", ហត្ថិនី "មេដំរី", កុក្កុដី "មាន់ញី" នេះជាឥត្ថីលិង្គ ព្រោះមានកំណើតមានភេទជាមនុស្សស្រី, ជាសត្វញី ទាំងស្រះទីបំផុតសព្ទក៏ជាឥត្ថីលិង្គស្រាប់ ។ វត្ថុំ "សំពត់", សកដំ "រទេះ", ឧទកំ "ទឹក" នេះជានបុំសកលិង្គ ព្រោះមានកំណើតមានភេទមិនមែនជាប្រុសមិនមែនជាស្រី ទាំងស្រះទីបំផុតសព្ទក៏ជានបុំសកលិង្គស្រាប់ ។ ដែលហៅថា ជាតិលិង្គ នេះគឺ ហៅតាមកំណើតតាមភេទប៉ុណ្ណោះ ក៏គឺបុំលិង្គ ឬ ឥត្ថីលិង្គ ឬ នបុំសកលិង្គនោះឯង ។

## សម្មតិលិង្គ

[៤៦] លិង្គដែលកំណត់ដោយសន្មតិ ខុសទំនងអំពីកំណើត អំពីភេទ ហៅថា សម្មតិលិង្គ ដូចពាក្យមានដើមថា ទារោ "ប្រពន្ធ", សព្ទនេះ បើតាមជាតិតាមភេទ ជាស្រី, គួរនឹងហៅថា ឥត្ថីលិង្គ, តែ ទារ សព្ទនេះ មានស្រៈទីបំផុតជាបុំលិង្គ ក៏សន្មត ទៅជាបុំលិង្គ ។ បទេសោ "ប្រទេស", សព្ទនេះ បើតាមជាតិ តាមភេទ មិនមែនជាប្រុសមិនមែនជាស្រី, គួរនឹងហៅថា នបុំ-សកលិង្គ, តែ បទេស សព្ទនេះ មានស្រៈទីបំផុតជាបុំលិង្គ ក៏ សន្មតទៅជាបុំលិង្គ ។ សាលា "សាលា, រោង", សិលា "ថ្ម", សព្ទទាំងពីរនេះ បើតាមជាតិតាមភេទ មិនមែនជាប្រុសមិនមែន ជាស្រី, គួរនឹងហៅថា នបុំសកលិង្គ, តែ សាលា និង សិលា សព្ទ ទាំងពីរនេះ មានស្រៈទីបំផុតជាឥត្ថីលិង្គ ក៏សន្មតទៅជា ឥត្ថីលិង្គ ។ ដែលហៅថា សម្មតិលិង្គ នេះគឺហៅតាមសន្មតិ ប៉ុណ្ណោះ ក៏គឺ បុំលិង្គ ឬឥត្ថីលិង្គ នោះឯង ។ ឯនាមនាម ដែលមានកំណើតមានភេទប្រាកដជាបុំលិង្គ ឬជាឥត្ថីលិង្គ ហើយ សន្មតទៅជានបុំសកលិង្គនោះ ក្នុងភាសាបាឡីមិនសូវមានប្រើ

ច្រើនមានប្រើតែនាមនាម ដែលទៅជាបទសមាសដែលធ្វើឲ្យទៅជា នបុំសកលិង្គឯកវចនៈ ដូចបទសមាសមានដើមថា តិលោកំ "លោកបី", ចតុទ្ទិសំ "ទិសបួន" ។ "លោក" ជាបុំលិង្គដោយសន្ទតិ "ទិសា" ជាឥត្ថីលិង្គដោយសន្ទតិ ក៏បំបែរឲ្យទៅជានបុំ-សកលិង្គឯកវចនៈ ជា "លោកំ, ទិសំ" ។ (មើលសមាសនិទ្ទេសទី ៣ ក្នុងខាងមុខ) ។

## នាមសព្ទមានលិង្គផ្សេងគ្នា

[៤៧] នាមនាម គុណនាម សព្វនាម ទាំងបីយ៉ាង ដែលមានលិង្គជាគ្រឿងសម្គាល់នោះ កុលបុត្រអ្នកសិក្សាត្រូវកំណត់ដឹងដូច្នេះថា នាមនាមក្នុងរូបសព្ទមួយប្រព្រឹត្តទៅបានតែលិង្គមួយ ហៅថា ឯកលិង្គិកៈ ក៏មាន បានលិង្គពីរ ហៅថា ទ្វិលិង្គិកៈ ក៏មាន ឬនាមនាមដែលមានមូលសព្ទគឺឫសគល់ពាក្យតែមួយ គ្រាន់តែផ្លាស់ស្រៈទីបំផុតសព្ទនោះឲ្យខុសគ្នា ទៅជាទ្វិលិង្គិកៈ ក៏មាន ។ ឯគុណនាមនិងសព្វនាមប្រព្រឹត្តទៅបានទាំងបីលិង្គ ហៅថា តិលិង្គិកៈ ឬ ត្រៃលិង្គ ។

# [៤៨] នាមនាមជាឯកលិង្គិកៈ

| បុំលិង្គ | ឥត្ថីលិង្គ | នបុំសកលិង្គ |
|---|---|---|
| អមរោ ទេវតា | អច្ឆរា ស្រីអប្សរ | អង្គំ អង្គ,អវយវៈ,ហេតុ |
| អាទិច្ចោ ព្រះអាទិត្យ | អាភា រស្មី | អារម្មណំ អារម្មណ៍ |
| ឥន្ទោ ព្រះឥន្ទ | ឥទ្ធិ ឫទ្ធិ | ឥណំ បំណុល |
| ឦសោ អ្នកធំ | ឦសា យាមនង្គ័ល | ឦរិណំវាល,វាលស្រែ |
| ឧទធិ សមុទ្ទ | ឧឡុ ផ្កាយ | ឧទកំ ទឹក |
| ឯណេយ្យោ សត្វទ្រាយ | ឯសិកា សសរខឿន | ឯឡាលុកំ រពៅ |
| ឱឃោ អន្លង់ទឹក, ជំនន់ | ឱជា ឱជារស | ឱកំ ទឹក |
| កណ្ណោត្រចៀក,មុំ.ជ្រុង | កដិ ចង្កេះ | កម្មំ កម្ម (អំពើ) |
| ចន្ទោ ព្រះចន្ទ | ចមូសេនា,កងទ័ពដើកគោក | ចក្ខុ ភ្នែក |
| តរុ ឈើ | តារា ផ្កាយ | តេលំ ប្រេង |
| បព្វតោ ភ្នំ | បភា រស្មី | បណ្ណំ សំបុត្រ,ស្លឹក |
| យក្ខោ យក្ស | យាគុ បបរ | យានំ យាន |
| អំកុសោ កង្វេរ | អំសុ រស្មី | អំសុកំ សំពត់ |

## [៤៩] នាមនាមជាទ្វិលិង្គិកៈ

| បុំលិង្គ | នបុំសកលិង្គ | ពាក្យប្រែ |
|---|---|---|
| អក្ខរោ | អក្ខរំ | អក្សរ, និព្វាន |
| អគារោ | អគារំ | ផ្ទះ |
| ឧតុ | ឧតុ | រដូវ |
| មនោ | មនំ | ចិត្ត |
| ទិវសោ | ទិវសំ | ថ្ងៃ |
| សំវច្ឆរោ | សំវច្ឆរំ | ឆ្នាំ |

[៥០] នាមនាមមានមូលសព្ទតែ ១ ផ្លាស់តែស្រៈទីបំផុតខុសគ្នាជាទ្វិលិង្គិកៈ ។

| បុំលិង្គ | | ឥត្ថីលិង្គ | |
|---|---|---|---|
| អរហា ឬអរហំ | ព្រះអរហន្តប្រុស | អរហន្តី | ព្រះអរហន្តស្រី |
| អាជីវកោ | អាជីវក | អាជីវិកា | អាជីវិកា |
| ឧបាសកោ | ឧបាសក | ឧបាសិកា | ឧបាសិកា |
| កុមារោ | ក្មេងប្រុស | កុមារី ឬកុមារិកា | ក្មេងស្រី |
| ខត្តិយោ | ក្សត្រប្រុស | ខត្តិយា ឬ ខត្តិយានី | ក្សត្រស្រី |

| បុំលិង្គ | | ឥត្ថីលិង្គ | |
|---|---|---|---|
| គោណោ | គោឈ្មោល | គាវី | គោញី |
| ចោរោ | ចោរប្រុស | ចោរី | ចោរស្រី |
| ញាតកោ | ប្រុសជាញាតិ | ញាតិកា | ស្រីជាញាតិ |
| តរុណោ | ប្រុសជំទង់,កំលោះ | តរុណី | ស្រីជំទង់,ក្រមុំ |
| ថេរោ | ព្រះថេរៈ | ថេរី | នាងថេរី |
| ទារកោ | ក្មេងប្រុស | ទារិកា | ក្មេងស្រី |
| នរោ | មនុស្សប្រុស | នារី | មនុស្សស្រី |
| បរិព្វាជកោ | បរិព្វាជក | បរិព្វាជិកា | បរិព្វាជិកា |
| ភិក្ខុ | ភិក្ខុ | ភិក្ខុនី | នាងភិក្ខុនី |
| ភវំ | ប្រុសដ៏ចម្រើន | ភោតី | ស្រីដ៏ចម្រើន |
| មនុស្សោ | មនុស្សប្រុស | មនុស្សី | មនុស្សស្រី |
| យុវា | ប្រុសកំលោះ | យុវតី | ស្រីក្រមុំ |
| រាជា | ស្តេចប្រុស | រាជិនី | ស្តេចស្រី |
| សខា | សំឡាញ់ប្រុស | សខី | សំឡាញ់ស្រី |
| ហត្ថី | ដំរីឈ្មោល | ហត្ថិនី | មេដំរី (ដំរីញី) |

## [៥១] គុណនាមជាតិលិង្គិកៈ

| បុំលិង្គ | ឥត្ថីលិង្គ | នបុំសកលិង្គ | ពាក្យប្រែ |
|---|---|---|---|
| កម្មការោ | កម្មការិនី | កម្មការំ | អ្នកធ្វើការ |
| គុណវា | គុណវតី | គុណវំ | មានគុណ |
| ចណ្ឌោ | ចណ្ឌា | ចណ្ឌំ | កាច |
| ជេដ្ឋោ | ជេដ្ឋា | ជេដ្ឋំ | ប្រសើរបំផុត |
| តាណោ | តាណា | តាណំ | ជាទីពំនាក់ |
| ថិរោ | ថិរា | ថិរំ | មាំមួន, ខ្ជាប់ខ្ជួន |
| ទក្ខោ | ទក្ខា | ទក្ខំ | ប្រសប់, វាងវៃ |
| ធម្មិកោ | ធម្មិកា | ធម្មិកំ | ប្រកបដោយធម៌ |
| នាថោ | នាថា | នាថំ | ជាទីពឹង |
| បាបោ | បាបា | បាបំ | លាមក, អាក្រក់ |
| ភោគី | ភោគិនី | ភោគិ | មានភោគ |
| មតិមា | មតិមតី | មតិមំ | មានគំនិត, មានប្រាជ្ញា |
| លាភី | លាភិនី | លាភិ | មានលាភ |
| សទ្ធោ | សទ្ធា | សទ្ធំ | មានសទ្ធា |

## វចនៈ

[៥២] ពាក្យសម្រាប់ប្រាប់ចំនួនឲ្យដឹងថាតិចឬច្រើន ហៅថា វចនៈ ។ តែមិនមែនសំខ្យាសព្ទដែលប្រាប់ចំនួនក្នុងវិធីរាប់ថា ១, ២, ៣, ៤, ៥ ជាដើម ដែលនឹងមានសម្តែងក្នុងខាងមុខ ត្រង់លេខ ៩០ នោះទេ ។ វចនៈនោះ ក្នុងភាសាបាឡី លោកចែកជា ២ យ៉ាងគឺ ឯកវចនៈ ១ ពហុវចនៈ ១ ។

វចនៈដែលប្រាប់ចំនួនតិច គឺអ្វី ៗ ដែលតែមួយ ហៅថា ឯកវចនៈ ដូចពាក្យថា បុរិសោ "ប្រុស" សម្គាល់ថាប្រុសតែ ១ នាក់ ។ វចនៈដែលប្រាប់ចំនួនច្រើន គឺអ្វី ៗ ដែលច្រើនតាំងពីត្រឹមពីរឡើងទៅ ហៅថា ពហុវចនៈ ដូចពាក្យថា បុរិសា "ប្រុសច្រើននាក់" តែក្នុងភាសាយើង លោកកំណត់ឲ្យប្រែថា "ប្រុសទាំងឡាយ" ពាក្យថា "ទាំងឡាយ" ជាពាក្យប្រាប់ចំនួនច្រើនសម្រាប់ប្រើតខាងចុងសព្ទជាពហុវចនៈ ។

## បែបប្រើវចនៈ

[៩៣] វចនៈទាំង ២ យ៉ាងនោះ បើសង្កេតតាមរូបសព្ទ គួរនឹងឲ្យចូលចិត្តថាជាការកំណត់ដោយដាច់ខាតតែប៉ុណ្ណោះ ព្រោះឯកវចនៈ ប្រែថា "ពាក្យប្រាប់នូវសព្ទតែមួយ", ពហុវចនៈ ប្រែថា "ពាក្យប្រាប់នូវសព្ទមានចំនួនច្រើន" ។ បើតាមន័យនេះ គួរនឹងកំណត់ចូលចិត្តថា បើសព្ទតែមួយ ត្រូវប្រើជាឯកវចនៈ, បើសព្ទប្រាប់នូវសេចក្ដីមានចំនួនច្រើន ត្រូវប្រើជាពហុវចនៈ ដោយដាច់ខាត ។ ដែលកំណត់យ៉ាងនេះជាការពិត តែក្នុងភាសាបាឡី ជួនកាលនាមសព្ទមានចំនួនច្រើន កាលបើទៅជាបទសមាស ត្រឡប់ប្រើទីបំផុតខាងចុងសព្ទជាឯកវចនៈក៏មាន ដូចបទសមាសមានដើមថា បណ្ណ-បុប្ផ-ផលំ "ស្លឹក និង ផ្កា និង ផ្លែ", ជួនកាលក៏ប្រើជាពហុវចនៈ ជា បណ្ណ-បុប្ផ-ផលានិ "ស្លឹក និង ផ្កា និង ផ្លែ ទាំងឡាយ" ។ កាលបើសង្កេតតាមន័យនេះ កុលបុត្រត្រូវដឹងថា ការកំណត់ឲ្យស្គាល់វចនៈទាំង ២ នោះ ត្រូវសម្គាល់ដោយ

អាងវិភត្តិនាម ព្រមទាំងអាខ្យាតកិរិយា ដែលនឹងមានសម្តែងក្នុង អាខ្យាតនិទ្ទេសទី ៥ ខាងមុខ ជាគ្រឿងចំណាំយ៉ាងសំខាន់ក្នុង ភាសាបាឡីនោះផង ទើបនឹងអាចយល់ច្បាស់ប្រាកដបាន ។

ន័យមួយទៀត វិធីប្រើវចនៈនោះ តាមទម្លាប់ក្នុងភាសា បាឡី, ជួនកាលនាមសព្ទមានសេចក្តីជាឯកវចនៈពិត តែកាល បើប្រើដោយសេចក្តីគោរព ឬដោយសេចក្តីលើកខ្លួនជាធំជាង ឬចាស់ជាងឥតមានសេចក្តីគោរព, ត្រូវឡប់ប្រើជាពហុវចនៈក៏ មាន, ដូចសេចក្តីត្រង់កាលដែលព្រះសម្មាសម្ពុទ្ធរៀបនឹងស្តេច ទៅប្រោសជម្ពុកាជីវក ព្រះអានន្ទត្ថេរក្រាបទូលសួរព្រះអង្គថា ភន្តេ កឹ តុម្ហេយេវ គមិស្សថ? "បពិត្រព្រះអង្គដ៏ចម្រើន ទ្រង់នឹង ស្តេចទៅតែមួយព្រះអង្គទេឬ ?" ។ តុម្ហេ ជាពហុវចនៈ តែក្នុង ទីនេះ មានសេចក្តីជា ឯកវចនៈ ព្រោះថាព្រះសម្មាសម្ពុទ្ធតែមួយ ព្រះអង្គ ដែលព្រះអានន្ទត្ថេរក្រាបទូលសួរដោយពាក្យថា តុម្ហេ នេះ គឺជាពាក្យសម្តែងនូវសេចក្តីគោរព ។ម្យ៉ាងទៀតដូចសេចក្តី

ត្រង់កាលដែល តិស្សត្ថេរ និយាយនឹងអាគន្តុកភិក្ខុទាំងឡាយថា មហល្លកកាលេ បព្វជិតា មយំ "យើងបួសក្នុងកាលដែលយើងចាស់ហើយ" ។ មយំ ជា ពហុវចនៈ តែក្នុងទីនេះ មានសេចក្តីជា ឯកវចនៈ ព្រោះថាតិស្សត្ថេរតែម្នាក់ឯង ដែលតិស្សត្ថេរពោលពាក្យថា មយំ នេះគឺជាពាក្យសម្តែងនូវសេចក្តីលើកខ្លួនថាជាធំដោយឥតមានសេចក្តីគោរព ។ ដែលប្រើពហុវចនៈ មានសេចក្តីជាឯកវចនៈយ៉ាងនេះ មានប្រើដោយច្រើនតែបុរិសសព្វនាម ត្រង់មជ្ឈិមបុរិសៈនិងឧត្តមបុរិសៈ (មើលបុរិសសព្វនាមក្នុងខាងមុខត្រង់លេខ ១១១ ។

នាមសព្ទទាំងអស់ ត្រូវប្រើវចនៈទាំង ២ យ៉ាងនេះជាគ្រឿងសម្គាល់ តែដែលនឹងសង្កេតឲ្យស្គាល់វចនៈទាំង ២ យ៉ាងនោះ ត្រូវកំណត់តាមវិភត្តិនាម ដែលតាំងនៅក្នុងទីបំផុតខាងចុងសព្ទនោះទើបនឹងអាចដឹងថាជាឯកវចនៈ ឬជាពហុវចនៈបាន ។

## វិភត្តិ

[៥៤] ការចែកនាមសព្ទមួយ ៗ ឲ្យមានទីបំផុតខាងចុងផ្សេងទីទៃពីគ្នា ដើម្បីនឹងប្រើ អាយតនិបាត តពាក្យឲ្យកើតជាសេចក្ដីស្ដាប់បាន ហៅថា វិភត្តិ ។ វិភត្តិក្នុងនាមនិទ្ទេសនេះ បើរាប់រៀងតួមាន ១៤ តួ គឺ សិ, យោ, អំ, យោ, នា, ហិ, ស, នំ, ស្មា, ហិ, ស, នំ, ស្មឹ, សុ ។ បើរាប់តាមពួកមាន ២ ពួក គឺ ជាឯកវចនៈ ១ ពួក ជាពហុវចនៈ ១ ពួក ។ ពួកឯកវចនៈមាន ៧ តួ គឺ សិ, ° (អំ), នា, ស, ស្មា, ស,ស្មឹ ។ ពួកពហុវចនៈមាន ៧ តួ គឺ យោ, យោ, ហិ, នំ, ហិ, នំ, សុ ។ បើរាប់តាមឈ្មោះមាន ៧ គឺ បឋមា, ទុតិយា, តតិយា, ចតុត្ថី, បញ្ចមី, ឆដ្ឋី, សត្តមី ។ សិ, យោ ឈ្មោះ បឋមា, អំ, យោ ឈ្មោះ ទុតិយា, នា, ហិ ឈ្មោះ តតិយា, ស, នំ ឈ្មោះ ចតុត្ថី, ស្មា, ហិ ឈ្មោះ បញ្ចមី, ស, នំ ឈ្មោះ ឆដ្ឋី, ស្មឹ, សុ ឈ្មោះ សត្តមី ។ បើរួម អាលបនៈ មកផង ជាឈ្មោះ

មាន ៨ តែអាលបនៈនោះ លោកមិនរាប់បញ្ចូលដោយពេញ បន្ទុកក្នុងវិភត្តិដោយឡែកទេ ព្រោះអាលបនៈលោកញែកចេញមកអំពីបឋមាវិភត្តិ ក៏គឺ បឋមាវិភត្តិ នោះឯង គ្រាន់តែប្លែកគ្នាដោយវិធីប្រើ អាយតនិបាត ប៉ុណ្ណោះ ។ តែក្នុងរបៀបរៀងវិភត្តិ ក៏គង់រៀបអាលបនៈឲ្យនៅត្រង់របៀបទី ៨ ។

## អាយតនិបាត

[៥៥] សព្ទសម្រាប់តពាក្យឲ្យកើតជាសេចក្ដីស្ដាប់បាន គឺបន្តពាក្យពីមួយទៅមួយឲ្យតគ្នាទៅជាសេចក្ដី ដូចជា ៉ី, នូវ, ដោយ, ដល់, អំពី, នៃ, ក្នុង ជាដើម ហៅថា អាយតនិបាត ។ អាយតនិបាតនោះ បើពោលដោយសង្ខេប មិនគឺអ្វីឡើយ, ក្នុងភាសាបាឡី, គឺទីបំផុតខាងចុងនាមសព្ទដែលសម្រេចដោយវិភត្តិស្រេចហើយនោះឯង, ក្នុងភាសាខ្មែរ គឺពាក្យប្រែរបស់វិភត្តិនោះឯង ។

# [៥៦] ពាក្យប្រែរបស់វិភត្តិ

ឯកវចនៈ

ទី ១- បឋមា សិ ប្រែថា "វី-"
ទី ២- ទុតិយា ំ ប្រែថា"នូវ-,កាន់-, ញាំង-, អស់-, នឹង-, ចំពោះ-"
ទី ៣- តតិយា នា ប្រែថា "ដោយ-, ដោយនូវ-, តាម-, ខាង-, គឺ-, ដែល-, ត្រូវ-, ហេតុ-, ព្រោះ-, ព្រោះតែ-, មាន-"
ទី ៤- ចតុត្ថី ស ប្រែថា "ដល់-, ដើម្បី-, បម្រុង-, នឹង-, ចំពោះ"
ទី ៥- បញ្ចមី ស្មា ប្រែថា "អំពី-, ចាក-, ជាង-, ហេតុ-, ព្រោះ-, ព្រោះតែ-"
ទី ៦- ឆដ្ឋី សប្រែថា"នៃ-,របស់-, កាល-, កាលបើ-, កាលដែល-, ជំនុំ-, បណ្ដា-"
ទី ៧- សត្តមី ស្មឹ ប្រែថា "ក្នុង-, ឰដ៏-, ត្រង់-, នា-, នាកាល-, កាលបើ-, កាលដែល-, និមិត្ត-, ជំនុំ-,បណ្ដា-, លើ-, ទៀប-, ជិត-"
ទី ៨- អាលបនៈ សិ ប្រែថា "បពិត្រ-, ម្នាល-, នៃ-, ហៃ-"

ពហុវចនៈ

យោ ប្រែថា "វី-ទាំងឡាយ"
យោ ប្រែថា "នូវ-ទ.,កាន់-ទ., ញាំង-ទ.,អស់-ទ.,នឹង-ទ.,ចំពោះ-ទ."
ហិ ប្រែថា "ដោយ-ទ., ដោយនូវ-ទ., តាម-ទ., ខាង-ទ., គឺ-ទ., ដែល-ទ., ត្រូវ-ទ., ហេតុ-ទ.,ព្រោះ-ទ., ព្រោះតែ-ទ., មាន-ទ."
នំ ប្រែថា "ដល់-ទ., ដើម្បី-ទ., បម្រុង-ទ., នឹង-ទ., ចំពោះ-ទ.,"
ហិ ប្រែថា"អំពី-ទ., ចាក-ទ.,ជាង-ទ., ហេតុ-ទ., ព្រោះ-ទ.,ព្រោះតែ-ទ.,"
នំ ប្រែថា "នៃ-ទ., របស់-ទ., កាល-ទ., កាលបើ-ទ., កាលដែល-ទ., ជំនុំ-ទ.,បណ្ដា-ទ., "
សុ ប្រែថា "ក្នុង-ទ., ឰដ៏-ទ.,ត្រង់-ទ., នា-ទ., នាកាល-ទ., កាលបើ-ទ.,កាលដែល-ទ., និមិត្ត-ទ., ជំនុំ-ទ.,បណ្ដា-ទ., លើ-ទ., ទៀប-ទ., ជិត-ទ.,"
យោ ប្រែថា "បពិត្រ-ទ.,ម្នាល-ទ., នៃ-ទ., ហៃ-ទ., "

## អត្ថរបស់អាយតនិបាត

[៥៧] ក្នុងវិភត្តិមួយ ៗ សឹងមានពាក្យជាអាយតនិបាត គឺពាក្យប្រែរបស់វិភត្តិ ច្រើនយ៉ាងផ្សេង ៗ គ្នា អាយតនិបាតទាំងនោះ មានអត្ថប្រព្រឹត្តទៅតាមទំនងសេចក្តី, ព្រោះហេតុនោះទើបមិនច្រឡំ មានទំនងល្មមឲ្យអ្នកប្រាជ្ញទាំងឡាយអាចកំណត់ស្គាល់បាន ។ អត្ថរបស់អាយតនិបាតនោះ ដូចមានសេចក្តីតទៅនេះ ។

### បឋមា-វិភត្តិ

បទនាមនាមដែលប្រកបផ្សំនឹងបឋមាវិភត្តិ ត្រង់ដែលប្រែថា "រី" ជាបទប្រធាន មានអត្ថ ៤ យ៉ាងគឺ

១- បើមិនមាន អាខ្យាតកិរិយា ឬ កិតកិរិយា ទទួលទេ ហៅថា លិង្គត្ថោ ឬ លិង្គត្ថបឋមា ឧ. ភិក្ខុនោ ចីវរំ "រីចីវររបស់ ភិក្ខុ", នវំ ចីវរំ "រីចីវរ ថ្មី" ។

២- ដែលមាន អាខ្យាតកិរិយា ឬ កិតកិរិយា ទទួលបើជា កត្តុវាចកៈ គឺដែលប្រាប់សេចក្តីថាជាអ្នកសម្រេចនូវអំពើ

ខ្លួនឯង ហៅថា សយកត្តា ឬ សយកត្តុបឋមា សម្ពន្ធចូល នឹងកិរិយា ឧ. ភិក្ខុនោ ចីវរំ អត្ថិ "រីចីវរ របស់ភិក្ខុ មាន", ថេរោ ធម្មំ ទេសេតិ "រីព្រះថេរៈ សម្តែង នូវធម៌" ។

៣- ដែលមាន អាខ្យាតកិរិយា ឬ កិតកិរិយា ទទួល បើជា ហេតុកត្តុវាចកៈ គឺដែលប្រាប់សេចក្តីថាជាអ្នកប្រើគេឲ្យ សម្រេចនូវអំពើ ហៅថា ហេតុកត្តា ឬ ហេតុកត្តុបឋមា សម្ពន្ធ ចូលនឹងកិរិយា ឧ. មាតា បុត្តំ ជនេតិ "រីមាតា ញ៉ាំងកូន ឲ្យ កើត", អាចរិយោ សិស្សេ សិក្ខាបេតិ "រីអាចារ្យ ញ៉ាំងសិស្ស ទាំងឡាយ ឲ្យរៀន" ។

៤- ដែលមាន អាខ្យាតកិរិយា ឬ កិតកិរិយា ទទួល បើជា កម្មវាចកៈ គឺដែលប្រាប់នូវអំពើ ហើយជាបទប្រធាន ឬ ដែលជា ហេតុកម្មវាចកៈ គឺដែលប្រាប់នូវអំពើដែលខ្លួនប្រើគេឲ្យ សម្រេច ហើយជាបទប្រធាន ហៅថា វុត្តកម្មំ ឬ វុត្តកម្មបឋមា សម្ពន្ធចូលនឹងកិរិយា ឧ. កុសលកម្មំ កត្តព្វំ "រីអំពើជាកុសល

(គឺជន) គប្បីធ្វើ″ (កម្មវាចកៈ) ។ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ ″រីសង្ឃ គឺភិក្ខុ ឈ្លាស ប្រតិពល គប្បីឲ្យដឹង″ (ហេតុកម្មវាចកៈ) ។

## ទុតិយា-វិភត្តិ

បទនាមនាមដែលប្រកបផ្សំនឹងទុតិយាវិភត្តិ មានអត្ថ ៦ យ៉ាង សម្ពន្ធចូលនឹងកិរិយា ដូច្នេះ :

១- ជាអំពើដែលគេត្រូវធ្វើ ។ ប្រែថា ″នូវ″ ហៅថា អវុត្តកម្ម ឬ អវុត្តកម្មត្ថទុតិយា ឧ. ធម្មំ សុណាតិ ″(គេ) ស្តាប់ នូវធម៌″ ។

២- ជាដំណើរ ឬជាទីទៅដល់ ។ ប្រែថា ″កាន់″ ហៅថា សម្បាបុណិយកម្ម ឬ សម្បាបុណិយកម្មត្ថទុតិយា ឧ. គាមំ គច្ឆតិ ″(គេ) ទៅ កាន់ស្រុក″ ។

៣- ជាទីទទួលសម្រេចនូវអំពើដែលគេប្រើឲ្យធ្វើ ។ ប្រែ ថា ″ញុំាង″ ហៅថា ការិតកម្ម ឬ ការិតកម្មត្ថទុតិយា ឧ. សុរិយោ លោកំ ឱភាសេតិ ″ព្រះអាទិត្យ ញុំាងលោកឲ្យភ្លឺ″ ។

៤- ជាទីប្រព្រឹត្តទៅរហូតដល់ ឬលុះដល់ ។ ប្រែថា "អស់" ហៅថា អច្ចន្តសំយោគោ ឬ អច្ចន្តសំយោគត្ថទុតិយា ឧ. តិយោជនំ គច្ឆតិ "(គេ) ទៅ អស់យោជន៍បី", ឯករត្តឹ វសតិ "(គេ) នៅ អស់យប់មួយ" ។

៥- ជាទីទទួលពាក្យដែលគេនិយាយចំពោះខ្លួន ។ ប្រែថា "នឹង" ឬ "ចំពោះ" ហៅថា អកថិតកម្មំ ឬ អកថិតកម្មត្ថទុតិយា ឧ. ភគវន្តំ ឯតទវោច "(ភិក្ខុនោះ) បាន ពោលហើយ នូវពាក្យនេះ នឹងព្រះដ៏មានព្រះភាគ" ។ (កាលបើមានបទមួយជា អកថិតកម្មំ ដូច្នេះ ត្រង់បទមួយ ដែលប្រែថា "នូវ" ដែលជា អវុត្តកម្មំ នោះ ត្រឡប់ទៅ ជាហៅថា កថិតកម្មំ ឬ កថិតកម្មត្ថទុតិយា វិញ) ។

៦- ជាគ្រឿងធ្វើកិរិយាឲ្យមានសេចក្ដីប្លែកជាងប្រក្រតី ។ ហៅថា កិរិយាវិសេសនំ ឬ ទុតិយាកិរិយាវិសេសនំ ឧ. សុខំ សេតិ "(គេ) ដេក សប្បាយ", ពាឡ្ហំ រោទតិ "(វា)

ឃំ ខ្លាំង" ។ (ត្រង់ន័យនេះជាទុតិយាវិភត្តិពិត តែមិនរាប់បញ្ចូលក្នុងអាយតនិបាតទេ ព្រោះមិនមានប្រែចេញពាក្យជាអាយតនិបាតណាមួយក្នុងទុតិយាវិភត្តិឡើយ) ។

## តតិយា-វិភត្តិ

បទនាមនាមដែលប្រកបផ្សំនឹងតតិយាវិភត្តិ មានអត្ថ ៦ យ៉ាង សម្ពន្ធចូលនឹងកិរិយាក៏មាន ចូលនឹងនាមក៏មាន ចូលនឹងនិបាតសព្ទគឺ សហ ឬ សទ្ធឹ ក៏មាន ដូច្នេះ

១- ជាគ្រឿងសម្រេចនូវអំពើ ។ ប្រែថា "ដោយ" ហៅថា ករណំ ឬ ករណត្ថតតិយា ឧ. កាយេន កម្មំ ករោតិ "(គេ) ធ្វើ នូវអំពើ ដោយកាយ" ។

២- ជាផ្លូវ ឬ ជាទំនង, ជាលំអាន ដែលប្លែកអំពីការសម្រេចនូវអំពើ ។ ប្រែថា "ដោយនូវ" ឬ "តាម" ហៅថា តតិយាវិសេសនំ ឬ វិសេសនត្ថតតិយា ឧ. ពុទ្ធោ តបតិ តេជសា "ព្រះពុទ្ធ រុងរឿង ដោយនូវតេជះ", មម វចនេន ករោហិ "(ឯង) ចូរធ្វើ, តាមពាក្យ នៃអញ", ទ្វារេន និក្ខមតិ "(គេ)

ចេញទៅ តាមទ្វារ" ។ (ពាក្យថា "ដោយនូវ" ជួនកាលមាន ទំនងសេចក្ដីគួរប្រែថា "ដោយសារ" ឬ "ដោយសារតែ" ឧ. មយា កតុបត្ថម្ភេន សោ ទេវសិកំ ជីវតិ "វា រស់នៅសព្វថ្ងៃ ដោយសារតែសេចក្ដីទំនុកបម្រុងដែលខ្ញុំធ្វើហើយ") ។

៣- ជាអ្នកសម្រេចនូវអំពើខ្លួនឯង, ក្នុងប្រយោគដែល ជាកម្មវាចកៈ ក៏មាន, ក្នុងប្រយោគដែលជា ភាវវាចកៈ គឺដែល ប្រាប់សេចក្ដីថាមិនមែនជាកត្តុវាចកៈ មិនមែនជាកម្មវាចកៈ ក៏មាន, ជាអ្នកប្រើគេឲ្យសម្រេចនូវអំពើ ក្នុងប្រយោគដែលជាហេតុកម្មវាចកៈ ក៏មាន ។ ប្រែថា "គឺ" ឬ "ដែល" ហៅថា អនភិហិតកត្តា ឬ អនភិហិតកត្វត្ថតតិយា ឧ. ចិត្តេន នីយតិ លោកោ "សត្វលោក គឺចិត្ត ដឹកនាំទៅ", អធិគតោ ខោ ម្យាយំ ធម្មោ "ធម៌នេះដែលតថាគតត្រាស់ដឹងហើយមែនពិត" (កម្មវាចកៈ) ។ ន បុនេវ តយា កត្តព្វំ "គឺអ្នកឯង មិនត្រូវធ្វើ យ៉ាងនេះ ទៀតឡើយ" (ភាវវាចកៈ) ។ សត្ថា តុម្ហេហិ ខមាបេតព្វោ "ព្រះសាស្ដា គឺអ្នកទាំងឡាយគប្បីឲ្យអត់ទោស" (ហេតុកម្មវាចកៈ) ។

៤- ជាហេតុ, ជាទំនង, ជាដំណើរ ។ ប្រែថា "ហេតុ" ឬ "ព្រោះ" ឬ "ព្រោះតែ" ហៅថា ហេតុ ឬ ហេត្វត្ថតតិយា ឧ. សក្ការេន បន សោ តត្ថ វសតិ" បានជា គាត់ នៅ ក្នុងទីនោះ ព្រោះតែសក្ការៈ", លាភេន ឧន្នតោ លោកោ អលាភេន ច ឱនតោ "សត្វលោក មានចិត្តខ្ពស់ឡើង ព្រោះលាភ មានចិត្តទ្រោមចុះ ព្រោះមិនមានលាភ (ឬ) ព្រោះខាតលាភ" ។

៥- ជាអាការ ដូចជាបទវិសេសនៈរបស់បទដែលមានវិភត្តិផ្សេងគ្នា ។ ប្រែថា "មាន" ហៅថា ឥត្ថម្ភូតំ ឬ ឥត្ថម្ភូតតតិយា ឧ. មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា "បើ (បុគ្គល) មានចិត្ត គឺទោសប្រទូស្តហើយ ពោល ក្តី ធ្វើ ក្តី" ។

៦- ជាគ្រឿងប្រកបជាមួយ ។ ប្រែថា "ដោយ" ហៅថា សហត្ថតតិយា ឧ. សមេតាយស្មា សង្ឃេន សទ្ធឹ "អ្នកដ៏មានអាយុ ចូរព្រមព្រៀង មួយអន្លើ ដោយសង្ឃ" ។ (ត្រង់ន័យនេះ ជួនណាមានទំនងសេចក្តី តាមប្រយោគភាសា

យើង គួរ ប្រែថា "នឹង" ឧ. មយា សទ្ធឹ តយា គន្តព្វំ "ឯង ត្រូវទៅ ជាមួយ នឹងអញ") ។

## ចតុត្ថី-វិភត្តិ

បទនាមនាមដែលប្រកបផ្សំនឹងចតុត្ថីវិភត្តិ មានអត្ថ ៣ យ៉ាង ហៅថា សម្បទានំ ឬ សម្បទានត្ថចតុត្ថី ដូចគ្នា ទាំង ៣ យ៉ាង សម្ពន្ធចូលនឹងកិរិយា ដូច្នេះ :

១- ជាទីឲ្យ ឬ ជាទីទទួលនូវអំណោយ ។ ប្រែថា "ដល់" ឧ. សង្ឃស្ស ទានំ ទេតិ "(ទាយក) ឲ្យ នូវទាន ដល់សង្ឃ" ។

២- ជាទីបម្រុង, ជាទីផ្ញើ ឬ ជាទីបញ្ជូន ។ ប្រែថា "ដើម្បី" ឬ "បម្រុង" ឧ. ភិក្ខុសង្ឃស្ស អាសនានិ បញ្ញាបេតិ "(គេ) ញ៉ាំងមនុស្សឲ្យក្រាល នូវអាសនៈទាំងឡាយ ដើម្បី (ឬ) បម្រុងភិក្ខុសង្ឃ", អាចរិយោ អន្តេវាសិកស្ស បរិក្ខារេ បេសេតិ "អាចារ្យផ្ញើទៅ នូវគ្រឿងបរិក្ខារទាំងឡាយ ដើម្បីកូនសិស្ស" ។

៣- ជាទីត្រូវគេប្រទូស្ត គេបៀតបៀន ។ ប្រែថា "ចំពោះ" ឬ "នឹង" ឧ. យោ អប្បទុដ្ឋស្ស នរស្ស ទុស្សតិ "អ្នកណា ប្រទូស្ត ចំពោះ (ឬ) នឹងមនុស្ស ដែលមិនប្រទូស្ត" ។

## បញ្ចមី-វិភត្តិ

បទនាមនាមដែលប្រកបផ្សំនឹងបញ្ចមីវិភត្តិ មានអត្ថ ៣ យ៉ាង ច្រើនតែសម្ពន្ធចូលនឹងកិរិយា ដូច្នេះ :

១- ជាដែនចេញ ឬ ជាដែនដែលគេត្រូវវៀរលែង ។ ប្រែថា "អំពី" ឬ "ចាក" ហៅថា អបាទានំ ឬ អបាទានត្ថបញ្ចមី ឧ. មរណស្មា ភយំ "ភ័យ អំពីសេចក្ដីស្លាប់", បាបា ចិត្តំ និវារយេ "(បុគ្គល) គប្បីឃាត់នូវចិត្ត ចាកបាប" ។

២- ជាដែនប្រៀបធៀបឲ្យដឹងថាលើសឬថយជាងគ្នា ។ ប្រែថា "ជាង", ហៅថា អបាទានំ ឬ វិភជ្ជនាបាទានត្ថបញ្ចមី

ឧ. ទានតោ[១] សីលំ មហប្ផលតរំ ហោតិ "សីល ជាគុណជាតមានផលច្រើន ជាងទាន" ។

៣- ជាមូលហេតុ គឺជាដើមហេតុ, ដើមចម ។ ប្រែថា "ហេតុ" ឬ "ព្រោះ" ឬ "ព្រោះតែ" ហៅថា ហេតុ ឬ ហេត្វត្ថាបាទានត្ថបញ្ចមី ឧ. អវិជ្ជាបច្ចយា សង្ខារា "សង្ខារទាំងឡាយ (សម្ភវន្តិ កើតព្រម) ព្រោះសេចក្ដីល្ងង់ជាបច្ច័យ (នាំអាទិ៍ឲ្យកើត") ។

## ឆដ្ឋី-វិភត្តិ

បទនាមនាមដែលប្រកបផ្សំនឹងឆដ្ឋីវិភត្តិ មានអត្ថ ៦ យ៉ាង សម្ពន្ធចូលបានតែនឹងនាមនាម ដូច្នេះ :

១- ជាគ្រឿងជាប់ដោយម្ចាស់របស់ ។ ប្រែថា "នៃ" ឬ "របស់" ហៅថា សម្ពន្ធោ ឬ សាមិសម្ពន្ធោ ឬ សាមិសម្ពន្ធឆដ្ឋី ឧ. ភិក្ខុនោ ចីវរំ "ចីវរ នៃ (ឬ) របស់ភិក្ខុ" ។

២- ជាគ្រឿងជាប់ដោយពួក ដោយក្រុម ។ ប្រែថា "នៃ" ហៅថា សមុហសម្ពន្ធោ ឬ សមុហសម្ពន្ធឆដ្ឋី ឧ. ជនានំ

---

១ តោ បច្ច័យ ចុះក្នុងអត្ថនៃបញ្ចមីវិភត្តិ (ចូរមើលទៅក្នុងខាងមុខត្រង់លេខ ១២៧)

សមុហោ "ប្រជុំ នៃជនទាំងឡាយ" គាវានំ យូថោ ហ្វូង នៃគោទាំងឡាយ" ។

៣- ជាគ្រឿងជាប់ដោយភាវសព្ទជាដើម ។ ប្រែថា "នៃ ហៅថា ភាវាទិសម្ពន្ធោ ឬ ភាវាទិសម្ពន្ធឆដ្ឋី ឧ. អត្ថស្ស ទុន្ន-យតា "ភាវៈ នៃអត្ថ គឺកុលបុត្រគប្បីដឹងបានដោយកម្រ", ឥទានិ សុរិយាលោកស្ស អត្ថិតាយ បទីបកិច្ចំ នត្ថិ "កិច្ច ដោយប្រទីប មិនមានឡើយ ព្រោះភាវៈ នៃពន្លឺនៃព្រះអាទិត្យ មាន ក្នុងកាលឥឡូវនេះ" ។

៤- ជាសេចក្តីជ្រែកចូលមកប្រហែលដូចជាបទប្រធាន ដោយឡែក ។ ប្រែថា "កាល", ថា "កាលបើ" ឬ "កាល ដែល" ហៅថា អនាទរោ ឬ អនាទរឆដ្ឋី ឧ. រុទតោ ទារ-កស្ស (បិតា និក្ខមិត្វា) បព្វជិ "កាលដែលទារក កំពុង យំ (បិតា ចេញទៅហើយ) បួសហើយ", ឯត្ថ តាវ ថោកំ អាគមេថ, បរិសថាតិ មេ វទតោ សីឃំ បរិសេយ្យាថ "( អ្នកទាំងឡាយ ) ចូររង់ចាំ ក្នុងទីនុ៎ះ បន្តិច សិន, កាល

បើខ្ញុំ និយាយ ថា "(អ្នកទាំងឡាយ) ចូរចូលមកចុះ ត្រូវចូលមក ឲ្យឆាប់" ។

៥- ជាសេចក្តីដកញែកចេញឲ្យដាច់ដោយឡែក អំពីចំនួនដែលរួម ដែលប្រមូលគ្នា ។ ប្រែថា "ជំនុំ" ឬ "បណ្តា" ហៅថា និទ្ធារណំ ឬ និទ្ធារណឆដ្ឋី ឧ. មនុស្សានំ ខត្តិយោ សូរតមោ "បណ្តាមនុស្សទាំងឡាយ ក្សត្រិយ៍ ក្លៀវក្លាបំផុត" ។

៦- ជាបទកម្ម គឺជាអំពើដែលគេត្រូវធ្វើ (ចុះជាជំនួសទុតិយាវិភត្តិ) សម្ពន្ធចូលនឹងបទដែលជា កិតនាម ។ ប្រែថា "នូវ" ហៅថា ឆដ្ឋីកម្ម ឬ កម្មត្ថឆដ្ឋី ឧ. ចិត្តស្ស ទមថោ សាធុ "កិរិយាទូន្មាន នូវចិត្ត ជាការប្រពៃ" ។

## សត្តមី-វិភត្តិ

បទនាមដែលប្រកបផ្សំនឹងសត្តមីវិភត្តិ មានអត្ថ ៩ យ៉ាង សម្ពន្ធចូលនឹងកិរិយាក៏មាន ចូលនឹងនាមក៏មាន ដូច្នេះ

១- ជាទីកំបាំង ។ ប្រែថា "ក្នុង" ហៅថា បដិច្ឆន្នាធារោ ឬ បដិច្ឆន្នាធារត្ថសត្តមី ឧ. អន្តោគេហេ និសីទតិ "(គេ) អង្គុយក្នុងខាងក្នុងនៃបន្ទប់" ។

២- ជាទីជ្រួតជ្រាប ឬលាយគ្នា ។ ប្រែថា "ក្នុង" ហៅថា ព្យាបិកាធារោ ឬ ព្យាបិកាធារត្ថសត្តមី ឧ. តិលេសុ តេលំ តិដ្ឋតិ "ប្រេង ស្ថិតនៅ ក្នុងល្ងទាំងឡាយ", ជលេ ខីរំ តិដ្ឋតិ "ទឹកដោះស្រស់ ស្ថិតនៅ ក្នុងទឹក" ។

៣- ជាទីនៅអាស្រ័យ ។ ប្រែថា "ក្នុង" ហៅថា វេស-យិកាធារោ ឬ វេសយិកាធារត្ថសត្តមី ឧ. ជលេ មច្ឆា វសន្តិ "ត្រីទាំងឡាយ នៅក្នុងទឹក" ។

៤- ជាកាល, ជាពេល ។ ប្រែថា "ក្នុង" ហៅថាកាល-សត្តមី ឬ កាលត្ថសត្តមី ឧ. យស្មឹ សមយេ កាមាវចរំ កុសល-ចិត្តំ ឧប្បន្នំ ហោតិ "កុសលចិត្ត ជាកាមាវចរ ជាចិត្តកើតឡើងហើយមានក្នុងសម័យឯណា" ។

៥- ជាទីរង, ជាទីទ្រ ឬ ជាទីផ្ទាប់, ជាទីជ្រៀតជ្រែក ។ ប្រែថា "លើ" ថា "ឰដ៏", ថា "ត្រង់" ឬ "នា" ហៅថា ឧប-សិលេសិកាធារោ ឬ ឧបសិលេសិកាធារត្ថសត្តមី ឧ. ភគវា បញ្ញត្តេ អាសនេ និសីទិ ព្រះដ៏មានព្រះភាគ គង់ហើយ លើ

អាសនៈ ដែលគេក្រាលហើយ", ឧ.រសិ លោមា "រោមទាំងឡាយពួដ៏ទ្រូង (ឬ) ត្រង់ទ្រូង" ។

៦- ជាសេចក្ដីជ្រែកចូលមក ប្រហែលដូចជាបទប្រធានដោយឡែក ។ ប្រែថា "នាកាល" ថា "កាលបើ" ឬ "កាលដែល" (មានសេចក្ដីប្រហែលគ្នានឹងអនាទរឆដ្ឋី) ហៅថា លក្ខណំ ឬ លក្ខណវន្តំ ឧ. សុរិយេ អត្ថង្គតេ ចន្ទោ ឧគ្គច្ឆតិ នាកាលព្រះអាទិត្យ អស្ដង្គតហើយ ព្រះចន្ទ រះឡើង", ឯវំ សន្តេ អម្ហេហិ បន ន គន្តព្វំ "កាលបើ (ហេតុ) យ៉ាងនេះ មាន, មានតែ យើង ត្រូវកុំទៅ", តស្មឹ កថេន្តេ កថេន្តេយេវ ព្រាហ្មណស្ស សកលសរីរំ បីតិយា បរិបូរិ "កាលដែល (មាណព) នោះ និយាយច្រើន ៗ ទៅ, សរីរៈទាំងអស់ នៃព្រាហ្មណ៍ ពេញផ្សព្វផ្សាយហើយដោយបីតិ" ។

៧- ជាគ្រឿងចំណាំ ឬ ជាហេតុ ។ ប្រែថា "និមិត្ត" ហៅថា និមិត្តសត្តមី ឧ. កុញ្ជរោ ទន្តេសុ ហញ្ញតេ "ដំរី (គឺគេ) សម្លាប់ និមិត្តភ្លុកទាំងឡាយ" ។ (ពាក្យថា "និមិត្ត" ត្រូវគ្នានឹងពាក្យថា "ព្រោះ" ឬ "ព្រោះតែ") ។

៨- ជាសេចក្ដីដកញែកចេញឲ្យដាច់ដោយឡែក អំពីចំនួនដែលរួម ដែលប្រមូលគ្នា ។ ប្រែថា "ជំនុំ" ឬ "បណ្ដា" ហៅថា និទ្ធារណំ ឬ និទ្ធារណសត្តមី ឧ. តេសុ ទ្វីសុ ស្វេកោ សោតាបត្តិផលំ បាបុណិ "ជំនុំ (ភិក្ខុទាំងឡាយ) ពីររូបនោះ, (ភិក្ខុ) មួយរូប ដល់ហើយ នូវសោតាបត្តិផល" (ត្រង់នេះ ប្រើឆដ្ឋីវិភត្តិនិងសត្តមីវិភត្តិដែលជានិទ្ធារណៈដូចគ្នា ផ្លាស់ប្ដូរគ្នាបានតាមពេញចិត្ត) ។

៩- ជាទីជិត, ជាទីប្រប ។ ប្រែថា "ជិត" ឬ "ទៀប" ហៅថា សមីបាធារោ ឬ សមីបាធារត្ថសត្តមី ឧ. នគរទ្វារេ គាមា "ស្រុកទាំងឡាយ ជិតក្រុង (ឬ) ទៀបក្រុង", សាវត្ថិយំ វិហរតិ ជេតវនេ "(ព្រះដ៏មានព្រះភាគ) គង់នៅ ក្នុងវត្តជេតពនជិតក្រុងសាវត្ថី" ។

(សត្តមីវិភត្តិ ត្រង់ដែលមានពាក្យថា "អាធារោ" នៅខាងចុងទាំងប៉ុន្មាននោះ នឹងហៅដោយខ្លីតែត្រឹម "អាធារោ" ឬ "អាធារត្ថសត្តមី" ប៉ុណ្ណោះ ដូចគ្នាទាំងអស់ក៏បាន) ។

## អាលបនៈ

បទនាមនាមដែលប្រកបផ្សំនឹងបឋមាវិភត្តិ ត្រង់ដែលប្រែថា "បពិត្រ, ម្នាល, នែ, ហៃ" តាមគួរដល់សេចក្ដីខ្ពស់និងទាបជាពាក្យសម្រាប់ស្រែកហៅ ឬ ពោលចំពោះមានអាការដូចជាស្រែកហៅ ហៅថា អាលបនំ, មាន ២ យ៉ាង គឺ ដែលពោលដោយសេចក្ដីគោរព ប្រែថា "បពិត្រ" ហៅថា សគារវាលបនំ ឬ ហៅត្រឹមតែ អាលបនំ ក៏បាន ឧ. ជយតុ ភវំ មហារាជ "បពិត្រមហារាជ សូមព្រះអង្គដ៏ចម្រើន ទ្រង់ឈ្នះ" ។ ដែលពោលដោយមិនមានសេចក្ដីគោរព ប្រែថា "ម្នាល, នែ, ហៃ" ហៅថា អគារវាលបនំ ឬ ហៅត្រឹមតែ អាលបនំ ក៏បាន ឧ. ធម្មំ វោ ភិក្ខវេ ទេសិស្សាមិ "ម្នាលភិក្ខុទាំងឡាយ (តថាគត) នឹងសម្ដែងនូវធម៌ ដល់អ្នកទាំងឡាយ", មា គច្ឆ បុត្ត តំ គាមំ "នែកូន (ឯង) ចូរកុំទៅ កាន់ស្រុក នោះឡើយ" ។

អត្ថនៃអាយតនិបាត ដូចបានសម្ដែងមកហើយនោះ គឺសម្ដែងតាមកំណាត់របៀបរៀនប្រែបាឡី តែឯពាក្យជាអាយត-

និបាតទាំងនោះ កាលបើគេប្រែពីបាឡីរៀបរៀងមកជាសេចក្ដីសម្រាយ ឬ សម្ដីដែលគេនិយាយគ្នាសព្វថ្ងៃក៏ដោយគេអាចកាត់អាយតនិបាតខ្លះចេញបាន ដូចពាក្យ "រី, នូវ, កាន់" ជាដើម, គេកាត់ចេញ គឺថាគេលុបចោលមិនបាច់ប្រើដូចជាក្នុងប្រយោគថា គោណោ តិណំ ខាទតិ "រីគោ ស៊ីនូវស្មៅ", គេកាត់ពាក្យ "រី" និងពាក្យ "នូវ" ចេញ, ទុកឲ្យនៅតែត្រឹមពាក្យថា "គោ ស៊ី ស្មៅ", សោ គេហំ គច្ឆតិ "រីគេ ទៅ កាន់ផ្ទះ", កាត់ពាក្យ "រី" និងពាក្យ "កាន់" ចេញ ទុកឲ្យនៅតែត្រឹមពាក្យថា "គេ ទៅ ផ្ទះ" ។ ដូច្នេះគេក៏គង់អាចដឹងច្បាស់ថា ត្រង់នោះ ៗ មានពាក្យជាអាយតនិ-បាតនោះ ៗ តែគេកាត់ចេញមិនប្រើ ។ ប៉ុន្តែមានពាក្យជាអាយតនិបាតខ្លះ ត្រូវតែទុកឲ្យនៅទើបស្ដាប់សេចក្ដីបាននោះក៏មាន ដូចជា មគ្គេន គច្ឆតិ "(គេ) ទៅ តាមផ្លូវ", មញ្ចេនិបជ្ជតិ "(គេ) ដេក លើគ្រែ" ។ យ៉ាងនេះ នឹងកាត់ពាក្យ "តាម", ពាក្យ "លើ" ចេញពុំបានឡើយ លុះតែទុកពាក្យឲ្យនៅគ្រប់គ្រាន់ទើបស្ដាប់សេចក្ដីបាន ។

## ការន្ត

[៥៨] ការន្ត ប្រែថា "ទីបំផុតនៃអក្សរ" គឺស្រៈជាទីបំផុតនៃនាមសព្ទដែលប្រព្រឹត្តទៅក្នុងលិង្គទាំង ៣ នោះឯង ហៅថា ការន្ត ។ ការន្តនោះជាគ្រឿងសម្គាល់ក្នុងការប្រកបនាមសព្ទផ្សំនឹងវិភត្តិ ។ កុលបុត្រអ្នកសិក្សាត្រូវកំណត់សម្គាល់ការន្តនោះឲ្យចាំស្ទាត់សិន ទើបនឹងអាចងាយស្គាល់ងាយយល់លិង្គនិងវិធីបំបែកនាមសព្ទផ្សំនឹងវិភត្តិ ។

ការន្តសម្រាប់ប្រើក្នុងនាមសព្ទនោះលោកកំណត់ទុកដូច្នេះ

ក្នុងបុំលិង្គមានការន្ត ៥ គឺ អ ឥ ឦ ឧ ឩ ។

ក្នុងឥត្ថីលិង្គមានការន្ត ៥ គឺ អា ឥ ឦ ឧ ឩ ។

ក្នុងនបុំសកលិង្គមានការន្ត ៣ គឺ អ ឥ ឧ ។

រួមការន្តក្នុងលិង្គទាំង ៣ ត្រូវជា ១៣ តួ ។

មានការន្តផ្សេង ១ តួទៀត គឺ ស្រៈ ឱ ហៅថា ឱការន្ត ចំពោះប្រើតែត្រង់នាមនាម ១ សព្ទគឺ គោ "គោ" ជាទ្វិលិង្គិកៈ គឺបុំលិង្គនិងឥត្ថីលិង្គ ។ បើរាប់ឱការន្តនេះបញ្ចូលផង ជាការន្តមាន ១៤ តួ ។

## វិធីបំបែកនាមសព្ទ

[៥៩] នាមនាមក្តី គុណនាមក្តី សព្វនាមក្តី សុទ្ធតែមានការន្តជាគ្រឿងសម្គាល់ទាំងអស់ ។ ប៉ុន្តែក្នុងការន្តមួយ ៗ ដែលប្រើចំពោះនាមសព្ទទាំង ៣ យ៉ាងនោះ មានវិធីបំបែកផ្សំនឹងវិភត្តិត្រូវបែបគ្នាខ្លះ ផ្សេងគ្នាខ្លះ ។ នាមនាមនិងគុណនាមទាំង ២ យ៉ាង កាលបើមានការន្តដូចគ្នាជាលិង្គណា ក៏មានវិធីបំបែកត្រូវគ្នាតែបែបមួយ តាមដំណើរការន្តក្នុងលិង្គនោះ វៀរលែងតែនាមនាមនិងគុណនាមខ្លះ ដែលជាពួកសព្ទមានវិធីបំបែកផ្សេងដោយឡែកនោះចេញ ។ ឯសព្វនាម មានវិធីបំបែកប្លែកគ្នាអំពីនាមនាមនិងគុណនាមដោយច្រើន ។

## រូបសិទ្ធិ

[៦០] វិធីសម្រេចរូបសព្ទឲ្យត្រូវតាមរបៀបប្រើក្នុងភាសាបាឡី ហៅថា រូបសិទ្ធិ ឬ និប្ផន្នរូបវិធី គឺវិធីតាំងតួ ឬ ធ្វើតួ ។ វិធីនេះ គឺចំពោះបែបបំបែកនាមសព្ទផ្សំនឹងវិភត្តិនោះឯង ។ បែបបំបែកនាមសព្ទនោះ ត្រង់បទខ្លះ ជួនគ្រាន់តែផ្សំនឹងវិភត្តិហើយ

ទុកជាស្រេច ឥតមានវិធីផ្លាស់ប្រែអ្វីក៏មាន, ជួនមានវិធីផ្លាស់វិភត្តិ ឬការន្ត ឬផ្លាស់វិភត្តិព្រមទាំងការន្ត ធ្វើឲ្យប្លែកចាករូបដើមក៏មាន ជួនសម្រេចរូបដោយវិធីលុបវិភត្តិចេញក៏មាន ទីឃៈការន្តខ្លីឲ្យជាការន្តវែងក៏មាន, រស្សៈការន្តវែងឲ្យជាការន្តខ្លីក៏មាន ឬចុះអាគមថែម ជាដើម ក៏មាន ។ អ្នកសិក្សាគប្បីសង្កេតតាមវិធីបំបែកនាមសព្ទនិងរូបសិទ្ធិដូចមានតទៅនេះ ។

[៦១] អការន្តបុំលិង្គ បំបែកយ៉ាង បុរិស "ប្រុស" ដូច្នេះ :

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. បុរិសោ[១] | បុរិសា |
| ទុ. បុរិសំ | បុរិសេ |
| ត. បុរិសេន | បុរិសេហិ, បុរិសេភិ |
| ច. បុរិសស្ស, បុរិសាយ, បុរិសត្ថំ | បុរិសានំ |
| បញ្ច.បុរិសស្មា, បុរិសម្ហា, បុរិសា | បុរិសេហិ, បុរិសេភិ |
| ឆ. បុរិសស្ស | បុរិសានំ |
| ស. បុរិសស្មឹ, បុរិសម្ហិ, បុរិសេ | បុរិសេសុ |
| អា. បុរិស | បុរិសា |

១ ត្រូវទន្ទេញ, សូត្រថា បឋមាឯកវចនៈ បុរិសោ, ពហុវចនៈ បុរិសា ។ល។ អាលបនៈ ឯកវចនៈ បុរិស, ពហុវចនៈ បុរិសា ។

# រូបសិទ្ធិ មានមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ប. សោ, សរលោបោ ។ ល ។ តុបកតិ | សព្វយោនីនមាង, សរលោបោ ។ ល ។ តុបកតិ |
| ទុ. សរលោបោ ។ល។ តុបកតិ | ដូច ប. ពហុ. |
| ត. អតោនេន,សរ ។ល។ តុបកតិ | សុហីស្វការោង,ស្មាហិស្មឹនម្ហាភិម្ហិវា |
| ច. សាគមោសេ, យទនុ ។ល។ សិជ្ឈន្តិ អាយចតុត្ថេកវចនស្សវុត្ | សុនំហីសុច |
| បញ្ច. ស្មាហិ។ល។ ភិម្ហិវា,ស្មាស្មឹនំវា | ដូច ត. ពហុ. |
| ឆ. សាគមោសេ, យទនុ ។ល។ សិជ្ឈន្តិ | ដូច ច. ពហុ. |
| ស. ស្មាហិស្មឹនម្ហាភិម្ហិវា,ស្មាស្មឹនំវា | សុហីស្វការោង |
| អា. អាល ។ល។ គសញ្ញោ, សេស ។ល។ សិបិ | ដូច ប. ពហុ. |

# រូបសិទ្ធិ ឥតមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ប. ផ្លាស់ សិ ជា ឱ ហើយលុប អ ចេញ ជា បុរិសោ | ផ្លាស់ យោ ជា អា ហើយលុប អ ចេញ ជាបុរិសា |
| ទុ. បុរិសផ្សំនឹង ំ ជាបុរិសំ | ផ្លាស់យោជាឯហើយលុបអចេញជាបុរិសេ |

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ត. ផ្លាស់ នា ជា ឯន ហើយលុប អ ចេញ ជា បុរិសេន | ផ្លាស់អជាឯផ្សំនឹងហិជាបុរិសេហិ,ផ្លាស់ហិជាភិហើយផ្លាស់អជាឯផ្សំជាបុរិសេភិ |
| ប.ចុះសអាគមផ្សំនឹងសវិភត្តិជាបុរិសស្ស, ផ្លាស់សជាអាយហើយលុបអចេញជាបុរិសាយ,ផ្លាស់សជាត្ថំជាបុរិសត្ថំ | ទីឃៈអជាអាផ្សំនឹងនំជាបុរិសានំ |
| បញ្ចា. បុរិសផ្សំនឹងស្មាជាបុរិសស្មា,ផ្លាស់ជាម្ហាជាបុរិសម្ហាៈ ផ្លាស់ស្មាជាអាហើយលុបអចេញជាបុរិសា | បុរិសេហិ,បុរិសេភិ ដូច ត. ពហុ. |
| ឆ. ចុះសអាគមផ្សំនឹងសវិភត្តិជាបុរិសស្ស | បុរិសានំ ដូច ច. ពហុ |
| ស. បុរិសផ្សំនឹងស្មឹជាបុរិសស្មឹៈផ្លាស់ស្មឹជាម្ហិជាបុរិសម្ហិ, ផ្លាស់ស្មឹជាឯហើយលុបអចេញជាបុរិសេ | ផ្លាស់អជាឯផ្សំនឹងសុជាបុរិសេសុ |
| អា. គ្រាន់តែលុប សិ ចេញគង់រូបនៅជា បុរិស ដូចដែល | បុរិសា ដូច ប. ពហុ. |

សព្ទជាអការន្តបុំលិង្គប៉ុណ្ណោះជាដើម បំបែកដូច បុរិស

| | | | |
|---|---|---|---|
| អាចរិយ | អាចារ្យ | ចន្ទ | ព្រះចន្ទ |
| កុមារ | ក្មេងប្រុស | ឆណ | មហោស្រព |
| គណ | ពួក, ក្រុម, បន. ហ្វូង | ជាតវេទ | ភ្លើង |

| | | | |
|---|---|---|---|
| ឈស | ត្រី | ផលិក | កែវផលិក |
| ញាតក | ជនជាញាតិ | ព្យគ្ឃ | ខ្លាធំ |
| ដំក | ពន្លាក, ដែកសម្រាប់ដាប់ថ្ម | ភុជង្គ | នាគ, ពស់ |
| ឱស | របោម | មក្កដក | ពីងពាង |
| តុម្ព | តុម្ព, នាឡិសម្រាប់វាល់ | យោធ | យោធា (ទាហាន) |
| ប៉ុស | អង្កាម, សំបក | វរ | សម្រែក |
| ទន្ត | ធ្មេញ, ភ្លុក | លុលាយ | ក្របី |
| ធជ | ទង់ | សស | ទន្សាយ |
| នខ | ក្រចក | ហត្ថ | ហត្ថ, ដៃ |
| បន្ថ | ផ្លូវ | ហរ | កិរិយាហារ (កិរិយាស្រែកហៅ) |

[៦២] ឥការន្តបុំលិង្គបំបែកយ៉ាង មុនិ "អ្នកប្រាជ្ញ" ដូច្នេះ

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | មុនិ | មុនយោ, មុនី |
| ទុ. | មុនឹ | មុនយោ, មុនី |
| ត. | មុនិនា | មុនីហិ, មុនីភិ |
| ច. | មុនិស្ស, មុនិនោ | មុនីនំ |

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| បញ្ច. មុនិស្មា, មុនិម្ហា, មុនិនា | មុនីហិ, មុនីភិ |
| ឆ. មុនិស្ស, មុនិនោ | មុនីនំ |
| ស. មុនិស្មឹ, មុនិម្හិ | មុនីសុ |
| អា. មុនិ | មុនយោ, មុនី |

«រូបសិទ្ធិ មានមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ប. សេសតោលោបំគសិបិ | ឥវណ្ណុវណ្ណាឈលា, យោស្វកតរ-ស្សោឈោ, ឃបតោ ។ល។ លោបោ, យោសុ ។ល។ ទីឃំ |
| ទុ. ឥវណ្ណុ...,អម្មោនិគ្គ។ល។ បេហិ (និគ្គហិតំឈការំនេតព្វំ កុលបុត្រគប្បីនាំនិគ្គហិត ទៅកាន់អក្ខរៈឈ្មោះឈ) | ដូច ប. ពហុ. |
| ត. គ្រាន់តែចុះនាវិភត្តិស្រេច | ស្មាហិស្មឹនម្ហាភិម្හិវា, សុនំហីសុច |
| ប. សាគមោសេ, ឥវណ្ណុ..., ឈល ។ ល ។ នោវា | សុនំហីសុច |
| បញ្ច. ស្មាហិស្មឹនម្ហាភិម្ហិវា, ឥវណ្ណុ... ឈលតោច | ដូច ត. ពហុ |

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ឆ. ដូច ច. ឯក. | ដូច ច. ពហុ. |
| ស. ស្មាហិស្មឹនម្ហាភិម្ហិវា | សុនំហិសុច |
| អា. អាល ។ ល ។ សញ្ញោ, សេសតោលោបំគសិបិ | ដូច ប. ពហុ. |

## រូបសិទ្ធិ ឥតមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ប. គ្រាន់តែលុប សិ ចេញគង់រូបនៅជាមុនិដូចដែល | ផ្លាស់ឥជាអផ្សំនឹងយោជាមុនយោ លុបយោចេញហើយទីឃៈឥជាឦជាមុនី |
| ទុ. មុនិ ផ្សំនឹង ំ ជា មុនឹ | មុនយោ, មុនីដូច ប. ពហុ. |
| ត. មុនិ ផ្សំនឹង នា ជាមុនិនា | ទីឃៈឥជាឦផ្សំនឹងហិជាមុនីហិ, ផ្លាស់ហិជាភិហើយទីឃៈឥជាឦផ្សំជាមុនីភិ |
| | ទីឃៈឥជាឦ ផ្សំនឹង នំជាមុនីនំ |
| ប. ចុះសអាគមផ្សំនឹងសវិភត្តិជាមុនិស្ស ផ្លាស់សជានោជាមុនិនោ | |
| បញ្ចា. មុនិផ្សំនឹងស្មាជាមនិស្មា, ផ្លាស់ស្មាជាម្ហាជាមុនិម្ហា, ផ្លាស់ស្មាជានាជាមុនិនា | មុនីហិ, មុនីភិ ដូច ត. ពហុ. |

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ឆ. មុនិស្ស, មុនិនោ ដូច ច. ឯក. | មុនីនំ ដូច ច. ពហុ. |
| ស. មុនិ ផ្សំនឹង ស្មឹ ជា មុនិស្មឹ, ផ្លាស់ ស្មឹជាម្ហិ ជាមុនិម្ហិ | ទីឃៈឥជាឦ ផ្សំនឹង សុជាមុនីសុ |
| អា. មុនិ ដូច ប. ឯក. | មុនយោ, មុនី ដូច ប. ពហុ |

## សព្ទជា ឥ ការន្តបុំលិង្គប៉ុណ្ណោះជាដើម បំបែកដូច មុនិ

| | | | |
|---|---|---|---|
| អគ្គិ | ភ្លើង | ទុន្ទុភិ | ស្គរ |
| អាលិ ឬ អាឡិ | ខ្ទួយ | ធម្មនិ | ពស់តុកកែ |
| ឥសិ | ឥសី | និធិ | កំណាប់, កំណាប់ទ្រព្យ |
| ឧណ្ហរំសិ | ព្រះអាទិត្យ | បត្តិ | ទាហានថ្មើរជើង |
| កបិ | ស្វា | ពរិហិ | ក្ងោក |
| គណ្ឋិ | សន្លាក់, ថ្នាំង | មណិ | កែវមណី |
| ចូឡាមណិ | ស្នៀតសក់ | យតិ | យោគី, អ្នកប្រព្រឹត្តធម៌ |
| ជលនិធិ | សមុទ្ទ | រាសិ | រាសី, គំនរ |
| ញាតិ | ញាតិ | វីហិ | ស្រូវ |
| តិលបណ្ណិ | ចន្ទន៍ក្រហម | សទាគតិ | ខ្យល់ |
| ថបតិ | ជាងឈើ | ហរិ | ព្រះនារាយន៍, មាស |

## [៦៣] ឦ ការន្តបុំលិង្គ បំបែកយ៉ាង សេដ្ឋី "សេដ្ឋី" ដូច្នេះ

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ប. សេដ្ឋី | សេដ្ឋិនោ, សេដ្ឋី |
| ទុ. សេដ្ឋឹ, សេដ្ឋិនំ | សេដ្ឋិនោ, សេដ្ឋី |
| ត. សេដ្ឋិនា | សេដ្ឋីហិ, សេដ្ឋីភិ |
| ច. សេដ្ឋិស្ស, សេដ្ឋិនោ | សេដ្ឋីនំ |
| បញ្ច. សេដ្ឋិស្មា,សេដ្ឋិម្ហា,សេដ្ឋិនា | សេដ្ឋីហិ, សេដ្ឋីភិ |
| ឆ. សេដ្ឋិស្ស, សេដ្ឋិនោ | សេដ្ឋីនំ |
| ស. សេដ្ឋិស្មឹ, សេដ្ឋិម្ហិ | សេដ្ឋីសុ |
| អា. សេដ្ឋិ | សេដ្ឋិនោ, សេដ្ឋី |

## រូបសិទ្ធិ មានមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ប. សេសតោលោបំគសិបិ | ឥវណ្ណុ..អយោ។ល។ស្វបិច,យោនន្នោ, ឥវណ្ណុ...យបតោចយោនំលោបោ ដូច ប. ពហុ. |
| ទុ. ឥវណ្ណុ..អយោ ។ល។ ស្វបិច. (និគ្គហិតំឈេការំនេតព្វំ),ឥវណ្ណុ..អយោ ។ល។ស្វបិច,នញ្ញតោកតរស្សា | |

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ត. ឥវណ្ណ...អយោ ។ល។ ស្វបិច | ស្មាហិស្មឹនម្ហាភិម្ហិវា |
| ច. ឥវណ្ណ..អយោ ។ល។ ស្វបិច, សាគមោសេ, យតនុ... ។ល។ ឈលតោ... | គ្រាន់តែចុះ នំ វិភត្តិស្រេច |
| បញ្ច.ឥវណ្ណ... អយោរស្សមេក... ស្មាហិ, ស្មឹ... ឈលតោច ។ល។ | ដូច ត. ពហុ. |
| ឆ. ដូច ច. ឯក | ដូច ច. ពហុ. |
| ស. ឥវណ្ណ..., ។ល។ ស្មាហិស្មឹ... | គ្រាន់តែចុះ សុ វិភត្តិស្រេច |
| អា.អាលបនេ។ល។ គសញ្ញោ,ឥវណ្ណ.. ឈលបារស្សំ,សេសតោ។ល។សិបិ | ដូច ប. ពហុ. |

## រូបសិទ្ធិ ឥតមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ប. គ្រាន់តែលុប សិ ចេញគង់រូប នៅជាសេដ្ឋីដូចដែល | រស្សៈឦជាឥហើយផ្លាស់យោជា នោជាសេដ្ឋិនោ, គ្រាន់តែលុបយោ ចេញគង់រូបនៅជាសេដ្ឋីដូចដែល |
| ទុ. រស្សៈឦជាឥផ្សំនឹងំជាសេដ្ឋឹ, រស្សៈឦជាឥហើយផ្លាស់ ំ ជានំ ជាសេដ្ឋិនំ | សេដ្ឋិនោ, សេដ្ឋី ដូច ប. ពហុ. |
| ត. រស្សៈ ឦ ជា ឥ ផ្សំនឹង នា ជា សេដ្ឋិនា | សេដ្ឋីផ្សំ នឹង ហិជាសេដ្ឋីហិ, ផ្លាស់ហិជាភិជាសេដ្ឋីភិ |

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. វស្សៈល្បជាតហើយចុះសអាគមផ្សំនឹងសវិភត្តិជាសេដ្ឋិស្ស,វស្សៈល្បជាតហើយផ្លាស់សជានោជាសេដ្ឋិនោ | សេដ្ឋីផ្សំ នឹង នំ ជាសេដ្ឋីនំ |
| បញ្ច. វស្សៈល្បជាតផ្សំនឹងស្មាជាសេដ្ឋិស្មា, វស្សៈល្បជាតហើយផ្លាស់ស្មាជាម្ហា.ជា នា ជា សេដ្ឋិម្ហា, សេដ្ឋិនា | សេដ្ឋីហិ, សេដ្ឋីភិ ដូចត.ពហុ. |
| ឆ. សេដ្ឋិស្ស,សេដ្ឋិនោ ដូច ច. ឯក. | សេដ្ឋីនំ ដូច ច. ពហុ. |
| ស.វស្សៈល្បជាតផ្សំនឹងស្មឹជាសេដ្ឋិស្មឹ,វស្សៈល្បជាតហើយផ្លាស់ស្មឹជាម្ហិជាសេដ្ឋិម្ហិ | សេដ្ឋី ផ្សំនឹង សុ ជា សេដ្ឋីសុ |
| អា.វស្សៈល្បជាតហើយលុបសិចេញជាសេដ្ឋិ | សេដ្ឋិនោ, សេដ្ឋី ដូច ប. ពហុ. |

## សព្ទជា ល្ប ការន្តបុំលិង្គប៉ុណ្ណោះជាដើម បំបែកដូច សេដ្ឋី[១]

| | | | |
|---|---|---|---|
| អនុជីវី | អ្នករាជការ | តបសី | ជនមានតបៈ |
| អន្តេវាសី | កូនសិស្ស | ទណ្ឌី | ជនមានឈើច្រត់ |
| ករី | ដំរី | ព្រហ្មចារី | អ្នកប្រព្រឹត្តព្រហ្មធម៌ |
| កេកី | ក្ងោក | ភោគី | ជនមានភោគ |

១ សព្ទជា ល្ប ការន្តបុំលិង្គនេះ កាលបើរួមចូលជាបទសមាសជាមួយនឹងសព្ទឯទៀត ហើយល្បការន្តនេះនៅខាងក្នុងអំពីមុខព្យញ្ជនៈត្រូវវស្សៈល្បជាត ជាកំណត់ ឧ. សេដ្ឋិបុត្តោ, ករិទន្តា. កេកិបក្ខា ។

| | | | |
|---|---|---|---|
| មន្តី | មន្ត្រី, អ្នកមានគំនិត | វេរី | ជនមានពៀរ, សត្រូវ |
| មេធាវី | អ្នកមានប្រាជ្ញា (អ្នកប្រាជ្ញ) | សិខរី | ភ្នំ, ដើមឈើ |
| រថាចារី | សារថី (អ្នកបររទេះ) | សិខី | ភ្លើង, ក្ងោក |
| រោគហារី | គ្រូពេទ្យ | សុខី | ជនមានសេចក្តីសុខ |
| វីណាវាទី | អ្នកដេញពិណ | សូលី | ព្រះឥសូរៈ |
| វិទ្វេសី | សត្រូវ | ហត្ថី | ដំរី |

[៦៤] ឧការន្តបុំលិង្គ បំបែកយ៉ាង គរុ "គ្រូ" ដូច្នេះ

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | គរុ | គរវោ, គរូ |
| ទុ. | គរុំ | គរវោ, គរូ |
| ត. | គរុនា | គរូហិ, គរូភិ |
| ច. | គរុស្ស, គរុនោ | គរូនំ |
| បញ្ច. | គរុស្មា, គរុម្ហា, គរុនា | គរូហិ, គរូភិ |
| ឆ. | គរុស្ស, គរុនោ | គរូនំ |
| ស. | គរុស្មឹ, គរុម្ហិ | គរូសុ |
| អា. | គរុ | គរវេ, គរវោ |

## រូបសិទ្ធិ មានមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ប. សេសតោលោបំគសិបិ | ឥវណ្ណុ...លតោវោកាវោច, វេវោសុ-<br>លោច,យបតោចយោនំលោបោ,<br>យោសុកតនិការលោបេសុទីឃំ<br>ដូច ប. ពហុ. |
| ទុ.ឥវណ្ណុ.. អម្មោនិគ្គហិតំឈលេ-<br>បេហិ,(និគ្គហិតំលការំនេតពុំ) | |

តាំងពីតតិយាដល់សត្តមីទាំង ២ វចនៈ និងអាលបនៈឯក-វចនៈមានរូបសិទ្ធិដូចឥការន្តបុំលិង្គ ។ ត្រង់អាលបនៈពហុវចនៈសម្រេចរូបដោយមេសូត្រ ឥវណ្ណុវណ្ណាឈលា, អកតរស្សាលតោឃ្វាលបនស្សវេវោ, វេវោសុលោច ។

## រូបសិទ្ធិ ឥតមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ប.គ្រាន់តែលុបសិចេញគង់<br>រូបនៅជាគរុដូចដែល<br>ទុ. គរុផ្សំនឹង ំ ជាគរុំ | ផ្លាស់យោជាវោហើយផ្លាស់ឧជាអជាគរ-<br>វោលុបយោចេញហើយទីឃៈឧជាឩជាគរូ<br>គរវោ, គរូ ដូច ប. ពហុ. |

តាំងពីតតិយាដល់សត្តមីទាំង ២ វចនៈ និងអាលបនៈឯកវចនៈ មានរូបសិទ្ធិដូចឥការន្តបុំលិង្គ ។ ត្រង់អាលបនៈពហុវចនៈ ផ្លាស់យោជាវេ, ជាវោ ហើយផ្លាស់ ឧជាអ ជាគវេ, គវោ ។

សព្ទជាឧការន្តបុំលិង្គប៉ុណ្ណោះជាដើមបំបែកដូច គរុ

| | | | |
|---|---|---|---|
| អកិលាសុ | ជនមិនខ្ជិលច្រអូស | បសុ | សត្វចិញ្ចឹម |
| អាខុ | កណ្ដុរ | ផរសុ | ដឹង, ប៉ូវថៅ |
| ឥន្ទុ | ព្រះចន្ទ | ពព្ពុ | ឆ្មា, ខ្លាត្រី |
| ឧសុ | កូនសរ, ព្រួញ | ភមុ | ចិញ្ចើម |
| ឩរុ | ភ្លៅ | មច្ចុ | មច្ចុ (សេចក្ដីស្លាប់) |
| កេតុ | ទង់ | រិបុ | សត្រូវ |
| ខាណុ | ដង្គត់, ចម្រូង | លេឌ្ឌុ | ដុំដី |
| ជន្តុ | សត្វ | វាយុ | ខ្យល់ |
| ទេវទារុ | ឈើទេព្វទារូ | សេតុ | ស្ពាន |
| ធូមកេតុ | ភ្លើង, ផ្កាយដុះកន្ទុយ | ហេតុ | ហេតុ, ដើមចម |

[៦៥] ឧការន្តបុំលិង្គ បំបែកយ៉ាង វិញ្ញូ "អ្នកប្រាជ្ញ" ដូច្នេះ:

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. វិញ្ញូ | វិញ្ញុនោ, វិញ្ញូ |
| ទុ. វិញ្ញុំ | វិញ្ញុនោ, វិញ្ញូ |
| ត. វិញ្ញុនា | វិញ្ញូហិ, វិញ្ញូភិ |
| ច. វិញ្ញុស្ស, វិញ្ញុនោ | វិញ្ញូនំ |
| បញ្ច. វិញ្ញុស្មា, វិញ្ញុម្ហា, វិញ្ញុនា | វិញ្ញូហិ, វិញ្ញូភិ |
| ឆ. វិញ្ញុស្ស, វិញ្ញុនោ | វិញ្ញូនំ |
| ស. វិញ្ញុស្មឹ, វិញ្ញុម្ហិ | វិញ្ញូសុ |
| អា. វិញ្ញុ | វិញ្ញុនោ, វិញ្ញូ |

រូបសិទ្ធិដូចគ្នានឹងឮការន្តបុំលិង្គ ផ្សេងគ្នាតែការន្តមួយជាឮមួយជាឧប៉ុណ្ណោះឯង ។

សព្ទជាឧការន្តបុំលិង្គប៉ុណ្ណោះជាដើម បំបែកដូចវិញ្ញូ[១]

| | |
|---|---|
| អភិភូ ព្រះអភិភូ (ព្រះពុទ្ធ) | កតញ្ញូ អ្នកដឹងនូវឧបការគុណ ដែលគេធ្វើហើយ |

១ កាលបើរួមចូលជាបទសមាសមានន័យដូចឮការន្តបុំលិង្គ ឧ. វិញ្ញុចរិយា កតញ្ញុចិត្តំ (មើលត្រង់លេខ ៦៣) ។

| | |
|---|---|
| បារគូ អ្នកដល់នូវត្រើយ | វេទគូ អ្នកដល់នូវវេទ |
| មត្តញ្ញូ អ្នកដឹងនូវប្រមាណ | សយម្ភូ ព្រះសយម្ភូ |

[៦៦] អា-ការន្តឥត្ថីលិង្គ បំបែកយ៉ាងកញ្ញា "ស្ត្រីក្រមុំ" ដូច្នេះ

| ឯកវចនៈ | | ពហុវចនៈ |
|---|---|---|
| ប. | កញ្ញា | កញ្ញាយោ, កញ្ញា |
| ទុ. | កញ្ញំ | កញ្ញាយោ, កញ្ញា |
| ត. | កញ្ញាយ | កញ្ញាហិ, កញ្ញាភិ |
| ច. | កញ្ញាយ | កញ្ញានំ |
| បញ្ច. | កញ្ញាយ | កញ្ញាហិ, កញ្ញាភិ |
| ឆ. | កញ្ញាយ | កញ្ញានំ |
| ស. | កញ្ញាយ, កញ្ញាយំ | កញ្ញាសុ |
| អា. | កញ្ញេ | កញ្ញាយោ, កញ្ញា |

រូបសិទ្ធិ មានមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. ឥត្ថិយមតោអាបច្ចយោ,អាយោ, សេសតោលោបំគសិបិ | ឥត្ថិយមតោ... អាយោ, យបតោ-ចយោនំលោបោ |

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ទុ. ឥត្ថិយមតោ... អាយោ, សរលោបោ ។ ល ។ តុបកតិ, ក្វចាទិមជ្ឈុត្តរានំ ។ ល ។ សុច | ដូច ប. ពហុ. |
| ត. ឥត្ថិយមតោ ... អាយោ, យតោនាទីនំ | ឥត្ថិយមតោ . . . អាយោ, ស្មាហិស្មឹនម្ហាភិម្ហិវា |
| ប. ដូច ត. ឯក. | ឥត្ថិយមតោ... អាយោ |
| បញ្ច. ដូច ត. ឯក. | ដូច ត. ពហុ |
| ឆ. ដូច ត. ឯក. | ដូច ច. ពហុ. |
| ស.ឥត្ថិយមតោ..។ល។ យបតោស្មឹយំវា | ឥត្ថិយមតោ... អាយោ |
| អា.ឥត្ថិយមតោ..អាយោ អាលបនេ.. យតេច.សរលោបោ ។ល។ តុបកតិ | ដូច ប. ពហុ |

## រូបសិទ្ធិ ឥតមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. គ្រាន់តែលុបសិចេញគង់រូបនៅជាកញ្ញាដូចដែល | កញ្ញា ផ្សំនឹង យោ ជាកញ្ញាយោ, គ្រាន់តែលុប យោ ចេញគង់រូបនៅជាកញ្ញាដូចដែល |
| ទុ. រស្សៈអាជាអផ្សំនឹង ំ ជាកញ្ញំ | កញ្ញាយោ, កញ្ញា ដូច ប. ពហុ. |
| ត. ផ្លាស់ នាជាអាយហើយលុបអា ចេញជា កញ្ញាយ | កញ្ញាផ្សំ នឹង ហិ ជាកញ្ញាហិ, ផ្លាស់ ហិ ជា ភិ ផ្សំជា កញ្ញាភិ |

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ប. ផ្លាស់ ស ជា អាយ ហើយ លុប អា ចេញ ជា កញ្ញាយ | កញ្ញា ផ្សំនឹង នំជា កញ្ញានំ |
| បញ្ច. ផ្លាស់ស្មា ជាអាយហើយ លុប អ ចេញ ជា កញ្ញាយ | កញ្ញាហិ, កញ្ញាភិ ដូច ត. ពហុ. |
| ឆ. កញ្ញាយ ដូច ច. ឯក. | កញ្ញានំ ដូច ច. ពហុ. |
| ស. ផ្លាស់ ស្មឹ ជា អាយ ហើយ លុប អា ចេញ ជា កញ្ញាយ, ផ្លាស់ ស្មឹ ជា យំ ជាកញ្ញាយំ | កញ្ញា ផ្សំនឹង សុ ជា កញ្ញាសុ |
| អា. ផ្លាស់ សិ ជា ឯ ហើយលុប អា ចេញ ជា កញ្ញេ | កញ្ញាយោ, កញ្ញា ដូច ប. ពហុ. |

## សព្ទជា អាការន្តឥត្ថីលិង្គប៉ុណ្ណោះជាដើម
## បំបែកដូច កញ្ញា[១]

| | | | |
| --- | --- | --- | --- |
| អង្គនា | ស្ត្រី | ឦហា | សេចក្តីព្យាយាម |
| អាសា | បំណង | ឧក្កា | គប់ភ្លើង, ចង្រ្កានធ្យូង |
| ឥក្ខណិកា | ស្រីមេមត់ | ឩហា | សេចក្តីត្រិះរិះ |

១ សព្ទជាអាការន្តឥត្ថីលិង្គនេះ កាលបើរួមចូលជាបទសមាសជាមួយនឹងសព្ទឯទៀតហើយ អាការន្តនៅខាងក្នុងអំពីមុខព្យញ្ជនៈ ត្រូវទុកឲ្យនៅជាអាដូចដែល ឧ. កញ្ញាយោព្វនំ, កថាបវត្តិ,បញ្ញាបាសាទោ, មុត្តាមណិ ។

| | | | |
|---|---|---|---|
| ឯលា | ទឹកមាត់, ក្រវាញ | ធរា | ផែនដី |
| ឱជា | ឱជារស | នាវា | ទូក. សំពៅ |
| កថា | ពាក្យសម្ដី | បញ្ញា | ប្រាជ្ញា |
| ខមា | សេចក្ដីអត់ឱន | ផាសុកា | ឆ្អឹងជំនីរ |
| គទា | ដំបង | ពាហា | កំភួនដៃ |
| ឃរគោលិកា | តុកកែ, ជីងចក់ | ភាសា | សម្ដី |
| ចូឡា | ជុក, កំប៉ោយ | មុត្តា | កែវមុក្ដា |
| ឆមា | ផែនដី | យាចនា | កិរិយាសូម. សំណូម |
| ជនិកា | មាតា (ម្ដាយ) | វច្ឆា | ថ្នល់. ផ្លូវដើរ, ច្រក |
| ឈល្លិកា | ចង្រិត | លីលា | កិរិយាយាងយាស |
| តិតិក្ខា | សេចក្ដីអត់ធន់(អំណត់) | វណិជ្ជា | ការលក់ដូរ. ជំនួញ |
| ថវិកា | ថង់, យាម, ស្លោកបាត្រ | សាខា | មែក |
| ទេវតា | ទេវតា | ហនុកា | ចង្កា |

[៦៧] ឥការន្តឥត្ថីលិង្គ បំបែកយ៉ាង រត្តិ "រាត្រី" ដូច្នេះ:

| ឯកវចនៈ | | ពហុវចនៈ |
|---|---|---|
| ប. | រត្តិ | រត្តិយោ, រត្តី |

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ទុ. | រត្តឹ | រត្តិយោ, រត្តី |
| ត. | រត្តិយា | រត្តីហិ, រត្តីភិ |
| ច. | រត្តិយា | រត្តីនំ |
| បញ្ច. | រត្តិយា, រត្យា | រត្តីហិ, រត្តីភិ |
| ឆ. | រត្តិយា | រត្តីនំ |
| ស. | រត្តិយា, រត្តិយំ, រត្យំ, | រត្តីសុ |
| អា. | រត្តិ | រត្តិយោ, រត្តី |

## រូបសិទ្ធិ មានមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. សេសតោលោបំគសិបិ | តេឥត្ថីខ្យាបោ យបតោចយោនំលោ-បោ,យោសុកតនិការលោបេសុទីឃំ |
| ទុ. តេឥត្ថីខ្យាបោ, អម្ហោនិគ្គហិតំ-ឈលបេហិ,(និគ្គហិតំបការំនេតព្វំ) | ដូច ប. ពហុ. |
| ត. តេឥត្ថីខ្យាបោ, បតោយា | សុនំហីសុច, ស្មាហិស្មឹនម្ហាភិម្ហិវា |
| ច. ដូច ត. ឯក. | សុនំហីសុច |

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| បញ្ច. តេឥត្ថីខ្យាបោ, បតោយា, ។ ល ។ អមាបតោស្មឹ-ស្មានំវា, បសញ្ញស្សច | ដូច ត. ពហុ. |
| ឆ. ដូច ច. ឯក. | ដូច ច. ពហុ. |
| ស. តេឥត្ថីខ្យាបោ, បតោយា, ។ល។យបតោស្មឹយំវា,អមាប-តោស្មឹស្មានំវាបសញ្ញស្សច | សុនំហីសុច |
| អា. អាលបនេសិ... សេសតោ ។ល។ សិបិ | ដូច ប. ពហុ. |

## រូបសិទ្ធិ ឥតមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. គ្រាន់តែលុប សិ ចេញគង់រូបនៅជា រត្តិ ដូចដែល | រត្តិផ្សំនឹងយោជារត្តិយោ, លុបយោចេញហើយទីឃៈ ឥ ជា ឦជារត្តី រត្តិយោ, រត្តី ដូច ប. ពហុ. |
| ទុ. រត្តិផ្សំនឹង ំ ជារត្តឹ | ទីឃៈ ឥ ជា ឦ ផ្សំនឹង ហិ ជារត្តីហិ, ផ្លាស់ ហិ ជា ភិ ហើយទីឃៈ ឥ ជា ឦ ជា រត្តីភិ |
| ត. ផ្លាស់ នា ជា យា ជារត្តិយា | |
| ច. ផ្លាស់ ស ជា យា ជារត្តិយា | ទីឃៈ ឥ ជា ឦ ផ្សំនឹងនំ ជា រត្តីនំ |
| បញ្ច. ផ្លាស់ស្មាជា យា ជា រត្តិយា, ផ្លាស់ស្មាជាអា ហើយផ្លាស់ឥជាយ ហើយលុបតមួយតួចេញផ្សំជារត្យា ហើយលុបតមួយតួចេញផ្សំជារត្យា | រត្តីហិ, រត្តីភិ ដូច ត. ពហុ |

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ឆ. រត្តិយា ដូច ច. ឯក. | រត្តីនំ ដូច ច. ពហុ. |
| ស. ផ្លាស់ ស្មឹ ជា យា ជា រត្តិយា, ផ្លាស់ស្មឹជាយំជារត្តិយំ, ផ្លាស់ស្មឹ ជា ០ ហើយផ្លាស់ត ជាយហើយ លុប ត មួយតួចេញផ្សំជា រត្យំ | ទីឃៈឥជាឦ ផ្សំនឹង សុ ជារត្តីសុ |
| អា. រត្តិ ដូច ប. ឯក. | រត្តិយោ, រត្តី ដូច ប. ពហុ |

សព្វជាឥការន្តឥត្ថីលិង្គប៉ុណ្ណោះជាដើម បំបែកដូច រត្តិ

| | | | |
| --- | --- | --- | --- |
| អនុសិដ្ឋិ | ពាក្យប្រៀនប្រដៅ | ថុតិ | សេចក្តីសរសើរ |
| អាជិ | សង្គ្រាម | ទិត្តិ | សេចក្តីរុងរឿង, រស្មី |
| ឦតិ | ចង្រៃ | ជាតិ | មេនំ (មេដោះ) ភីលៀង |
| ឧក្ខលិ | ឆ្នាំង | នាភិ | ផ្ចិត, ដុំរទេះ |
| ឩមិ | រលក | បញ្ញត្តិ | សេចក្តីហាមប្រាម |
| កិត្តិ | កេរ្តិ៍ (កេរ្តិ៍ឈ្មោះ) | ពុទ្ធិ | ប្រាជ្ញា |
| ខន្តិ | ខន្តី (សេចក្តីអត់ធន់) | ភិត្តិ | ជញ្ជាំង |
| គណ្ឋិ | រគាំង, ចូង | មេត្តិ | មេត្រី (សេចក្តីរាប់អាន) |
| ឆវិ | សម្បុរថ្ងៃ, សម្បុរស្បែក | រំសិ | រស្មី |
| ជលសុត្តិ | ខ្យងហោង, គ្រំ | វិញ្ញត្តិ | កិរិយាសូម, កិរិយាជូនដំណឹង |
| តន្តិ | អំបោះ, ខ្សែពិណ | សតិ | ស្មារតី |

[៦៨] ណ្ឌៀការន្តឥត្ថីលិង្គ បំបែកយ៉ាង នារី "ស្ត្រី, នាង" ដូច្នេះ

| ឯកវចនៈ | | ពហុវចនៈ |
|---|---|---|
| ប. | នារី | នារិយោ, នារី |
| ទុ. | នារឹ | នារិយោ, នារី |
| ត. | នារិយា | នារីហិ, នារីភិ |
| ច. | នារិយា | នារីនំ |
| បញ្ច. | នារិយា | នារីហិ, នារីភិ |
| ឆ. | នារិយា | នារីនំ |
| ស. | នារិយា, នារិយំ | នារីសុ |
| អា. | នារិ | នារិយោ, នារី |

រូបសិទ្ធិ មានមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. សេសតោលោបំគសិបិ | តេឥត្ថីខ្យាបោ, អយោ ។ល។ ស្វបិច, តេឥត្ថីខ្យាបោ, យប-តោចយោនំលោបោ |
| ទុ. តេឥត្ថីខ្យាបោ, អយោ ។ល។ ស្វបិច, អម្មោនិគ្គហិតំឈលបេហិ (និគ្គហិតំបការំនេតព្វំ) | ដូច ប. ពហុ |

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ត. តេឥត្ថីខ្យាបោ, អយោរស្ស-មេ..., បតោយា | ស្មាហិស្មឹនម្ហាភិម្ហិវា |
| ប. ដូច ត. ឯក. | គ្រាន់តែចុះនំវិភត្តិស្រេច |
| បញ្ច.ដូច ត. ឯក. | ដូច ត. ពហុ. |
| ឆ. ដូច ច. ឯក. | ដូច ច. ពហុ. |
| ស. តេឥត្ថីខ្យាបោ ។ ល ។ យ-បតោស្មឹយំវា | គ្រាន់តែចុះសុវិភត្តិស្រេច |
| អា. តេឥត្ថីខ្យាបោ, អាលបនេ... ឈលបារស្សំ,សេសតោលោបំគសិបិ | ដូច ប. ពហុ. |

## រូបសិទ្ធិ ឥតមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ប. គ្រាន់តែលុប សិ ចេញគង់រូប នៅជា នារី ដូចដែល | រស្សៈឦ ជា ឥ ផ្សំនឹង យោ ជា នារិយោ គ្រាន់តែ លុប យោ ចេញគង់រូបនៅជា នារី ដូចដែល |
| ទុ. រស្សៈឦជាឥផ្សំនឹង ំ ជានារឹ | នារិយោ, នារី ដូច ប. ពហុ. |
| ត. រស្សៈឦ ជា ឥ ហើយផ្លាស់ នា ជា យា ជា នារិយា | នារី ផ្សំនឹង ហិ ជា នារីហិ, ផ្លាស់ ហិ ជា ភិ ផ្សំជា នារីភិ |
| ច. រស្សៈឦ ជា ឥ ហើយផ្លាស់ ស ជា យា ជា នារិយា | នារី ផ្សំនឹង នំ ជា នារីនំ |

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| បញ្ច. រស្សៈល្ស ជា ត ហើយ ផ្លាស់ស្មា ជា យា ជា នារិយា | នារីហិ, នារីភិ ដូច ត. ពហុ. |
| ឆ. នារិយា ដូច ច. ឯក. | នារីនំ ដូច ច. ពហុ. |
| ស. រស្សៈល្សជាត ហើយផ្លាស់ស្មី ជាយា,ជាយំជានារិយា,ជានារិយំ | នារី ផ្សំនឹង សុ ជា នារីសុ |
| អា. រស្សៈល្ស ជា ត ហើយលុប សិ ចេញជា នារិ | នារិយោ, នារី ដូច ប. ពហុ. |

សព្ទជាឦការន្តឥត្ថីលិង្គប៉ុណ្ណោះជាដើមបំបែកដូចនារី[១]

| | | | |
| --- | --- | --- | --- |
| អរណី | ដែកភ្លើង | គោលោមី | លំពាន់ |
| អាកុដី | ដើមស្មាច់ | ឃរណី | ស្រ្តីមេផ្ទះ (ប្រពន្ធ) |
| ឥង្គុទី | ឈើសម្រោង | តជ្ជនី | ចង្អុលដៃ |
| ឧព្វី | ផែនដី | ទេហនី | ធរណីទ្វារ |
| កក្ការី | រពៅ, ត្រសក់ | ធរណី | ផែនដី |

---

១ សព្ទជាល្សការន្តឥត្ថីលិង្គនេះ កាលបើរួមចូលជាបទសមាសជាមួយនឹងសព្ទឯទៀត ហើយល្សការន្តនេះនៅខាងក្នុងអំពីមុខព្យញ្ជនៈ ត្រូវទុកឲ្យនៅជាល្សដូចដែល ឧ. នារីលក្ខណំ, ឥត្ថីលិង្គំ, នទីតីរំ, សារីបុត្តោ ។

| | | | |
|---|---|---|---|
| នទី[១] | ស្ទឹង, ទន្លេ | រុក្ខាទនី | បញ្ញើក្អែក |
| នន្ទី | ខ្សែ,ខ្សែស្បែក,ខ្សែជ្រាម,ព្រ័ត្រ | លក្ខី | លក្ស្មី (ស្រីសួស្តី, សម្បត្តិ, លម្អ) |
| បច្ចរី | ផៃ, ក្បូន | វីជនី | ផ្លិត |
| ពាកុចី | កំញ៉ាន | សោណី | ត្រគាក |
| មាលតី | ដើមមាលតី | ហរីតកី | ឈើសម៉ |

[៦៩] ឧការន្តឥត្ថីលិង្គ បំបែកយ៉ាង រជ្ជុ "ខ្សែ" ដូច្នេះ:

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | រជ្ជុ | រជ្ជុយោ, រជ្ជូ |
| ទុ. | រជ្ជុំ | រជ្ជុយោ, រជ្ជូ |
| ត. | រជ្ជុយា | រជ្ជូហិ, រជ្ជូភិ |
| ច. | រជ្ជុយា | រជ្ជូនំ |
| បញ្ច. | រជ្ជុយា | រជ្ជូហិ, រជ្ជូភិ |

១ នទីសព្ទនេះ ក្នុងកច្ចាយនបករណ៍ ថាត្រង់ ប. ពហុ., ត. ឯក., ច. ឆ. ឯក. ឲ្យផ្លាស់ទីរបស់នទី: (ប. ពហុ.) ជា "ជ្ជោ", (ត.ឯក.) ជា "ជ្ជា" (ច. ឆ. ឯក.) ជា "ជ្ជា" ដោយមេសូត្រ មាតុលាទីនមានត្តមីការេ ហើយតម្រួតជា "ជ្ជោ.ជ្ជា" សម្រេចរូបជា "នជ្ជោ, នជ្ជា, នជ្ជា" ក៏បាន ។

| ឯកវចនៈ | | ពហុវចនៈ |
|---|---|---|
| ឆ. | រជ្ជុយា | រជ្ជូនំ |
| ស. | រជ្ជុយា, រជ្ជុយំ | រជ្ជូសុ |
| អា. | រជ្ជុ | រជ្ជុយោ, រជ្ជូ |

រូបសិទ្ធិដូចគ្នានឹងឥការន្តឥត្ថីលិង្គ ផ្សេងគ្នាតែការន្តមួយជាឥ មួយជា ឧ ប៉ុណ្ណោះឯង ។

## សព្ទជាឧការន្តឥត្ថីលិង្គប៉ុណ្ណោះជាដើម បំបែកដូច រជ្ជុ

| | | | |
|---|---|---|---|
| អលាពុ ឬ អលាវុ | ឃ្លោក | នត្ថុ | ច្រមុះ |
| ឧរុ | ខ្សាច់ | យាគុ | បបរ |
| កុ | ផែនដី | លាពុ ឬ លាវុ | ឃ្លោក |
| កាសុ | រណ្តៅ, អណ្តូង | វិជ្ជុ | ផ្លេកបន្ទោរ |
| ខជ្ជុ | រោគស្រែង | សស្សុ | ម្តាយក្មេក |
| តនុ | ខ្លួន, កាយ | សានុ | ញកភ្នំ, ច្រកភ្នំ, កំពូលភ្នំ |
| ធេនុ | មេគោ | អំសុ | រស្មី |

[៧០] ឩការន្តឥត្ថីលិង្គ បំបែកយ៉ាង វធូ "ស្ត្រីមានគូស្រករ, ប្រពន្ធក្រមុំ" ដូច្នេះ:

| ឯកវចនៈ | | ពហុវចនៈ |
|---|---|---|
| ប. | វធូ | វធុយោ, វធូ |
| ទុ. | វធុំ | វធុយោ, វធូ |
| ត. | វធុយា | វធូហិ, វធូភិ |
| ច. | វធុយា | វធូនំ |
| បញ្ច. | វធុយា | វធូហិ, វធូភិ |
| ឆ. | វធុយា | វធូនំ |
| ស. | វធុយា, វធុយំ | វធូសុ |
| អា. | វធុ | វធុយោ, វធូ |

រូបសិទ្ធិដូចគ្នានឹង ឦការន្តឥត្ថីលិង្គ ផ្សេងគ្នាតែការន្តមួយជាឦ មួយជាឩ ប៉ុណ្ណោះឯង ។

សព្វជាឧការន្តឥត្ថីលិង្គប៉ុណ្ណោះជាដើម បំបែកដូច វធូ[១]

| | | | |
|---|---|---|---|
| ចមូ | សេនា, កងទ័ពជើងគោក | ភូ | ផែនដី, ចិញ្ចើម |
| ជម្ពូ | ជម្ពូ, ព្រីង | សរពូ | តុកកែ |

[៧១] អការន្តនបុំសកលិង្គបំបែកយ៉ាងកុល "ត្រកូល" ដូច្នេះ

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | កុលំ | កុលានិ, កុលា |
| ទុ. | កុលំ | កុលានិ, កុលេ |
| ត. | កុលេន | កុលេហិ, កុលេភិ |
| ច. | កុលស្ស, កុលាយ, កុលត្ថំ | កុលានំ |
| បញ្ច. | កុលស្មា, កុលម្ហា, កុលា | កុលេហិ, កុលេភិ |
| ឆ. | កុលស្ស | កុលានំ |
| ស. | កុលស្មឹ, កុលម្ហិ, កុលេ | កុលេសុ |
| អា. | កុល | កុលានិ, កុលា |

១ កាលបើរួមចូលជាបទសមាស មានន័យដូចព្យការន្តឥត្ថីលិង្គ ឧ. វធូធនំ, ចមូបរិក្ខិតោ, ភូបាលទិន្នំ, សរពូមូសិកា, ជម្ពូនទំ (មើលត្រង់លេខ ៦៨) ។ តែ ជម្ពូ សព្ទ ១ នេះ ជួនណាប្រើជាឧការន្តឥត្ថីលិង្គជា ជម្ពុ ដូច្នេះក៏មាន ។

## រូបសិទ្ធិ មានមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ប. សិ, សរលោ ។ ល ។ តុបកតិ | យោនន្និនបុំសកេហិ, យោសុកត និការលោបេសុទីឃំ, យោនន្និន- បុំសកេហិ, សព្វយោនីនមាង |
| ទុ. សរលោ ។ ល ។ តុបកតិ | ដូច ប. ពហុ. |

តាំងពីតតិយាដល់សត្តមី ទាំង ២ វចនៈ និងអាលបនៈឯក- វចនៈ មានរូបសិទ្ធិដូចអការន្តបុំលិង្គៈ ត្រង់អាលបនៈពហុវចនៈ ដូចបឋមាពហុវចនៈ ។

## រូបសិទ្ធិ ឥតមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ប. ផ្លាស់ សិ ជា ំ ជាកុលំ | ផ្លាស់យោជានិ ហើយទីឃៈអជាអាជា កុលានិ,ផ្លាស់យោជានិហើយផ្លាស់និ ជាអាហើយលុបអចេញជាកុលា |
| ទុ. កុល ផ្សំនឹង ំ ជាកុលំ | កុលានិដូច ប. ពហុ, ផ្លាស់យោជានិ ហើយ ផ្លាស់និជាឯហើយលុបអចេញជាកុលេ |

តាំងពីតតិយាដល់សត្តមីទាំង ២ វចនៈ និងអាលបនៈឯក-វចនៈ មានរូបសិទ្ធិដូចអការន្តបុំលិង្គ, ត្រង់អាលបនៈពហុវចនៈ ដូចបឋមាពហុវចនៈ ។

## សព្ទជាអការន្តនបុំសកលិង្គប៉ុណ្ណោះជាដើម

## បំបែកដូច កុល

| | | | |
|---|---|---|---|
| អង្គុលិយក | ចិញ្ចៀន | ឆទន | ដំបូល, ស្លឹកឈើ |
| អាតបត្ត | ឆត្រ, តាំងយូ | ជាតរូប | មាស |
| ឥន្ទ្រិយ | ឥន្ទ្រិយ | ញាណ | ញាណ |
| ឧទក | ទឹក | តុណ្ឌ | ចំពុះ. មាត់ |
| ឱសាន | ទីបំផុត, ទីចប់ | ទុស្ស | សំពត់ |
| កមល | ផ្កាឈូក | ធន | ទ្រព្យ |
| ខេត្ត | ខេត្ត, ស្រែ | នយន | ភ្នែក |
| គោកុល | ក្រោលគោ, រោងគោ | បោត្ថក | បុស្តក (ក្រាំង, សៀវភៅគម្ពីរ):សំពត់សម្បកឈើ |
| ឃរ | ផ្ទះ | | |
| ចក្ក | ចក្រ (កង់) | ផាណិត | ទឹកអំពៅ |

| | |
|---|---|
| យោត្ត ខ្សែ | វាសន គ្រឿងអប់ |
| រដ្ឋ ដែន | សរីរ សរីរៈ (រាងកាយ) |

[៧២] ឥការន្តនបុំសកលិង្គ បំបែកយ៉ាងអក្ខិ "ភ្នែក" ដូច្នេះ:

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. អក្ខិ | អក្ខីនិ, អក្ខី |
| ទុ. អក្ខិំ | អក្ខីនិ, អក្ខី |
| ត. អក្ខិនា | អក្ខីហិ, អក្ខីភិ |
| ច. អក្ខិស្ស, អក្ខិនោ | អក្ខីនំ |
| បញ្ច. អក្ខិស្មា, អក្ខិម្හා, អក្ខិនា | អក្ខីហិ, អក្ខីភិ |
| ឆ. អក្ខិស្ស, អក្ខិនោ | អក្ខីនំ |
| ស. អក្ខិស្មឹ, អក្ខិម្හិ | អក្ខីសុ |
| អា. អក្ខិ | អក្ខីនិ, អក្ខី |

## រូបសិទ្ធិ មានមេសូត្រ

ត្រង់ ប. ពហុ. ទុ. ពហុ. អា. ពហុ. សម្រេចរូបដោយមេសូត្រ យោនន្និនបុំសកេហិ, យោសុកត ។ល។ សុទីឃំ,

ឥវណ្ណុវណ្ណាឈលា, យបតោចយោនំលោបោ, យោសុកត ។ល។ សុទីឃំ ។ ត្រង់ ទុ. ឯក. និងតាំងពីតតិយាដល់សត្តមី ទាំង ២ វចនៈ មានរូបសិទ្ធិដូចឥការន្តបុំលិង្គ ។

### រូបសិទ្ធិ ឥតមេសូត្រ

ត្រង់ ប. ពហុ. ទ. ពហុ. អា. ពហុ ផ្លាស់យោជានិហើយ ទីឃៈឥជាឦជាអគ្គីនិ, លុបយោចេញហើយទីឃៈឥជាឦជាអគ្គី ។ ក្រៅពីនោះមានរូបសិទ្ធិដូចឥការន្តបុំលិង្គ ។

### សព្ទជាឥការន្តនបុំសកលិង្គឈ្មោះជាដើម

### បំបែកដូច អគ្គិ

| | | | |
|---|---|---|---|
| អច្ចិ | អណ្តាតភ្លើង | ទធិ | ទឹកដោះជូរ |
| អដ្ឋិ | ឆ្អឹង | សប្បិ | ទឹកដោះថ្លា |

[៧៣] ឧការន្តនបុំសកលិង្គ បំបែកយ៉ាង វត្ថុ "វត្ថុ" ដូច្នេះ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. វត្ថុ | វត្ថូនិ, វត្ថូ |

| ឯកវចនៈ | | ពហុវចនៈ |
| --- | --- | --- |
| ទុ. | វត្ថុំ | វត្ថូនិ, វត្ថូ |
| ត. | វត្ថុនា | វត្ថូហិ, វត្ថូភិ |
| ច. | វត្ថុស្ស, វត្ថុនោ | វត្ថូនំ |
| បញ្ច. | វត្ថុស្មា, វត្ថុម្ហា, វត្ថុនា | វត្ថូហិ, វត្ថូភិ |
| ឆ. | វត្ថុស្ស, វត្ថុនោ | វត្ថូនំ |
| ស. | វត្ថុស្មឹ, វត្ថុម្ហិ | វត្ថូសុ |
| អា. | វត្ថុ | វត្ថូនិ, វត្ថូ |

រូបសិទ្ធិដូចគ្នានឹងឥការន្តនបុំសកលិង្គ ផ្សេងគ្នាតែការន្តមួយជា ឥ មួយជា ឧ ប៉ុណ្ណោះឯង ។

## សព្ទជាឧការន្តនបុំសកលិង្គប៉ុណ្ណោះជាដើម

## បំបែកដូច វត្ថុ

| | | | |
| --- | --- | --- | --- |
| អម្ពុ | ទឹក | ចក្ខុ | ភ្នែក |
| អស្សុ | ទឹកភ្នែក | ជតុ | ជ័រ, ល័ខ, អាចម៍ល័ខ |
| អាយុ | អាយុ | តិបុ | សំណ |

| | | | |
|---|---|---|---|
| ទារុ | ឈើ, ឧស | មស្សុ | ពុកចង្កា, ពុកមាត់ |
| ធនុ | ធ្នូ | វបុ | អត្តភាព, រាងកាយ |
| មធុ | ទឹកឃ្មុំ | សជ្ឈុ | ប្រាក់ |

## បកិណ្ណកសព្ទ

[៧៤] នាមសព្ទទាំងឡាយ ដែលបានសម្ដែងមកហើយក្នុងខាងដើមនោះ ជាសព្ទមានវិធីបំបែកផ្សំនឹងវិភត្តិត្រូវរបៀបគ្នាតាមគោលតាមដំណើររបស់ការន្ត ។ មាននាមសព្ទឯទៀតខ្លះដែលជាអការន្ត ឬ ឧការន្តជាដើមនោះដែរ ប៉ុន្តែមានវិធីបំបែកផ្សេង ៗ គ្នាខ្លះចំពោះដោយពួក ៗ គឺពួកនាមសព្ទដែលនឹងមានសម្ដែងតទៅនេះឯង ហៅថា "បកិណ្ណកសព្ទ" ប្រែថា "សព្ទរាត់រាយ" គឺសព្ទមានវិធីបំបែកផ្សំនឹងវិភត្តិផ្សេងគ្នាដោយឡែក ៗ មិនសូវសាធារណៈទូទៅដល់សព្ទឯទៀត ៗ ច្រើនឡើយ ។ បកិណ្ណកសព្ទនោះ, ក្នុងទីនេះនឹងលើកយកតែសព្ទ ១៣ មកសម្ដែងដោយសង្ខេប គឺ ព្រហ្ម, អត្ត, សខ, រាជ, ភគវន្តុ, អរហន្តុ, ភវន្តុ, សត្ថុ, បិតុ, មាតុ, មន, កម្ម, គោ ។

វិធីបំបែកបកិណ្ណកសព្ទ ដែលនឹងរៀបជារបៀបតទៅនេះ រៀបតាមលទ្ធិកច្ចាយនបករណ៍ដោយច្រើន ។ មានរបៀបបំបែកដោយអន្លើខ្លះ មិនសូវមានប្រើ[១] ក្នុងគម្ពីរទាំងពួងទេ តែបើទុកជាដូច្នោះ ក្នុងទីនេះក៏ត្រូវតែរៀបរៀងតាមលទ្ធិកច្ចាយនបករណ៍ ដើម្បីប្រយោជន៍ជាផ្លូវចម្រើនសេចក្ដីឆ្លៀវឆ្លាសដល់កុលបុត្រ អ្នកសិក្សា ។

[៧៥] ព្រហ្ម "ព្រហ្ម" អការន្តបុំលិង្គ បំបែកដូច្នេះ:

| | ឯកវចន | ពហុវចន |
|---|---|---|
| ប. | ព្រហ្មា | ព្រហ្មានោ |
| ទុ. | ព្រហ្មានំ, (ព្រហ្មំ) | ព្រហ្មានោ |
| ត. | ព្រហ្មុនា | ព្រហ្មេហិ, ព្រហ្មេភិ |
| ច. | ព្រហ្មុនោ (ព្រហ្មស្ស) | ព្រហ្មានំ |
| បញ្ច. | ព្រហ្មុនា | ព្រហ្មេហិ, ព្រហ្មេភិ |

១ ក្នុងរបៀបបំបែកសព្ទទាំងនោះ បទណាដែលមាននៅក្នុងសញ្ញា ( ) នេះ ដូចជា(ព្រហ្មំ), (អត្តំ) ជាដើមនោះ គឺសម្គាល់ឲ្យដឹងថាជាបទមិនសូវមានប្រើក្នុងគម្ពីរទាំងពួង ។

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ឆ. ព្រហ្មុនោ (ព្រហ្មស្ស) | ព្រហ្មានំ |
| ស. ព្រហ្មនិ | ព្រហ្មេសុ |
| អា. ព្រហ្មេ | ព្រហ្មានោ |

## រូបសិទ្ធិ មានមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ប. ស្យាច, សរលោបោ។ ល ។ តុបកតិ | យោនមានោ, សរលោបោ។ល។ តុបកតិ |
| ទុ. ព្រហ្មត្តសខរាជាទិតោអមានំ, សរលោបោ ។ ល ។ តុបកតិ | ដូច ប. ពហុ. |
| ត. ឧត្តំសនាសុ | សុហីស្វកាពាង, ស្មាហិស្មឹនម្ហាភិម្ហិវា |
| ច. ឧត្តំសនាសុ, ឥវណ្ណុ . . . , ឈលតោសស្សនោវា | សុនំហីសុច |
| បញ្ច. អម្ហតុម្ហន្តុ ។ល។ ស្មានាវ, ឧត្តំសនាសុ | ដូច ត. ពហុ. |
| ឆ. ដូច ច. ឯក. | ដូច ច. ពហុ. |
| ស. ព្រហ្មតោគុស្មឹនិ | សុហីស្វការោង |
| អា.អាលបនេសិ..., ព្រហ្មតោគស្យច | ដូច ប. ពហុ. |

-១២៦-

## រូបសិទ្ធិ ឥតមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. ផ្លាស់ សិ ជា អា ហើយលុប អ ចេញជា ព្រហ្មា | ផ្លាស់ យោ ជា អានោ ហើយ លុប អ ចេញជា ព្រហ្មានោ |
| ទុ. ផ្លាស់ំ ជាអានំហើយលុបអចេញ ជាព្រហ្មានំ, ព្រហ្មផ្សំនឹងំ ជា ព្រហ្មំ | ព្រហ្មានោ ដូច ប. ពហុ. |
| ត. ផ្លាស់អជាឧផ្សំនឹងនាជាព្រហ្មុនា | ផ្លាស់អជាឯ ផ្សំនឹងហិជា ព្រហ្មេហិ, ផ្លាស់ ហិ ជា ភិ ហើយផ្លាស់ អ ជា ឯ ផ្សំជា ព្រហ្មេភិ |
| ច. ផ្លាស់អ ជា ឧ ហើយផ្លាស់ស ជានោ ជាព្រហ្មុនោ, ចុះសអាគម ផ្សំនឹង ស វិភត្តិជា ព្រហ្មស្ស | ទីឃៈអជាអាផ្សំនឹង នំជាព្រហ្មានំ |
| បញ្ច. ផ្លាស់ អជាឧ ហើយផ្លាស់ ស្មា ជា នា ជា ព្រហ្មុនា | ព្រហ្មេហិ,ព្រហ្មេភិ ដូច ត. ពហុ. |
| ឆ.ព្រហ្មុនោ,ព្រហ្មស្ស ដូចច.ឯក. | ព្រហ្មានំ ដូច ច. ពហុ. |
| ស. ផ្លាស់ ស្មឹ ជា និ ជា ព្រហ្មនិ | ផ្លាស់អជាឯផ្សំនឹងសុជាព្រហ្មេសុ |
| អា. ផ្លាស់ សិ ជា ឯ ហើយលុប អចេញជា ព្រហ្មេ | ព្រហ្មានោ ដូច ប. ពហុ. |

[៧៦] អត្ត "ខ្លួន, អាត្មា, ចិត្ត" អការន្តបុំលិង្គ ។ ពហុវចនៈ មិនសូវមានប្រើ ដែលមានប្រើខ្លះតាមអំណាចមេសូត្រក្នុង

កច្ចាយនបករណ៍ ត្រង់ ប. ពហុ. ទុ. ពហុ. អា. ពហុ. ជា "អត្តានោ" សម្រេចរូបដោយមេសូត្រ យោនមានោ, សរលោបោអមាទេសបច្ចយា ។ ល ។ តុបកតិ គឺផ្លាស់យោជាអានោ ហើយលុបអចេញជាអត្តានោ ។ ត្រង់ ត. ពហុ. បញ្ច. ពហុ. ជា "អត្តនេហិ, អត្តនេភិ" សម្រេចរូបដោយមេសូត្រ អត្តន្តោ ហិស្មិមនត្តំ, សុហីស្វការោង គឺផ្លាស់អទីបំផុតនៃអត្តជាអន ហើយផ្លាស់អទីបំផុតនៃអនជាឯផ្សំនឹងហិជាអត្តនេហិ, ផ្លាស់ហិជាភិជាអត្តនេភិ ។

បែបបំបែក **អត្ត** ជាឯកវចនៈ ដូច្នេះ

| ឯកវចនៈ | | ឯកវចនៈ | |
|---|---|---|---|
| ប. | អត្តា | បញ្ច. | អត្តនា |
| ទុ. | អត្តានំ, (អត្តំ) | ឆ. | អត្តនោ |
| ត. | អត្តនា | ស. | អត្តនិ |
| ច. | អត្តនោ | អា. | អត្ត |

## រូបសិទ្ធិ មានមេសូត្រ

### ឯកវចនៈ

ប. ស្បាច, សរលោបោ ។ ល ។ តុបកតិ

ទុ. ព្រហ្មត្ត ។ល។ អមានំ, សរលោបោ ។ល។ តុបកតិ

ត. គ្រាន់តែចុះនាវិភត្តិស្រេច

ប៊. សស្សនោ

### ឯកវចនៈ

បញ្ច. ស្មានា

ឆ. ដូច ច. ឯក.

ស. តតោស្មឹនិ

អា. អាលបនេ..., សេសតោលោបំគសិបិ

## រូបសិទ្ធិ ឥតមេសូត្រ

### ឯកវចនៈ

ប. ផ្លាស់ សិ ជា អា ហើយលុប អ ចេញជា អត្តា

ទ. ផ្លាស់ ំ ជាអានំហើយលុប អ ចេញជាអត្តានំ, អត្តផ្សំនឹង ំ អត្តំ

ត. អត្ត ផ្សំនឹង នា ជា អត្តនា

ប៊. ផ្លាស់ ស ជា នោ ជា អត្តនោ

### ឯកវចនៈ

បញ្ច. ផ្លាស់ស្មាជានាជាអត្តនា

ឆ. អត្តនោ ដូច ច. ឯក.

ស. ផ្លាស់ស្មឹជានិជាអត្តនិ

អា. គ្រាន់តែលុប សិ ចេញគង់រូបនៅជាអត្តដូចដែល

[៧៧] សខ "សំឡាញ់" ជាទិ្វលិង្គកៈ គឺបុំ. និងឥ. ។ បុំលិង្គ បំបែកដូច្នេះ:

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. សខា | សខានោ, (សខាយោ, សខិនោ) |
| ទុ. សខានំ, សខារំ, (សខំ) | សខានេ, (សខាយោ), សខិនោ) |
| ត. សខិនា | សខារេហិ, (សខេហិ) |
| ច. សខិស្ស, សខិនោ | សខារានំ, (សខីនំ) |
| បញ្ច. សខិនា | សខារេហិ, (សខេហិ) |
| ឆ. សខិស្ស, សខិនោ | សខារានំ, (សខីនំ) |
| ស. សខេ | សខារេសុ (សខេសុ) |
| អា. សខ,(សខា,សខិ,សខី,សខេ) | សខានោ, (សខាយោ, សខិនោ) |

## រូបសិទ្ធិ មានមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. ស្យាទ. សរលោបោ ។ ល ។ តុបកតិ | យោនមានោ,សរលោបោ។ល។ តុបកតិ សខតោបាយោនោ, សខាន្តស្សិនោនានំសេសុ |
| ទុ. ព្រហ្មត្តសខ។ល។អមានំ,សរលោបោ ។ល។ តុបកតិ, សុនមំសុវា,សរលោបោ ។ល។ តុបកតិ | ដូច ប. ពហុ. |

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ត. សខាន្តស្សិនោនាន់សេសុ | អាពោហិម្ហិវា, សុហីស្វកាពេង |
| ច. សខាន្តស្សិនោនាន់សេសុ, សា-គមោសេ, សខាន្តស្សិនោ ... , ឈលតោសស្សនោវា | សុនមំសុវា,សុនំហីសុច,សខាន្ត-ស្សិនោនាន់សេសុ, សុនំហីសុច |
| បញ្ច. អម្ហតុម្ហន្តុ ។ល។ ស្មានាវ, សខាន្តស្សិនោ... | ដូច ត. ពហុ. |
| ឆ. ដូច ច. ឯក. | ដូច ច. ពហុ. |
| ស. ស្មិមេ | សុនមំសុវា, សុហីស្វកាពេង |
| អា. អាលបនេសិ...,សខតោតស្សេវា | ដូច ប. ពហុ. |

## រូបសិទ្ធិ ឥតមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. ផ្លាស់ សិ ជា អា ហើយលុប អ ចេញជា សខា | ផ្លាស់យោជា អានោ, ជាអាយោ, ជា នោ ហើយលុប អ ចេញជា សខានោ, ជាសខាយោ, ផ្លាស់អ ជា ឥ ផ្សំនឹង នោ ជា សខិនោ |
| ទុ. ផ្លាស់ ំ ជា អានំ ហើយ លុប អ ចេញជា សខានំ, ផ្លាស់ អ ជា អារ ផ្សំនឹង ំ ជា សខារំ, សខផ្សំនឹង ំ ជា សខំ | សខានោ, សខាយោ, សខិនោ ដូច ប. ពហុ. |

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ត. ផ្លាស់អជាឥផ្សំនឹងនាជាសខិនា | ផ្លាស់ អ ជា អារ ហើយផ្លាស់ អ របស់រជាឯផ្សំនឹងហិ ជាសខារេហិ ផ្លាស់អជាឯផ្សំនឹង ហិជាសខេហិ |
| ប. ផ្លាស់ អជាឥ ហើយចុះសអាគម ផ្សំនឹងសវិភត្តិជាសខិស្ស, ផ្លាស់សជា នោ ជា សខិនោ | ផ្លាស់អជាអារហើយទីឃៈអរបស់ រ ជា អា ផ្សំនឹង នំ ជា សខារានំ, ផ្លាស់ អ ជា ឥ ហើយទីឃៈ ឥ ជា ឦផ្សំនឹងនំជាសខីនំ |
| បញ្ច. ផ្លាស់ ស្មា ជា នា ហើយ ផ្លាស់ អ ជា ឥ ជា សខិនា | សខារេហិ, សខេហិ ដូច ត.ពហុ. |
| ឆ. សខិស្ស,សខិនោ ដូច ច.ឯក. | សខារានំ, សខីនំ ដូច ច. ពហុ. |
| ស.ផ្លាស់ ស្មឹ ជា ឯ ហើយលុប អ ចេញជា សខេ | ផ្លាស់ អ ជា អារ ហើយផ្លាស់ អ របស់រជាឯផ្សំនឹងសុជាសខារេសុ, ផ្លាស់អជាឯផ្សំនឹងសុជាសខេសុ |
| អា.ផ្លាស់ សិជាអ,ជាអា,ជាឥ,ជាឦ,ជាឯ ហើយលុបអចេញជា, សខ, សខា, សខិ, សខី, សខេ | សខានោ, សខាយោ, សខិនោ ដូច ប. ពហុ. |

ឥត្ថីលិង្គ ចុះឦបច្ច័យ ជា សខី "ស្ត្រីជាសំឡាញ់" មានវិធីបំបែកផ្សំនឹងវិភត្តិដូច "នារី" តាមរបៀបឦការន្តឥត្ថីលិង្គក្នុង

ខាងដើម ត្រង់លេខ ៦៨ ។ (សខសព្ទនេះ ពិតជាមានវិធីបំបែកច្រើនន័យដូច្នេះមែន ប៉ុន្តែមិនសូវមានប្រើតាមរបៀបដែលបំបែកនោះទេ)

[៧៨] រាជ "ស្តេច" ជាទ្វិលិង្គិកៈ គឺ បុំ. និង ឥ. ។ បុំលិង្គបំបែកដូច្នេះ:

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | រាជា | រាជានោ |
| ទុ. | រាជានំ | រាជានោ |
| ត. | រញ្ញា | រាជូហិ, រាជូភិ |
| ច. | រញ្ញោ (រាជិនោ, រាជស្ស) | (រញ្ញំ) រាជូនំ |
| បញ្ច. | រញ្ញា | រាជូហិ, រាជូភិ |
| ឆ. | រញ្ញោ (រាជិនោ, រាជស្ស) | (រញ្ញំ) រាជូនំ |
| ស. | រញ្ញេ, រាជិនិ | រាជូសុ |
| អា. | រាជ | រាជានោ |

## រូបសិទ្ធិ មានមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. ស្យាច, សរលោបោ ។ល។ តុបកតិ | យោនមានោ,សរលោបោ ។ល។ តុបកតិ |
| ទុ. ព្រហ្មត្តសខ ។ល។ អមានំ, សរលោ ។ល។ តុបកតិ | ដូច ប. ពហុ. |
| ត. នាម្ហិរញ្ញាវា | រាជស្ស រាជូសុនំហីសច. ស្មាហិ-សឹនម្ហាភិម្ហិវា |
| ច. រាជស្សរញ្ញោរាជិនោសេ,សា-គមោសេ | រញ្ញំនម្ហិវា, រាជស្ស រាជូសុនំហី-សុច |
| បញ្ច. អម្ហតុម្ហន្ត ។ល។ ស្មានាវ, នាម្ហិរញ្ញាវា | ដូច ត. ពហុ. |
| ឆ. ដូច ច. ឯក. | ដូច ច. ពហុ. |
| ស. ស្មិម្ហិរញ្ញេរាជិនិ | រាជស្ស រាជូសុនំហីសុច |
| អា. អាលបនេសិ ..., សេសតោ-លោបំគសិបិ | ដូច ប. ពហុ. |

## រូបសិទ្ធិ ឥតមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. ផ្លាស់ សិ ជា អា ហើយលុប អ ចេញជា រាជា | ផ្លាស់ យោ ជា អានោ ហើយ លុប អ ចេញជា រាជានោ |
| ទុ. ផ្លាស់ º ជា អានំ ហើយលុប អ ចេញជា រាជានំ | រាជានោ ដូច ប. ពហុ. |

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ត. ផ្លាស់ រាជ និង នាជា រញ្ញោ | ផ្លាស់ រាជ ជា រាជូ ផ្សំនឹង ហិ ជា រាជូហិ, ផ្លាស់ ហិ ជា ភិ ជា រាជូភិ |
| ច. ផ្លាស់ រាជ និង ស ជា រញ្ញោ, ជា រាជិនោ ចុះសអាគម ផ្សំនឹងសវិភត្តិ ជា រាជស្ស | ផ្លាស់ រាជ និង នំ ជា រញ្ញំ, ផ្លាស់ រាជ ជា រាជូ ផ្សំនឹង នំ ជា រាជូនំ |
| បញ្ច. ផ្លាស់ ស្មា ជា នា ហើយ ផ្លាស់ រាជ និង នា ជា រញ្ញោ | រាជូហិ, រាជូភិ ដូច ត. ពហុ. |
| ឆ.រញ្ញោ,រាជិនោ,រាជស្សដូច ច.ឯក. | រញ្ញំ, រាជូនំ ដូច ច. ពហុ. |
| ស.ផ្លាស់ រាជ និង ស្មឹ ជា រញ្ញេ, ជា រាជិនិ | ផ្លាស់ រាជ ជា រាជូ ផ្សំនឹងសុ ជា រាជូសុ |
| អា.គ្រាន់តែលុប សិ ចេញគង់រូបនៅជា រាជ ដូចដែល | រាជានោ ដូច ប. ពហុ. |

ឥត្ថីលិង្គ ចុះឥនីបច្ច័យ ជា រាជិនី "ស្តេចស្រី" មានវិធីបំបែកផ្សំនឹងវិភត្តិដូច"នារី"(មើលក្នុងខាងដើមត្រង់លេខ ៦៨)។

[៧៩] សព្ទជាបទសមាសដែលមានរាជសព្ទនៅខាងចុងបំផុតដូច មហារាជ "ស្តេចជាធំ, ស្តេចប្រសើរ" ជាដើមបំបែកដូច្នេះ :

| ឯកវចនៈ | | ពហុវចនៈ |
| --- | --- | --- |
| ប. | មហារាជា | មហារាជានោ |
| ទុ. | មហារាជំ | មហារាជេ |

| ឯកវចន | | ពហុវចន |
|---|---|---|
| ត. | មហារាជេន | មហារាជេហិ, មហារាជេភិ |
| ប. | មហារាជស្ស, មហារាជាយ, មហារាជត្ថំ | មហារាជានំ |
| បញ្ច. | មហារាជស្មា, មហារាជម្ហា, មហារាជា | មហារាជេហិ, មហារាជេភិ |
| ឆ. | មហារាជស្ស | មហារាជានំ |
| ស. | មហារាជស្មឹ, មហារាជម្ហិ, មហារាជេ | មហារាជេសុ |
| អា. | មហារាជ | មហារាជានោ |

សព្ទប៉ុន្មានជាដើម បំបែកដូច មហារាជ

| | |
|---|---|
| អគ្គរាជ ស្តេចប្រសើរ | ទេវរាជ ទេវតាជាស្តេច,ស្តេចនៃទេវតា |
| អនុរាជ ស្តេចតូច | នាគរាជ នាគជាស្តេច,ស្តេចនៃនាគ |
| អភិរាជ ស្តេចក្រៃលែង | មិគរាជ ម្រឹគជាស្តេច,ស្តេចនៃម្រឹគ |
| ឧបរាជ ឧបរាជ (ស្តេចបន្ទាប់រាជ្យ) | សុបណ្ណរាជ គ្រុឌជាស្តេច,ស្តេចនៃគ្រុឌ |
| ចក្កវត្តិរាជ ស្តេចចក្រពត្តិ | ហំសរាជ ហង្សជាស្តេច,ស្តេចនៃហង្ស |

រូបសិទ្ធិ ត្រង់បឋមាព្រមទាំងអាលបនៈទាំង២វចនៈដូចរាជសព្ទ ។ តាំងពីទុតិយាដល់សត្តមីទាំង ២ វចនៈ ដូចបុរិសសព្ទ ។

[៨០] ភគវន្តុ "ព្រះមានព្រះភាគ, ព្រះមានជោគ" ឧការន្ត បុំលិង្គ បំបែកដូច្នេះ:

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ប. ភគវា | ភគវន្តា, ភគវន្តោ |
| ទុ. ភគវន្តំ | ភគវន្តេ, ភគវន្តោ |
| ត. ភគវតា, (ភគវន្តេន) | ភគវន្តេហិ, ភគវន្តេភិ |
| ច. ភគវតោ, (ភគវន្តស្ស) | ភគវតំ, ភគវន្តានំ |
| បញ្ច. ភគវតា | ភគវន្តេហិ, ភគវន្តេភិ |
| ឆ. ភគវតោ (ភគវន្តស្ស) | ភគវតំ, ភគវន្តានំ |
| ស. ភគវតិ, ភគវន្តេ, (ភគវន្តស្មឹ, ភគវន្តម្ហិ) | ភគវន្តេសុ |
| អា. ភគវ, ភគវា | ភគវន្តា, ភគវន្តោ |

រូបសិទ្ធិ មានមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ប. អាសិម្ហិ | ន្តុស្សន្តោយោសុច, សព្វយោនីនមាង, ន្តុស្សន្តោ |
| ទុ. ន្តុស្សន្តោយោសុច..., | ន្តុស្សន្តោយោសុច, សព្វយោនីនមាង, តតោយោនមោតុ |

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ត. តោតិតាសស្មឹនាសុ, ន្តុស្ស-ន្តោយោសុច, អតោនេន | ន្តុស្សន្តោយោសុច, សុហីស្វកា-រោង,ស្មាហិស្មឹនម្ហាភិម្ហិវា |
| ច. តោតិតាសស្មឹនាសុ,ន្តុស្សសេវា | នម្ហិតំវា, ន្តុស្សន្តោយោសុច, សុ-នំហីសុច |
| បញ្ច. អម្ហ ។ ល ។ ស្មានាវ, តោតិតាសស្មឹនាសុ | ដូច ត. ពហុ. |
| ឆ. ដូច ច. ឯក. | ដូច ច. ពហុ. |
| ស.តោតិតាសស្មឹនាសុ, ន្តុស្ស-ន្តោយោសុច, ស្មាស្មឹនំវា, ន្តុស្ស-ន្តោយោសុច,ស្មាហិស្មឹនម្ហាភិម្ហិវា | ន្តុស្សន្តោយោសុច, សុហីស្វ-ការោង |
| អា. អាលបនេសិគសញ្ញោ អវ-ណ្ណាចគេ, អាសិម្ហិ | ដូច ប. ពហុ. |

## រូបសិទ្ធិ ឥតមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. ផ្លាស់ន្តុនិងសិជាអាជាភគវា | ផ្លាស់ឧរបស់ន្តុ ជាអ ហើយផ្លាស់ យោ ជា អា ហើយលុប អ ចេញ ជា ភគវន្តា ផ្លាស់ ន្តុ និង យោ ជា ន្តោ ជា ភគវន្តោ |
| ទុ. ផ្លាស់ ឧ របស់ ន្តុ ជា អ ផ្សំ នឹង ° ជាភគវន្តំ | ផ្លាស់ឧរបស់ន្តុជាអ ហើយផ្លាស់ យោ ជា ឯ ហើយលុប អ ចេញ ជាភគវន្តេ, ផ្លាស់ ឧ របស់ ន្តុ ជា អ ហើយផ្លាស់ យោ ជា ឱ ហើយលុប អ ចេញ ជា ភគវន្តោ |

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ត. ផ្លាស់ ន្តុនិងនា ជាតាជាភគវតា,ផ្លាស់ ឧ របស់ ន្តុ ជា អ ហើយផ្លាស់ នា ជា ឯនហើយ លុប អ ចេញ ជា ភគវន្តេន | ផ្លាស់ឧរបស់ន្តុជាអ ហើយផ្លាស់ អជាឯ ផ្សំនឹង ហិ ជា ភគវន្តេហិ, ផ្លាស់ហិជាភិជាភគវន្តេភិ |
| ច. ផ្លាស់ ន្តុ និង ស ជា តោ ជា ភគវតោ, ផ្លាស់ ន្តុ និង ស ជា ន្តស្ស ជា ភគវន្តស្ស | ផ្លាស់ ន្តុ និង នំ ជា តំ ជា ភគវតំ, ផ្លាស់ ឧ របស់ ន្តុ ជា អ ហើយ ទីឃៈអជាអាផ្សំនឹងនំជាភគវន្តានំ |
| បញ្ច. ផ្លាស់ ន្តុ និង ស្មា ជា តា ជា ភគវតា | ភគវន្តេហិ, ភគវន្តេភិ ដូច ត. ពហុ. |
| ឆ.ភគវតោ, ភគវន្តស្សដូច ច. ឯក. | ភគវតំ, ភគវន្តានំ ដូច ច. ពហុ. |
| ស. ផ្លាស់ន្តុនិងស្មឹំជាតិជាភគវតិ, ផ្លាស់ឧរបស់ន្តុជាអ ហើយផ្លាស់ស្មឹំជាឯហើយលុបអចេញជាភគវន្តេ, ផ្លាស់ ឧ របស់ ន្តុ ជា អ ផ្សំនឹង ស្មឹំ ជា ភគវន្តស្មឹំ, ផ្លាស់ ស្មឹំ ជាម្ហិជាភគវន្តម្ហិ | ផ្លាស់ ឧ របស់ ន្តុ ជា អ ហើយ ផ្លាស់ អ ជា ឯ ផ្សំ នឹង សុ ជា ភគវន្តេសុ |
| អា. ផ្លាស់ន្តុនិងសិ ជា អជាភគវ, ភគវា ដូច ប. ឯក. | ភគវន្តា, ភគវន្តោ ដូច ប. ពហុ. |

## សព្ទជាឧការន្តប៉ុណ្ណោះជាដើម បំបែកដូច ភគវន្តុ

| | |
| --- | --- |
| គុណវន្តុ ជនមានគុណ | ជុតិមន្តុ ជនមានសេចក្តីរុងរឿង |
| ចក្ខុមន្តុ ជនមានចក្ខុ | ធនវន្តុ ជនមានទ្រព្យ |

| | |
|---|---|
| ធិតិមន្តុ ជនមានប្រាជ្ញាខ្ជាប់ខ្ជួន | យសវន្តុ ជនមានយស |
| បញ្ញវន្តុ ជនមានប្រាជ្ញា | សតិមន្តុ ជនមានស្មារតី |
| បុញ្ញវន្តុ ជនមានបុណ្យ | សិរីមន្តុ ជនមានសិរី |
| ពន្ធុមន្តុ ជនមានផៅពង្ស | សីលវន្តុ ជនមានសីល |
| មតិមន្តុជនមានគំនិត,ជនមានប្រាជ្ញា | ហិរិមន្តុ ជនមានសេចក្តីខ្មាស |

វន្តុ និង មន្តុ នេះជាតួបច្ច័យក្នុងតទ្ធិត បច្ច័យទាំងពីរនេះមានរបៀបប្រើក្នុងទីផ្សេងគ្នា គឺ វន្តុ សម្រាប់ប្រើផ្សំនឹងសព្ទដែលជាអការន្ត ឬ អាការន្ត ដូចជា គុណវន្តុ, ធនវន្តុ, បញ្ញវន្តុ, បុញ្ញវន្តុ, ភគវន្តុ, យសវន្តុ, សីលវន្តុ ជាដើម ។ មន្តុ សម្រាប់ប្រើផ្សំនឹងសព្ទដែលជាការន្តផ្សេង ដូចយ៉ាង ឥការន្ត ឬ ឧការន្ត ដូចជា ជុតិមន្តុ, ធិតិមន្តុ, មតិមន្តុ, សតិមន្តុ, អាយស្មន្តុ[១] ចក្ខុ-មន្តុ, ពន្ធុមន្តុ ជាដើម ។

---

១ អាយុ+មន្តុ, ផ្លាស់ ឧ របស់ យុ ជា អស ហើយផ្សំ ស និង ម របស់ មន្តុជា ស្ម ជា អាយស្មន្តុ "ជនអ្នកមានអាយុ" ។ សព្ទនេះជា គុណនាមពិត ប៉ុន្តែជួនណាប្រើស្រដៀងគ្នានឹងតុម្ហសព្ទក៏មាន ដូច ជា "សមតាយស្មា សង្ឃេន សទ្ធឹ លោកអ្នកមានអាយុចូរព្រមព្រៀង គ្នា ជាមួយនឹងសង្ឃ ។ តត្ថាយស្មន្តេ បុច្ឆាមិ ខ្ញុំ (សូម, សួរ នូវលោក អ្នកមានអាយុទាំងឡាយក្នុងដំណើរនោះ) ។

ភគវន្តុសព្ទនេះជាគុណនាមពិត គួរតែនឹងបំបែកផ្សំនឹងវិភត្តិបានទាំង ៣ លិង្គតាមលំនាំគុណនាម តែអាស្រ័យហេតុដែលលោកប្រើចំពោះតែត្រង់បុំលិង្គម្យ៉ាង ទើបសង្គ្រោះរាប់បញ្ចូលជាបុំលិង្គដោយដាច់ខាតទៅវិញ ។ ឯសព្ទឯទៀតក្នុងពួកនេះ មានគុណវន្តុជាដើមនោះក៏សុទ្ធតែជាគុណនាម បំបែកផ្សំនឹងវិភត្តិបានទាំង ៣ លិង្គ ។ ក្នុងបុំលិង្គ បំបែកដូច ភគវន្តុ ។ ក្នុងឥត្ថីលិង្គចុះឦបច្ច័យ ជា គុណវតី ឬ គុណវន្តី បំបែកផ្សំនឹងវិភត្តិតាមលំនាំឦការន្តឥត្ថីលិង្គ ដូច នារី ។ សម្រេចរូបដោយមេសូត្រ ន្តុស្សតមីការេ, នទាទិតោវាឦ (ផ្លាស់ ន្តុ ជា ត ហើយចុះឦបច្ច័យ) ជា គុណវតី, សម្រេចរូបដោយមេសូត្រ ន្តុស្សន្តោយោសុច, នទាទិតោវាឦ (ផ្លាស់ ឧ របស់ ន្តុ ជា អ ហើយចុះឦបច្ច័យហើយលុប អ ចេញ) ជា គុណវន្តី ។ ក្នុងនបុំសកលិង្គត្រង់ ប. ឯក. ជា គុណវំ, គុណវន្តំ, សម្រេចរូបដោយមេសូត្រ អន្ទបុំសកេ (ផ្លាស់ ន្តុ និង សិ ជា អំ) ជា គុណវំ, សម្រេចរូបដោយមេសូត្រ ន្តុស្សន្តោយោសុច, សិ (ផ្លាស់ ឧ របស់ ន្តុ ជា អ ហើយផ្លាស់ សិ ជា អំ) ជា គុណវន្តំ ។ ត្រង់ ប. ទុ. អា.

ពហុ. សម្រេចរូបដោយមេសូត្រ ន្តុស្សន្តោយោសុច. យោ-
នន្និនបុំសកេហិ, យោសុកតនិការលោបេសុទីឃំ (ផ្លាស់ ន្ត របស់ ន្តុ ជា អ ហើយផ្លាស់ យោ ជា និ ហើយទីឃៈ អ ជា អា) ជា គុណវន្តានិ ។ ក្រៅអំពីនោះដូច ភគវន្តុ ។

សព្ទដែលចុះឥមន្តុបច្ច័យក្នុងតទ្ធិត ដូច បុត្តិមន្តុ "ជនមានបុត្រ" ជាដើមនោះក្តី, សព្ទដែលចុះតវន្តុបច្ច័យក្នុងក្រិត ដូច សុតវន្តុ "ជនអ្នកស្តាប់" ជាដើមនោះក្តី មានវិធីបំបែកផ្សំនឹងវិភត្តិនាម ដូច ភគវន្តុ ដែរ ។ (មើលតទ្ធិតនិទ្ទេសត្រង់លេខ ១៥០ និងកិតកនិទ្ទេសត្រង់លេខ ១៧៩) ។

[៨១] អរហន្ត "ព្រះអរហន្ត" ជាទ្វិលិង្គិកៈ គឺបុំលិង្គនិង ឥត្ថីលិង្គ ។ ក្នុងបុំលិង្គ ត្រង់ ប. ឯក. ជា អរហា, អរហំ ។ សម្រេចរូបដោយមេសូត្រ សេសេសុន្តុវ, អាសិម្ហិ (ផ្លាស់ន្តនិងសិ ជា អា) ជាអរហា, សម្រេចរូបដោយមេសូត្រ យទនុបបន្នា-និបាតនាសិជ្ឈន្តិ (សូត្រតទ្ធិត) ឬមេសូត្រ បច្ចយាទនិដ្ឋានិបាត-នាសិជ្ឈន្តិ (សូត្រក្រិត) ក៏បាន (ផ្លាស់ន្តនិងសិជាអំ) ជា អរហំ ។ ក្រៅពីនោះដូចភគវន្តុ តែត្រង់ណាដែលគួរប្រើមេសូត្រ សេសេ-

សុន្ទរ ក៏ត្រូវប្រើសូត្រនោះផង ។ ក្នុងឥត្ថីលិង្គចុះឦបច្ច័យ ជា អរហន្តី វិធីបំបែកផ្សំនឹងវិភត្តិដូច នារី ។

សព្ទជាគុណនាមឯទៀតដែលមាន ន្ត ជាទីបំផុត ដូចយ៉ាង មហន្ត ជាដើម មានវិធីបំបែកដូច អរហន្ត ខ្លះក៏មានដោយអន្លើ ដូចត្រង់ ត. ឯក មហតា ភិក្ខុសង្ឃេន ជាដើម ។

[៨២] ភវន្ត "អ្នកដ៏ចម្រើន" ជាទ្វិលិង្គិកៈ គឺ បុំលិង្គនិងឥត្ថីលិង្គ ។ ក្នុងបុំលិង្គបំបែកដូច្នេះ:

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. ភវំ | ភវន្តា, ភវន្តោ |
| ទុ. ភវន្តំ | ភវន្តេ, ភវន្តោ |
| ត. ភវតា, ភោតា, (ភវន្តេន) | ភវន្តេហិ, ភវន្តេភិ |
| ច. ភវតោ, ភោតោ, (ភវន្តស្ស) | ភវតំ, ភវន្តានំ |
| បញ្ច.ភវតា, ភោតា (ភវន្តស្មា, ភវន្តម្ហា) | ភវន្តេហិ, ភវន្តេភិ |
| ឆ. ភវតោ ភោតោ (ភវន្តស្ស) | ភវតំ, ភវន្តានំ |
| ស. ភវន្តេ, ភវន្តស្មឹ, (ភវន្តម្ហិ) | ភវន្តេសុ |
| អា. ភោ | ភវន្តា, ភវន្តោ, ភោន្តា, ភោន្តោ |

# រូបសិទ្ធិ មានមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. សិទ្ធិគច្ឆន្តាទីនន្តសទ្ទោអំ | សព្វយោនីនមាង, សេសេសុ-ន្តុវ, ន្តុស្ស្រន្តោ |
| ទុ. សរលោបោអមាទេសបច្ច-យាទិម្ហិ ។ល។ តុបកតិ | សព្វយោនីនមាង, តតោយោ-នមោតុ |
| ត. សេសេសុន្តុវ, តោតិតាសស្មឹ-នាសុ, ភោគេតុ, អតោនេន | ស្មាហិស្មឹនម្ហាភិម្ហិវា, សុហីស្វ-ការេង |
| ច. សេសេសុន្តុវ, តោតិតាសស្មឹ-នាសុ, ភោគេតុ, សេសេ-សុន្តុវ, ន្តុស្សសេវា | សេសេសុន្តុវ, នម្ហិតំវា, សុនំ-ហីសុច |
| បញ្ច. សេសេសុន្តុវ, អម្ហតុម្ហ ។ល។ នាវ, តោតិតាសស្មឹនាសុ ភោគេតុ,ស្មាហិស្មឹនម្ហាភិម្ហិវា | ដូច. ត. ពហុ. |
| ឆ. ដូច ច. ឯក. | ដូច. ច. ពហុ. |
| ស.ស្មាស្មឹនំវា,ស្មាហិស្មឹនម្ហាភិម្ហិវា | សុហីស្វការេង |
| អា. អាលបនេសិគសញ្ញោ, ភោ-គេតុ, សេសតោលោបំគសិបិ | ភវន្តា, ភវន្តោ ដូច ប. ពហុ. ឱកាពេក្ខចិយោសុវការស្ស, ស-ព្វយោនីនមាង, ភោគេតុ |

# រូបសិទ្ធិ ឥតមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. ផ្លាស់ ន្ត និង សិ ជា ំ ជាភវំ | ផ្លាស់ យោ ជា អា ហើយលុប អ ចេញជា ភវន្តា, ផ្លាស់ន្តនិងយោ ជា ន្តោ ជា ភវន្តោ |
| ទុ. ភវន្តផ្សំនឹង ំ ជាភវន្តំ | ផ្លាស់ យោ ជា ឯ ហើយលុប អ ចេញជា ភវន្តេ, ផ្លាស់ យោ ជា ឱ ហើយលុប អ ចេញជា ភវន្តោ |
| ត.ផ្លាស់ ន្ត និង នាជាតាជាភវតា, ផ្លាស់ ភវន្ត និង នា ជា ភោតា, ផ្លាស់ នា ជា ឯន ហើយលុប អ ចេញ ជា ភវន្តេន | ផ្លាស់ អ ជា ឯ ផ្សំនឹង ហិ ជា ភវន្តេហិ, ផ្លាស់ ហិ ជា ភិ ជា ភវន្តេភិ |
| ច. ផ្លាស់ន្ត និង ស ជា តោជាភវ-តោ, ផ្លាស់ភវន្តនិងសជាភោតោ, ផ្លាស់ន្តនិងសជាន្តស្សជាភវន្តស្ស | ផ្លាស់ ន្ត និង នំ ជា តំ ជា ភវតំ, ទីឃៈ អ ជា អា ផ្សំ នឹង នំ ជា ភវន្តានំ |
| បញ្ច. ផ្លាស់ន្តនិងស្មាជាតាជាភវតា, ផ្លាស់ ភវន្ត និងស្មា ជាភោតា ភវន្ត ផ្សំនឹង ស្មា ជា ភវន្តស្មា, ផ្លាស់ ស្មា ជា ម្ហា ជា ភវន្តម្ហា | ភវន្តេហិ, ភវន្តេភិ ដូច ត. ពហុ. |
| ឆ.ភវតោ, ភោតោ, ភវន្តស្ស ដូច ច. ឯក. | ភវតំ, ភវន្តានំ ដូច ច. ពហុ |
| ស. ផ្លាស់ ស្មឹជាឯ ហើយលុប អ ចេញជាភវន្តេ, ភវន្តផ្សំនឹងស្មឹជា ភវន្តស្មឹ, ផ្លាស់ស្មឹជាម្హិជាភវន្តម្ហិ | ផ្លាស់ អ ជា ឯ ផ្សំនឹង សុ ជា ភវន្តេសុ |
| អា. ផ្លាស់ ភវន្ត ជា ភោ ហើយ លុប សិ ចេញ | ភវន្តា, ភវន្តោ ដូច ប. ពហុ.ផ្លាស់វ របស់ ភវន្ត ជា ឱ ហើយផ្លាស់ យោ ជា អា ជា ភោន្តា, ផ្លាស់ភវន្ត និង យោ ជា ភោន្តោ, |

ឥត្ថីលិង្គ ចុះល្បៀបច្ច័យហើយផ្លាស់ការន្តជាភោត (ដោយមេសូត្រ ភវតោភោតោ) កើតបានរូបជា ភោតី វិធីបំបែកផ្សំនឹងវិភត្តិដូច នារី ។

[៨៣] សត្ថុ "សាស្តា, គ្រូ" ឧការន្តបុំលិង្គ បំបែកដូច្នេះ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. សត្ថា | សត្ថារោ |
| ទុ. សត្ថារំ | សត្ថារោ |
| ត. សត្ថារា, សត្ថុនា | សត្ថារេហិ, សត្ថារេភិ |
| ច. សត្ថុ, សត្ថុនោ (សត្ថុស្ស) | សត្ថារានំ (សត្ថានំ, សត្ថូនំ) |
| បញ្ច. សត្ថារា | សត្ថារេហិ, សត្ថារេភិ |
| ឆ. សត្ថុ, សត្ថុនោ (សត្ថុស្ស) | សត្ថារានំ (សត្ថានំ, សត្ថូនំ) |
| ស. សត្ថរិ | សត្ថារេសុ |
| អា. សត្ថា (សត្ថ) | សត្ថារោ |

រូបសិទ្ធិ មានមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. សត្ថុបិតាទីនមាសិស្មឹសិលោបោច | អញ្ញេស្វារត្ត, តតោយោនមោតុ |
| ទុ. អញ្ញេស្វារត្តំ | ដូច ប. ពហុ. |

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ត. អញ្ញេស្វារត្តំ, នាអា | អញ្ញេស្វារត្តំ, សុហីស្វកាពេង, ស្មាហិស្មឹនម្ហាភិម្ហិវា |
| ច. ឧសស្មឹសលោបោច, ឥវណ្ណុ-វណ្ណាឈលា, ឈលតោស-ស្សនោវា, សាគមោសេ | វានម្ហិ, សុនំហីសុច, សត្ថុនា-ត្តញ្ច, សុនំហីសុច |
| បញ្ច.អញ្ញេស្វារត្តំ, អម្ហ ។ ល ។ ស្មានាវ, នាអា | ដូច ត. ពហុ. |
| ឆ. ដូច ច. ឯក. | ដូច ច. ពហុ. |
| ស.អញ្ញេស្វារត្តំ, តតោស្មិមិ, អា-ពេរស្សមិការេ | អញ្ញេស្វារត្តំ. សុហីស្វកាពេង |
| អា. អាលបនេសិគសញ្ញោ, សត្ថុ-បិតាទីនមាសិស្មឹសិលោបោច,អា-លបនេ ។បេ។ អាកាពេវា | ដូច ប. ពហុ. |

## រូបសិទ្ធិ ឥតមេស្ស៊ូត្រ

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ប. ផ្លាស់ ឧ របស់ សត្ថុ ជា អា ហើយលុប សិ ចេញ ជា សត្ថា | ផ្លាស់ ឧ របស់ សត្ថុ ជា អារ ហើយផ្លាស់យោជាឱជាសត្ថារោ |

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ទុ.ផ្លាស់ ឧ របស់ សត្ថុជាអារផ្សំនឹងᐤ ជា សត្ថារំ | សត្ថារោ ដូច ប. ពហុ. |
| តិ.ផ្លាស់ ឧ របស់ សត្ថុ ជា អារ ហើយផ្លាស់នាជាអាជាសត្ថារា | ផ្លាស់ ឧរបស់សត្ថុ ជាអារ ហើយផ្លាស់អរបស់រជាឯផ្សំនឹងហិជាស-ត្ថារេហិ,ផ្លាស់ហិជាភិជាសត្ថារេភិ |
| ច.ផ្លាស់ឧរបស់សត្ថុជាឧហើយលុប សវិភត្តិចេញ គង់រូបនៅជាសត្ថុ ដូចដែល, ផ្លាស់ ស ជា នោជា សត្ថុនោ ចុះ សអា-គមផ្សំនឹង សវិភត្តិ ជា សត្ថុស្ស | ផ្លាស់ ឧរបស់សត្ថុ ជាអារ ហើយទីឃៈ អរបស់រជាអា ផ្សំនឹង នំ ជា សត្ថារានំ, ផ្លាស់ឧរបស់សត្ថុ ជា អ ហើយទីឃៈ អជាអា ផ្សំនឹងនំ ជា សត្ថានំ. ទីឃៈឧរបស់សត្ថុ ជា ឩ ផ្សំនឹងនំ ជា សត្ថូនំ |
| បញ្ច. ផ្លាស់ ឧ របស់សត្ថុជាអារ ហើយផ្លាស់ស្មាជាអាជាសត្ថារា | សត្ថារេហិ, សត្ថារេភិ ដូច ត. ពហុ. |
| ឆ.សត្ថុ, សត្ថុនោ,សត្ថុស្ស ដូច ច.ឯក. | សត្ថារានំ, សត្ថានំ, សត្ថូនំ ដូច ច. ពហុ. |
| ស. ផ្លាស់ ឧ របស់ សត្ថុ ជា អារ ហើយផ្លាស់ ស្មឹជាឥ ហើយរស្សៈ អារជាអរ ហើយលុប អ ចេញជា សត្ថរិ | ផ្លាស់ ឧ របស់ សត្ថុ ជា អារ ហើយផ្លាស់ អ របស់ រ ជា ឯ ផ្សំនឹង សុ ជា សត្ថារេសុ |
| អា.ផ្លាស់ ឧ របស់សត្ថុ និងសិ ជាអា ជា សត្ថា,រស្សៈអារបស់សត្ថាជាអជាសត្ថ | សត្ថារោ ដូច ប. ពហុ. |

## សព្វប៉ុណ្ណោះជាដើម បំបែកដូច សត្ថុ

| | |
|---|---|
| កត្តុ ជនអ្នកធ្វើ | នេតុ ជនអ្នកនាំ |
| ខត្តុ ជនអ្នកជីក | ភត្តុ ជនអ្នកចិញ្ចឹម (ប្តី) |
| ញាតុ ជនអ្នកដឹង | វត្តុ ជនអ្នកពោល, អ្នកនិយាយ |
| ទាតុ ជនអ្នកឲ្យ | សោតុ ជនអ្នកស្តាប់ |
| នត្តុ ចៅ | ហន្តុ ជនអ្នកបៀតបៀន, អ្នកសម្លាប់ |

[៨៤] បិតុ "បិតា" ឧការន្តបុំលិង្គ បំបែកដូច្នេះ:

| ឯកវចនៈ | | ពហុវចនៈ |
|---|---|---|
| ប. | បិតា | បិតរោ |
| ទុ. | បិតរំ | បិតរោ |
| ត. | បិតរា, បិតុនា | បិតរេហិ, បិតរេភិ, បិតូហិ, បិតូភិ |
| ច. | បិតុ, បិតុនោ (បិតុស្ស) | បិតរានំ, បិតូនំ |
| បញ្ច. | បិតរា | បិតរេហិ, បិតរេភិ, បិតូហិ, បិតូភិ |
| ឆ. | បិតុ, បិតុនោ (បិតុស្ស) | បិតរានំ, បិតូនំ |
| ស. | បិតរិ | បិតរេសុ, បិតូសុ |
| អា. | បិតា | បិតរោ |

រូបសិទ្ធិ មានវិធីដូច សត្ថុ ប្លែកគ្នាតែត្រង់វិធីវស្សៈអារជាអរ ដោយមេសូត្រ បិតាទីនមសិម្ទិ ប៉ុណ្ណោះ ឯបទខ្លះក្រៅអំពីរបៀប សត្ថុ មានរូបសិទ្ធិដូចគរុ (មើលត្រង់លេខ ៦២ និងលេខ ៦៤ ខាងដើម) ។ បិតុសព្ទនេះ ត្រង់អាលបនៈ គ្រាន់តែមានវិធីបំបែក តាមរបៀបជា បិតា, បិតរោ ដូច្នេះឯង ប៉ុន្តែក្នុងការនិយាយភាសា បាឡីឬតែងសេចក្តីជាភាសាបាឡីមិនដែលប្រើទេ ឲ្យប្រើ "តាត" សព្ទជំនួសវិញ ត្រង់ អា. ឯក. ជា តាត. អា. ពហុ. ជា តាតា ។ តាតសព្ទនេះជាអការន្តបុំលិង្គ វិធីបំបែកផ្សំនឹងវិភត្តិដូច បុរិស, ត្រង់អាលបនៈប្រើបាន ទាំងបិតា ទាំងបុត្រ និងជនឯទៀតក៏ប្រើ បានខ្លះ ឧ. តាត "បពិត្របិតា". តាត "នៃកូន", តាត "នៃអ្នក, ហៃបា, ហៃចៅ", បើត្រង់វិភត្តិឯទៀតក្រៅអំពីអាលបនៈនោះប្រើ ចំពោះបានតែបិតា ១ យ៉ាង ។

សព្ទគឺ ភាតុ "បងប្រុស, បងប្អូនប្រុស", ជាមាតុ "កូន ប្រសាប្រុស", ទាំងពីរសព្ទនេះបំបែកដូច បិតុ ។

[៨៥] មាតុ "មាតា ឥការន្តឥត្ថីលិង្គ បំបែកដូច្នេះ:

| ឯកវចនៈ | | ពហុវចនៈ |
|---|---|---|
| ប. | មាតា | មាតរោ |
| ទុ. | មាតរំ | មាតរោ |
| ត. | មាតរា, មាតុយា | មាតរាហិ, មាតរាភិ,មាតូហិ,មាតូភិ |
| ច. | មាតុ, មាតុយា | មាតរានំ មាតូនំ |
| បញ្ច. | មាតរា, មាតុយា | មាតរាហិ,មាតរាភិ,មាតូហិ,មាតូភិ |
| ឆ. | មាតុ, មាតុយា | មាតរានំ, មាតូនំ |
| ស. | មាតរិ | មាតរាសុ, មាតូសុ |
| អា. | មាតា | មាតរោ |

រូបសិទ្ធិ មានវិធីដូច បិតុ ប្លែកគ្នាតែដំណើរលិង្គ ដោយហេតុសព្ទមួយជាបុំលិង្គ មួយជាឥត្ថីលិង្គប៉ុណ្ណោះ ឯបទខ្លះក្រៅអំពីរបៀបបិតុនោះមានរូបសិទ្ធិដូច រដ្ឋុ (មើលត្រង់ លេខ ៦៧ និងលេខ ៦៩ ខាងដើម) ។

មាតុសព្ទនេះ ត្រង់អាលបនៈ គ្រាន់តែមានវិធីបំបែកតាមរបៀបជា មាតា, មាតរោ ដូច្នេះឯង ប៉ុន្តែមិនដែលប្រើទេ ឲ្យប្រើ

"អម្ម" សព្ទជំនួសវិញ. ត្រង់ អា. ឯក. ជា អម្ម, អា. ពហុ. ជា អម្មា ប្រើទួទៅបានទាំងមាតាទាំងធីតា និងស្ត្រីឯទៀតក៏ប្រើបាន ឧ. អម្ម "បពិត្រម៉ែ", អម្ម "ម្នាលកូន", អម្ម "នែនាង" ។ ប៉ុន្តែមាតុសព្ទនេះ បើរួមចូលនឹងសព្ទឯទៀតជាតប្បុរិសសមាស. ត្រង់អាលបនៈត្រូវប្រើជា "មាតេ" វិញ ទាំងធីតុសព្ទក៏ដូចគ្នាដែរ ឧ. តិស្សមាតេ, ទេវមាតេ, ទេវធីតេ ។ រូបសិទ្ធិ ត្រូវផ្លាស់ឧជាអហើយចុះអាបច្ច័យ ហើយប្រើវិធីដូចអាលបនៈក្នុងអាការន្តឥត្ថីលិង្គ (មើលត្រង់លេខ ៦៦ ខាងដើម) ។

សព្ទគឺ ធីតុ "កូនស្រី", ទុហិតុ "កូនស្រី" បំបែកដូចមាតុ ។

សព្ទពួកនេះ (មានបិតុសព្ទជាដើម), កាលបើចុះ តោ[១] បច្ច័យផ្ទាល់ក្តី មានសព្ទឯទៀតរាំងអំពីមុខក្តី ត្រូវផ្លាស់ ឧរបស់ខ្លួនជា ឥ ដោយអំណាចអសិម្ពិសព្ទក្នុងមេសូត្រ បិតាទីនមសិម្ពិ ឧ. បិតិតោ "អំពីបិតា", មាតិតោ "អំពីមាតា", ភាតិតោ "អំពីបង ប្អូន", ទុហិតិតោ "អំពីកូនស្រី", មាតិបក្ខតោ "អំពីពួកនៃមាតា", បិតិបក្ខតោ "អំពីពួកនៃបិតា" ។

---

១ មើលទៅក្នុងខាងមុខត្រង់លេខ ១២៧ ។

ភាតុ សព្ទនេះ មិនប្រាកដជាបងប្រុសឬប្អូនប្រុសឡើយ គឺប្រើចំពោះបានទាំងបងទាំងប្អូន បើលុះតែមានសព្ទគឺ ជេដ្ឋ និង កនិដ្ឋ ចូលផ្សំជាមួយផងនោះ ទើបមានសេចក្តីប្រាកដបាន ។. ជេដ្ឋភាតុ "បងប្រុស", កនិដ្ឋភាតុ "ប្អូនប្រុស ។ ជួនកាល ប្រើ "ភាតិក" សព្ទជំនួស ភាតុ ក៏មាន ភាតិក ជាអការន្ត បុំលិង្គ មានវិធីបំបែកផ្សំនឹងវិភត្តិដូច បុរិស ។

## មនោគណសព្ទ

[៨៦] សព្ទទាំងឡាយ ១២ មានមនសព្ទជាដើម ដែលនឹងពោលតទៅនេះ ហៅថា មនោគណសព្ទ ព្រោះជាពួកនៃមនសព្ទ មានវិធីបំបែកផ្សំនឹងវិភត្តិដូចគ្នានឹងមនសព្ទ ។ ឯវិធីបំបែកព្រមទាំងរូបសិទ្ធិ ក៏មិនសូវប្លែកគ្នាអំពីបែបអការន្តបុំលិង្គ និងអការន្តនបុំសកលិង្គ ដែលបានពោលមកហើយក្នុងខាងដើម ត្រង់លេខ ៦១ និងលេខ ៧១ នោះណាស់ណាដែរទេ មានប្លែកគ្នាខ្លះដោយអន្លើតែ ៦ វិភត្តិត្រង់ឯកវចនៈ គឺ ត្រង់ ទុ. ត. ច. បញ្ច. ឆ. ស. ។ នឹងបំបែកតែត្រង់ ៦ វិភត្តិជាឯកវចនៈដែលដូចគ្នានឹងអការន្ត បុំ.- នបុំ.- ហើយនឹងដែលប្លែកគ្នាអំពីនោះឲ្យឃើញ

ដូច្នេះ ទុ. ឯក. ដែលដូចគ្នា មនំ, ដែលប្លែកគ្នា មនោ, ត. ឯក. ដែលដូចគ្នា មនេន, ដែលប្លែកគ្នា មនសា, ច. ឯក. និង ឆ. ឯក. ដែលដូចគ្នា មនស្ស,.. ដែលប្លែកគ្នា មនសោ, ស. ឯក. ដែលដូចគ្នា មនស្មឹ, មនម្ហិ, មនេ, ដែលប្លែកគ្នា មនសំ ។

## រូបសិទ្ធិ មានមេសូត្រ ចំពោះតែត្រង់បទដែលប្លែកគ្នា

| ឯកវចនៈ | ឯកវចនៈ |
|---|---|
| ទុ. សស្សបោ | បញ្ច. អម្ហ ។ល។ ស្មានាវ, មនោ ។ល។ នមិអា |
| ត. មនោគណាទិតោស្មឹនានមិ-អា, សសរេវាគមោ | ឆ. ដូច ច. ឯក. |
| ប. សស្សបោ, សសរេវាគមោ | ស.មនោ។ល។នមិអា,សសរេវាគមោ, |

## រូបសិទ្ធិ ឥតមេសូត្រ ចំពោះតែត្រង់បទដែលប្លែកគ្នា

| ឯកវចនៈ | ឯកវចនៈ |
|---|---|
| ទុ. ផ្លាស់ អំ ជា ឱ ហើយលុប អ ចេញជា មនោ | បញ្ច. ផ្លាស់ស្មាជាអា ហើយចុះ សអាគម ជា មនសា |
| ត. ផ្លាស់នាជាអា ហើយចុះ ស អាគម ជា មនសា | ឆ. មនសោ ដូច ច. ឯក. |
| ប. ផ្លាស់ អាជាឱ ហើយចុះ ស អាគម ជា មនសោ | ស. ផ្លាស់ ស្មឹ ជា ឥ ហើយចុះ ស អាគម ជា មនសិ |

## មនោគណសព្ទនោះដូច្នេះ

| | |
|---|---|
| មន ចិត្ត | បយ ទឹក, ទឹកដោះ |
| អយ ដែក | យស យស (បរិវារ) |
| ឱរ ទ្រូង,ជីវិត | វច ពាក្យ. សម្ដី |
| ចេត ចិត្ត, តម្រិះ | វយ វ័យ (ដំណើរចម្រើនឡើងនៃអាយុ), សេចក្ដីសាបសូន្យ |
| តប តបៈ (កម្ដៅ) | |
| តម ងងឹត | |
| តេជ តេជះ (អំណាច), ភ្លើង | សិរ ក្បាល, កំពូល, ចុង |

បណ្ដាសព្ទទាំង ១២ នេះ, មនសព្ទជាអការន្តទ្វិលិង្គិកៈ គឺបុំលិង្គនិងនបុំសកលិង្គ ក្រៅអំពីនោះជាអការន្តបុំលិង្គទាំងអស់ ។ ម្យ៉ាងទៀត មនោគណសព្ទ បើរួមចូលនឹងសព្ទឯទៀត សម្រេចរូបជាបទសមាស ឬរួបចូលនឹងបច្ច័យតទ្ធិត ឬបច្ច័យក្រិត សម្រេចរូបជាបទតទ្ធិត ឬបទក្រិត នោះត្រូវផ្លាស់ស្រះអរបស់ខ្លួនជាឱដោយមេសូត្រ ឯតេសមោលោបេ ៥. មនោគណោ "ពួកនៃមនសព្ទ", មនោធាតុ "ធាតុគឺចិត្ត", អយោមយំ "វត្ថុដែលជនធ្វើហើយដោយដែក" ឬ "វត្ថុជាវិការៈនៃដែក", តេជោធាតុ

"ធាតុគឺភ្លើង (ធាតុភ្លើង)" តេជោសមោ "ស្មើដោយតេជះ", តបោធនោ "ជនមានតបះជាទ្រព្យ (តាបស)", តមោនុទោ" អ្នកកម្ចាត់បង់នូវងងឹត", សិរោរុហោ "អាការដែលដុះលើក្បាល (សក់", តបោវនំ "ព្រៃជាទីប្រព្រឹត្តនូវតបៈ" ។

សព្ទជាអការន្តឯទៀតក្រៅអំពីមនោគណសព្ទ ជួនមានវិធីបំបែកនិងវិធីផ្លាស់អជាឱ ដូចមនោគណសព្ទដែរក៏មានខ្លះ ដូចជាពិល "រន្ធ, រូង, ប្រហោង, ព្រង់" (ជានបុំ.), បទ "ជើង" (ជាបុំ.), បទ "បទ, ព្រះនិព្វាន, គ្នាម, ដើមចម, ទី, ការរក្សា, ចំណែក, ស្នាមឬជានជើង, លំអាន" (ជានបុំ.), ត្រង់ ត. ឯក. និង បញ្ច. ឯក. ជា ពិលសា, បទសា, ត្រង់ស. ឯក. ជា ពិលសិ, បទសិ ។ អហ "ថ្ងៃ" (ជាទ្វិលិង្គិកៈ គឺ បុំ. នបុំ.) រត្តិ "យប់" (ជាឥ). ផ្លាស់ អរបស់ ហ ជា ឱ ហើយផ្លាស់ ឥ របស់ ត្តិ ជា អ ផ្សំ ជា អហោរត្ត "ថ្ងៃនិងយប់" (ក្លាយជាបុំ.) វាយ "ខ្យល់" (ជាបុំ.) អាប "ទឹក" (ជាបុំ.)ធាតុ"ធាតុ"(ជាទ្វិលិង្គិកៈគឺ បុំ. ឥ.)សម"សម, ប្រហែល, ស្រដៀង, ស្មើ, សេចក្តីរម្ងាប់"(ជាតិលិង្គិកៈ) ផ្លាស់ អ របស់ យ.

របស់ ប ជា ឱ ផ្សំ ជា វាយោធាតុ "ធាតុគឺខ្យល់ (ធាតុខ្យល់)", អាបោធាតុ "ធាតុគឺទឹក (ធាតុទឹក)", អាបោសមោ "ស្មើដោយទឹក,..." ។

វិធីនៃមនោគណសព្ទ ដូចសេចក្ដីដែលពោលខាងលើនោះ គឺសំដៅចំពោះដំណើរដែលរមែងមានដោយច្រើន តែបើនឹងនិយាយតាមវិធីវិសេស គឺតាមបែបបទដែលប្លែកពីនេះខ្លះនោះជួនណាមនោគណសព្ទ មិនបាច់ផ្លាស់អជាឱឡើយក៏បាន ប៉ុន្តែបែបនោះមានប្រើតិច យូរ ៗ ប្រទះឃើញមានខ្លះម្ដង ៗ ឧ. តមវិនោទនោ "អ្នកបន្ទោបង់ ឬ កម្ចាត់បង់នូវងងឹត", យសសម្បត្តិ "កិរិយាដល់ព្រមដោយយស ឬ-នៃយស", តបបរិក្ខារោ "គ្រឿងបរិក្ខារសម្រាប់ប្រព្រឹត្តនូវតបៈ, តបចរណំ "កិរិយាប្រព្រឹត្តនូវតបៈ" ។

ម្យ៉ាងទៀត អំពីមុខសព្ទដែលជាមនោគណៈ ឬមិនមែនជាមនោគណៈក៏ដោយ, ផ្លាស់ត. ឯក. គឺនា ជាសោក៏បានខ្លះ ដោយមេសូត្រ សោវា ឧ. អត្ថសោ "ដោយអត្ថ" ព្យញ្ជនសោ "ដោយ

ព្យញ្ជនៈ″ សុត្តសោ ‶ដោយសូត្រ″, បទសោ ‶ដោយបទ″, យសសោ ‶ដោយយស″, ឧបាយសោ ‶ដោយឧបាយ″, សព្វ-សោ ‶ដោយសព្វគ្រប់″, ឋានសោ ‶ដោយហេតុជាទីតាំង″, ថាមសោ ‶ដោយកម្លាំង″ ។ អំពីមុខទីឃៈនិងឧរសព្ទ ផ្លាស់ បញ្. ឯក. គឺស្មា ជាសោក៏បានខ្លះ ដោយមេសូត្រ ទីឃោរេហិ ឱ. ទីឃសោ ‶អំពីប្រវែង″, ឧរសោ ‶អំពីទ្រូង″ ។ វិធីផ្លាស់ ស្មាជាសោនេះ ប្រើបានចំពោះតែអំពីមុខទីឃៈនិងឧរតែ ២ សព្ទ ប៉ុណ្ណោះ ។

[៨៧] កម្ម ‶កម្ម (អំពី)″ អការន្តនបុំសកលិង្គ បំបែកដូច្នេះ:

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. កម្មំ | កម្មានិ |
| ទុ. កម្មំ | កម្មានិ |
| ត. កម្មុនា, កម្មេន | កម្មេហិ, កម្មេភិ |
| ប. កម្មុនោ, កម្មស្ស | កម្មានំ |
| បញ្.កម្មុនា, កម្មស្មា, កម្មម្ហា | កម្មេហិ, កម្មេភិ |

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ឆ. កម្មុនោ, កម្មស្ស | កម្មានំ |
| ស. កម្មនិ, កម្មស្មឹ, កម្មម្ហិ, កម្មេ | កម្មេសុ, |
| អា. កម្ម | កម្មានិ |

## រូបសិទ្ធិ មានមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. សឹ,... | អតោនិច្ចំ, យោសុកតនិការលោ-បេសុទីឃំ |
| ទុ. សរលោបោ ។ល។ តុបកតិ | ដូច ប. ពហុ. |
| ត. អកម្មន្តស្សច, អតោនេន | ស្មាហិស្មឹនម្ហាភិម្ហិវា,សុហីស្វការោឯ |
| ច. ហិវិភត្តិម្ហិច, ឈលតោស-ស្សនោវា, សាគមោសេ | សុនំហីសុច |
| បញ្ច. អម្ហ ។ល។ ស្មានាវ, ហិវិ-ភត្តិម្ហិច, ស្មាហិស្មឹនម្ហាភិម្ហិវា | ដូច ត. ពហុ. |
| ឆ. ដូច ច. ឯក. | ដូច ច. ពហុ. |
| ស. ព្រហ្មតោគុស្មឹនិ,ស្មាហិស្មឹន-ម្ហាភិម្ហិវា, ស្មាស្មឹនំវា | សុហីស្វការោឯ |
| អា. អាលបនេសិគសញ្ញោ, សេ-សតោលបំគសិបិ | ដូច ប. ពហុ. |

# រូបសិទ្ធិ ឥតមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. ផ្លាស់ សិ ជា ៎ ជាកម្មំ | ផ្លាស់ យោ ជា និ ហើយទីឃៈ អ ជា អា ជា កម្មានិ |
| ទុ. កម្មផ្សំនឹង ៎ ជាកម្មំ | កម្មានិ ដូច ប. ពហុ. |
| ត. ផ្លាស់ អ ជា ឧ ផ្សំនឹង នា ជា កម្មុនា, ផ្លាស់ នា ជា ឯន ហើយលុប អ ចេញជា កម្មេន | ផ្លាស់ អជាឯផ្សំនឹងហិជាកម្មេហិ, ផ្លាស់ ហិ ជា ភិ ជា កម្មេភិ |
| ចៈ.ផ្លាស់ អជាឧ ហើយផ្លាស់ ស ជា នោ ជា កម្មុនោ, ចុះសអាគម ផ្សំនឹង ស វិភត្តិជាកម្មស្ស | ទីឃៈអជាអាផ្សំនឹងនំជាកម្មានំ |
| បញ្ចៈ. ផ្លាស់ ស្មា ជា នា ហើយ ផ្លាស់ អ ជា ឧ ផ្សំជា កម្មុនា, កម្មផ្សំនឹង ស្មា ជា កម្មស្មា, ផ្លាស់ ស្មា ជា ម្ហា ជា កម្មម្ហា | កម្មេហិ, កម្មេភិ ដូច ត. ពហុ. |
| ឆៈ. កម្មុនោ,កម្មស្ស ដូច ច. ឯក. | កម្មានំ ដូច ច. ពហុ. |
| ស. ផ្លាស់ ស្មឹ ជា និ ផ្សំជា កម្មនិ, កម្មផ្សំនឹងស្មឹជាកម្មស្មឹ, ផ្លាស់ស្មឹ ជា ម្ហិផ្សំ ជា កម្មម្ហិ, ផ្លាស់ ស្មឹ ជា ឯ ហើយលុប អ ចេញផ្សំជាកម្មេ | ផ្លាស់អជាឯផ្សំនឹងសុជាកម្មេសុ |
| អា.គ្រាន់តែលុប សិ ចេញ គង់ រូបនៅជា កម្ម ដូចដែល | កម្មានិ ដូច ប. ពហុ. |

ក្នុងកច្ចាយនៈ ត្រង់ ត. ឯក. និង ស. ពហុ. មានវិធីឲ្យផ្លាស់ អ របស់ កម្ម ជា អ ជា អា ដោយមេសូត្រ អកម្មន្តស្សចផ្សំជា កម្មនា, កម្មានា, កម្មាសុ ។

[៨៨] ខ្ញុំបាននិយាយរួចមកហើយក្នុងខាងដើម ត្រង់លេខ ៥៨ ថា គោ "គោ" ជាឱការន្ត (ពីព្រោះមានស្រះឱនៅទីបំផុតនៃអក្សរ "គ") ជាទ្វិលិង្គិកៈ គឺ បុំលិង្គនិងឥត្ថីលិង្គ ។ គោ-សព្ទនេះមានវិធីបំបែកច្រើនបែប នឹងបំបែកតែត្រង់បែបដែលនិយមប្រើដោយច្រើននោះឲ្យឃើញ ដូច្នេះ:

| ឯកវចនៈ | | ពហុវចនៈ |
|---|---|---|
| ប. | គោ | គាវោ |
| ទុ. | គាវំ, គាវុំ | គាវោ |
| ត. | គាវេន | គោហិ, គោភិ, គាវេហិ, គាវេភិ |
| ច. | គាវស្ស | គោនំ, គុន្នំ, គាវានំ |
| បញ្ច. | គាវស្មា, គាវម្ហា, គាវា | គោហិ, គោភិ, គាវេហិ, គាវេភិ |
| ឆ. | គាវស្ស | គោនំ, គុន្នំ, គាវានំ |

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ស. គាវស្មឹ, គាវម្ហិ, គាវេ | គោសុ, គាវេសុ |
| អា. គាវ | គាវោ |

## រូបសិទ្ធិ មានមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ប. សេសតោលោបំគសិបិ | យោសុច, តតោយោនមោតុ |
| ទុ. អវម្ហិច, អាវស្សុវា | ដូច ប. ពហុ. |
| ត. យោសុច, អតោនេន | ស្មាហិស្មឹនម្ហាភិម្ហិវា, យទនុបបន្នា-និបាតនាសិជ្ឈន្តិ,សុហីស្វការោង |
| ច. គាវសេ, សាគមោសេ | សុហិនាសុច, នោតទ្វាទិតោនម្ហិ, យទនុបបន្នានិបាតនាសិជ្ឈន្តិ,សុ-នំហីសុច |
| បញ្ច. យោសុច, ស្មាហិស្មឹនម្ហា-ភិម្ហិវា, ស្មាស្មឹនំវា | ដូច ត. ពហុ. |
| ឆ. ដូច ច. ឯក. | ដូច ច. ពហុ. |
| ស. យោសុច, ស្មាហិស្មឹនម្ហា-ភិម្ហិវា, ស្មាស្មឹនំវា | យោសុច, សុហីស្វការោង |
| អា.យទនុបបន្នា ។ល។សិជ្ឈន្តិ, សេសតោលោបំគសិបិ | ដូច ប. ពហុ. |

# រូបសិទ្ធិ ឥតមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| **ប.** គ្រាន់តែលុប សិ ចេញគង់រូប នៅ ជា គោ ដូចដែល | ផ្លាស់ ឱ របស់ គោ ជា អាវ ហើយផ្លាស់ យោ ជា ឱ ហើយ លុប អ ចេញជា គាវោ |
| **ទុ.** ផ្លាស់ ឱ របស់ គោ ជា អាវ ផ្សំនឹង អំ ជា គាវំ, ផ្លាស់ អ របស់ វ ជា ឧ ផ្សំនឹងំជា គាវុំ | គាវោ ដូច ប. ពហុ. |
| **ត.** ផ្លាស់ ឱ របស់ គោ ជា អាវ ហើយផ្លាស់ នាជាឯន ហើយ លុប អ ចេញជា គាវេន | គោផ្សំនឹងហិជាគោហិ, ផ្លាស់ហិ ជាភិជាគោភិ, ផ្លាស់ឱរបស់គោ ជា អាវ ហើយ ផ្លាស់ អ របស់ វ ជា ឯ ផ្សំនឹង ហិ ជា គាវេហិ, ផ្លាស់ ហិ ជា ភិ ជា គាវេភិ |
| **ច.** ផ្លាស់ ឱ របស់ គោ ជា អាវ ហើយចុះ សអាគម ផ្សំនឹង សវិភត្តិ ជា គាវស្ស | គោផ្សំនឹងនំជាគោនំ, ផ្លាស់គោ ជា គុ ហើយចុះ នអាគមផ្សំនឹងនំ វិភត្តិជាគុន្នំ, ផ្លាស់ឱរបស់គោ ជា អាវ ហើយទីឃៈ អ របស់ វ ជា អា ផ្សំនឹង នំ ជា គាវានំ |
| **បញ្ច.** ផ្លាស់ ឱរបស់គោជាអាវផ្សំនឹងស្មាជាគាវស្មា,ផ្លាស់ស្មាជាម្ហា ជាគាវម្ហា, ផ្លាស់ស្មាជាអាហើយ លុប អ របស់ វ ចេញជា គាវា | គោហិ, គោភិ, គាវេហិ, គាវេភិ, ដូច ត. ពហុ. |
| **ឆ.** គាវស្ស ដូច ច. ឯក. | គោនំ, គុន្នំ, គាវានំ ដូច ច. ពហុ. |

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| **ស.** ផ្លាស់ ឱ របស់គោជាអាវផ្សំនឹងស្មឹជា គាវស្មឹ, ផ្លាស់ ស្មឹ ជា ម្ហិ ជា គាវម្ហិ, ផ្លាស់ស្មឹជាឯហើយ លុប អ របស់ វ ចេញជា គាវេ | គោ ផ្សំនឹង សុ ជា គោសុ, ផ្លាស់ ឱ របស់ គោ ជា អាវ ហើយ ផ្លាស់ អ របស់ វ ជា ឯ ផ្សំនឹង សុ ជា គាវេសុ |
| **អា.**ផ្លាស់ ឱរបស់គោជាអាវ ហើយ គ្រាន់តែលុប សិ ចេញជា គាវ | គាវោ ដូច ប. ពហុ. |

ក្នុងកច្ចាយនៈ មានវិធីឲ្យសម្រេចរូបដូចបែបបំបែកខាងលើនេះផង ផ្សេងអំពីនេះផងក៏មាន ដូចសេចក្ដីនិយាយដោយសង្ខេបតទៅនេះ:

១. ឲ្យផ្លាស់ឱរបស់គោជាអវ ផ្សំជា គវ ។

២. ឲ្យផ្លាស់គោជា គោណ, ជា គវយ ។

កាលបើផ្លាស់បានរូបជាគវ, ជាគោណ, ជាគវយ ដូច្នេះហើយ, ក្នុងកច្ចាយនៈមិនមានរៀបរបៀបបំបែកផ្សំគ្រប់វិភត្តិទុកជាបែបឲ្យទេ មានបំបែកជាបែបឲ្យឃើញខ្លះតែដោយអន្លើ ប៉ុន្តែមានទំនងគួរឲ្យសង្កេតបានថា គោណនិងគវយ ទាំង ២ យ៉ាងនេះ មានលំនាំជាអការន្តបុំលិង្គ គង់មានវិធីបំបែកគ្រប់វិភត្តិទាំង ២ វចនៈ តាមដំណើរអការន្តបុំលិង្គដូច បុរិស ។ ឯ គវ

ត្រង់ ច. ឆ. ពហុ. មានបង្គាប់ថាឲ្យផ្លាស់នំជាអំផ្សំជាគរំក៏បាន, ត្រង់បឋមាវិភត្តិព្រមទាំងអាលបនៈទាំង ២ វចនៈមិនដែលឃើញមានវិធីឲ្យប្រើ ក្រៅអំពីនោះ មានទំនងជាអការន្តបុំលិង្គដូច បុរិស ។

វិធីបំបែកគោសព្ទ ដែលបាននិយាយមកហើយក្នុងខាងលើនោះ ប្រើបានទាំង ២ លិង្គគឺបុំ. ឥ. តាមជាតិរបស់សព្ទ តែបើនឹងពោលតាមវិធីវិសេសឲ្យឃើញផ្សេង ដោយឡែកនោះ កាលបើផ្លាស់ឱរបស់គោជា អាវ ផ្សំជា គាវ ហើយចុះឦបច្ច័យសម្រេចរូបជា គាវី ហើយ ក៏ជាឥត្ថីលិង្គតាមដំណើរ មានវិធីបំបែកដូច នារី ។

[៨៩] វិធីបំបែកនាមសព្ទខ្លះ ដែលមានបែបប្លែកបន្តិចបន្តួចដោយអន្លើផ្សេង អំពីបែបដែលបានពោលមកហើយនោះក្តី នាមសព្ទពិសេសទាំងឡាយមានសព្ទគឺ បុម "ប្រុស" មឃវ "ទេវរាជទ្រង់ព្រះនាមមឃវ (ព្រះឥន្ទ្រ)", យុវ "កំលោះ" ជាដើមនោះក្តី ខ្ញុំមិនបាននាំមករៀបរៀងពន្យល់ឲ្យសព្វគ្រប់ក្នុងនាមនិទ្ទេសនេះទេ វេយ្យាករណបណ្ឌិតជាអាចារ្យបង្រៀន ត្រូវពន្យល់អ្នករៀន តាមលទ្ធិក្នុងកច្ចាយនបករណ៍និងគម្ពីរសព្ទសាស្ត្រទាំងឡាយឯទៀត ឲ្យបានទូលាយត្រាតែអ្នករៀនបានយល់ច្បាស់លាស់ឡើងផងចុះ ។

# សំខ្យាសព្ទ

[៩០] សព្ទសម្រាប់រាប់នាមនាមហៅថា សំខ្យា,មាន ២ យ៉ាង គឺ បកតិសំខ្យា ១ បូរណសំខ្យា ១ ។ សំខ្យាដែលរាប់តាមប្រក្រតី ឲ្យដឹងចំនួនរបស់នាមនាមថាប៉ុណ្ណោះ ៗ គឺរាប់ថា "មួយ, ពីរ, បី, បួន, ប្រាំ" ជាដើម ហៅថា បកតិសំខ្យា ។ សំខ្យាដែលរាប់នាមនាមបង្គ្រប់ជាជាន់ ៗ តាមលំដាប់តាមថ្នាក់ គឺរាប់ថា "ទីមួយ, ទីពីរ, ទីបី, ទីបួន, ទីប្រាំ" ឬរាប់ថា "ជាដំបូង, គម្រប់ពីរ, គម្រប់បី, គម្រប់បួន, គម្រប់ប្រាំ" ជាដើម ហៅថា បូរណសំខ្យា ។ បកតិសំខ្យាចែកចេញជា ៣ ពួក គឺតាំងពី ឯក "១" រៀងដល់ចតុ "៤" ជាសព្វនាម ហៅថា សំខ្យាសព្វនាម ជាពួក ១, តាំងពី បញ្ច "៥" រៀងទៅដល់ អដ្ឋនវុតិ "៩៨" ជាគុណនាម ហៅថា សំខ្យាគុណនាម ជាពួក ១, តាំងពី ឯកូនសតំ ឬ ឩនសតំ "៩៩" រៀងទៅដល់ អសំខេយ្យំ "អសំខេយ្យ" ដ្ឋនណាប្រើជាគុណនាម ហៅថា សំខ្យាគុណនាម ដ្ឋនណាប្រើជានាមនាម ហៅថា សំខ្យានាមនាម ជាពួក ១ ។ ឯបូរណសំខ្យា ជាគុណនាមទាំងអស់ ហៅថា សំខ្យាគុណនាម ។

# *វិធីរាប់បកតិសំខ្យា*

[៩១] ដើម្បីឲ្យងាយចំណាំ, វិធីរាប់បកតិសំខ្យាចែកជា ៤ ផ្នែកដូច្នេះ:

## ផ្នែកទី ១- វិធីរាប់ពីត្រឹម ១ ដល់ ១០

| សព្ទបាឡី | សព្ទប្រែ |
|---|---|
| ឯក ................................................ | ១ |
| ទ្វិ ................................................ | ២ |
| តិ ................................................ | ៣ |
| ចតុ ................................................ | ៤ |
| បញ្ច................................................ | ៥ |
| ឆ. ................................................ | ៦ |
| សត្ត ................................................ | ៧ |
| អដ្ឋ ................................................ | ៨ |
| នវ ................................................ | ៩ |
| ទស ................................................ | ១០ |

## ផ្នែកទី ២- វិធីរាប់ពីត្រឹម ១១ ដល់ ៩៩


| សព្ទបាឡី | សព្ទប្រែ |
|---|---|
| ឯកាទស, ឯការស ..................................... | ១១ |
| ទ្វាទស, ពារស ............................................ | ១២ |
| តេរស ...................................................... | ១៣ |
| ចតុទ្ទស, ចុទ្ទស, ចោទ្ទស................................ | ១៤ |
| បញ្ចទស, បណ្ណរស ...................................... | ១៥ |
| សោឡស ................................................. | ១៦ |
| សត្តរស ................................................... | ១៧ |
| អដ្ឋារស................................................... | ១៨ |
| ឯកូនវីស, ឩនវីស, ឯកូនវីសតិ, ឩនវីសតិ............ | ១៩ |
| វីស, វីសតិ ................................................ | ២០ |
| ឯកវីស, ឯកវីសតិ........................................ | ២១ |
| ទ្វាវីស, ទ្វាវីសតិ, ពាវីស, ពាវីសតិ..................... | ២២ |
| តេវីស, តេវីសតិ........................................... | ២៣ |
| ចតុវីស, ចតុវីសតិ ...................................... | ២៤ |

| សព្ទបាឡី | សព្ទប្រែ |
|---|---|
| បញ្ចវីស, បញ្ចវីសតិ ................................. | ២៥ |
| ឆព្វីស, ឆព្វីសតិ ......................................... | ២៦ |
| សត្តវីស, សត្តវីសតិ ...................................... | ២៧ |
| អដ្ឋវីស, អដ្ឋវីសតិ ...................................... | ២៨ |
| ឯកូនតឹស, ឯកូនតឹសតិ, ឩនតឹស, ឩនតឹសតិ ........ | ២៩ |
| តឹស, តឹសតិ ................................................ | ៣០ |
| ឯកត្តឹស, ឯកត្តឹសតិ ...................................... | ៣១ |
| ទ្វត្តឹស, ទ្វត្តឹសតិ, ពត្តឹស, ពត្តឹសតិ .................... | ៣២ |
| តេត្តឹស, តេត្តឹសតិ ....................................... | ៣៣ |
| ចតុត្តឹស, ចតុត្តឹសតិ .................................... | ៣៤ |
| បញ្ចត្តឹស, បញ្ចត្តឹសតិ .................................. | ៣៥ |
| ឆត្តឹស, ឆត្តឹសតិ .......................................... | ៣៦ |
| សត្តត្តឹស, សត្តត្តឹសតិ .................................. | ៣៧ |
| អដ្ឋត្តឹស, អដ្ឋត្តឹសតិ ................................... | ៣៨ |

សព្ទបាឡី សព្ទប្រែ

ឯកូនចត្តាឡីស, ឩនចត្តាឡីស, ឯកូនតាឡីស, ឩនតាឡីស ........................................ ៣៩
ចត្តាឡីស, តាឡីស.................................. ៤០
ឯកចត្តាឡីស, ឯកត្តាឡីស............................ ៤១
ទ្វេចត្តាឡីស, ទ្វេតាឡីស.............................. ៤២
តេចត្តាឡីស, តេតាឡីស ............................ ៤៣
ចតុចត្តាឡីស, ចតុត្តាឡីស.......................... ៤៤
បញ្ចចត្តាឡីស, បញ្ចត្តាឡីស........................ ៤៥
ឆចត្តាឡីស, ឆត្តាឡីស................................ ៤៦
សត្តចត្តាឡីស, សត្តត្តាឡីស......................... ៤៧
អដ្ឋចត្តាឡីស, អដ្ឋត្តាឡីស ......................... ៤៨
ឯកូនបញ្ញាស, ឩនបញ្ញាស, ឯកូនបណ្ណាស, ឩនបណ្ណាស ........................................ ៤៩
បញ្ញាស, បណ្ណាស...................................... ៥០

| សព្ទបាឡី | សព្ទប្រែ |
|---|---|
| ឯកបញ្ញាស, ឯកបណ្ណាស ............................ | ៥១ |
| ទ្វេបញ្ញាស, ទ្វេបណ្ណាស.............................. | ៥២ |
| តេបញ្ញាស, តេបណ្ណាស .............................. | ៥៣ |
| ចតុបញ្ញាស, ចតុបណ្ណាស.............................. | ៥៤ |
| បញ្ចបញ្ញាស, បញ្ចបណ្ណាស.......................... | ៥៥ |
| ឆបញ្ញាស, ឆបណ្ណាស.................................. | ៥៦ |
| សត្តបញ្ញាស, សត្តបណ្ណាស........................... | ៥៧ |
| អដ្ឋបញ្ញាស, អដ្ឋបណ្ណាស............................. | ៥៨ |
| ឯកូនសដ្ឋី, ឩនសដ្ឋី .................................... | ៥៩ |
| សដ្ឋី.............................................................. | ៦០ |
| ឯកសដ្ឋី .......................................................... | ៦១ |
| ទ្វេសដ្ឋី, ទ្វាសដ្ឋី ........................................... | ៦២ |
| តេសដ្ឋី ............................................................ | ៦៣ |
| ចតុសដ្ឋី .......................................................... | ៦៤ |

សព្ទបាឡី | សព្ទប្រែ

បញ្ចសង្ខ្យា ........................................ ៦៥
ឆសង្ខ្យា ........................................ ៦៦
សត្តសង្ខ្យា ........................................ ៦៧
អដ្ឋសង្ខ្យា ........................................ ៦៨
ឯកូនសត្តតិ, ឩនសត្តតិ, ឯកូនសត្តរិ,
ឩនសត្តរិ ........................................ ៦៩
សត្តតិ, សត្តរិ ........................................ ៧០
ឯកសត្តតិ, ឯកសត្តរិ ........................................ ៧១
ទ្វេសត្តតិ, ទ្វេសត្តរិ, ទ្វាសត្តតិ, ទ្វាសត្តរិ .............. ៧២
តេសត្តតិ, តេសត្តរិ ........................................ ៧៣
ចតុសត្តតិ, ចតុសត្តរិ ........................................ ៧៤
បញ្ចសត្តតិ, បញ្ចសត្តរិ ........................................ ៧៥
ឆសត្តតិ, ឆសត្តរិ ........................................ ៧៦
សត្តសត្តតិ, សត្តសត្តរិ ........................................ ៧៧
អដ្ឋសត្តតិ, អដ្ឋសត្តរិ ........................................ ៧៨

សព្ទបាឡី សព្ទប្រែ

ឯកូនអសីតិ, ឯកូនាសីតិ, ឩនអសីតិ,
ឩនាសីតិ ........................................ ៧៩
អសីតិ ........................................ ៨០
ឯកអសីតិ, ឯកាសីតិ ........................................ ៨១
ទ្វេអសីតិ, ទ្វាសីតិ ........................................ ៨២
តេអសីតិ, ត្យាសីតិ ........................................ ៨៣
ចតុអសីតិ, ចតុរាសីតិ ........................................ ៨៤
បញ្ចអសីតិ, បញ្ចាសីតិ ........................................ ៨៥
ឆអសីតិ, (ឆាសីតិ), ឆឡាសីតិ, ឆឡាសីតិ ........................................ ៨៦
សត្តអសីតិ, សត្តាសីតិ ........................................ ៨៧
អដ្ឋអសីតិ, អដ្ឋាសីតិ ........................................ ៨៨
ឯកូននវុតិ, ឩននវុតិ ........................................ ៨៩
នវុតិ ........................................ ៩០
ឯកនវុតិ ........................................ ៩១
ទ្វេនវុតិ, ទ្វានវុតិ ........................................ ៩២

| សព្ទបាឡី | សព្ទប្រែ |
|---|---|
| តេនវុតិ | ៩៣ |
| ចតុនវុតិ | ៩៤ |
| បញ្ចនវុតិ | ៩៥ |
| ឆនវុតិ, ឆន្នវុតិ | ៩៦ |
| សត្តនវុតិ | ៩៧ |
| អដ្ឋនវុតិ | ៩៨ |
| ឯកូនសតំ, ឩនសតំ | ៩៩ |

## ផ្នែកទី ៣- វិធីរាប់ពីត្រឹមរយដល់កោដិ

| សព្ទបាឡី | | សព្ទប្រែ |
|---|---|---|
| សតំ | រយ | (១០០) |
| សហស្សំ | ពាន់ | (១.០០០) |
| ទសសហស្សំ | ម៉ឺន | (១០.០០០) |
| សតសហស្សំ, (លក្ខំ) | សែន | (១០០.០០០) |
| ទសសតសហស្សំ | លាន | (១.០០០.០០០) |
| កោដិ | កោដិ | (១០.០០០.០០០) |

## ផ្នែកទី ៤- វិធីរាប់ពីត្រឹមបកោដិដល់អសង្ខេយ្យ

| សព្ទបាឡី | សព្ទប្រែ |
|---|---|
| បកោដិ ........................... | រយសែនកោដិ |
| កោដិបកោដិ .................... | រយសែនបកោដិ |
| នហុតំ ............................ | រយសែនកោដិបកោដិ |
| និន្នហុតំ .......................... | រយសែននហុត |
| អក្ខោភិនី ......................... | រយសែននិន្នហុត |
| ពិន្ទុ ................................. | រយសែនអក្ខោភិនី |
| អព្ពុទំ .............................. | រយសែនពិន្ទុ |
| និរព្ពុទំ ............................ | រយសែនអព្ពុទៈ |
| អហហំ ........................... | រយសែនអព្ពុទៈ |
| អពពំ .............................. | រយសែនអហហៈ |
| អដដំ .............................. | រយសែនអពពៈ |
| សោគន្ធិកំ ........................ | រយសែនអដដៈ |
| ឧប្បលំ ........................... | រយសែនសោគន្ធិកៈ |
| កុមុទំ .............................. | រយសែនឧប្បលៈ |

សព្ទបាឡី | សព្ទប្រែ
---|---
បុណ្ឌរីកំ........................ | រយសែនកុមុទៈ
បទុមំ........................... | រយសែនបុណ្ឌរីកៈ
កថានំ ......................... | រយសែនបទុមៈ
មហាកថានំ ................... | រយសែនកថានៈ
អសំខេយ្យំ.................... | រយសែនមហាកថានៈ ។

## សេចក្តីពន្យល់ដោយសង្ខេប

[៩២] វិធីរាប់បកតិសំខ្យា ដែលបានរៀបរៀងមកហើយនោះ, បានជាចែកចេញជា ៤ ផ្នែក, ពីព្រោះមានសេចក្តីប្លែកគ្នាខ្លះ គួរឲ្យឈោងដល់សេចក្តីអធិប្បាយ ដូចមានតទៅនេះ

ផ្នែកទី ១- តាំងពី "១" ដល់ចំនួន "១០" ជាសំខ្យាមានដំណើរប្រាប់ចំនួនដាច់ខាតដោយឡែក ៗ រាល់សព្ទ ឥតមានវិធីផ្សំឬផ្លាស់ប្រែឡើយ គឺមិនមានវិធីឲ្យតាំង "ឯក" (១) ពីរដងហើយផ្លាស់ "ឯក" ទាំង ២ ធ្វើជា "ទ្វិ" (២) ឬតាំង "ឯក" និង "ទ្វិ" ហើយផ្លាស់សព្ទទាំង ២ នេះធ្វើជា "តិ" (៣) ជាដើមនោះ

ឡើយ ប៉ុន្តែក្នុងភាសាខ្មែរយើង ត្រង់សំខ្យា ៤ អន្លើ គឺត្រង់ "៦, ៧, ៨, ៩" នេះ រាប់ចេញពាក្យមានចំនួនផ្សំជាមួយនឹង "ប្រាំ" ជាដរាប គឺប្រាំនិងមួយជា "ប្រាំមួយ" (ឆ), ប្រាំនិងពីរជា "ប្រាំពីរ" (សត្ត), ប្រាំនិងបីជា "ប្រាំបី" (អដ្ឋ), ប្រាំនិងបួនជា "ប្រាំបួន" (នវ) ។

ផ្នែកទី ២- តាំងពីចំនួន "១១" រៀងទៅដល់ចំនួន "៩៩" ជាសំខ្យាមានវិធីឲ្យផ្សំនឹងចំនួនឯទៀត ហើយនិងវិធីផ្លាស់រូបធ្វើឲ្យក្លាយចាកភាពដើមខ្លះ ឲ្យប្លែកខុសចាកភាពដើមខ្លះ ដូចយ៉ាងចំនួន "១១" ឲ្យតាំងដូច្នេះគឺ បុំ. "ឯកោ ច ទស ច" ឥ. "ឯកា ច ទស ច", នបុំ. "ឯកំ ច ទស ច" (ប្រើតាមលំនាំលិង្គរបស់នាមនាម ដែលសំខ្យាត្រូវប្រាប់ចំនួន) ហើយសម្រេចរូបជា "ឯកាទស" ឬ "ឯការស" (ទាំង ៣ លិង្គដូចគ្នា) ប្រែថា "មួយនិងដប់", តែក្នុងភាសាយើង ត្រង់ពាក្យថា "និង" ក្លាយមកជាពាក្យថា "ដន់" ប្រើរាប់តាមពាក្យធម្មតាថា "មួយដន់ដប់" ។ ន័យមួយទៀត ឲ្យតាំង, ត្រង់បុំ.

“ឯកេន អធិកា ទស”, ត. “ឯកាយ អធិកា ទស”, នបុំ. “ឯកេន អធិកានិ ទស” ហើយសម្រេចរូបជា “ឯកាទស” ឬ “ឯការស” (ដូចន័យមុន) ប្រែថា “ដប់ក្រៃលែងដោយមួយ”, ក្នុងភាសាយើង កាត់ពាក្យថា “ក្រៃលែងដោយ” នេះចេញ ប្រើត្រឹមតែពាក្យថា “ដប់មួយ” ។ តាំងពី “ទ្វាទស” ឬ “ពារស” (១២) ជាដើមរៀងទៅក៏មានន័យដូចគ្នា ប្លែកគ្នាតែរូបសព្ទដែលប្រាប់ចំនួននិងលំនាំលិង្គ, វចនៈ ប៉ុណ្ណោះ ។ ប៉ុន្តែត្រង់ចំនួន “២០, ៣០, ៤០, ៥០, ៦០, ៧០, ៨០, ៩០, នេះ ឲ្យតាំង “ទស” (១០) តាមចំនួនសំខ្យា ហើយឲ្យផ្លាស់ “ទស” ទាំងអស់តាមចំនួន ធ្វើជារូបសព្ទទាំងនោះ ដូចយ៉ាង “២០” ឲ្យតាំង “ទស” ២ ដង ដូច្នេះ “ទស ច ទស ច” ប្រែថា “ដប់និងដប់” គឺ “ដប់២ដង”, ហើយឲ្យផ្លាស់ “ទស” ទាំង ២ ធ្វើជា “វីស” ឬជា “វីសតិ”, សព្ទនេះក៏គង់នៅមានសេចក្តីថា “ដប់២ដង” ដូចដើម ពីព្រោះផ្លាស់រូបចេញមកពី “ទស” ទាំង ២ ប៉ុន្តែភាសាយើងហៅថា “ម្ភៃ” ក៏គឺ “ដប់ ២ ដង” នុ៎ះឯង ។ តាំងពី “៣០” រៀងទៅក៏មានន័យដូចគ្នា

គឺឲ្យតាំង "ទស" ៣ ដង ។ល។ "ទស" ៩ ដង ហើយផ្លាស់ "ទស" ទាំងនោះតាមចំនួនធ្វើជា "តឹស" ឬជា "តឹសតិ" (៣០) ។ល។ ជា "នវុតិ"[១] (៩០) ។ ឯត្រង់ចំនួន "១៩, ២៩, ៣៩, ៤៩, ៥៩, ៦៩, ៧៩, ៨៩, ៩៩" នេះ បើតាមរូបបកតិសំខ្យាក្នុងភាសាបាឡី "នវ" ថា "៩" គួរតែផ្សំ "នវ" នេះជាមួយនឹង "ទស" (១០) សម្រេចរូបជា "នវទស" (១៩) ផ្សំជាមួយនឹង "វីស" ឬ "វីសតិ" (២០) សម្រេចរូបជា "នវវីស" ឬ "នវវីសតិ" (២៩) ដូច្នេះជាដើមរៀងទៅក៏ឃើញថាជាការងាយតាមរបៀបវិធីផ្សំសំខ្យាសព្ទ ប៉ុន្តែរបៀបនេះ ក្នុងភាសាបាឡីមិនដែលប្រើឡើយ ឲ្យប្រើផ្សំនឹងសព្ទគឺ "ឯកូន" ប្រែថា "ខ្វះមួយ" ឬ "ឩន" ប្រែថា "ខ្វះ" នេះវិញ គឺឲ្យផ្សំជា "ឯកូនវីស, ឯកូនវីសតិ" ប្រែថា "២០ ខ្វះ ១" គឺ "១៩" ឬ "ឩនវីស, ឩនវីសតិ" ប្រែថា "២០ ខ្វះ" ក៏គឺ "១៩" ។ល។ "ឯកូនសតំ" ឬ "ឩនសតំ" ប្រែថា "១០០ ខ្វះ១"

---

១ រូបសិទ្ធិទាំងនេះ តាមន័យក្នុងកច្ចាយនៈ មានវិធីផ្សេងអំពីបែបនេះដោយច្រើន ។ (ចូរមើលក្នុងកច្ចាយនបករណ៍តទ្ធិតត្រង់និយាយអំពីសំខ្យា) ។

ឬ "១០០ ខ្ទះ" គឺ "៩៩" ។ ប៉ុន្តែវិធីផ្សំសំខ្យាសព្ទជាមួយនឹងឱនសព្ទ មិនសូវប្រើ ច្រើនប្រើផ្សំជាមួយនឹងឯកូនសព្ទ ពីព្រោះឯកូនសព្ទមានសេចក្តីជាក់លាក់ជាង ។

ផ្នែកទី៣ - តាំងពីត្រឹម "សតំ" (១០០) រៀងទៅដល់ "កោដិ" (កោដិ) មានវិធីឲ្យតាំងជាដំណើរលេខគុណរៀងឡើងទៅតាមលំដាប់ គឺឲ្យតាំង "ទស" (១០) ហើយយក "ទស" (១០) គុណជា "សតំ" (១០០), ឲ្យតាំង "សតំ" យក "ទស" គុណជា "សហស្សំ" (១០០០), ឲ្យតាំង "សហស្សំ" យក "ទស" គុណជា "ទសសហស្សំ" (១០ពាន់) គឺ "ម៉ឺន", ឲ្យតាំង "ទសសហស្សំ" យក "ទស" គុណជា "សតសហស្សំ" (១០០ពាន់) គឺ "សែន" ឬគុណជា "លក្ខំ" ក៏ប្រែថា "សែន" ដែរ, ឲ្យតាំង "សតសហស្សំ" ឬ "លក្ខំ" យក "ទស" គុណជា "ទសសតសហស្សំ" (១០សែន) គឺ "លាន", ឲ្យតាំង "ទសសតសហស្សំ" យក "ទស" គុណជា "កោដិ" (កោដិ) ។

តាមពាក្យមេសូត្រក្នុងកច្ចាយនបករណ៍ថា ឲ្យតាំង ១០ យក ១០ គុណជារយ, តាំងរយយក ១០ គុណជាពាន់, តាំង

ពាន់យក ១០ គុណជាម៉ឺន, តាំងម៉ឺនយក ១០ គុណជាសែន, តាំងសែនយក ១០ គុណជាលាន, តាំងលានយក ១០ គុណជាកោដិ, (តាំងសែនកោដិយករយគុណជាបកោដិ, ...) ។

ផ្នែកទី ៤- តាំងពីត្រឹម "បកោដិ" (បកោដិ) រៀងទៅដល់ "អសំខេយ្យំ" (អសំខេយ្យ) មានវិធីឲ្យតាំងជាដំណើរលេខគុណដែរ ប៉ុន្តែឲ្យតាំង "សែន" ហើយយក "រយ" គុណតាមលំដាប់រៀងឡើងទៅ គឺឲ្យតាំង "សែនកោដិ" ហើយយក "សតំ" (១០០) គុណជា "បកោដិ" គឺ "រយសែនកោដិ", ឲ្យតាំង "សែនបកោដិ" យក "សតំ" (១០០) គុណជា "កោដិ-បកោដិ" គឺ "រយសែនបកោដិ", ឲ្យតាំង សែនកោដិបកោដិ" យក "សតំ" (១០០) គុណជា "អក្ខោភិនី" គឺ "រយសែនកោដិ-បកោដិ" ។ល។ ឲ្យតាំង "សែនមហាកថានំ" យក "សតំ" (១០០) គុណជា "អសំខេយ្យំ" គឺ "រយសែនមហាកថាន" ។

តាមន័យក្នុងកច្ចាយនបករណ៍ (ដូចសេចក្តីដែលបានពោលមកហើយនោះ) លោកប្រាប់ថាដល់មកចំនួន "អសំ-ខេយ្យ" មានសូន្យ "១៤០" សូន្យនៅមុខលេខខ្ទង់រាយ ។

តែក្នុងគម្ពីរសព្ទសាស្ត្រទាំងឡាយខ្លះ សម្ដែងប្រាប់ន័យប្លែកអំពីបែបក្នុងកច្ចាយនៈក៏មាន ។ ខ្ញុំមិនអធិប្បាយដោយសព្វគ្រប់ក្នុងទីនេះទេ ពីព្រោះឃើញថាកុំឲ្យយឺតដំណើរសិក្សារបស់កុលបុត្រអ្នកទើបនឹងរៀនថ្មី ។

## វិធីផ្សំឧត្តរសព្ទជាមួយនឹងសំខ្យាសព្ទ

[៩៣] សំខ្យាសព្ទតាំងពីចំនួន "សតំ" (១០០) ឡើងទៅដែលផ្សំដោយចំនួន "សេស" ជាមួយនឹងសំខ្យាសព្ទផងគ្នាដូចជាត្រង់ចំនួន "១០១, ១០២" ជាដើម នឹងផ្សំផ្ទាល់ជាមួយនឹង "ឯក" (១), "ទ្វិ" (២) ឲ្យជា "ឯកសតំ,[១] ទ្វិសតំ" ហើយសំដៅយកសេចក្ដីថា "១០១, ១០២" ក៏បានដែរ តែពុំសូវជាក់លាក់ បើផ្សំយ៉ាងនេះត្រូវប្រែថា "មួយរយ,[១] ពីរយ" ដូច្នេះវិញទើបច្បាស់លាស់ជាង ។ បើសំដៅយកសេចក្ដីថា "១០១, ១០២" នោះ ត្រូវផ្សំជាមួយនឹងសព្ទគឺ "ឧត្តរ" ដែលប្រែថា

---

១ ត្រង់ចំនួននេះ ក្នុងបាឡីភាសា បើទុកជាមិនមាន "ឯក" ផ្សំជាមួយផងយ៉ាងនេះ មានតែ "សតំ" ទទេប៉ុណ្ណោះ ក៏គង់មានសេចក្ដីថា "មួយរយ" ពេញទី ។ តាំងពី "សហស្សំ" រៀងទៅក៏ដូចគ្នានឹងន័យនេះដែរ ។ បើតាំងពីត្រឹមចំនួន "២០០" ជាដើមឡើងទៅនោះទើបត្រូវតែផ្សំនឹងសំខ្យាសព្ទចំនួនសេសមាន "ទ្វិ" ជាដើម ដោយដាច់ខាត ។

"លើស" នេះវិញទើបជាក់ប្រាកដឥតសង្ស័យ ត្រូវដាក់ "ឧត្តរ" ត្រង់ចន្លោះនៃសំខ្យាទាំង ២ កុំឲ្យសំខ្យានិងសំខ្យាតផ្ទាល់គ្នា ដូចជា "១០១, ១០២" ត្រូវផ្សំដូច្នេះ "ឯក-ឧត្តរ-សតំ" សម្រេចរូបជា "ឯកុត្តរសតំ" ប្រែថា "១០០ លើសដោយ ១" គឺ "១០១" "ទ្វិ-ឧត្តរ-សតំ" សម្រេចរូបជា ទ្វយុត្តរសតំ" (១០០ លើសដោយ ២) គឺ "១០២" ។ អ្នករៀនត្រូវសង្កេតវិធីផ្សំឲ្យត្រាតែយល់ជាក់ប្រាកដក្នុងចិត្ត នោះទើបអាចនឹងប្រើសំខ្យាពួកនេះមិនច្រឡំ ។

វិធីផ្សំដូចមានរបៀបជាបែបឲ្យឃើញខ្លះខាងក្រោយនេះ:

| សព្ទរាយ | សព្ទសម្រេច | សព្ទប្រែ |
|---|---|---|
| ឯក-ឧត្តរ[១]-សតំ | ឯកុត្តរសតំ | ១០១ |
| ទ្វិ-ឧត្តរ-សតំ | ទ្វយុត្តរសតំ | ១០២ |

១ ត្រង់សព្ទរាយនេះ តាមដំណើរក្នុងសមាសត្រូវតាំងជាវិគ្គហៈដូច្នេះ "ឯកេន - ឧត្តរំ > ឯកុត្តរំ ។ ឯកុត្តរំ-សតំ > ឯកុត្តរសតំ ។ ទ្វីហិ-ឧត្តរំ > ទ្វយុត្តរំ ។ ទ្វយុត្តរំ-សតំ > ទ្វយុត្តរសតំ" ។ល។ លុះអ្នករៀនបានសិក្សាដល់ទៅ សមាសនិទ្ទេសខាងមុខ ក៏គង់នឹងបែរយោបល់ងាកត្រឡប់យល់មករកវិធីផ្សំសព្ទទាំងនេះវិញដោយងាយ។ តែក្នុងកាលដែលកំពុងសិក្សានាមនិទ្ទេសនេះ អ្នករៀនមិនបាច់ឈោងគំនិតស្រាវជ្រាវទៅរកវិធីតាំងវិគ្គហៈក្នុងសមាសនិទ្ទេសនោះឡើយ ត្រូវខំប្រឹងសង្កេតឲ្យយល់ចំពោះតែត្រឹមវិធីផ្សំឧត្តរសព្ទជាមួយនឹងសំខ្យាសព្ទប៉ុណ្ណោះឯង ។

| សព្ទរាយ | សព្ទសម្រេច | សព្ទប្រែ |
|---|---|---|
| **តិ.** ឧត្តរ - សហស្សំ | ត្យុត្តរសហស្សំ | ១០០៣ |
| **ចតុ.**ឧត្តរ-សហស្សំ- | ចតុត្តរសហស្សំ | ១០០៤ |
| **បញ្ច.**ឧត្តរ - ទសស-<br>ហស្សំ | បញ្ចុត្តរទសសហស្សំ | ១០,០០៥ |
| **វីស.** ឧត្តរ - ទសស-<br>ហស្សំ | វីសុត្តរទសសហស្សំ | ១០,០២០ |
| **បញ្ញាស.** ឧត្តរ - ស-<br>តសហស្សំ | បញ្ញាសុត្តរសតស-<br>ហស្សំ | ១០០.០៥០ |

ន័យមួយទៀត បើមានសំខ្យាសព្ទនាមផងគ្នាក្តី សំខ្យាគុណនាមផងគ្នាក្តី សំខ្យាសព្ទនាមនិងសំខ្យាគុណនាមក្តី ដែលជាចំនួនសេសរបស់សំខ្យានាមនាម នៅផ្ទាល់ប្រទ្បំនៅនោះផង យ៉ាងនេះ ក៏ត្រូវប្រើ "ឧត្តរ" ដាក់រាំងត្រង់ចន្លោះនៃសំខ្យាសព្ទ-នាមឬសំខ្យាគុណនាមនោះដែរ ដូចជា "ទ្វិ-តិសតំ ចតុ-បញ្ចស-ហស្សំ, នវ-នវសតសហស្សំ" ត្រូវដាក់ "ឧត្តរ" រាំងត្រង់ចន្លោះ

ជា ទ្វយុត្តរតិសតំ "៣០២", ចតុត្តរបញ្ចសហស្សំ "៥០០៤", នវុត្តរនវសតសហស្សំ" ៩០០,០០៩ (៩សែន៩)" ។

វិធីផ្សំដូចមានរបៀបជាបែបឲ្យឃើញខ្លះខាងក្រោយនេះ:

| សព្ទរាយ | សព្ទសម្រេច | សព្ទប្រែ |
|---|---|---|
| ចតុ. ឧត្តរ-ទ្វិសតំ | ចតុត្តរទ្វិសតំ | ២០៤ |
| តិ. ឧត្តរ-បញ្ចសតំ | ត្យុត្តរបញ្ចសតំ | ៥០៣ |
| បញ្ច. ឧត្តរ-នវសតំ | បញ្ចុត្តរនវសតំ | ៩០៥ |
| នវ.ឧត្តរ-សត្តសហស្សំ | នវុត្តរសត្តសហស្សំ | ៧០០៩ |
| ចត្តាឡីស.ឧត្តរ-តិសហស្សំ | ចត្តាឡីសុត្តរតិសហស្សំ | ៣០៤០ |
| តឹស.ឧត្តរ-ឆសតសហស្សំ | តឹសុត្តរឆសតសហស្សំ | ៦០០,០៣០ |

## វិធីផ្សំអធិកាសព្ទជាមួយនឹងសំខ្យាសព្ទ

[៩៤] បើមានសំខ្យានាមនាមតាំងពី "សតំ" ចំនួនរយជាដើមឡើងទៅនៅម្ខាងខាងដើម ហើយមានសំខ្យាសព្ទនាមឬ

សំខ្យាគុណនាម នៅម្ខាងខាងចុង ត្រង់ចន្លោះនៃសំខ្យាទាំង ២, នោះនឹងប្រើ "ឧត្តរ" ផ្សំរាំងដូចន័យមុនពុំបានឡើយ, កាលបើដូច្នេះ, ត្រូវប្រើផ្សំជាមួយនឹងសព្ទគឺ "អធិក" ដែលប្រែថា "ក្រៃលែង" នេះវិញ ដូចជា "ទ្វិសត-ទ្វិសហស្សំ" កុំផ្សំតាមទំនងន័យមុនជា "ទ្វិសតុត្តរទ្វិសហស្សំ" ដូច្នេះឡើយ ត្រូវផ្សំដូច្នេះវិញជា "ទ្វិសតាធិកទ្វិសហស្សំ" ប្រែថា" ពីរពាន់ក្រៃលែងដោយពីររយ" គឺ "២២០០" ។

វិធីផ្សំដូចមានរបៀបជាបែបឲ្យឃើញខ្លះខាងក្រោយនេះ:

| សព្ទរាយ | សព្ទសម្រេច | សព្ទប្រែ |
|---|---|---|
| បញ្ចសត-អធិក-តិស-ហស្សំ | បញ្ចសតាធិកតិស-ហស្សំ | ៣៥០០ |
| តិសត-អធិក-បញ្ចស-ហស្សំ | តិសតាធិកបញ្ចស-ហស្សំ | ៥៣០០ |
| ចតុសត-អធិក-ឆស-ហស្សំ | ចតុសតាធិកឆស-ហស្សំ | ៦៤០០ |

| សព្ទរាយ | សព្ទសម្រេច | សព្ទប្រែ |
|---|---|---|
| ឆសត-អធិក-សត្តស-ហស្សំ | ឆសតាធិកសត្តស-ហស្សំ | ៧៦០០ |
| សត្តសហស្ស-អធិក-តិទសសហស្សំ | សត្តសហស្សាធិក-តិទសសហស្សំ | ៣៧,០០០ |
| តិទសសហស្ស-អធិក-តិសតសហស្សំ | តិទសសហស្សាធិ-កតិសតសហស្សំ | ៣៣០,០០០ |

## វិធីផ្សំឧត្តរនិងអធិកលាយគ្នា

[៩៥] បើមានសំខ្យាតាំងពីត្រឹមចំនួន "១០០០" ឡើងទៅផ្សំលាយជាមួយនឹងសំខ្យាចំនួន "១០០" ហើយនិងចំនួន "១០" គឺត្រង់ចំនួន "១០, ២០, ៣០, ៤០, ៥០" ជាដើមរួមចូលជាមួយគ្នា, នោះត្រូវប្រើ "ឧត្តរ" និង "អធិក" លាយគ្នាគឺត្រូវដាក់រាំងត្រង់ចន្លោះ ៗ នៃសំខ្យាទាំងនោះ តាមន័យដែលបានពន្យល់មកហើយ ដូចជា តេសត្តតិ "៧៣", ចតុសតំ "៤០០", ទ្វិសហស្សំ "២០០០" ត្រូវដាក់ "ឧត្តរ" និង "អធិក"

រាំងត្រង់ចន្លោះតាមកន្លែងដែលត្រូវផ្សំជា "តេសត្តតិ - ឧត្តរ - ចតុ-សត - អធិក - ទ្វិសហស្សំ" សម្រេចរូបជា "តេសត្តតុត្តរចតុសតាធិកទ្វិសហស្សំ" ប្រែថា "ពីរពាន់ក្រៃលែងដោយបួនរយលើសដោយ ៧៣" គឺ "២៤៧៣" ។ តឹស "៣០" នវសត "៩០០", សហស្សំ "១០០០" ផ្សំជា "តឹស - ឧត្តរ - នវសត - អធិក - សហស្សំ" សម្រេចរូបជា "តឹសុត្តរនវសតាធិកសហស្សំ" ប្រែថា "មួយពាន់ក្រៃលែងដោយ ៩ រយលើសដោយ ៣០ គឺ "១៩៣០" ។ ទ្វេនវុតិ "៩២", ទ្វិសត "២០០", សហស្សំ "១០០០" ផ្សំជា "ទ្វេនវុតិ - ឧត្តរ - ទ្វិសត - អធិក - សហស្សំ" សម្រេចរូបជា "ទ្វេនវុត្យុត្តរទ្វិសតាធិកសហស្សំ" ប្រែថា "មួយពាន់ក្រៃលែងដោយពីររយលើសដោយ ៩២" គឺ "១២៩២" ជាដើម ។

## រូបសិទ្ធិដោយសង្ខេប

[៩៦] វិធីផ្សំសំខ្យាសព្ទចូលជាមួយនឹង "ឧត្តរ, អធិក" នេះ បើស្រះរបស់ព្យញ្ជនៈដែលរៀងខាងដើម "ឧត្តរ" ជាស្រះ "ឥ" ឬ

"ឰ" ត្រូវផ្លាស់ស្រៈ ឥ ឬ ឰ ធ្វើជា "យ" ឬលុប ឥ ឬ ឰ ចេញក៏បានខ្លះ ដូចជា "អសីតិ - ឧត្តរ - តិសតំ" ជា "អសីត្យុត្តរ-តិសតំ" ឬជា "អសីតុត្តរតិសតំ" (៣៨០), "សដ្ឋី - ឧត្តរ - ចតុ-សតំ" ជា "សដ្ឋ្យុត្តរចតុសតំ" ឬជា "សដ្ឋុត្តរចតុសតំ" (៤៦០) ។ នឹងផ្លាស់ "ឥ" ជា "អយ" ក៏បានខ្លះ ដូចជា "តិ - ឧត្តរ - បញ្ចសតំ" ជា "តយុត្តរបញ្ចសតំ" (៥០៣) ។ បើជាស្រៈ "ឧ" ត្រូវលុប ឧ របស់ព្យញ្ជនៈខាងដើមចេញ ដូចជា "ចតុ - ឧត្តរ - ទ្វិសតំ" ជា "ចតុត្តរទ្វិសតំ" (២០៤) ។ ម្យ៉ាងទៀត បើនឹងចុះ "រ" អា-គមដាក់ត្រង់ចន្លោះខាងដើមឧត្តរ ក៏បានខ្លះដោយអន្លើ ដូចជា "បញ្ច - ឧត្តរ - សតំ" មិនធ្វើជា "បញ្ចុត្តរសតំ", ចុះ "រ" អាគមជា "បញ្ចរុត្តរសតំ" (១០៥), "ឆ - ឧត្តរ - សហស្សំ" មិនធ្វើជា "ឆុត្តរសហស្សំ", ចុះ "រ" អាគមជា "ឆរុត្តរសហស្សំ" (១០០៦) ។ ឯចំណែកខាង "អធិក" ត្រូវតែទីឃៈ "អ" ជា "អា" ជាដរាប ដូចជា "បញ្ចសត - អធិក - តិសហស្សំ" ជា "បញ្ចសតាធិកតិស-ហស្សំ" (៣៥០០) ។

## បកតិសំខ្យាប្រើជានាមនាម

[៩៧] សេចក្តីដែលបាននិយាយមកហើយ ក្នុងខាងដើម ត្រង់លេខ ៩០ ត្រង់សេចក្តីដែលថា បកតិសំខ្យាតាំងពីត្រឹម ឯកូនសតំ ឬ ឩនសតំ "៩៩" រៀងទៅដល់ អសំខេយ្យំ "អសំ-ខេយ្យ" ជួនណាប្រើជាគុណនាម ហៅថា សំខ្យាគុណនាម, ជួនណាប្រើជានាមនាម ហៅថា សំខ្យានាមនាម នោះ ព្រោះហេតុសំខ្យាពួកនេះមានដំណើរមិនទៀង គឺ ជួនណាប្រើជាគុណ-បទជាវិសេសនៈរបស់នាមនាម ប្រាប់ចំនួននាមនាមនោះឲ្យដឹងថា មានចំនួនប៉ុណ្ណោះៗ យ៉ាងនេះជាសំខ្យាគុណនាម, ជួនក៏ប្រើចេញដំណើរប្រាប់ចំនួនរបស់នាមនាម ដោយដាច់ខាតលើខ្លួន មិនសម្តែងអាការជាបទវិសេសនៈរបស់នាមនាមឡើយ យ៉ាងនេះជានាមនាម ។ នឹងសម្តែងអំពីសំខ្យានាមនាមជាមុន ។

អ្នកសិក្សាត្រូវសង្កេតដូច្នេះ កាលណាបើនាមនាមបទណាដែលជារូបចំនួនប៉ុន្មាន ៗ នោះ ប្រកបផ្សំនឹងឆដ្ឋីវិភត្តិ ទោះជាបទវាយក្តី, រួមចូលជាមួយនឹងសំខ្យានោះជាបទសមាសក្តី

ហើយដែលនឹងឲ្យដឹងថា នាមនាម បទនោះមានចំនួនតិចច្រើន ប៉ុណ្ណោះ ៗ នោះ គឺ សំខ្យាពួកនេះឯង ប្រកបផ្សំនឹងបឋមាវិភត្តិ ប្រើជាបទប្រធានក្តី ប្រកបផ្សំនឹងវិភត្តិឯទៀតក្តី សម្តែងអាការ ចេញមុខប្រាប់ចំនួនផ្ទាល់លើខ្លួនតែម្តង មិនមែនជាបទវិសេសនៈ របស់នាមនាមណាទ្បើយ យ៉ាងនេះ ជានាមនាម ហៅថាសំខ្យា-នាមនាម ។ (ដែលជាបទរាយ) ដូចជាៈ ជនានំ ឯកូនសតំ "រី (ចំនួន) ៩៩ នៃជនទាំងទ្បាយ", ភិក្ខូនំ សតំ"រយ នៃ ភិក្ខុទាំងទ្បាយ", ឥត្ថីនំ សហស្សំ "រីពាន់ នៃស្ត្រីទាំងទ្បាយ", កហាបណានំ ទសសហស្សំ "រីម៉ឺន នៃកហាបណៈទាំងទ្បាយ", ភិក្ខូនំ សតសហស្សំ "រីសែន នៃភិក្ខុទាំងទ្បាយ, យោជានំ ទសសតសហស្សំ "រីលាន នៃទាហានទាំងទ្បាយ", មនុស្សានំ កោដឹ "នូវកោដិ នៃមនុស្សទាំងទ្បាយ" ។ (ដែលជាបទសមាស) ដូចជាៈ ភិក្ខុសតំ "រីរយនៃភិក្ខុ", មនុស្សកោដិយោ "រីកោដិ នៃមនុស្សទាំងទ្បាយ" កហាបណសហស្សេន "ដោយពាន់នៃ កហាបណៈ", ទ្វិន្នំ ភិក្ខុសតានំ "ដល់រយនៃភិក្ខុទាំងទ្បាយ ពីរ" ជាដើម ។

ដែលនឹងកំណត់ឲ្យដឹងថា សំខ្យាពួកនេះជាគុណនាមនោះ ត្រូវសង្កេតដូច្នេះ កាលណាបើសំខ្យាពួកនេះរួមចូលជាពហុព្វី-ហិសមាសក្ដី ប្រើតាមលំនាំខ្លួនឯងចេញអាការជាបទវិសេសនៈរបស់នាមនាមក្ដី យ៉ាងនេះ ជាគុណនាម ហៅថាសំខ្យាគុណ-នាម (ដែលជាពហុព្វីហិសមាស) ដូចជាៈ បញ្ចសតមត្តា ភិក្ខូ "វីភិក្ខុទាំងឡាយ មានរយប្រាំជាប្រមាណ" អនេកសហស្សា ហត្ថី "វីដំរីទាំងឡាយ មានពាន់មិនមែនតែមួយ គឺច្រើនពាន់" ។ ដែលប្រើតាមលំនាំខ្លួនឯងជាបទវិសេសនៈនោះ ពិតជាចេញអា-ការជាបទវិសេសនៈដូចជាគុណនាមមែន ប៉ុន្តែសំខ្យាពួកនេះ មិនបំបែរលិង្គរបស់ខ្លួន ឲ្យងាកទៅតាមលិង្គរបស់នាមនាមដែលមានលិង្គទីទៃអំពីខ្លួននោះទេ ដូចជាៈ សតំ ទណ្ឌោ "វីពិន័យ ១០០", សហស្សំ ទណ្ឌោ "វីពិន័យ ១០០០", សហស្សមបិ ចេ វាចា "បើវីវាចា សូម្បីមួយពាន់ម៉ាត់", សតំ សមំ "អស់ឆ្នាំ មួយរយ" ជាដើម ។

ឯបកតិសំខ្យាតាំងពី "ឯក" រៀងដល់ "អដ្ឋនវុតិ" នោះនឹងប្រើចេញអាការជានាមនាម ដូចជាប្រើថា ឯកោ "វីមួយ",

ទេ្វ "វីពីរទាំងឡាយ", បញ្ចហិ "ដោយប្រាំទាំងឡាយ", អដ្ឋនវុតិយា "ដល់ ៩៨" ដូច្នេះជាដើមនោះពុំបានឡើយ ត្រូវប្រើបានចំពោះតែជាបទវិសេសនៈរបស់នាមនាម តែម្យ៉ាងប៉ុណ្ណោះដោយដាច់ខាត គឺត្រូវប្រើដូច្នេះ ឯកោ ជនោ "វីជន មួយនាក់", ទេ្វ ឥត្ថិយោ "វីស្ត្រីទាំងឡាយ ពីរនាក់", បញ្ចហិ កហាបណេហិ "ដោយកហាបណៈទាំងឡាយ ប្រាំ", អដ្ឋនវុតិយា ភិក្ខូនំ "ដល់ភិក្ខុទាំងឡាយ ៩៨ រូប" ។ ព្រោះហេតុនេះឯងហើយទើបបកតិសំខ្យាពួកនេះមានឈ្មោះប្រាកដថា សំខ្យាសព្វនាម, ថា សំខ្យាគុណនាម ដោយដាច់ខាត ។

## បកតិសំខ្យាមានលិង្គនិងវចនៈផ្សេងគ្នា

[៩៨] បកតិសំខ្យាទាំង ៣ ពួកនោះមានលិង្គនិងវចនៈផ្សេងគ្នាតាមដំណើររបស់ខ្លួន ៗ ដូចសេចក្ដីតទៅនេះ

១- ឯក "១" ប្រើបាន ២ យ៉ាង គឺប្រើជាសំខ្យាសព្វនាមក៏បាន ប្រើជាវិសេសនសព្វនាមក៏បាន ។ បើប្រើជាសំខ្យាសព្វនាម ជា តិលិង្គិកៈ បានចំពោះតែជាឯកវចនៈម្យ៉ាង, បើ

ប្រើជាវិសេសនសព្វនាម ជា តិលិង្គិកៈ បានទាំង ២ វចនៈ, ប៉ុន្តែបើប្រើជាវិសេសនសព្វនាម មានកំណត់ឲ្យប្រែថា "ពួកមួយ" ឬថា "មួយពួក" ឧ. ឯកេ ជនា "វីជនទាំងឡាយ ពួកមួយ", ឯកា ឥត្ថិយា "វីស្ត្រីទាំងឡាយ មួយពួក", ឯកានិ កុលានិ "វីត្រកូលទាំងឡាយ មួយផៅ" ជាដើម ។ បើចុះ "ក" អាគមផ្សំជា "ឯកក" ប្រែថា "តែមួយ, តែម្នាក់ឯង, តែឯង" ជាគុណនាម ជា តិលិង្គិកៈ ឃើញមានប្រើតែជាឯកវចនៈ, ត្រង់ឥត្ថី.លិង្គជា "ឯកីកា" ។

២- តាំងពី ទ្វិ "២" រៀងដល់ ចតុ "៤" ជាសំខ្យា-សព្វនាម ជា តិលិង្គិកៈ ប្រើចំពោះបានតែជាពហុវចនៈម្យ៉ាង ។

៣- តាំងពី បញ្ច "៥" រៀងទៅដល់ អដ្ឋារស "១៨" ជាសំខ្យាគុណនាម ជា តិលិង្គិកៈប្រើចំពោះបានតែជាពហុវចនៈម្យ៉ាង ។

៤- តាំងពី ឯកូនវីស, ឯកូនវីសតិ ឬ ឩនវីស, ឩនវីសតិ "១៩" រៀងទៅដល់ អដ្ឋនវុតិ "៩៨" ជាសំខ្យាគុណនាម ជា ឥត្ថីលិង្គ ប្រកបផ្សំនឹងវិភត្តិចំពោះបានតែខាងប៉ែកឯកវចនៈ

ប៉ុន្តែប្រើជាបទវិសេសនៈរបស់នាមនាមបានទាំង ៣ លិង្គ និងវចនៈទាំង ២, តែត្រូវឲ្យមានវិភត្តិស្មើគ្នានឹងវិភត្តិរបស់នាមនាមដែលខ្លួនប្រាប់ចំនួននោះ ដូចជាៈ ប. ឯកូនវីសតិ ជនោ "វីជន ១៩ នាក់", វីសតិ ជនា វីជនទាំងឡាយ ២០ នាក់", ឯកូនតឹសតិត្ថិយោ "វីស្ត្រីទាំងឡាយ ២៩ នាក់", តឹសតិ កមលានិ "វីផ្កាឈូកទាំងឡាយ ៣០ ផ្កា" ។ ទុ. ឯកូនចត្តាឡីសំ បុរិសេ "នូវបុរសទាំងឡាយ ៣៩ នាក់" ។ ត. បញ្ញាសាយ កុមារីហិ "គឺក្មេងស្រីទាំងឡាយ ៥០ នាក់" ។ ច. សដ្ឋិយា ភិក្ខូនំ "ដល់ភិក្ខុទាំងឡាយ ៦០ រូប" ។ បញ្. សត្តតិយា វាណិជេហិ "អំពីឈ្មួញទាំងឡាយ ៧០ នាក់" ។ ឆ. អសីតិយា ហត្ថីនំ "នៃដំរីទាំងឡាយ ៨០" ។ ស. នវុតិយំ ខេត្តេសុ "ក្នុងស្រែទាំងឡាយ ៩០" ជាដើម ។

៥- តាំងពី ឯកូនសតំ ឬ ឩនសតំ "៩៩" រៀងទៅដល់អសំខេយ្យំ "អសំខេយ្យ" លើកលែងតែ ៤ សព្ទគឺ កោដិ, បកោដិ, កោដិបកោដិ, អក្ខោភិនី នេះចេញ, សុទ្ធតែជានបុំសកលិង្គទាំងអស់ ប្រើបានទាំងពីរវចនៈ ។ ឯសព្ទទាំងបួនមានកោដិជាដើម

នោះជាឥត្ថីលិង្គ ប្រើបានទាំងពីរវចនៈ ។ សំខ្យាសព្ទពួកនេះ ប្រើជាគុណនាមក៏បាន ប្រើជានាមនាមក៏បាន (តាមន័យខាងដើមត្រង់លេខ ៩៧) ។

## វិធីបំបែកបកតិសំខ្យា

បកតិសំខ្យាទាំងអស់ដែលមានវិធីបំបែកតាមពួក ដូចបានពោលមកហើយនោះ ត្រង់អាលបនៈមិនមានប្រើទេ ។ នឹងបំបែកឲ្យឃើញជាបែបខ្លះ ដូចមានរបៀបរៀបរៀងតទៅនេះ ។

[៩៩] ឯក "១" បើប្រើជាសំខ្យាសព្ទនាម បំបែកបានចំពោះតែខាងប៉ែកជាឯកវចនៈទាំងបីលិង្គ ដូច្នេះ

| បុំលិង្គ | ឥត្ថីលិង្គ | នបុំសកលិង្គ |
|---|---|---|
| ប. ឯកោ | ប. ឯកា | ប. ឯកំ |
| ទុ. ឯកំ | ទុ. ឯកំ | ទុ. ឯកំ |
| ត. ឯកេន | ត. ឯកាយ | ត. ឯកេន |
| ច. ឯកស្ស | ច. ឯកាយ | ច. ឯកស្ស |
| បញ្ច. ឯកស្មា | បញ្ច. ឯកាយ | បញ្ច. ឯកស្មា |
| ឆ. ឯកស្ស | ឆ. ឯកាយ | ឆ. ឯកស្ស |
| ស. ឯកស្មឹ | ស. ឯកាយ | ស. ឯកស្មឹ |

រូបសិទ្ធិ ត្រង់បុំលិង្គដូច "បុរិស", ត្រង់ឥត្ថីលិង្គដូច "កញ្ញា", ត្រង់នបុំសកលិង្គដូច "កុល" ។

ឯក បើប្រើជាវិសេសនសព្ទនាម មានវិធីបំបែកទាំង ៣ លិង្គព្រមទាំងវចនៈទាំងពីរដូច "យ" សព្ទ ប្លែកខ្លះអំពី យសព្ទ តែត្រង់ ច. ឆ. ឯក. ជា "ឯកិស្សា", ត្រង់ ស. ឯក. ជា ឯកិស្សំ" ដែលមានវិធីដូច "ត" សព្ទនោះប៉ុណ្ណោះ ក្រៅអំពីនោះដូច យសព្ទ ទាំងអស់ ។ (មើលទៅខាងមុខត្រង់លេខ ១១២ និងលេខ ១១៦) ។

[១០០] ទ្វិ "២" បំបែកដូចគ្នាទាំង ៣ លិង្គ ដូច្នេះ:

| ពហុវចនៈ | | | ពហុវចនៈ | | |
|---|---|---|---|---|---|
| ប. | ទ្វេ, | ទុវេ | បញ្ច. | ទ្វីហិ | |
| ទុ. | ទ្វេ, | ទុវេ | ឆ. | ទ្វិន្នំ, | ទុវិន្នំ |
| ត. | ទ្វីហិ | | ស. | ទ្វីសុ | |
| ច. | ទ្វិន្នំ, | ទុវិន្នំ | | | |

## រូបសិទ្ធិ មានមេសូត្រ

| ពហុវចនៈ | ពហុវចនៈ |
|---|---|
| ប. យោសុទ្ធិន្នំទ្វេច | បញ្ច. ដូច ត. ពហុ. |
| ទុ. ដូច ប. ពហុ. | ឆ. ដូច ច. ពហុ. |
| ត. សុនំហីសុច | ស. សុនំហីសុច |
| ចំ. ឧភាទិតោនមិន្នំ ឬ នោចទ្វាទិតោ-នម្ហិ,យោសុទ្ធិន្នំទ្វេច.ឧភាទិតោនមិន្នំ | |

## រូបសិទ្ធិ ឥតមេសូត្រ

| ពហុវចនៈ | ពហុវចនៈ |
|---|---|
| ប. ផ្លាស់ទ្វិនិងយោជាទ្វេ, ជាទុវេ | បញ្ច. ទ្វីហិ ដូច ត. ពហុ. |
| ទុ. ទ្វេ, ទុវេ ដូច ប. ពហុ. | ឆ. ទ្វិន្នំ, ទុវិន្នំ ដូច ច. ពហុ. |
| ត. ទីឃៈឥជាឦផ្សំនឹងហិជាទ្វីហិ | ស.ទីឃៈឥជាឦផ្សំនឹងសុជាទ្វីសុ |
| ចំ. ចុះ ន អាគមផ្សំនឹងនំជាទ្វិន្នំ, ផ្លាស់ទ្វិជាទុវិហើយចុះ នអាគមផ្សំនឹង នំ ជា ទុវិន្នំ | |

## ឧភនិងឧភយ

ទ្វិសព្ទនេះ អាចផ្លាស់រូបទៅជា “ឧភ” ឬជា “ឧភយ” ក៏បាន ដោយមេសូត្រ យោសុទ្ធិន្នំទ្វេច ។ ឧភ និង ឧភយ ប្រែថា

"ទាំង ២" ប៉ុន្តែ ឧភ ប្រើបានចំពោះតែជាពហុវចនៈម្យ៉ាង ទាំង ៣ លិង្គមានវិធីបំបែកតែបែប ១ ដូច ទ្វិ ដែលជារូបដើមរបស់ខ្លួនដែរ ។ ឯ "ឧភយ" ជា តិលិង្គិកៈ ប្រើបានទាំង ២ វចនៈ ទាំង ៣ លិង្គមានវិធីបំបែកផ្សំនឹងវិភត្តិដូច "យ" សព្ទ (ចូរមើលទៅខាងមុខត្រង់លេខ ១១៦) ។ នឹងបំបែកតែ ឧភ ឲ្យឃើញដូច្នេះ:

| ពហុវចនៈ | ពហុវចនៈ |
| --- | --- |
| ប. ឧភោ | បញ្ច. ឧភោហិ |
| ទុ. ឧភោ | ឆ. ឧភិន្នំ |
| ត. ឧភោហិ | ស. ឧភោសុ |
| ច. ឧភិន្នំ | |

## រូបសិទ្ធិ មានមេសូត្រ

| ពហុវចនៈ | ពហុវចនៈ |
| --- | --- |
| ប. តតោយោនមោតុ | បញ្ច. ដូច ត. ពហុ. |
| ទុ. ដូច ប. ពហុ. | ឆ. ដូច ច. ពហុ. |
| ត. យទនុ ។ល។ សិជ្ឈន្តិ, (អការស្សេហ្វាត្តំ កត្តព្វំ) | ស. យទនុ ។ល។ សិជ្ឈន្តិ, (អការស្សេហ្វាត្តំ កត្តព្វំ) |
| ច. ឧភាទិតោនមិន្នំ | |

## រូបសិទ្ធិ ឥតមេសូត្រ

| ពហុវចនៈ | ពហុវចនៈ |
| --- | --- |
| ប. ផ្លាស់ យោជាឱ ហើយលុបអ ចេញផ្សំជា ឧភោ | បញ្ច. ឧភោហិ ដូច ត. ពហុ. |
| ទុ. ឧភោ ដូច ប. ពហុ. | ឆ. ឧភិន្នំ ដូច ច. ពហុ. |
| ត. ផ្លាស់អជាឱផ្សំនឹងហិជាឧភោហិ | ស. ផ្លាស់ អជាឱ ផ្សំនឹងសុជា ឧភោសុ |
| ច. ផ្លាស់ នំជាឥន្នំ ហើយលុបអ ចេញផ្សំជា ឧភិន្នំ | |

[១០១] តិ "៣" ទាំង ៣ លិង្គមានវិធីបំបែកផ្សេងគ្នា ដោយអន្លើដូច្នេះ:

| បុំលិង្គ ពហុវចនៈ | ឥត្ថីលិង្គ ពហុវចនៈ | នបុំសកលិង្គ ពហុវចនៈ |
| --- | --- | --- |
| ប. តយោ | ប. តិស្សោ | ប. តីណិ |
| ទុ. តយោ | ទុ. តិស្សោ | ទុ. តីណិ |
| ត. តីហិ | ត. តីហិ | ត. តីហិ |
| ច. តិណ្ណំ[១],តិណ្ណន្នំ | ច. តិស្សន្នំ | ច. តិណ្ណំ[១],តិណ្ណន្នំ |
| បញ្ច.តីហិ | បញ្ច.តីហិ | បញ្ច.តីហិ |
| ឆ. តិណ្ណំ[១], តិណ្ណន្នំ | ឆ. តិស្សន្នំ | ឆ. តិណ្ណំ[១], តិណ្ណន្នំ |
| ស តីសុ | ស តីសុ | ស តីសុ |

១ ក្នុងកច្ចាយនៈថា ចុះនអាគមផ្សំនឹងនំវិភត្តិដោយមេសូត្រ នោចទ្វាទិតោនម្ហិ ជា "តិន្នំ" ក៏បានខ្លះ ។

## រូបសិទ្ធិ មានមេសូត្រ រួមទាំង ៣ លិង្គ

| បុំលិង្គ | ឥត្ថីលិង្គ | នបុំសកលិង្គ |
|---|---|---|
| ពហុវចនៈ | ពហុវចនៈ | ពហុវចនៈ |
| ប. តិចតុន្នំតិស្សេា ។ល។តីណិចត្តារិ | ប. តិចតុន្នំតិស្សេា ។ល។តីណិចត្តារិ | ប. តិចតុន្នំតិស្សេា ។ល។តីណិចត្តារិ |
| ទុ. ដូច ប. ពហុ. | ទុ. ដូច ប. ពហុ. | ទុ. ដូច ប. ពហុ. |
| ត. សុនំហើសុច | ត. ដូចក្នុងបុំលិង្គ | ត. ដូចក្នុងបុំលិង្គ |
| ច. ឥណ្ណមិណ្ណន្នំតីហិ សំខ្យាហិ | ច. នោចទ្វាទិតោនម្ហិ ឬ បញ្ចាទីនមត្ថំ | ច. —— |
| បញ្ច. ដូច ត. ពហុ. | បញ្ច. ដូចក្នុងបុំលិង្គ | បញ្ច. —— |
| ឆ. ដូច ច. ពហុ. | ឆ. ដូច ច. ពហុ. | ឆ. —— |
| ស. សុនំហើសុច | ស. ដូចក្នុងបុំលិង្គ | ស. —— |

## រូបសិទ្ធិ ឥតមេសូត្រ រួមទាំង ៣ លិង្គ

| បុំលិង្គ | ឥត្ថីលិង្គ | នបុំសកលិង្គ |
|---|---|---|
| ពហុវចនៈ | ពហុវចនៈ | ពហុវចនៈ |
| ប. ផ្លាស់ តិនិងយោ ជា តយោ | ប. ផ្លាស់ តិនិងយោ ជា តិស្សេា | ប. ផ្លាស់ តិនិងយោ ជា តីណិ |
| ទុ.តយោដូចប.ពហុ. | ទុ.តិស្សេាដូចប.ពហុ. | ទុ.តីណិ ដូចប.ពហុ. |

| បុំលិង្គ | ឥត្ថីលិង្គ | នបុំសកលិង្គ |
|---|---|---|
| ពហុវចនៈ | ពហុវចនៈ | ពហុវចនៈ |
| ត.ទីឃៈ ត ជា ត្ស ផ្សំនឹងហិ ជា តីហិ | ត. តីហិ ដូចក្នុងបុំលិង្គ | ត. តីហិ ដូចក្នុង បុំលិង្គ |
| ប. ផ្លាស់នំជាឥណ្ណំ,ជាឥណ្ណន្នំ ហើយលុបឥរបស់ តិ ចេញផ្សំជាតិណ្ណំ, ជា តិណ្ណន្នំ | ប. ចុះស្សអាគមហើយចុះ នអាគមផ្សំនឹងនំជា តិស្សន្នំ | ប.តិណ្ណំ,តិណ្ណន្នំដូចក្នុងបុំលិង្គ |
| បញ្ច.តីហិដូចត.ពហុ. | បញ្ច.តីហិដូចក្នុងបុំលិង្គ | បញ្ច.តីហិដូចក្នុងបុំលិង្គ |
| ឆ. តិណ្ណំ,តិណ្ណន្នំ ដូចច. ពហុ. | ឆ. តិស្សន្នំ ដូច ច. ពហុ. | ឆ.តិណ្ណំ,តិណ្ណន្នំដូចបុំលិង្គ |
| ស.ទីឃៈ តជាត្ស ផ្សំនឹង សុ ជា តីសុ | ស. តីសុ ដូចក្នុង បុំលិង្គ | ស. តីសុ ដូចក្នុងបុំលិង្គ |

[១០២] ចតុ "៤" ទាំង ៣ លិង្គមានវិធីបំបែកផ្សេងគ្នាដោយអន្លើដូច្នេះ:

| បុំលិង្គ | ឥត្ថីលិង្គ | នបុំសកលិង្គ |
|---|---|---|
| ពហុវចនៈ | ពហុវចនៈ | ពហុវចនៈ |
| ប. ចត្តារោ, ចតុរោ | ប. ចតស្សោ | ប. ចត្តារិ |
| ទុ. ចត្តារោ, ចតុរោ | ទុ. ចតស្សោ | ទុ. ចត្តារិ |
| ត. ចតូហិ | ត. ចតូហិ | ត. ចតូហិ |

| បុំលិង្គ | ឥត្ថីលិង្គ | នបុំសកលិង្គ |
|---|---|---|
| ពហុវចនៈ | ពហុវចនៈ | ពហុវចនៈ |
| ប. ចតុន្នំ | ប. ចតស្សន្នំ | ប. ចតុន្នំ |
| បញ្ច. ចតូហិ | បញ្ច. ចតូហិ | បញ្ច. ចតូហិ |
| ឆ. ចតុន្នំ | ឆ. ចតស្សន្នំ | ឆ. ចតុន្នំ |
| ស. ចតូសុ | ស. ចតូសុ | ស. ចតូសុ |

## រូបសិទ្ធិ មានមេសូត្រ រួមទាំង ៣ លិង្គ

| បុំលិង្គ | ឥត្ថីលិង្គ | នបុំសកលិង្គ |
|---|---|---|
| ពហុវចនៈ | ពហុវចនៈ | ពហុវចនៈ |
| ប.តិចតុន្នំ។ល។តីណិ-ចត្តារិ,ឧសរេច, តតោយោនមោតុ | ប. តិចតុន្នំ ។ល។ តីណិចត្តារិ | ប. តិចតុន្នំ។ល។ តីណិចត្តារិ |
| ទុ. ដូច ប. ពហុ. | ទុ. ដូច ប. ពហុ. | ទុ. ដូច ប. ពហុ. |
| ត. សុនំហីសុច | ត. ដូចក្នុងបុំលិង្គ | ត. ដូចក្នុងបុំលិង្គ |
| ច. នោចទ្វាទិតោនម្ហិ | ច.នោចទ្វាទិតោនម្ហិ ឬ បញ្ចាទីនមត្តំ | ច. ——— |
| បញ្ច. ដូច ត. ពហុ. | បញ្ច. ដូចក្នុងបុំលិង្គ | បញ្ច. ——— |
| ឆ. ដូច ច. ពហុ. | ឆ. ដូច ច. ពហុ. | ឆ. ——— |
| ស. សុនំហីសុច | ស. ដូចក្នុងបុំលិង្គ | ស. ——— |

# រូបសិទ្ធិ ឥតមេសូត្រ រួមទាំង ៣ លិង្គ

| បុំលិង្គ<br>ពហុវចនៈ | ឥត្ថីលិង្គ<br>ពហុវចនៈ | នបុំសកលិង្គ<br>ពហុវចនៈ |
|---|---|---|
| ប. ផ្លាស់ចតុនិងយោជា ចត្តារោ,ផ្លាស់ឧរបស់ ចតុ ជា ឧរ ហើយផ្លាស់ យោ ជា ឱ ជាចតុរោ | ប. ផ្លាស់ចតុនិងយោ ជា ចតស្សោ | ប. ផ្លាស់ចតុ និង យោ ជា ចត្តារិ |
| ទុ. ចត្តារោ, ចតុរោ ដូច ប. ពហុ. | ទុ. ចតស្សោដូចប. ពហុ. | ទុ. ចត្តារិដូច ប. ពហុ. |
| ត. ទីឃៈឧជាឩ ផ្សំ នឹងហិជាចតូហិ | ត. ចតូហិដូចក្នុងបុំលិង្គ | ត. ចតូហិដូចក្នុង បុំលិង្គ |
| ច. ចុះ នអាគម ផ្សំ នឹងនំជាចតុន្នំ | ច.ចុះស្សអាគមហើយ ចុះនអាគមផ្សំនឹងនំ ហើយផ្លាស់ឧ របស់ ចតុ ជាអ ផ្សំជាចតស្សន្នំ | ច. ចតុន្នំ ដូចក្នុង បុំលិង្គ |
| បញ្ច.ចតូហិដូចត.ពហុ. | បញ្ច.ចតូហិដូចក្នុងបុំលិង្គ | បញ្ច.ចតូហិដូចក្នុងបុំ. |
| ឆ. ចតុន្នំ ដូច ច.ពហុ. | ឆ. ចតស្សន្នំដូច ច. ពហុ. | ឆ. ចតុន្នំ ដូចក្នុងបុំ. |
| ស.ទីឃៈ ឧជាឩផ្សំនឹង សុ ជា ចតូសុ | ស.ចតូសុដូចក្នុងបុំលិង្គ | ស. ចតូសុដូចក្នុងបុំ. |

[១០៣] បញ្ច "៥" បំបែកដូចគ្នាទាំង ៣ លិង្គ ដូច្នេះ:

| ពហុវចនៈ | ពហុវចនៈ |
|---|---|
| ប. បញ្ច | បញ្ច. បញ្ចហិ |
| ទុ. បញ្ច | ឆ. បញ្ចន្នំ |
| ត. បញ្ចហិ | ស. បញ្ចសុ |
| ច. បញ្ចន្នំ | |

រូបសិទ្ធិ: ត្រង់ ប., ទុ. ផ្លាស់អរបស់សំខ្យាធ្វើជាអដូចដើម ដោយមេសូត្រ បញ្ចាទីនមការោ ហើយលុបយោវិភត្តិចេញ គង់រូបនៅជាបញ្ចដូចដែល ។ ត្រង់ ត., បញ្ច., ស. ផ្លាស់អរបស់សំខ្យាធ្វើជាអដូចដើម ដោយមេសូត្រ បញ្ចាទីនមត្តំ ហើយមិនបាច់ផ្លាស់អជាឯឬទីឃៈអជាអាឡើយ គ្រាន់តែផ្សំនឹងហិ, ផ្សំនឹងសុក៏ជាការស្រេច ។ ត្រង់ ច., ឆ. ផ្លាស់អរបស់សំខ្យាធ្វើជាអដូចដើម ដោយមេសូត្រ បញ្ចាទីនមត្តំ ហើយចុះនអាគមផ្សំនឹងនំ ដោយមេសូត្រ នោចទ្វាទិតោនម្ហិ ។ តាំងពី ឆ "៦" រៀងទៅដល់ អដ្ឋារស "១៨" មានវិធីបំបែកព្រមទាំងរូបសិទ្ធិដូចគ្នានឹង បញ្ច នេះទាំងអស់ ។

តាំងពី ឯកូនវីស "១៩" រៀងទៅដល់ អដ្ឋនវុតិ "៩៨" ដែលបាននិយាយក្នុងខាងដើមត្រង់លេខ ៩៨ រួចមកហើយថា ជាឥត្ថីលិង្គ ប្រើបានតែជាឯកវចនៈម្យ៉ាងនោះ អ្នកសិក្សាត្រូវសង្កេតតាមដំណើរការន្តក្នុងឥត្ថីលិង្គ របស់សំខ្យាសព្ទទាំងនោះ ដូច្នេះគឺ បើសព្ទដែលមាន "-ស" នៅខាងចុងបំផុត ដូចយ៉ាង ឯកូនវីស ជាដើមនោះ ត្រូវចុះអាបច្ច័យថែម ដោយមេសូត្រ ឥត្ថិ-យមតោអាបច្ចយោ ឲ្យជាអាការន្តឥត្ថីលិង្គ គឺធ្វើ "សំ" ឲ្យទៅជា "-សា" ត្រូវបំបែកដូច កញ្ញា (ខាងប៉ែកឯកវចនៈ), ប្លែកអំពី កញ្ញា តែត្រង់បឋមាវិភត្តិ ត្រូវរស្សអាជាអ ហើយទុកឲ្យនៅជា "-ស" ប៉ុណ្ណោះក៏បាន, ចុះនិគ្គហិតអាគមថែមមកទៀត ដោយ មេសូត្រ អន្តេនិគ្គហិតញ្ច (មេសូត្រតទ្ធិត) ឲ្យទៅជា "-សំ" ក៏បាន ខ្លះ ឯក្រៅពីនោះដូច កញ្ញា ទាំងអស់ ។ សព្ទដែលមានស្រៈ "ឥ" នៅខាងចុងបំផុត ដូចយ៉ាង ឯកូនវីសតិ ជាដើម ត្រូវបំបែកដូច រត្តិ (ខាងប៉ែកឯកវចនៈ) ។ សព្ទដែលមានស្រៈ "ឦ" នៅខាង

ចុងបំផុត ដូចយ៉ាង ឯកូនសង្ឃី ជាដើម ត្រូវបំបែកដូច នារី (ខាងប៉ែកឯកវចនៈ) ។ រូបសិទ្ធិក៏មានវិធីតាមដំណើរការន្តក្នុងឥត្ថីលិង្គទាំងនោះ ។

នឹងបំបែកឲ្យឃើញជាបែបខ្លះ ដូចខាងក្រោយនេះ:

[១០៤] ឯកូនវីស "១៩" បំបែកដូច្នេះ:

| ឯកវចនៈ: | ឯកវចនៈ: |
| --- | --- |
| ប. ឯកូនវីស, ឯកូនវីសំ | បញ្ញ. ឯកូនវីសាយ |
| ទុ. ឯកូនវីសំ (ឯកូនវីស) | ឆ. ឯកូនវីសាយ |
| ត. ឯកូនវីសាយ | ស. ឯកូនវីសាយ, ឯកូនវីសាយំ |
| ច. ឯកូនវីសាយ | |

[១០៥] ឯកូនវីសតិ "១៩" បំបែកដូច្នេះ:

| ឯកវចនៈ: | ឯកវចនៈ: |
| --- | --- |
| ប. ឯកូនវីសតិ | បញ្ញ. ឯកូនវីសតិយា, ឯកូនវីសត្យា |
| ទុ. ឯកូនវីសតឹ (ឯកូនវីសតិ) | ឆ. ឯកូនវីសតិយា |
| ត. ឯកូនវីសតិយា | ស. ឯកូនវីសតិយា, ឯកូនវីសតិយំ, ឯកូនវីសត្យំ |
| ច. ឯកូនវីសតិយា | |

[១០៦] ឯកូនសង្ខ៏ី "៥៩" បំបែកដូច្នេះ:

| ឯកវចនៈ | ឯកវចនៈ |
|---|---|
| ប. ឯកូនសដ្ឋី | បញ្ច. ឯកូនសដ្ឋិយា |
| ទុ. ឯកូនសដ្ឋឹ (ឯកូនសដ្ឋី) | ឆ. ឯកូនសដ្ឋិយា |
| ត. ឯកូនសដ្ឋិយា | ស. ឯកូនសដ្ឋិយា, ឯកូនសដ្ឋិយំ |
| ច. ឯកូនសដ្ឋិយា | |

តាំងពី ឯកូនសតំ "៩៩" រៀងទៅដល់ អសំខេយ្យំ "អសំខេយ្យ" មិនបាច់បំបែកជាបែបឲ្យឃើញក្នុងទីនេះទេ ពីព្រោះមានវិធីងាយល្មមអ្នកសិក្សាយល់បាន ។ (ចូរសង្កេតតាមសេចក្ដីពន្យល់ខាងដើមត្រង់លេខ ៩៨ នោះចុះ) ។

## បូរណសំខ្យា

[១០៧] បកតិសំខ្យានោះឯង កាលបើចុះបច្ច័យថែមមកទៀត, អំណាចបច្ច័យនោះបំបែរឲ្យមានសេចក្ដីប្រាប់ចំនួនរបស់នាមនាមបង្គ្រប់ជាជាន់ ៗ ដោយឡែកដោយសង្កាត់តាមលំដាប់ប្លែកចាកប្រក្រតីរបស់ខ្លួនទៅវិញ ក៏បានឈ្មោះថា បូរណសំខ្យា,

ជាគុណនាម ហៅថា សំខ្យាគុណនាម ជា តិលិង្គិកៈ ដូចបាន និយាយខ្លះក្នុងខាងដើមត្រង់លេខ ៩០ រួចមកហើយ ។

បូរណសំខ្យានោះ ក្នុងភាសាយើងមានកំណត់ឲ្យរាប់ថា "គម្រប់-, ជាគម្រប់-" ឬថា "ទី-" ដូចយ៉ាង ទុតិយោ វគ្គោ "ជំពូក គម្រប់ ២" ឬ "ជំពូក ទី ២", តតិយោ បការោ "ប្រការ គម្រប់ ៣" ឬ "ប្រការ ទី ៣" ជាដើម ។ ប៉ុន្តែត្រង់ថ្នាក់ដំបូង បំផុតមុនថ្នាក់ទី ២ នោះ ប្រើ "បឋ" សព្ទ ដែលប្រែថា "តាំងនៅមុន" នេះជាជំនួស "ឯក" សព្ទ, ចុះម-បច្ច័យផ្សំមកជា "បឋម" ប្រែថា "ដំបូង, ជាដំបូង ឬថា "ទី១", នឹងនិយាយថា "គម្រប់ ១" ដូច្នេះពុំបានទ្បើយ ពីព្រោះជាសំខ្យាទីដំបូងបង្អស់ មិនទាន់មានចំនួនណាមកបង្គ្រប់នៅទ្បើយ ដូចយ៉ាង បឋមោ វគ្គោ កុំប្រែថា "ជំពូក គម្រប់ ១" ចូរប្រែថា "ជំពូក ដំបូង" ឬថា "ជំពូក ទី ១" ដូច្នេះទើបត្រូវ ។

# វិធីរាប់បូរណសំខ្យា

[១០៨] របៀបបូរណសំខ្យាទាំង ៣ លិង្គ ដូច្នេះ:

| បុំលិង្គ | ឥត្ថីលិង្គ | នបុំសកលិង្គ | ពាក្យប្រែ |
|---|---|---|---|
| បឋមោ | បឋមា | បឋមំ | ទី ១ |
| ទុតិយោ | ទុតិយា | ទុតិយំ | - ២ |
| តតិយោ | តតិយា | តតិយំ | - ៣ |
| ចតុត្ថោ | ចតុត្ថី, ចតុត្ថា | ចតុត្ថំ | - ៤ |
| បញ្ចមោ | បញ្ចមី,បញ្ចមា | បញ្ចមំ | - ៥ |
| ឆដ្ឋោ | ឆដ្ឋី, ឆដ្ឋា | ឆដ្ឋំ | - ៦ |
| សត្តមោ | សត្តមី,សត្តមា | សត្តមំ | - ៧ |
| អដ្ឋមោ | អដ្ឋមី, អដ្ឋមា | អដ្ឋមំ | - ៨ |
| នវមោ | នវមី, នវមា | នវមំ | - ៩ |
| ទសមោ | ទសមី,ទសមា | ទសមំ | - ១០ |
| ឯកាទសមោ | ឯកាទសី | ឯកាទសមំ | - ១១ |
| ទ្វាទសមោ,ពារ-សមោ | ទ្វាទសី,ពារសី | ទ្វាទសមំ,ពារ-សមំ | - ១២ |

| បុំលិង្គ | ឥត្ថីលិង្គ | នបុំសកលិង្គ | ពាក្យប្រែ |
|---|---|---|---|
| តេរសមោ | តេរសី | តេរសមំ | ទី ១៣ |
| ចុទ្ទសមោ | ចតុទ្ទសី,ចាតុទ្ទសី | ចតុទ្ទសមំ | - ១៤ |
| បណ្ណរសមោ | បញ្ចទ្ទសី, បណ្ណ-រសី | បណ្ណរសមំ | - ១៥ |
| សោឡសមោ | សោឡសី | សោឡសមំ | - ១៦ |
| សត្តរសមោ | សត្តរសី | សត្តរសមំ | - ១៧ |
| អដ្ឋារសមោ | អដ្ឋារសី | អដ្ឋារសមំ | - ១៨ |
| ឯកូនវីសតិមោ | ឯកូនវីសតិមា | ឯកូនវីសតិមំ | - ១៩ |
| វីសតិមោ | វីសតិមា | វីសតិមំ | - ២០ |
| ឯកវីសតិមោ | ឯកវីសតិមា | ឯកវីសតិមំ | - ២១ |
| ។ល។ | ។ល។ | ។ល។ | ។ល។ |
| តឹសតិមោ | តឹសតិមា | តឹសតិមំ | - ៣០ |
| ។ល។ | ។ល។ | ។ល។ | ។ល។ |
| ចត្តាឡីសមោ | ចត្តាឡីសមា | ចត្តាឡីសមំ | - ៤០ |
| ។ល។ | ។ល។ | ។ល។ | ។ល។ |

| បុំលិង្គ | ឥត្ថីលិង្គ | នបុំសកលិង្គ | ពាក្យប្រែ |
|---|---|---|---|
| បញ្ញាសមោ | បញ្ញាសមា | បញ្ញាសមំ | ទី ៥០ |
| ។ល។ | ។ល។ | ។ល។ | ។ល។ |
| សដ្ឋិមោ | សដ្ឋិមា | សដ្ឋិមំ | - ៦០ |
| ។ល។ | ។ល។ | ។ល។ | ។ល។ |
| សត្តតិមោ | សត្តតិមា | សត្តតិមំ | - ៧០ |
| ។ល។ | ។ល។ | ។ល។ | ។ល។ |
| អសីតិមោ | អសីតិមា | អសីតិមំ | - ៨០ |
| ។ល។ | ។ល។ | ។ល។ | ។ល។ |
| នវុតិមោ | នវុតិមា | នវុតិមំ | - ៩០ |
| ។ល។ | ។ល។ | ។ល។ | ។ល។ |
| សតមោ | សតមា | សតមំ | - ១០០ |
| ។ល។ | ។ល។ | ។ល។ | ។ល។ |
| សហស្សមោ | សហស្សមា | សហស្សមំ | - ១០០០ |
| ។ល។ | ។ល។ | ។ល។ | ។ល។ |

| បុំលិង្គ | ឥត្ថីលិង្គ | នបុំសកលិង្គ | ពាក្យប្រែ |
|---|---|---|---|
| កោដិមោ | កោដិមា | កោដិមំ | ទីឬគម្រប់កោដិ |
| ។ល។ | ។ល។ | ។ល។ | ។ល។ |
| អសំខេយ្យមោ | អសំខេយ្យមា | អសំខេយ្យមំ | ទីឬគម្រប់អសំ-ខេយ្យ |

## បូរណសំខ្យាអាស្រ័យបច្ច័យ

[១០៩] បច្ច័យសម្រាប់ចុះផ្សំឲ្យបកតិសំខ្យាក្លាយជាបូរណ-សំខ្យាមាន ៥ គឺ តិយ. ថ. ឋ. ម. ឦ ។ មានបច្ច័យ ២ ទៀត គឺ ឦ, អា ជា សាធារណបច្ច័យ សម្រាប់ចុះនាំមុខសព្ទឲ្យក្លាយជាឥត្ថីលិង្គ ក៏យកមកប្រើក្នុងបូរណសំខ្យានេះដែរ ប្រើចុះថែមជាមួយនឹងបច្ច័យរបស់បូរណសំខ្យាឲ្យក្លាយជាឥត្ថីលិង្គ ។ សំខ្យាសព្ទណាអាស្រ័យបច្ច័យណាខ្លះនោះ ដូចមានរបៀបប្រាប់ខាងក្រោយនេះ:

១- ទុតិយ, តតិយ ចុះតិយ-បច្ច័យ, ផ្លាស់ "ទ្វិ" ជា "ទុ" ផ្លាស់ "តិ" ជា "ត" ផ្សំនឹងតិយ-បច្ច័យ ជា ទុតិយ, តតិយ ។

២- ចតុត្ថ ចុះថ-បច្ច័យ, តម្រួត "ត" លើ ថ-បច្ច័យ ជា "ត្ថ" ផ្សំនឹង ចតុ ជា ចតុត្ថ ។

៣- ឆដ្ឋ ចុះឋ-បច្ច័យ, តម្រួត "ដ" លើ ឋ-បច្ច័យ ជា "ដ្ឋ" ផ្សំនឹង ឆ ជា ឆដ្ឋ[១] ។

៤- សព្ទដែលមាន "ម" នៅខាងចុង គឺតាំងពី បឋម, បញ្ចម, សត្តម, អដ្ឋម, នវម, ទសម ជាដើមរៀងទៅ សុទ្ធតែចុះម-បច្ច័យ ។

៥- សព្ទប្រាប់ចំនួន ៨ អន្លើគឺ ឯកាទសី, ទ្វាទសី ឬ ពារសី, តេរសី, ចតុទ្ទសី ឬ ចាតុទ្ទសី[២] បញ្ចទ្ទសី[២] ឬ បណ្ណរសី, សោឡសី, សត្តរសី, អដ្ឋារសី នេះចុះឦ-បច្ច័យ (សម្រាប់បូរណសំខ្យានេះ) ។

៦- ក្នុងឥត្ថីលិង្គ ត្រង់សំខ្យា ៧ អន្លើ គឺ ចតុត្ថី, បញ្ចមី, ឆដ្ឋី, សត្តមី, អដ្ឋមី[២] នវមី, ទសមី ចុះបច្ច័យសម្រាប់បូរណសំខ្យានេះគឺ ថ, ឋ, ម ផង ចុះឦ-បច្ច័យដែលសម្រាប់ចុះនាំមុខសព្ទឲ្យក្លាយជាឥត្ថីលិង្គនោះផង ។

---

១ ចុះម-បច្ច័យថែមមកទៀតជា ឆដ្ឋម ក៏បានខ្លះ ដូចក្នុងបរាភវសូត្រថា ឆដ្ឋមោ សោ បរាភវោ ។

២ ត្រង់ ប. ឯក. រស្សៈឦជាឥហើយចុះនិគ្គហិតអាគមថែមមកទៀតដោយមេសូត្រ អន្តេនិគ្គហិតញ្ច (សូត្រតទ្ធិត) ឲ្យជា ចាតុទ្ទសឹ,... បញ្ចទ្ទសឹ ។ ល ។ អដ្ឋមឹ,... ក៏បានខ្លះ ។

៧- ក្នុងឥត្ថីលិង្គ ត្រង់សំខ្យាសព្ទដែលមាន "អា" នៅខាងចុងទាំងប៉ុន្មានដូចយ៉ាង បឋមា, ទុតិយា, តតិយា, ចតុត្ថា, បញ្ចមា ជាដើមរៀងទៅនោះ សុទ្ធតែចុះអា-បច្ច័យថែមផ្សំនឹងបច្ច័យទាំង ៣ គឺ ថ, ឋ, ម ប៉ុន្តែចុះផ្សំនឹងម-បច្ច័យច្រើនជាងបច្ច័យទាំង ២ ។ (ចូរមើលក្នុងតទ្ធិតនិទ្ទេសខាងមុខត្រង់បូរណតទ្ធិតលេខ ១៥២) ។ ម្យ៉ាងទៀត បកតិសំខ្យាដែលផ្សំនឹងបច្ច័យឲ្យក្លាយមកជាបូរណសំខ្យា ដូចមានរបៀបដែលរៀបរៀងមកហើយនោះ ខ្ញុំផ្សំឲ្យមិនគ្រប់សព្ទទាំងអស់ទេ ត្រង់ចំនួនខ្លះដែលមានបែបឲ្យប្រើច្រើនយ៉ាងបានដូចគ្នា ដូចយ៉ាង ឯកូនវីស, ឩនវីស, ឯកូនវីសតិ, ឩនវីសតិ "១៩" ជាដើម, យកតែត្រង់ ឯកូនវីសតិ ១ សព្ទមកផ្សំនឹងបច្ច័យជាបែបឲ្យឃើញជាទំនងប៉ុណ្ណោះ សព្ទដែលនៅសល់ក្រៅពីនោះទាំងប៉ុន្មាន អ្នករៀនត្រូវហាត់ផ្សំតាមន័យដែលបានពន្យល់មកហើយនោះចុះ ។

## វិធីបំបែកបូរណសំខ្យា

[១១០] បកតិសំខ្យាលើកលែងតែ "ឯក" មួយសព្ទនេះចេញ កាលបើក្លាយមកជាបូរណសំខ្យាហើយ ក៏ជាគុណនាម

ជា តិលិង្គិកៈ ទាំងអស់ មានវិធីបំបែកតាមដំណើរលិង្គទាំង ៣ គ្រប់វិភត្តិទាំង៧ និងវចនៈទាំង ២ វៀរលែងតែត្រង់អាលបនៈព្រោះមិនមានប្រើទេ, ខាងប៉ែកពហុវចនៈត្រូវបំបែក ប៉ុន្តែមិនសូវមានប្រើ ។ ប៉ែកខាងបុំលិង្គទាំងអស់ បំបែកដូច បុរិស, ប៉ែកខាងឥត្ថីលិង្គ ត្រង់សព្ទណាដែលជាឦការន្ត បំបែកដូច នារី, សព្ទណាដែលជាអាការន្ត បំបែកដូច កញ្ញា, ខាងនបុំសកលិង្គ បំ-បែកដូច កុល ។

## សព្វនាម

បាននិយាយខ្លះមកហើយក្នុងខាងដើមត្រង់លេខ ៤៣ ថា នាមដែលប្រើជំនួស ឬប្រើជាជំនួយនាមនាមដែលបាននិយាយចេញឈ្មោះរួចមកហើយ ឬដែលកំពុងនិយាយចំពោះដើម្បីនឹងមិនឲ្យផ្ទួនពាក្យជញ្ជាន់ស្លាញដដែល ៗ ឬដើម្បីឲ្យលះសេចក្តីមិនឲ្យប្រទាំ ហៅថា "សព្វនាម", មាន ២ យ៉ាងគឺ បុរិសសព្វ-នាម ១ វិសេសនសព្វនាម ១ ។

## បុរិសសព្វនាម

[១១១] សព្វនាមដែលប្រើជំនួសឈ្មោះមនុស្ស, សត្វ ឬ អ្វី ៗ ដោយចំពោះរូប ប៉ុន្តែមិនចេញចំឈ្មោះនោះទេ យកពាក្យដទៃផ្សេងពីនោះមកជំនួសវិញ ហៅថា "បុរិសសព្វនាម" មាន ៣ យ៉ាង គឺ "ត" ដែលមិនប្រែថា "នោះ" ១ តុម្ហ ១ អម្ហ ១ ។ បានជាហៅថា បុរិសសព្វនាម ពីព្រោះលោកកំណត់តាមដំណើរ "បុរិសៈ" ក្នុងអាខ្យាតដែលចែកជា ៣ យ៉ាង គឺ បឋមបុរិសៈ ១ មជ្ឈិមបុរិសៈ ១ ឧត្តមបុរិសៈ ១ ។ "ត" ជា បឋមបុរិសៈ "បុរស ទី ១", "តុម្ហ" ជា មជ្ឈិមបុរិសៈ "បុរសកណ្ដាល", "អម្ហ" ជា ឧត្តមបុរិសៈ "បុរសឧត្តម" ។ (ចូរមើលទៅក្នុងអាខ្យាតនិទ្ទេសខាងមុខ) ។

"ត" បើប្រែថា "នោះ" ជាវិសេសនសព្វនាម, បើប្រែថា "ព្រះអង្គ, លោក, នាង, គេ, គាត់, វា,..." (តាមពាក្យខ្ពស់កណ្ដាល, ទាប ដែលប្រើក្នុងភាសាយើង) យ៉ាងនេះជាបុរិសសព្វនាម ។ បើប្រើជាវិសេសនសព្វនាម ត្រូវប្រើជាបទវិសេ-

សនៈរបស់នាមនាម, បើប្រើជាបុរិសសព្វនាម ត្រូវប្រើតាមទំនើង ខ្លួនឯង គឺមិនបាច់ជាវិសេសនៈនឹងនាមនាមឡើយ ដូចឧទាហរណ៍ទាំងឡាយ ដែលរៀបរៀងឲ្យឃើញជាបែបខ្លះក្នុងខាងក្រោយនេះ:

ក) "ត" ដែលប្រែថា "ព្រះអង្គ" ឧ. ស្វេ សត្ថា ឥធាគមិស្សតិ, មយំ តំ វន្ទិស្សាម តស្ស ធម្មំ សុណិស្សាម "ក្នុងថ្ងៃស្អែក ព្រះជាគ្រូ នឹងយាងមក ក្នុងទីនេះ, យើងទាំងឡាយនឹងថ្វាយបង្គំ នូវព្រះអង្គ នឹងស្ដាប់ នូវធម៌ នៃព្រះអង្គ" ។

ខ) "ត" ដែលប្រែថា "លោក" ឧ. មយ្ហំ ឧបជ្ឈាយោ បញ្ចាសីតិវស្សាយុកោ, សោ បន ទេវសិកំ តាវ ភិក្ខុសាមណេរានំ បរិយត្តិធម្មំ វាចេតុំ សក្កោតិ "ព្រះឧបជ្ឈាយ៍របស់ខ្ញុំ មានព្រះជន្ម ៨៥ ឆ្នាំ (ហើយ), ប៉ុន្តែ លោក អាចដើម្បីបង្រៀន - នូវព្រះបរិយត្តិធម៌ - ដល់ភិក្ខុនិងសាមណេរទាំងឡាយ-បាននៅឡើយ" ។

គ) "ត" ដែលប្រែថា "នាង" ៖ វិសាខា មហាឧបាសិកា សទ្ធា អហោសិ អភិប្បសន្នា ពុទ្ធសាសនេ, តថា ច តស្សា បុត្តធីតរោ "មហាឧបាសិកា ឈ្មោះវិសាខា ជាស្ត្រីមានសទ្ធា ជ្រះថ្លាក្រៃពេក ក្នុងព្រះពុទ្ធសាសនា, ឯ កូនប្រុសនិងកូនស្រី ទាំងឡាយ របស់នាង ក៏ដូច្នោះដែរ" ។

ឃ) "ត" ដែលប្រែថា "គេ", ថា "គាត់" ៖ ឯកោ មហល្លកវឌ្ឍកី ឯកគាមវាសីនំ មនុស្សានំ បិយោ អហោសិ មនាបោ, សោ ហិ តេសំ ឧបការមកាសិ, តស្មឹ បន មតេ សព្វេបិ តេ ឯកច្ឆន្ទា ហុត្វា សក្កច្ចំ តស្ស សរីរកិច្ចមកំសុ ជាងឈើចាស់ ម្នាក់ ជាទីស្រឡាញ់-ពេញចិត្ត នៃមនុស្ស ទាំងឡាយ អ្នកនៅក្នុងស្រុកជាមួយ. ពីព្រោះ គាត់ បានធ្វើ ហើយ នូវសេចក្តីទំនុកបម្រុង ដល់គេទាំងឡាយ ក៏ កាលដែល គាត់ ស្លាប់ហើយ គេទាំងឡាយ ទាំងអស់គ្នា បានធ្វើហើយ នូវសរីរកិច្ច នៃគាត់ ដោយយកចិត្តទុកដាក់" ។

ង) "ត" ដែលប្រែថា "វា" ៖. ឯកោ មេ អវជាតបុត្តោ អត្ថិ, នេវ តំ ឱវាទំ គណ្ហាបេតុំ សក្កោមិ ឥទានិ បន

សោ ពាទ្ធគិលានោ, សចេបិ មហាថេរោ មម គេហំ អាគន្ត្វា តស្សោវាទំ ទស្សតិ, សោ តស្សោវាទេ ឋស្សតិ មញ្ញេ "កូនប្រុស-ម្នាក់របស់ខ្ញុំ ជាអវជាតបុត្រ, (ខ្ញុំ) មិនអាច-ដើម្បី-ញ៉ាំងវា-ឲ្យទទួល-នូវឱវាទ-បានឡើយ, ប៉ុន្តែឥឡូវវា ឈឺធ្ងន់ណាស់, បើប្រសិនជាព្រះមហាថេរនឹង-និមន្តមក-ផ្ទះ-ខ្ញុំ-ហើយឲ្យ-នូវឱវាទ-ដល់វា, ប្រហែលជា វា នឹងស្ថិតនៅ ក្នុងឱវាទរបស់លោក" ។ អម្ភោ កុមារកា, ឯសោ សាលិកបោតកោ គណ្ហថ, នំ, នៃក្មេងតូចទាំងឡាយ រ៉ឺយ, កូននៃសត្វសាលិកា នុ៎ះនំ, (ឯងទាំងឡាយ) ចូរចាប់ "នូវវា" ។ មម សរកោ ចិរំ នដ្ឋោ, ឥទានិ អសុកគេហេ តំ បស្សាមិ "ផ្តិល របស់ខ្ញុំ បាត់យូរហើយ, ឥឡូវ (ខ្ញុំ) ឃើញ នូវវា ក្នុងផ្ទះឯណោះ" ។

"ត" សព្ទក្នុងឧទាហរណ៍ទាំងអម្បាលនេះបើប្រែយ៉ាងនេះ ជាបុរិសសព្វនាម, បើប្រើជាវិសេសនសព្វនាមដែលប្រែថា "នោះ" វិញក៏បាន ត្រូវបញ្ចូលនាមនាមតាមសព្ទដើមដដែល

ថែមមកទៀត ដូច្នេះ: ត្រង់ ក) តំ-សត្ថារំ "នូវព្រះជាគ្រូ-នោះ", តស្ស-សត្ថុនោ "នៃព្រះជាគ្រូ-នោះ" ។ ត្រង់ ខ) សោ-មម ឧ-បជ្ឈាយោ "រីព្រះឧបជ្ឈាយ៍ របស់ខ្ញុំ-នោះ" ។ ត្រង់ គ) តស្សា វិ-សាខាយ "របស់មហាឧបាសិកាឈ្មោះវិសាខា-នោះ" ។ ត្រង់ ឃ) សោ-វឌ្ឍកី "រីជាងឈើ-នោះ", តេសំ-មនុស្សានំ "ដល់មនុស្សទាំងឡាយ-នោះ", តស្មឹ-វឌ្ឍកិស្មឹ កាលដែលជាងឈើ-នោះ", តេ-មនុស្សា "រីមនុស្សទាំងឡាយ-នោះ", តស្ស-វឌ្ឍកិនោ "នៃជាងឈើ-នោះ" ។ ត្រង់ ង) តំ បុត្តំ "ញុំាងកូន-នោះ", សោ-បុត្តោ "រីកូន-នោះ", តស្ស-បុត្តស្ស "ដល់កូន-នោះ", សោ-បុត្តោ "រីកូន-នោះ", តស្ស-មហាថេរស្ស "របស់ព្រះមហាថេរ-នោះ" ។ នំ-សាលិកបោតកំ "នូវកូននៃសត្វសាលិកា-នោះ" ។ តំ-សរកំ "នូវផ្តិល-នោះ" ។

មែនពិត, បើតាមដំណើរសម្តី, ក្នុងឧទាហរណ៍ទាំងឡាយដែលបាននិយាយមកហើយនោះ បានជាប្រើ "ត" សព្ទ ជំនួសនាមនាមដែលបានចេញឈ្មោះរួចមកហើយ ដើម្បីមិនឲ្យយកនាមនាមដដែលមកដាក់ថែមត្រង់កន្លែងនោះទៀត ពីព្រោះ

ប្រយោគមានដំណើរសេចក្តីថ្លែងតែអំពី នាមនាមដដែលនោះ ហើយមានឃ្លាល្បះក៏នៅបន្តជិតគ្នានៅឡើយ គឺកុំឲ្យប្រើនាមនាមបន្ថែមដូច្នេះ ត្រង់ *ក*) ស្វេ សត្ថា ឥធាគមិស្សតិ, មយំ សត្ថារំ វន្ទិស្សាម សត្ថុនោ ធម្មំ សុណិស្សាម "ក្នុងថ្ងៃស្អែក ព្រះជាគ្រូនឹងយាងមក ក្នុងទីនេះ យើងទាំងឡាយ នឹងថ្វាយបង្គំ នូវព្រះជាគ្រូ នឹងស្តាប់ នូវធម៌ នៃព្រះជាគ្រូ" ត្រូវប្រើ "ត" សព្ទ ជំនួសត្រង់កន្លែង "សត្ថារំ" ឲ្យដាក់ "តំ" ត្រង់កន្លែង "សត្ថុនោ" ឲ្យដាក់ "តស្ស" ឲ្យប្រែថា "នូវព្រះអង្គ, នៃព្រះអង្គ" ដើម្បីកុំឲ្យផ្ទួនពាក្យជញ្ជាន់ស្លាញដដែល ៗ ថា "នូវព្រះជាគ្រូ, នៃព្រះជាគ្រូ" ដូច្នេះទៀត នាំឲ្យអផ្សុកត្រចៀក ។ បើទុកជាដាក់ "ត" សព្ទ ត្រង់កន្លែងនោះមកហើយ, ហើយប្រើជាវិសេសនសព្ទ-នាមថា "តំ-សត្ថារំ នូវព្រះជាគ្រូ-នោះ, តស្ស-សត្ថុនោ នៃព្រះជាគ្រូ-នោះ" យ៉ាងនេះ ក៏គង់តែនៅជញ្ជាន់ស្លាញ មិនពីរោះ, ព្រោះហេតុនោះ ទើបកំណត់ឲ្យប្រែជាបុរិសសព្ទនាមតាមទំនើង "ត" សព្ទ ខ្លួនឯងថា "តំ" នូវព្រះអង្គ, តស្ស នៃព្រះអង្គ" ដូច្នេះវិញ ។ បើនឹងប្រែពីភាសាបាឡីមកជាសេចក្តីតាមលំនាំភាសាយើង ក៏

គង់ប្រើថា "ស្អែក ព្រះជាគ្រូ នឹងយាងមក ក្នុងទីនេះ យើងចាំថ្វាយបង្គំ ព្រះអង្គ ចាំស្តាប់ ធម៌ ព្រះអង្គ", ដូច្នេះទើបស្រួលស្តាប់មិនទាស់ត្រចៀក ។

(ក្នុងឧទាហរណ៍ឯទៀតក៏ត្រូវឲ្យអ្នករៀនចូលចិត្តតាមន័យនេះ ។ លោកអាចារ្យអ្នកបង្រៀនត្រូវនាំយកឧទាហរណ៍ក្រៅពីនេះឲ្យច្រើន មកពន្យល់សិស្សផងចុះ ពីព្រោះ "ត" សព្ទ ដែលប្រើជាបុរិសសព្វនាមនិងវិសេសនសព្វនាម រមែងមានទំនងផ្សេងគ្នាតាមដំណើរសេចក្តីនិងប្រយោគ ពិបាកចំណាំ ជាហេតុឲ្យកុលបុត្រអ្នកទើបនឹងសិក្សាថ្មីក្រយល់បន្តិចដែរ) ។

"តុម្ហ" ជាសព្ទសម្រាប់ប្រើជំនួសឈ្មោះបុគ្គលដែលគេកំពុងនិយាយទៅរកក្នុងទីចំពោះមុខ គឺថាបុគ្គលដែលគេកំពុងនិយាយជាមួយនោះឈ្មោះអ្វី មិនចេញចំឈ្មោះនោះឡើយ ប្រើ "តុម្ហ" សព្ទនេះជំនួសឈ្មោះនោះវិញ ។ "តុម្ហ" ប្រែថា "ព្រះអង្គ, លោក, អ្នក, នាង, ឯង, អា, ហង,..." (តាមពាក្យខ្ពស់, កណ្តាល, ទាប) ។

"អម្ហ" ជាសព្ទសម្រាប់ប្រើជំនួសឈ្មោះខ្លួនឯង គឺថា ខ្លួនឈ្មោះអ្វី មិនចេញឈ្មោះនោះ ប្រើ "អម្ហ" សព្ទនេះជំនួស វិញ "អម្ហ" ប្រើថា "ខ្ញុំព្រះអង្គ, ខ្ញុំព្រះករុណា, ខ្ញុំបាទ, ខ្ញុំឯង, អញខ្ញុំ, ខ្ញុំម្ចាស់, ខ្ញុំ, អាត្មាភាព, អាត្មា, អញ, យើង, យើង-ខ្ញុំ,..." (តាមពាក្យខ្ពស់, កណ្តាល, ទាប) ។

អ្នករៀនត្រូវសិក្សាឲ្យស្គាល់របៀបប្រើពាក្យខ្ពស់, កណ្តាល, ទាប ក្នុងបុរិសសព្វនាម តាមថ្នាក់និងភេទរបស់បុគ្គល ទើប អាចនឹងប្រែសេចក្តីពីភាសាបាឡីមកជាភាសាយើងមិនឆ្គង ពី-ព្រោះក្នុងភាសាយើង ត្រង់បុរិសសព្វនាមនេះមានពាក្យប្រើច្រើន ណាស់. ឯក្នុងភាសាបាឡី មានប្រើចំពោះតែ ៣ ពួក គឺ "ត, តុម្ហ, អម្ហ" ប៉ុណ្ណោះ ផ្សេងគ្នាតែវិភត្តិនិងវចនៈ ។ (ចូរមើល ត្រង់បែបប្រើវចនៈក្នុងខាងដើមត្រង់លេខ ៥៣) ។

តុម្ហ និង អម្ហ ទាំង ២ សព្ទនេះជា ទ្វិលិង្គិកៈ គឺប្រើបាន តែក្នុងបុំលិង្គនិងឥត្ថីលិង្គ មានវិធីបំបែកទាំង ២ លិង្គដូចគ្នាតែ បែបមួយ ។ ឯចំណែកខាង "ត" សព្ទ ទោះប្រើជាបុរិស-

សព្វនាមក្តី ជាវិសេសនសព្វនាមក្តី ជា តិលិង្គិកៈ គឺប្រើបាន ទាំង ៣ លិង្គ ។ ក្នុងសព្វនាមទាំងអស់មិនមានអាលបនៈទេ ។

[១១២] បែបបំបែក "ត" សព្ទ ក្នុងលិង្គទាំង ៣ ផ្សេងគ្នាដូចម្តេចខ្លះនោះ ដូចមានរបៀបតទៅនេះ:

"ត" សព្ទ ក្នុងបុំលិង្គ បំបែកដូច្នេះ:

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | សោ | តេ |
| ទុ. | តំ, នំ | តេ, នេ |
| ត. | តេន | តេហិ, នេហិ |
| ច. | តស្ស, អស្ស | តេសំ, តេសានំ, នេសំ, នេសានំ |
| បញ្. | តស្មា, អស្មា, តម្ហា | តេហិ, នេហិ |
| ឆ. | តស្ស, អស្ស | តេសំ, តេសានំ, នេសំ, នេសានំ |
| ស. | តស្មឹ, អស្មឹ, តម្ហិ, នម្ហិ | តេសុ, នេសុ |

រូបសិទ្ធិ មានមេសូត្រ

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | ឯតតេសន្តោ, សោ | សព្វនាមការតេបឋមោ,សរលោបោ.. |
| ទុ. | តស្សវានត្តំសព្វត្ថ, សរលោ-<br>បោ ។ ល ។ តុបកតិ | តស្សវានត្តំសព្វត្ថ, សព្វយោនីន-<br>មាឯ,... |

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| គ. អតោនេន, សរលោបោ ។ ល ។ តុបកតិ | តស្សរានត្តំសព្វត្ថ, សុហីស្វកា-រោង |
| ប. សស្មាស្មឹសំសាស្វត្តំ, សាគ-មោសេ | តស្សរានត្តំសព្វត្ថ, សព្វនាមាន-ន្ទម្ហិច, សព្វតោនំសំសានិ |
| បញ្ច. សស្មាស្មឹសំសាស្វត្តំ, ស្មា-ហិស្មឹនម្ហាភិម្ហិវា | ដូច ត. ពហុ. |
| ឆ. ដូច ច. ឯក. | ដូច ច. ពហុ. |
| ស. សស្មា ។ល។ ស្វត្តំ, តស្សរា-នត្តំសព្វត្ថស្មាហិស្មឹនម្ហាភិម្ហិវា | តស្សរានត្តំសព្វត្ថ, សុហីស្វកា-រោង |

## រូបសិទ្ធិ ឥតមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប.ផ្លាស់ តជាសហើយ ផ្លាស់ សិ ជាឱហើយលុបអចេញជាសោ | ផ្លាស់ យោជាង ហើយលុប អ ចេញជា តេ |
| ទុ. តផ្សំនឹង ខ ជាតំ, ផ្លាស់តជាន ផ្សំនឹង ខ ជានំ | ផ្លាស់យោជាឯហើយលុបអចេញ ជាតេ,ផ្លាស់តជាន, ផ្លាស់យោជា ឯ ហើយលុប អ ចេញជា នេ |
| ត. ផ្លាស់ នាជាឯន ហើយលុប-អ ចេញជា តេន | ផ្លាស់ អជាឯ ផ្សំនឹង ហិជាតេហិ, ផ្លាស់តជានហើយផ្លាស់អជាឯផ្សំ នឹង ហិ ជា នេហិ |

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ប. ចុះសអាគមផ្សំនឹងសវិភត្តិជា តស្សផ្លាស់ តជាអ ហើយចុះ ស-អាគមផ្សំនឹងសវិភត្តិជាអស្ស | ផ្លាស់តជាន,ផ្លាស់អរបស់តរបស់នជាឯ ផ្លាស់ នំជាសំ ជាសានំជា តេសំ, តេសានំ, នេសំ, នេសានំ |
| បញ្ច. តផ្សំនឹងស្មាជាតស្មា,ផ្លាស់ តជាអផ្សំនឹងស្មាជាអស្មា, ផ្លាស់ ស្មាជាម្ហា ជា តម្ហា | តេហិ, នេហិ, ដូច ត. ពហុ. |
| ឆ. តស្ស, អស្ស ដូច ច. ឯក. | តេសំ,តេសានំ,នេសំ,នេសានំដូច ច.ពហុ. |
| ស. តផ្សំនឹងស្មឹជាតស្មឹ, ផ្លាស់ត ជាអផ្សំនិងស្មឹជាអស្មឹ, ផ្លាស់ស្មឹ ជាម្ហិជាតម្ហិ, ផ្លាស់តជានហើយ ផ្លាស់ស្មឹជាម្ហិ ជា នម្ហិ | ផ្លាស់ អជាឯ ផ្សំនឹង សុជាតេសុ ផ្លាស់ តជានហើយ ផ្លាស់អជាឯ ផ្សំនឹងសុជានេសុ |

"ត" សព្ទ ក្នុងឥត្ថីលិង្គ បំបែកដូច្នេះ:

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ប. សា | តា |
| ទុ. តំ, នំ | តា |
| ត. តាយ, (នាយ) | តាហិ, (នាហិ) |
| ច.តស្សា,អស្សា,តិស្សា,តិស្សាយ | តាសំ, (តាសានំ) |
| បញ្ច. តាយ, (នាយ) | តាហិ, (នាហិ) |
| ឆ.តស្សា,អស្សា,តិស្សា,តិស្សាយ | តាសំ, តាសានំ |
| ស. តស្សំ, អស្សំ, តិស្សំ (តាយំ,នាយំ) | តាសុ |

# រូបសិទ្ធិ មានមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. ឯតតេសន្តោ, ឥត្ថិយមតោអាបច្ច-យោអាយោ, សេសតោលោបំគសិបិ | ឥត្ថិយមតោអាបច្ចយោ, អា-យោ, យបតោចយោនំលោបោ |
| ទុ. តស្សវានត្តំសព្វត្ថ, ឥត្ថិយម-តោអាបច្ចយោ, អាយោ, ក្វចាទិ-មជ្ឈុត្តរានំ ។ល។ សុច | ដូច ប. ពហុ. |
| ត. តស្សវានត្តំសព្វត្ថ, ឥត្ថិយមតោ អាបច្ចយោ, អាយោ, យតោនាទិនំ | តស្សវានត្តំសព្វត្ថ, ឥត្ថិយម-តោអាបច្ចយោ, អាយោ |
| ច. ឥត្ថិយមតោអាបច្ចយោ, អាយោ, យបតោស្មឹសានំសំសា, សស្មាស្មឹ-សំសាស្វត្តំ,ឃោរស្សំ, សំសាស្វេក-វចនេសុច,តស្សាវា,តតោសស្សស្សាយ | ឥត្ថិយមតោអាបច្ចយោ, អា-យោ, សព្វតោនំសំសានំ |
| បញ្ច. ដូច ត. ឯក. | ដូច ត. ពហុ. |
| ឆ. ដូច ច. ឯក. | ដូច ច. ពហុ. |
| ស.ឥត្ថិយមតោ...អាយោ,យបតោ-ស្មឹសានំសំសា,សស្មាស្មឹសំសាស្វត្តំ, ឃោរស្សំ, តស្សា, សំសាស្វេកវច-នេសុច, ឥត្ថិយមតោ..., អាយោ, តស្សវានត្តំសព្វត្ថ ។ល។ (នេតាហិ-ស្មិមាយយា), យបតោស្មឹយំវា | ឥត្ថិយមតោអាបច្ចយោ,អាយោ |

# រូបសិទ្ធិ ឥតមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ប. ផ្លាស់ តជាស ហើយចុះ អា-បច្ច័យ ហើយលុប អ របស់ ស និង សិ ចេញផ្សំជា សា | ចុះ អាបច្ច័យ ហើយលុប អ របស់តនិងយោចេញផ្សំជាតា |
| ទុ. ចុះ អាបច្ច័យ ហើយលុប អ របស់តចេញផ្សំជាតា, រស្សៈអាជា អឲ្យទៅជាតវិញ, ផ្សំនឹង ំ ជាតំ, ផ្លាស់ តជានហើយចុះ អាបច្ច័យ ធ្វើដូចន័យមុនជា នំ | តា ដូច ប. ពហុ. |
| តិ. ចុះ អាបច្ច័យ ហើយលុប អ របស់តចេញផ្សំជាតា,ផ្លាស់នាជា អាយហើយលុបអារបស់តាចេញ ផ្សំជាតាយ,ផ្លាស់តជានហើយចុះ អាបច្ច័យធ្វើដូចន័យមុនជានាយ | ចុះអាបច្ច័យ ហើយលុប អ របស់ ត ចេញជា តា ផ្សំនឹង ហិ ជា តាហិ, ផ្លាស់ ត ជា ន ហើយចុះអាបច្ច័យធ្វើដូចន័យ មុនជា នាហិ |
| ច. ចុះ អាបច្ច័យហើយ លុប អ របស់ ត ចេញផ្សំ ជា តា, ផ្លាស់ ស វិភត្តិជាសា, រស្សៈអារបស់តាជា អ ឲ្យទៅជាតវិញហើយចុះ សអាគម ផ្សំជាតស្សា, វិធីសព្វគ្រប់ដូចន័យ មុន ប្លែកតែផ្លាស់ អា របស់ តាជាត ផ្សំជាតិស្សា,ផ្លាស់សវិភត្តិជាស្សាយ ផ្សំជាតិស្សាយ, ចុះអាបច្ច័យ ។ល។ ផ្លាស់ ត ជា អ ផ្សំជា អស្សា | ចុះអាបច្ច័យ ហើយលុប អ របស់ តចេញផ្សំជាតា, ផ្លាស់ នំជាសំ ជាសានំ ផ្សំជាតាសំ, តាសានំ |

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| បញ្ច. តាយ, នាយដូច ត.ឯក.ប្លែកតែផ្លាស់ ស្មា ជា អាយ ប៉ុណ្ណោះ | តាហិ នាហិ ដូច ត. ពហុ. |
| ឆ.តស្សា, អស្សា, តិស្សា, តិស្សាយ ដូច. ច. ឯក. | តាសំ, តាសានំ ដូច ច. ពហុ. |
| ស. ចុះ អាបច្ច័យហើយលុប អ របស់តចេញផ្សំជាតា, ផ្លាស់ស្មឹជាសំ, រស្សៈអារបស់តាជាអឲ្យទៅជា ត វិញហើយចុះសអាគមផ្សំជា តស្សំ, វិធីសព្វគ្រប់ដូចន័យមុន ប្លែកតែផ្លាស់ អា របស់ តាជាត ផ្សំជាតិស្សំ, ផ្លាស់តជាអផ្សំជា អស្សំ, ចុះ អាបច្ច័យហើយលុប អ របស់ ត ចេញផ្សំជា តា, ផ្លាស់ស្មឹជាយំហើយលុប អា របស់តាចេញផ្សំជាតាយំ, ផ្លាស់តជានហើយចុះអាបច្ច័យធ្វើដូចន័យមុនផ្សំជានាយំ | ចុះអាបច្ច័យហើយលុបអរបស់តចេញជាតាផ្សំនឹងសុជាតាសុ |

"ត" សព្ទ ក្នុងនបុំសកលិង្គ ត្រង់ ប. ឯក. ជា "តំ", ត្រង់ ប. ទុ. ពហុ. ជា "តានិ" (រូបសិទ្ធិ ដូច កុល) ក្រៅពីនោះមានវិធីបំបែកដូច "ត" ក្នុងបុំលិង្គទាំងអស់ ។

[១១៣] "តុម្ហ" សព្ទ ទាំង ២ លិង្គបំបែកតែបែបមួយដូច្នេះ:

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. ត្វំ, តុវំ | តុម្ហេ, (តុម្ហំ, តុម្ហានំ) វោ |
| ទុ. តំ. តវំ, តុវំ, (ត្វំ) | តុម្ហេ (តុម្ហាកំ, តុម្ហំ, តុម្ហានំ) វោ |
| ត. តយា (ត្វយា) តេ | តុម្ហេហិ, វោ |
| ច. តុយ្ហំ, (តុម្ហំ), តវ, តេ | តុម្ហាកំ, វោ |
| បញ្ចា. តយា | តុម្ហេហិ |
| ឆ. តុយ្ហំ. (តុម្ហំ), តវ, តេ | តុម្ហាកំ, វោ |
| ស. តយិ, (ត្វយិ) | តុម្ហេសុ |

## រូបសិទ្ធិ មានមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. ត្វមហំសិម្ហិច | សព្វនាមការតេបឋមោ, វាយ្វបឋមោ, ពហុវចនេសុវោនោ |
| ទុ. តម្មមម្ហិ, តវម្មមញ្ញវា, តុម្ហស្សតុវំត្វមម្ហិ | សព្វយោនីនមាឯ, វាយ្វបឋមោ, បទតោទុតិយាចតុត្ថីឆដ្ឋីសុវោនោ |
| ត. នាម្ហិតយាមយា, តយាតយីនន្តកាវោត្វត្តំវា, វាតតិយេច | សុហីស្វការោឯ, ពហុវចនេសុវោនោ |
| ច. តុយ្ហំមយ្ហញ្ច, សស្សំ, តវមមសេ, តេមេកវចនេសុ | តុម្ហាម្ហេហិនមាកំ, បទតោទុតិយា ។ល។ សុវោនោ |
| បញ្ចា. អម្ហតុម្ហន្តុ ។ល។ ស្មានាវ, នាម្ហិតយាមយា | សុហីស្វការោឯ |
| ឆ. ដូច ច. ឯក. | ដូច ច. ពហុ. |
| ស. តុម្ហាម្ហាកំតយិមយិ | សុហីស្វការោឯ |

## រូបសិទ្ធិ ឥតមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. ផ្លាស់តុម្ហ និង សិ ជាត្វំ,ជាតុវំ | ផ្លាស់ យោជាឯ ហើយលុប អ ចេញផ្សំជាតុម្ហេ, ផ្លាស់យោជាអំ, ជាអានំ ហើយលុបអចេញផ្សំជា តុម្ហំ, តុម្ហានំ ផ្លាស់តុម្ហនិងយោជាវោ |
| ទុ. ផ្លាស់តុម្ហនិងºជាតំ,តវំ,តុវំ,ត្វំ | ផ្លាស់ យោ ជា ឯ ហើយលុប អ ចេញផ្សំជាតុម្ហេ,ផ្លាស់យោជាអា-កំ, ជាអំ, ជា អានំ ហើយលុប អ ចេញផ្សំជាតុម្ហាកំ, តុម្ហំ, តុម្ហានំ, ផ្លាស់ តុម្ហ និង យោ ជា វោ |
| ត. ផ្លាស់ តុម្ហ និង នា ជា តយា. ត្វយា, តេ | ផ្លាស់អជាឯផ្សំនឹងហិជាតុម្ហេហិ, ផ្លាស់ តុម្ហ និង ហិ ជា វោ |
| ច. ផ្លាស់ តុម្ហនិងសជាតុយ្ហំ, តវ, តេ, ផ្លាស់ សជាអំផ្សំ ជា តុម្ហំ | ផ្លាស់ នំជាអាកំ ហើយលុប អ ចេញផ្សំជាតុម្ហាកំ, ផ្លាស់តុម្ហ និង នំ ជា វោ |
| បញ្ច. ផ្លាស់ តុម្ហនិងស្មា ជាតយា | តុម្ហេហិ ដូច ត. ពហុ. |
| ឆ. តុយ្ហំ តុម្ហំ. តវ, តេ ដូច ច.ឯក. | តុម្ហាកំ, វោ ដូច ច. ពហុ. |
| ស. ផ្លាស់តុម្ហនិងស្មឹជាតយិ,ត្វយិ | ផ្លាស់ អជាឯផ្សំនឹងសុជាតុម្ហេសុ |

តេ និង វោ ទាំង ២ នេះ លុះតែមានបទឯទៀតនៅខាងដើមហើយរៀងឲ្យនៅអំពីមុខបទនោះ ទើបប្រើបាន ឧ. អយំ តេ បត្តោ ។ ឥទំ តេ វត្ថំ ។ ធម្មំ វោ ភិក្ខវេ ទេសិស្សាមិ ។ គាមំ វោ គច្ឆេយ្យាថ ។

[១១៤] "អម្ហ" សព្ទទាំង ២ លិង្គបំបែកតែបែបមួយដូច្នេះ:

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ប. អហំ | មយំ, (អម្హេ, អម្ហំ, អម្ហានំ), នោ |
| ទុ. មំ, មមំ | អម្ហេ, (អម្ហាកំ, អម្ហំ, អម្ហានំ) នោ |
| ត. មយា, មេ | អម្ហេហិ, នោ |
| ច. មយ្ហំ, (អម្ហំ), មម, (មមំ), មេ | អម្ហាកំ, នោ |
| បញ្ច. មយា | អម្ហេហិ |
| ឆ. មយ្ហំ, (អម្ហំ), មម, (មមំ), មេ | អម្ហាកំ, នោ |
| ស. មយិ | អម្ហេសុ |

## រូបសិទ្ធិ មានមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ប. ត្វមហំសិម្ហិច | មយំយោម្ហិបឋមេ, សព្វនាមការតេ-បឋមោ, វាយ្វបឋមោ,ពហុវច-នេសុវោនោ |
| ទុ. តម្ហមម្ហិ, តវម្ហមញ្ញនវា | សព្វយោនីនមាឯ, វាយ្វបឋមោ, បទតោ ។ល។ សុវោនោ |
| ត. នាម្ហិតយាមយា, វាតតិយេច | សុហីស្វកាពោឯ,ពហុវចនេសុវោនោ |
| ច. តុយ្ហំមយ្ហញ្ច, សស្សំ, តវមម-សេ, អម្ហស្សមមំសវិភត្តិស្ស-សេ, តេមេកវចនេសុ | តុម្ហាម្ហេហិនមាកំ, បទតោទុតិយា ។ល។ សុវោនោ |

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| បញ្ច. អម្ហតុម្ហន្តុ ។ល។ ស្មានាវ, នាម្ហិតយាមយា | សុហីស្វការោង |
| ឆ. ដូច ច. ឯក. | ដូច ច. ពហុ. |
| ស. តុម្ហាម្ហាភិតយិមយំ | សុហីស្វការោង |

## រូបសិទ្ធិ ឥតមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. ផ្លាស់ អម្ហ និង សិ ជា អហំ | ផ្លាស់អម្ហនិងយោជាមយំ, ផ្លាស់យោជាឯហើយលុបអចេញផ្សំជា អម្ហេ, ផ្លាស់ យោ ជា អំ, ជាអានំ ហើយលុប អ ចេញផ្សំ ជា អម្ហំ, អម្ហានំ, ផ្លាស់អម្ហេនិងយោជានោ |
| ទុ. ផ្លាស់ អម្ហ និង ំ ជាមំ, មមំ | ផ្លាស់យោជាឯហើយលុបអចេញ ផ្សំជាអម្ហេ,ផ្លាស់យោជាអាកំ, ជា អំ, ជាអានំ ហើយលុបអចេញផ្សំ ជាអម្ហាកំ, អម្ហំ, អម្ហានំ, ផ្លាស់ អម្ហ និង យោ ជា នោ |
| ត. ផ្លាស់ អម្ហ និង នាជាមយា,មេ | ផ្លាស់អជាឯផ្សំនឹងហិជាអម្ហេហិ, ផ្លាស់ អម្ហ និង ហិ ជា នោ |
| ច. ផ្លាស់អម្ហនិងសជា មយ្ហំ, មម, មមំ,មេ,ផ្លាស់សជាអំផ្សំជាអម្ហំ | ផ្លាស់នំជាអាកំហើយលុបអចេញ ផ្សំជាអម្ហាកំ, ផ្លាស់អម្ហនិងនំជានោ |
| បញ្ច. ផ្លាស់ អម្ហនិងស្មាជាមយា | អម្ហេហិ ដូច ត. ពហុ. |
| ឆ. មយ្ហំ, អម្ហំ, មម, មមំ, មេ ដូច ច. ឯក. | អម្ហាកំ, នោ ដូច ច. ពហុ. |
| ស. ផ្លាស់ អម្ហ និង ស្មឹ ជា មយិ | ផ្លាស់អជាឯផ្សំនឹងសុជាអម្ហេសុ |

មេនិងនោ ទាំង ២ នេះ លុះតែមានបទឯទៀតនៅខាងដើមហើយរៀងឲ្យនៅអំពីមុខបទនោះ ទើបប្រើបាន ឧ. អយំ មេ បត្តោ ។ ឥទំ មេ ចីវរំ ។ ឯសោ នោ សត្ថា ។ គាមំ នោ គច្ឆេយ្យាម ។

## វិសេសនសព្វនាម

[១១៥] សព្ទសម្រាប់ប្រើជាជំនួយនាមនាម មានលំនាំជាបទវិសេសនៈ (ទំនងប្រហែលគ្នានឹងគុណនាម) ដើម្បីនឹងមិនឲ្យប្រទាំសេចក្ដីក្នុងសង្កាត់ប្រយោគមួយ ៗ ហៅថា "វិសេសនសព្វនាម", មាន ២ យ៉ាងគឺ និយម ១ អនិយម ១ ។ វិសេសនសព្វនាមដែលសម្ដែងសេចក្ដីទៀងទាត់ដាច់ស្រេច ហៅថា និយម, ដែលសម្ដែងសេចក្ដីមិនទៀងមិនដាច់ស្រេច ហៅថា អនិយម ។ នឹងរៀបរៀងខាងអនិយមមុន ។

## វិសេសនសព្វនាម អនិយម មាន ១២ សព្ទ គឺ

| | | |
|---|---|---|
| យ | ប្រែថា | ឯណា, ណា, ដែល- |
| អញ្ញ | — | ដទៃ, ឯទៀត |

| | | |
|---|---|---|
| អញ្ញតរ | ប្រែថា | ណាមួយ, ម្នាក់,... |
| អញ្ញតម | — | ណាមួយ, ម្នាក់,... |
| បរ | — | ដទៃ, ឯទៀត,... |
| អបរ | — | ដទៃទៀត, ផ្សេងទៀត,... |
| កតរ | — | ណា,ណាមួយ,ណាខ្លះ,អ្វី,ដូចម្តេច,... |
| កតម | — | ណា,ណាមួយ,ណាខ្លះ,អ្វី,ដូចម្តេច,... |
| ឯក | — | ពួកមួយ |
| ឯកច្ច | — | អ្នកខ្លះ, ពួកខ្លះ, -ខ្លះ |
| សព្វ | — | ទាំងពួង,ទាំងអស់,ទាំងមូល,ទាំងស្រុង,... |
| កឹ | — | ណា, អ្នកណា, ដូចម្តេច, អ្វី,... |

## វិសេសនសព្វនាម-និយម មាន ៥ សព្ទ គឺ

| | | |
|---|---|---|
| ត | ប្រែថា | នោះ |
| ឯត | — | នុ៎ះ, នុ៎ះន៎, ហ្នឹង, នេះ |
| ឥម | — | នេះ |
| ឥតរ | — | ម្នាក់ទៀត, មួយទៀត, ក្រៅនេះ |
| អមុ | — | ឯនោះ (ឯណោះ) |

# វិធីបំបែកវិសេសនសព្វនាម

វិសេសនសព្វនាមទាំងអស់ជា តិលិង្គិកៈ មានវិធីបំបែកក្នុងលិង្គទាំង ៣ ត្រូវគ្នាខ្លះ ផ្សេងគ្នាដោយអន្លើ ៗ ខ្លះ ដូចមានរបៀបតទៅនេះ:

[១១៦] "យ" សព្ទ ក្នុងបុំលិង្គ បំបែកដូច្នេះ:

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | យោ | យេ |
| ទុ. | យំ | យេ |
| ត. | យេន | យេហិ |
| ច. | យស្ស | យេសំ, យេសានំ |
| បញ្ច. | យស្មា, យម្ហា | យេហិ |
| ឆ. | យស្ស | យេសំ, យេសានំ |
| ស. | យស្មឹ, យម្ហិ | យេសុ |

## រូបសិទ្ធិ មានមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. សោ,... | សព្វនាមការតេបឋមោ,សរលោបោ ។ល។ តុបកតិ |
| ទុ. សរលោបោ ។ល។ តុបកតិ | សព្វយោនីនមាឯ, សរលោបោ ។ល។ បកតិ |

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ត. អតោនេន, សរលោបោ ។ល។ តុបកតិ | សុហីស្វការោង |
| ច. សាគមោសេ | សព្វនាមានន្ទម្ហិច,សព្វតោនំសំសានំ |
| បញ្ច. ស្មាហិស្មីនម្ហាភិម្ហិវា | ដូច ត. ពហុ. |
| ឆ. ដូច ច. ឯក. | ដូច ច. ពហុ. |
| ស. ស្មាហិស្មីនម្ហាភិម្ហិវា | សុហីស្វការោង |

## រូបសិទ្ធិ ឥតមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ប. ផ្លាស់ សិជាឱ ហើយលុប អ ចេញជាយោ | ផ្លាស់ យោជាឯ ហើយលុប អ ចេញជាយេ |
| ទុ. យ ផ្សំនឹង ំ ជា យំ | យេ ដូច ប. ពហុ. |
| ត. ផ្លាស់ នាជាឯនហើយលុប អ ចេញជា យេន | ផ្លាស់ អជាឯ ផ្សំនឹង ហិជាយេហិ |
| ច. ចុះសអាគម ផ្សំនឹង សវិភត្តិ ជា យស្ស | ផ្លាស់ អជាឯ, ផ្លាស់នំជាសំ, ជា សានំ ផ្សំជាយេសំ, យេសានំ |
| បញ្ច. យ ផ្សំនឹង ស្មា ជា យស្មា, ផ្លាស់ ស្មាជាម្ហា ផ្សំជា យម្ហា | យេហិ ដូច ត. ពហុ. |
| ឆ. យស្ស ដូច ច. ឯក. | យេសំ, យេសានំ ដូច ច ពហុ. |
| ស. យ ផ្សំនឹង ស្មឹជាយស្មឹ, ផ្លាស់ ស្មឹ ជា ម្ហិ ផ្សំជា យម្ហិ | ផ្លាស់ អជាឯ ផ្សំនឹង សុជាយេសុ |

"យ" សព្ទ ក្នុងឥត្ថីលិង្គ បំបែកដូច្នេះ:

| ឯកវចនៈ | | | ពហុវចនៈ |
|---|---|---|---|
| ប. | យា | | យា |
| ទុ. | យំ | | យា |
| ត. | យាយ | | យាហិ |
| ច. | យស្សា | | យាសំ, យាសានំ |
| បញ្ច. | យាយ | | យាហិ |
| ឆ. | យស្សា | | យាសំ, យាសានំ |
| ស. | យស្សំ | (យាយំ) | យាសុ |

## រូបសិទ្ធិ មានមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. ឥត្ថិយមតោអាបច្ចយោ, អាយោ, សេសតោលោបំគសិបិ | ឥត្ថិយមតោ..., អាយោ, យបតោចយោនំលោបោ |
| ទុ. ឥត្ថិយមតោ..., អាយោ, ក្វចាទិ ។ល។ សុច | ដូច ប. ពហុ. |
| ត. ឥត្ថិយមតោ..., អាយោ, យតោនាទីនំ,... | ឥត្ថិយមតោ..., អាយោ |
| ច. ឥត្ថិយមតោ..., អាយោ, យបតោស្មឹសានំសំសា, យោរស្សំ, សំសាសេកវចនេសុច | ឥត្ថិយមតោ... អាយោ, សព្វតោនំសំសានំ |

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| បញ្ច. ដូច ត. ឯក. | ដូច ត. ពហុ. |
| ឆ. ដូច ច. ឯក. | ដូច ច. ពហុ. |
| ស. ឥត្ថិយមតោ..., អាយោ, យបតោស្មឹសានំសំសា,យោរស្សំសំសាស្វេកវចនេសុច, (នេតាហិស្មិមាយយា), យបតោស្មឹយំវា,... | ឥត្ថិយមតោ..., អាយោ |

## រូបសិទ្ធិ ឥតមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. ចុះអាបច្ច័យ ហើយលុប អ របស់ យ និង សិ ចេញផ្សំជា យា | ចុះអាបច្ច័យហើយលុប អ របស់យ និង យា ចេញផ្សំជា យា |
| ទុ. ចុះអាបច្ច័យ ហើយលុប អ របស់យចេញផ្សំជាយា, រស្សៈអាជាអឲ្យទៅជាយវិញ,ផ្សំនឹងំជាយំ | យា ដូច ប. ពហុ. |
| ត. ចុះអាបច្ច័យ ហើយលុប អ របស់យចេញផ្សំជាយា, ផ្លាស់នា ជាអាយ ហើយលុប អ របស់ យា ចេញផ្សំជា យាយ | ចុះអាបច្ច័យ...ផ្សំនឹងហិជាយាហិ |
| ច. ចុះអាបច្ច័យ ហើយលុប អ របស់យចេញផ្សំជាយា, ផ្លាស់ សវិភត្តិ ជា សា, រស្សៈអារបស់យា ជា អ ឲ្យទៅជា យ វិញហើយចុះ សអាគមផ្សំជាយស្សា | ចុះអាបច្ច័យហើយផ្លាស់នំជាសំ ជាសានំផ្សំជាយាសំ. យាសានំ |

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| បញ្. យាយ ដូច ត. ឯក. ប្លែក តែផ្លាស់ស្មាជាអាយប៉ុណ្ណោះ | យាហិ ដូច ត. ពហុ. |
| ឆ. យស្សា ដូច ច. ឯក. | យាសំ យាសានំ ដូច ច. ពហុ. |
| ស. ចុះអាបច្ច័យ ហើយលុប អ របស់យចេញផ្សំជាយា, ផ្លាស់ស្មឹ ជាសំ,រស្សៈអារបស់យាជាអឲ្យទៅ ជាយវិញហើយចុះសអាគមផ្សំជា យស្សំ, ចុះអាបច្ច័យ... ផ្លាស់ស្មឹ ជាយំ... ផ្សំជា យាយំ | ចុះអាបច្ច័យ...ផ្សំនឹងសុជាយាសុ |

"យ" សព្ទ ក្នុងនបុំសកលិង្គ ត្រង់ ប. ឯក. ជា យំ, ត្រង់ ប. ទុ. ពហុ. ជា យានិ (រូបសិទ្ធិដូចកុល) ក្រៅពីនោះ មានវិធីបំបែកដូចក្នុងបុំលិង្គទាំងអស់ ។

វិសេសនសព្វនាម-អនិយម ១០ សព្ទគឺ អញ្ញ, អញ្ញតរ, អញ្ញតម, បរ, អបរ, កតរ, កតម, ឯក, ឯកច្ច, សព្វ នេះ បំបែកទាំង ៣ លិង្គ ដូច "យ" សព្ទ ។ ទាំង "ឧភយ" ដែលប្រែថា "ទាំងពីរ" ជាពួកសំខ្យាសព្វនាមនោះក៏បំបែក

ទាំង ៣ លិង្គទាំង ២ វចនៈដូច "យ" សព្ទដែរ ។ "ឧភយ" សព្ទនេះជាពួកសំខ្យាសព្ទនាមក៏ពិតមែន ប៉ុន្តែនឹងរាប់បញ្ចូលមកក្នុងពួកវិសេសនសព្ទនាមនេះក៏បាន តែគួរបញ្ចូលទៅខាងពួក និយម ដ្បិត ឧភយ ប្រែថា "ទាំងពីរ" ជាសព្ទប្រាប់សេចក្តីដាច់ស្រេច ឯវិធីបំបែកត្រូវបញ្ចូលមកខាងពួក អនិយម ពីព្រោះមានដំណើរដូច "យ" សព្ទ ។

## "កឹ" សព្ទ

[១១៧] "កឹ" សព្ទ ក្នុងបុំលិង្គ បំបែកដូច្នេះ:

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | កោ | កេ |
| ទុ. | កំ | កេ |
| ត. | កេន | កេហិ |
| ច. | កស្ស | កេសំ, កេសានំ |
| បញ្. | កស្មា, កម្ហា | កេហិ |
| ឆ. | កស្ស | កេសំ, កេសានំ |
| ស. | កស្មឹ, កម្ហិ | កេសុ |

"កី" សព្ទ ក្នុងឥត្ថីលិង្គ បំបែកដូច្នេះ:

| ឯកវចនៈ | | ពហុវចនៈ |
|---|---|---|
| ប. | កា | កា |
| ទុ. | កំ | កា |
| ត. | កាយ | កាហិ |
| ច. | កស្សា | កាសំ, កាសានំ |
| បញ្ច. | កាយ | កាហិ |
| ឆ. | កស្សា | កាសំ, កាសានំ |
| ស. | កស្សំ, (កាយំ) | កាសុ |

រូបសិទ្ធិ: ទាំង ២ លិង្គត្រូវផ្លាស់ "កី" ជា "ក" ដោយមេសូត្រ កិស្សកវេច ហើយសម្រេចរូបដូច "យ" សព្ទ ក្នុងបុំ. និង ឥ. ។

"កឹ" សព្ទ ក្នុងនបុំសកលិង្គ បំបែកដូច្នេះ:

| ឯកវចនៈ | | ពហុវចនៈ |
|---|---|---|
| ប. | កឹ | កានិ |
| ទុ. | កឹ | កានិ |
| ត. | កេន | កេហិ |

| ឯកវចនៈ | | ពហុវចនៈ |
|---|---|---|
| ច. | កស្ស, កិស្ស | កេសំ, កេសានំ |
| បញ្ច. | កស្មា, កម្ហា | កេហិ |
| ឆ. | កស្ស, កិស្ស | កេសំ, កេសានំ |
| ស. | កស្មឹ, កិស្មឹ, កម្ហិ | កេសុ |

រូបសិទ្ធិៈ ត្រង់ប. ទុ. ឯក. គ្រាន់តែលុបសិ, លុបអំចេញ គង់រូបនៅជា កឹ ដូចដែល, ត្រង់ ប. ទុ. ពហុ. ផ្លាស់កឹជាក រួចផ្លាស់យោជានិ ហើយទីឃៈអជាអាផ្សំជាកានិ ។ តាំងពី ត. ដល់ ស. ទាំង ២ វចនៈ ដូចកឹក្នុងបុំលិង្គ វៀរលែងតែ ច. ឆ. ស. ឯក. ត្រង់ កិស្ស, កិស្មឹ នេះចេញ ដ្បិតត្រូវលុបនិគ្គហិតរបស់កឹចេញ គឺធ្វើកឹឲ្យជាកិហើយផ្សំនឹងស្សជាកិស្ស, ផ្សំនឹងស្មឹជាកិស្មឹ ។

## បែបប្រើ "កឹ" សព្ទ

"កឹ" សព្ទនេះ ជួនណាមិនបាច់ប្រើជាវិសេសនៈរបស់នាមនាមឡើយ ប្រើតាមទំនើងខ្លួនឯងតែម្តងក៏បាន ឧ. កោ ឯសោ? "អ្នកណា នុ៎ះ?" កោ មំ បក្កោសតិ?... អ្នកណា ហៅ ខ្ញុំ?" ។ កោ ឥមំ បឋវឹ វិជេស្សតិ... "អ្នកណា នឹងស្គាល់ច្បាស់ នូវផែនដី នេះ..." ។

កាលបើបញ្ចូល "ចិ" សព្ទ ដែលជា អសាកល្យត្ថវាចក-និបាត គឺនិបាតសព្ទប្រាប់សេចក្តីថា "ដូនណា, ដូនកាល..." នេះ រៀងឲ្យនៅខាងចុងភ្ជាប់ជាមួយជា "កឹចិ" ត្រូវប្រែថា "ណា-មួយ, ណា ៗ, អ្នកណា ៗ, នីមួយ, អ្វីមួយ, តិចតួច,..." បើជាពហុវចនៈ ត្រូវប្រែថា "ពួកមួយ, ពួកខ្លះ, អ្នកខ្លះ,-ខ្លះ,..." ។ បើមាន "យ" សព្ទ រៀងនៅខាងដើមថែមមកទៀតជា "យ-កឹចិ" ត្រូវសរសេរ "យ" ឲ្យដាច់ដោយខ្លួនជា "យ-កឹចិ" តែត្រូវប្រែរួមទាំងអស់ជាមួយគ្នាថា "ឯណាមួយ, ឯណានីមួយ, អ្នកណាមួយ,..." វិធីបំបែកត្រូវទុក "ចិ" ឲ្យនៅនឹងដូចដើមមិនមានផ្លាស់ប្រែឡើយ ដ្បិតជាអព្យយសព្ទ ឯចំណែកខាង "យ" និង "កឹ" ត្រូវបំបែកតាមដំណើររបស់ខ្លួន ក្នុងលិង្គទាំង ៣ និងវចនៈទាំងពីរ, ត្រង់ដែលមាននិគ្គហិត, គឺត្រង់ "កឹ, កំ, សំ, នំ, ស្មឹ" នោះ ត្រូវផ្លាស់និគ្គហិតជា "ញ" ពីព្រោះមាន "ចិ" នៅខាងចុង (មើលអក្ខរវិធីនិទ្ទេសខាងដើម ត្រង់និគ្គហិតាទេសសន្ធិលេខ ២៩) ។

ត្រូវបំបែកដូច្នេះ (ប.) បុំ. កោចិ, កេចិ, យោ កោចិ, យេ កេចិ, ឥ, កាចិ, យា កាចិ, នបុំ. កិញ្ចិ, កានិចិ, យំ កិញ្ចិ, យានិ កានិចិ ។ (ទុ.) បុំ. កញ្ចិ, កេចិ, យំ កញ្ចិ, យេ កេចិ, ឥ. កញ្ចិ, កាចិ, យំ កញ្ចិ, យា កាចិ, នបុំ. កិញ្ចិ, កានិចិ, យំ កិញ្ចិ, យានិ កានិចិ ។ (ត.) បុំ. កេនចិ, កេហិចិ, យេន កេនចិ, យេហិ កេហិចិ, ឥ. កាយចិ កាហិចិ, យាយ កាយចិ, យាហិ កាហិចិ, នបុំ. ដូច បុំ. ។ (ច.) បុំ. កស្សចិ, កេសញ្ចិ, កេសានញ្ចិ, យស្ស កស្សចិ, យេសំ កេសញ្ចិ, យេសានំ កេសានញ្ចិ, ឥ. កស្សាចិ, កាសញ្ចិ, កាសានញ្ចិ, យស្សា កស្សាចិ, យាសំ កាសញ្ចិ, យាសានំ កាសានញ្ចិ, នបុំ. ដូចបុំ. ។ បេ ។

## វិសេសនសព្វនាម-និយម

[១១៨] ក្នុងពួកវិសេសនសព្វនាមខាងនិយមនោះ "ត" សព្ទមានវិធីបំបែកទាំង ៣ លិង្គ ត្រូវគ្នានឹង "ត" សព្ទ ជាបុរិស-សព្វនាម ព្រោះហេតុនោះ មិនបាច់បំបែកក្នុងទីនេះទៀតទេ ។ "ត" សព្ទ ជាវិសេសនសព្វនាមត្រូវប្រែថា "នោះ" ហើយត្រូវប្រើ

ជាបទវិសេសនៈរបស់នាមនាមដោយដាច់ខាត ឬប្រើជាវិសេសនៈរបស់បុរិសសព្វនាមត្រង់មជ្ឈិមបុរិសៈនិងឧត្តមបុរិសៈ គឺត្រង់តុម្ហ និងអម្ហដែលជាជាតិសព្វនាមដូចគ្នាក៏បាន ឯនឹងប្រើតាមទំនើងខ្លួនឯងពុំបានឡើយ ឧ. សោ ភគវា អរហំ... "ព្រះមានជោគនោះ ទ្រង់ព្រះនាមថាអរហំ..." ។ ...សោ មេ អត្ថោ អនុប្បត្តោ... "...ប្រយោជន៍ នោះ គឺអញ បានផ្តល់រៀងមកហើយ..." ។ សោ (ត្វំ) ករោហិ ទីបមត្តនោ "(អ្នក) នោះ ចូរធ្វើ នូវទីពឹង ដល់ខ្លួន" ។ សោហំ ន តំ ជានាមិ "ខ្ញុំ នោះមិនស្គាល់វាទេ" ។ ត្រង់ពាក្យថា "អ្នក នោះ, ខ្ញុំ នោះ" បើតាមលំនាំសម្តីរបស់យើង, "សោ" ក្នុងប្រយោគយ៉ាងនេះ គួរប្រែថា "ឯង" គឺត្រូវប្រែថា "អ្នក ឯង ចូរធ្វើ នូវទីពឹង ដល់ខ្លួន" ។ "ខ្ញុំ ឯង មិនស្គាល់ វា ទេ" ។ "សោ" បើទុកជាប្រែថា "ឯង" យ៉ាងនេះក៏គង់នៅជាវិសេសនសព្វនាមរបស់ "ត្វំ" និង "អហំ" ដូចគ្នានឹងពាក្យប្រែថា "នោះ" ដែរ ។

[១១៩] "ឯត" សព្ទ ក្នុងបុំលិង្គ បំបែកដូច្នេះ

| ឯកវចនៈ | | ពហុវចនៈ |
|---|---|---|
| ប. | ឯសោ | ឯតេ |
| ទុ. | ឯតំ, ឯនំ | ឯតេ |
| ត. | ឯតេន | ឯតេហិ |
| ច. | ឯតស្ស | ឯតេសំ, ឯតេសានំ |
| បញ្ច. | ឯតស្មា, ឯតម្ហា | ឯតេហិ |
| ឆ. | ឯតស្ស | ឯតេសំ, ឯតេសានំ |
| ស. | ឯតស្មឹ, ឯតម្ហិ | ឯតេសុ |

"ឯត" សព្ទ ក្នុងឥត្ថីលិង្គ បំបែកដូច្នេះ:

| ឯកវចនៈ | | ពហុវចនៈ |
|---|---|---|
| ប. | ឯសា | ឯតា |
| ទុ. | ឯតំ, ឯនំ | ឯតា |
| ត. | ឯតាយ | ឯតាហិ |
| ច. | ឯតស្សា,ឯតិស្សា,ឯតិស្សាយ | ឯតាសំ, ឯតាសានំ |
| បញ្ច. | ឯតាយ | ឯតាហិ |
| ឆ. | ឯតស្សា,ឯតិស្សា,ឯតិស្សាយ | ឯតាសំ, ឯតាសានំ |
| ស. | ឯតស្សំ ឯតិស្សំ, (ឯតាយំ) | ឯតាសុ |

"ឯត" សព្ទ ក្នុងនបុំសកលិង្គ ត្រង់ ប. ឯក. ជា ឯតំ, ត្រង់ ប., ទុ. ពហុ. ជា ឯតានិ (រូបសិទ្ធិដូច កុល) ក្រៅពីនោះដូចបុំលិង្គទាំងអស់ ។

រូបសិទ្ធិ: ត្រង់ "ឯសោ, ឯសា, ឯនំ" ផ្លាស់ "ត" របស់ឯត ជា "ស", ជា "ន" ដោយមេសូត្រ ឯតតេសន្តោ, តស្សវានត្តំ សព្វត្ថ វិធីសម្រេចរូបគ្រប់វិភត្តិដូច "ត" សព្ទ ទាំង ៣ លិង្គ ប្លែកអំពីតសព្ទតែត្រង់ផ្លាស់អាជាឥ ត្រូវប្រើមេសូត្រ ឯតិមាសមិ ។

[១២០] "ឥម" សព្ទ ក្នុងបុំលិង្គ បំបែកដូច្នេះ:

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. អយំ | ឥមេ |
| ទុ. ឥមំ | ឥមេ |
| ត. ឥមិនា, អនេន | ឥមេហិ, (ឯហិ) |
| ច. ឥមស្ស, អស្ស | ឥមេសំ, ឥមេសានំ, (ឯសំ) |
| បញ្ច. ឥមស្មា, ឥមម្හា, អស្មា | ឥមេហិ, (ឯហិ) |
| ឆ. ឥមស្ស, អស្ស | ឥមេសំ, ឥមេសានំ, (ឯសំ) |
| ស. ឥមស្មឹ, ឥមម្ហិ, អស្មឹ | ឥមេសុ, (ឯសុ) |

## រូបសិទ្ធិ មានមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. អនបុំសកស្សាយំសិម្ហិ | សព្វនាមការតេបឋមោ,សរលោបោ... |
| ទុ. យទនុបបន្នានិបាតនាសិជ្ឈន្តិ | សព្វយោនីនមាឯ, សរលោបោ... |
| ត. អនិមិនាម្ហិច, អតោនេន... | សុហីស្វកាពោឯ, សព្វស្សិមស្សេវា |
| ច.សាគមោសេ, ឥមសទ្ទស្សច, សាគមោសេ | សព្វនាមានន្នម្ហិច, សព្វតោនំសំ-សានំ, សព្វស្សិមស្សេវា |
| បញ្ច. ស្មាហិស្មិនម្ហាភិម្ហិវា, ឥម-សទ្ទស្សច | ដូច ត. ពហុ. |
| ឆ. ដូច ច. ឯក. | ដូច ច. ពហុ. |
| ស. ស្មាហិស្មិនម្ហាភិម្ហិវា, ឥម-សទ្ទស្សច | សុហីស្វកាពោឯ, សព្វស្សិមស្សេវា |

## រូបសិទ្ធិ ឥតមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. ផ្លាស់ ឥម និង សិ ជា អយំ | ផ្លាស់យោជាឯហើយលុបអ ចេញផ្សំជាឥមេ |
| ទុ. ឥមផ្សំនឹង ំ ជាឥមំ | ឥមេ ដូច ប. ពហុ. |
| ត. ផ្លាស់ ឥមជាឥមិផ្សំនឹងនាជា-ឥមិនា, ផ្លាស់ ឥម ជា អន, ផ្លាស់ នា ជា ឯន ហើយលុប អ ចេញជា អនេន | ផ្លាស់អជាឯផ្សំនឹងហិជាឥមេហិ, ផ្លាស់ ឥមជាឯ ផ្សំនឹង ហិជាឯហិ |
| ច. ចុះសអាគមផ្សំនឹងសវិភត្តិជា ឥមស្ស, ផ្លាស់ឥមជាអហើយចុះ សអាគម ផ្សំនឹង សវិភត្តិជាអស្ស | ផ្លាស់នំជាសំ, ជាសានំ, ហើយ ផ្លាស់ អជាឯផ្សំជាឥមេសំ, ឥមេ-សានំ, ផ្លាស់ឥមជាឯហើយផ្លាស់ នំ ជា សំ ផ្សំ ជា ឯសំ |

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| បញ្ច. ឥមផ្សំនឹងស្មាជាឥមស្មា, ផ្លាស់ស្មាជាម្ហាផ្សំឥមម្ហា, ផ្លាស់ឥម ជា អផ្សំនឹង ស្មា ជា អស្មា | ឥមេហិ, ឯហិ ដូច ត. ពហុ. |
| ឆ. ឥមស្ស, អស្ស ដូច ច. ឯក. | ឥមេសំ,ឥមេសានំ,ឯសំដូច ច.ពហុ. |
| ស.ឥមផ្សំនឹងស្មឹជាឥមស្មឹ, ផ្លាស់ ស្មឹ ជា ម្ហិ ជា ឥមម្ហិ, ផ្លាស់ឥម ជា អ ផ្សំនឹង ស្មឹ ជា អស្មឹ | ផ្លាស់អជាឯផ្សំនឹងសុជាឥមេសុ, ផ្លាស់ ឥមជាឯផ្សំនឹងសុជាឯសុ |

"ឥម" សព្ទ ក្នុងឥត្ថីលិង្គ បំបែកដូច្នេះ:

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| ប. អយំ | ឥមា |
| ទុ. ឥមំ | ឥមា |
| ត. ឥមាយ | ឥមាហិ |
| ច. ឥមិស្សា,ឥមិស្សាយ,អស្សា | ឥមាសំ, ឥមាសានំ |
| បញ្ច. ឥមាយ | ឥមាហិ |
| ឆ. ឥមិស្សា, ឥមិស្សាយ, អស្សា | ឥមាសំ, ឥមាសានំ |
| ស. ឥមិស្សំ, អស្សំ, (ឥមាយំ) | ឥមាសុ |

# រូបសិទ្ធិ មានមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប.ឥត្ថិយមតោ..., អាយោ, ក្វចា-ទិ ។ ល ។ សុច, អនបុំ-សកស្សាយំសិម្ហិ | ឥត្ថិយមតោ..., អាយោ, យប-តោចយោនំលោបោ |
| ទុ. ឥត្ថិយមតោ..., អាយោ, ក្វចាទិ-។ ល ។ សុច | ដូច ប. ពហុ. |
| ត.ឥត្ថិយមតោ...,អាយោ,យតោនាទីនិ | ឥត្ថិយមតោ..., អាយោ |
| ច. ឥត្ថិយមតោ..., អាយោ,យបតោស្មឹ-សានំសំសា, ឯតិមាសមិ, សំសាស្វេ-កវចនេសុច, តតោសស្សស្សាយ, ឥត្ថិយមតោ...។ល។ឥមស្សសទ្ទស្សច... | ឥត្ថិយមតោ..., អាយោ, សព្វ-តោនំសំសានំ |
| បញ្ច. ដូច ត. ឯក. | ដូច ត. ពហុ. |
| ឆ. ដូច ច. ឯក. | ដូច ច. ពហុ. |
| ស.ឥត្ថិយមតោ... អាយោ.យបតោ ស្មឹសានំសំសា, ឯតិមាសមិ, ឥម-សទ្ទស្សច, នេតាហិស្មិមាយយា យបតោស្មឹយំវា | ឥត្ថិយមតោ..., អាយោ |

# រូបសិទ្ធិ ឥតមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
| --- | --- |
| **ប**. ចុះ អាបច្ច័យហើយលុប អ របស់មចេញ ផ្សំ ជា ឥមា, វស្សៈអា របស់ មា ជា អឲ្យទៅជាឥមវិញ ហើយផ្លាស់ឥមនិងសិជាអយំ[១] | ចុះអាបច្ច័យហើយលុបអរបស់ ម និង យោ ចេញផ្សំជា ឥមា |
| **ទុ**. ចុះ អាបច្ច័យហើយលុប អ របស់មចេញផ្សំជាឥមា,វស្សៈអាជា អឲ្យទៅជាឥមវិញផ្សំនឹងំជាឥមំ | ឥមា ដូច ប. ពហុ. |
| **ត**. ចុះ អាបច្ច័យហើយលុប អ របស់ ម ចេញផ្សំជា ឥមា, ផ្លាស់ នា ជា អាយ ហើយលុបអារបស់ មា ចេញផ្សំជា ឥមាយ | ចុះអាបច្ច័យហើយលុបអរបស់ មចេញផ្សំនឹងហិជាឥមាហិ |
| **ច**.ចុះអាបច្ច័យហើយលុបអរបស់ មចេញផ្សំជាឥមា,ផ្លាស់សវិភត្តិជា សា, ផ្លាស់អារបស់មាជាតហើយ, ចុះសអាគមផ្សំជាឥមិស្សា, ផ្លាស់ សវិភត្តិជាស្សាយផ្សំជាឥមិស្សាយ ចុះអាបច្ច័យ ។ល។ ផ្លាស់ឥមជាអ ។ល។ ផ្សំជាអស្សា | ចុះ អាបច្ច័យហើយ ផ្លាស់ នំ ជា សំ ជា សានំ ផ្សំជា ឥមាសំ, ឥមាសានំ |
| **បញ្ច**. ឥមាយ ដូច ត. ឯក. ប្លែកតែ ផ្លាស់ ស្មា ជា អាយ ប៉ុណ្ណោះ | ឥមាហិ ដូច ត. ពហុ. |
| **ឆ**. ឥមស្សា, ឥមិស្សាយ, អស្សា ដូច ច. ឯក. | ឥមាសំ, ឥមាសានំ ដូច ច.ពហុ. |

(១) មិនបាច់ធ្វើតាមវិធីនេះ "គ្រាន់តែផ្លាស់ឥមនិងសិជាអយំតែម្តងក៏បាន ។

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ស. ចុះ អាបច្ច័យហើយលុប អ របស់មចេញផ្សំជាឥមា, ផ្លាស់ស្មឹ ជាសំ, ផ្លាស់ អា របស់ មា ជា ឥ ហើយចុះសអាគមផ្សំជាឥមិស្សំ, ចុះ អាបច្ច័យ ។ល។ រស្សៈ អា របស់ មា ជា អ ឲ្យទៅជាឥមវិញ ហើយផ្លាស់ឥមជាអ។ល។ ផ្សំជា អស្សំ, ចុះអាបច្ច័យ ។ល។ ផ្លាស់ ស្មឹជាយំ ។ល។ ផ្សំជាឥមាយំ | ចុះអាបច្ច័យផ្សំនឹងសុជាឥមាសុ |

"ឥម" សព្ទ ក្នុងនបុំសកលិង្គ ត្រង់ប. ឯក. ជា ឥទំ ត្រង់ ទុ. ឯក. ជា ឥមំ ឥទំ, ត្រង់ ប. ទុ. ពហុ. ជា ឥមានិ ។ រូបសិទ្ធិ, ត្រង់ ប. ទុ. ឯក ផ្លាស់ឥមនិងសិនិង ំ ជា ឥទំ ដោយមេសូត្រ ឥមស្សិទមំសីសុនបុំសកេ, ត្រង់ ប. ទុ. ពហុ, ដូច កុល, ក្រៅ ពីនោះដូច ឥម ក្នុងបុំលិង្គ ។

[១២១] "អមុ" សព្ទ ក្នុងបុំលិង្គ បំបែកដូច្នេះ:

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | អមុ, អសុ | អមូ |
| ទុ. | អមុំ | អមូ |
| ត. | អមុនា | អមូហិ |
| ច. | អមុស្ស, អមុនោ | អមូសំ, អមូសានំ |

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| បញ្ច. អមុស្មា, អមុម្ហា | អមូហិ |
| ឆ. អមុស្ស, អមុនោ | អមូសំ, អមូសានំ |
| ស. អមុស្មឹ, អមុម្ហិ | អមូសុ |

## រូបសិទ្ធិ មានមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. សេសតោលោបំគសិបិ, អមុស្សមោសំ, សេសតោលោបំគសិបិ | ឥវណ្ណុវណ្ណាឈលា, យបតោចយោនំលោបោ,យោសុកតនិការលោបេសុទីឃំ |
| ទុ. ឥវណ្ណុ...អម្ហោ។ល។លបេហិ (និគ្គហិតំលការំនេតព្វំ) | ដូច ប. ពហុ. |
| ត. គ្រាន់តែចុះនាវិភត្តិស្រេច | សុនំហីសុច |
| ច. សាគមោសេ, ឥវណ្ណុ...,ឈលតោសស្សនោវា | សព្វតោនំសំសានំ, សុនំហីសុច |
| បញ្ច. ឥវណ្ណុ... ឈលតោច | ដូច ត. ពហុ. |
| ឆ. ដូច ច. ឯក. | ដូច ច. ពហុ. |
| ស. ស្មាហិស្មឹនម្ហាភិម្ហិវា | សុនំហីសុច |

## រូបសិទ្ធិ ឥតមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. គ្រាន់តែលុប សិ ចេញគង់រូបនៅជា អមុ ដូចដែល, ផ្លាស់ ម របស់ អមុ ជា ស ហើយលុប សិ ចេញផ្សំជា អសុ | លុប យោ ចេញហើយទីឃៈ ឧ ជា ឩ ជា អមូ |

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ទុ. អមុ ផ្សំនឹង ំ ជា អមុំ | អមូ ដូច ប. ពហុ. |
| ត. អមុ ផ្សំនឹង នា ជា អមុនា | ទីឃៈឧជាឩផ្សំនឹងហិជាអមូហិ |
| ច. ចុះសអាគមផ្សំនឹងសវិភត្តិជា | ផ្លាស់នំជាសំ, ជាសានំហើយទីឃៈ |
| អមុស្សផ្លាស់សជានោផ្សំជាអមុនោ | ឧជាឩផ្សំជាអមូសំ, អមូសានំ |
| បញ្ច. ផ្លាស់ស្មាជានាផ្សំជាអមុនា | អមូហិ ដូច ត. ពហុ. |
| ឆ. អមុស្ស, អមុនោ ដូច ច. ឯក. | អមូសំ, អមូសានំ ដូច ច. ពហុ. |
| ស. អមុ ផ្សំនឹង ស្មឹ ជា អមុស្មឹ, ផ្លាស់ស្មឹជាម្ហិផ្សំជាអមុម្ហិ | ទីឃៈឧជាឩផ្សំនឹងសុជាអមូសុ |

"អមុ" សព្ទ ក្នុងឥត្ថីលិង្គ បំបែកដូច្នេះ

| | ឯកវចនៈ | ពហុវចនៈ |
|---|---|---|
| ប. | អមុ, អសុ | អមូ |
| ទុ. | អមុំ | អមូ |
| ត. | អមុយា | អមូហិ |
| ច. | អមុស្សា | អមូសំ, អមូសានំ |
| បញ្ច. | អមុយា | អមូហិ |
| ឆ. | អមុស្សា | អមូសំ, អមូសានំ |
| ស. | អមុស្សំ, (អមុយំ) | អមូសុ |

## រូបសិទ្ធិ មានមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប. សេសតោលោបំគសិបិ, អមុស្សមោសំ, សេសតោលោបំគសិបិ | តេឥត្ថីខ្យាបោ, យបតោចយោនំលោបោ, យោសុកតនិការលោបេសុទីឃំ |
| ទុ. តេឥត្ថីខ្យាបោ, អម្មោ ។ល។ លបេហិ, (និគ្គហិតំបការំនេតព្វំ) | ដូច ប. ពហុ. |
| ត. តេឥត្ថីខ្យាបោ, បតោយា | សុនំហីសុច |
| ច.តេឥត្ថីខ្យាបោ,យបតោស្មឹសានំសំសា, សំសាស្វេកវចនេសុច | តេឥត្ថីខ្យាបោ, យបតោនំសំសានំ, សុនំហីសុច |
| បញ្ច. តេឥត្ថីខ្យាបោ, បតោយា | ដូច ត. ពហុ. |
| ឆ. ដូច ច. ឯក. | ដូច ច. ពហុ. |
| ស. តេឥត្ថីខ្យាបោ, យបតោស្មឹសានំសំសា, សំសាស្វេកវចនេសុច, តេឥត្ថីខ្យាបោ,យបតោស្មឹយំវា | សុនំហីសុច |

## រូបសិទ្ធិ ឥតមេសូត្រ

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ប.គ្រាន់តែលុប សិ ចេញគង់រូបនៅជាអមុដូចដែល, ផ្លាស់ ម របស់ អមុ ជា ស ហើយ លុប សិ ចេញផ្សំជា អសុ | លុប យោ ចេញហើយ ទីឃៈ ឧ ជា ឩ ជា អមូ |

| ឯកវចនៈ | ពហុវចនៈ |
|---|---|
| ទុ. អមុ ផ្សំនឹង ° ជា អមុំ | អមូ ដូច ប. ពហុ. |
| ត. ផ្លាស់ នាជាយា ផ្សំជាអមុយា | ទីយៈ ឧជាឱ ផ្សំនឹង ហិជា អមូហិ |
| ច. ផ្លាស់សវិភត្តិជាសាហើយចុះ សអាគម ផ្សំជា អមុស្សា | ផ្លាស់ នំ ជា សំ, ជាសានំ ហើយ ទីយៈឧជាឱផ្សំជាអមូសំ,អមូសានំ |
| បញ្ច.ផ្លាស់ស្មាជាយាផ្សំជាអមុយា | អមូហិ ដូច ត. ពហុ. |
| ឆ. អមុស្សា ដូច ច. ឯក. | អមូសំ, អមូសានំ ដូច ច. ពហុ. |
| ស.ផ្លាស់ ស្មឹ ជា សំ ហើយចុះ សអាគមផ្សំជា អមុស្សំ, ផ្លាស់ ស្មឹ ជា យំ ផ្សំជា អមុយំ | ទីយៈ ឧជាឱ ផ្សំនឹង សុជាអមូសុ |

"អមុ" សព្ទ ក្នុងនបុំសកលិង្គ ត្រង់ ប. ទុ. ឯក. ជា អទុំ, ប. ទុ. ពហុ. ជា អមូនិ ។ រូបសិទ្ធិ ត្រង់ ប. ទុ. ឯក ផ្លាស់ អមុនិងសិនិង ° ជា អទុំ ដោយមេសូត្រ អមុស្សាទុំ. ត្រង់ ប. ទុ. ពហុ. ដូច វត្ថុ. ក្រៅពីនោះដូច អមុ ក្នុងបុំលិង្គ ។

អមុ ក្តី អសុ ដែលផ្លាស់រូបចេញមកពីអមុនោះក្តី កាលបើចុះ "ក" អាគមថែមមកទៀតដោយមេសូត្រ សព្វតោកោ សម្រេចរូបជា អមុក. អសុក. យ៉ាងនេះក៏គង់នៅប្រែថា "ឯណោះ" ដូចដែល ប៉ុន្តែមានវិធីបំបែកដូច "យ" សព្ទ ទាំង ៣ លិង្គ ។

# អព្យយសព្ទ

[១២២] មានសព្ទពួកមួយផ្សេងដោយឡែក ហៅថា "អព្យយសព្ទ" ប្រែថា "សព្ទមិនវិនាស" គឺមិនប្រែប្រួលចាកភាពដើមរបស់ខ្លួន, រូបដើមយ៉ាងណា ក៏នៅនឹងយ៉ាងនោះដូចដែល ជា "អលិង្គ" គឺនឹងកំណត់ថាជាបុំលិង្គ, ឥត្ថីលិង្គ ឬនបុំសកលិង្គ ក៏មិនមែន, នឹងបំបែកដោយវិភត្តិទាំង ៧ វចនៈទាំងពីរពុំបានឡើយ ជាសព្ទសម្រាប់ប្រើជាជំនួយនាមសព្ទនិងកិរិយាសព្ទ ឲ្យមានសេចក្ដីប្លែកចាកប្រក្រតីក៏មាន សម្រាប់ប្រើផ្ដើមត, បំពេញសេចក្ដីក្នុងសង្កាត់ឃ្លាប្រយោគមួយ ៗ ក៏មាន ។ ល ។

អព្យសព្ទនោះចែកជា ៣ ពួកគឺ ជា ឧបសគ្គ ១ ពួក ជា និបាត ១ ពួក ជា បច្ច័យ ១ ពួក ។ ពួកឧបសគ្គ សម្រាប់ប្រើដាក់រៀងភ្ជាប់ឲ្យនៅខាងដើមនាមសព្ទនិងកិរិយាសព្ទ ។ ពួកនិបាត សម្រាប់ប្រើដាក់រៀងដាច់ដោយខ្លួន ត្រង់ចន្លោះឬត្រង់សង្កាត់ពាក្យក្នុងឃ្លាសេចក្ដីមួយ ៗ រៀងភ្ជាប់ជាមួយនឹងនាម-

សព្ទ ដែលរួមជាបទសមាសក៏បានខ្លះ ។ ពួកបច្ច័យ សម្រាប់ចុះត្រង់ខាងចុងធាតុជាកិរិយាសព្ទក៏បាន ចុះត្រង់ខាងចុងនាម-សព្ទ ក៏បាន ហៅថា "អព្យយបច្ច័យ" ។

## ឧបសគ្គ

[១២៣] ឧបសគ្គមាន ២០ សព្ទ ។ ខ្ញុំនឹងរៀបរៀងឧបសគ្គទាំងនោះតាមលំដាប់អក្សរតាំងពីអអារៀងទៅ ដើម្បីឲ្យអ្នកសិក្សាងាយចំណាំ ដូចមានរបៀបខាងក្រោយនេះ:

អតិ កន្លង, ក្រៃ, ក្រៃពេក, ពេក...

អធិ ក្រៃលែង,ក្រៃពេក,លើសលប់,លើសលែង,សង្កត់..

អនុ តាម,តូច,បន្ទាប់,រង,ក្រោយ,បណ្ដោយ,លំដាប់.

អប ប្រាស, គេច, ជៀស....

អបិ ឬ បិ[១] ជិត, ខាងលើ,....។

---

១ អបិ ឬ បិ ទាំង ២ សព្ទនេះ ជា ឧបសគ្គ-និបាត ពីព្រោះប្រើជាឧបសគ្គក៏បាន, ប្រើជានិបាតក៏បាន, បើប្រើជាឧបសគ្គ ហៅថា ឧបសគ្គ, បើប្រើជានិបាត ហៅថា និបាត ។

អភិ ក្រៃពេក, ធំ, ចំពោះ,ឆ្ពោះ, ខាងមុខ,...

អវ ឬ ឱ ចុះ, ចុះក្រោម, ទាប, ស្រេច,...

អា ទូទៅ, សព្វ, ក្រៃលែង,...

ឧ ឡើង, ខ្ពស់, ក្រៅ,...

ឧប ជិត, ចូល, ចូលទៅជិត, មាំ, ស៊ប់,...

ទុ អាក្រក់, ក្រ, កម្រ, លំបាក (ពិបាក),...

និ ចេញ, មិនសល់, មិនមាន, ឥត,...

នី ចេញ, ចូល, ចុះ,...

ប ទូទៅ, ខាងមុខ, ចេញ, មុន,...

បដិ ឬ បតិ ចំពោះ, តប, ត, ច្រាស, ត្រឡប់...

បរា ខាងមុខ,...

បរិ ជុំ, ជុំវិញ, គ្រប់គ្រាន់, ស្រេច....

វិ ផ្សេង, ប្លែក, ច្បាស់, ដាក់, ប្រាកដ,...

សំ ព្រម, ជាមួយ, ល្អ, ប្រពៃ,...

សុ[១] ងាយ,ស្រួល,ស្រណុក,ល្អ,ប្រពៃ,ណាស់,ម្ល៉េះ,អ្វីម្ល៉េះ

---

១ សុ ក៏ជា ឧបសគ្គ-និបាត ដូច អបិ និង បិ ដែរ ។

## កាថាសម្រាប់ចង្អេញឲ្យដាយចាំ

អត្យា-ធ្យា នុ អបា-ប្យា-ភិ អវ អា ឧ ឧប ទុ្ស និ នី ប បដិ បរា សំ សុ បរិ វិ (វីសធា សិយុំ) ។

## បែបប្រើឧបសគ្គ

[១២៤] ឧបសគ្គ ទាំង ២០ សព្ទនោះ បើដាក់រៀងជាខាងដើមនាំមុខនាមសព្ទ ប្រើចំពោះបានតែនាំមុខនាមនាមនិងគុណនាមតែ ២ យ៉ាងប៉ុណ្ណោះ នឹងប្រើនាំមុខសព្វនាមពុំបានឡើយ ។ ឯចំណែកខាងកិរិយាសព្ទ ត្រូវដាក់ឧបសគ្គនាំមុខបាន តាមគួរដល់ការប្រកបប្រើ ។ ឧបសគ្គ បើនាំមុខនាមនាមច្រើនតែមានអាការប្រហែលដូចគុណនាមជាបទវិសេសនៈ ឧ. បតិ "ម្ចាស់, ចៅហ្វាយ, នាយ", អធិបតិ "ចៅហ្វាយធំ, ចាងហ្វាង", នាយកោ "នាយក (អ្នកដឹកនាំ, អ្នកត្រួតត្រា)", អនុនាយកោ "នាយកបន្ទាប់, នាយករង" ។ បើនាំមុខគុណនាម ច្រើនតែនាំសព្ទនោះឲ្យមានសេចក្ដីជាអតិវិសេសគុណនាម ឧ. សុន្ទរោ "ល្អ", អតិសុន្ទរោ "ល្អកន្លង, ល្អណាស់" ។ បើនាំមុខកិរិយាសព្ទ ច្រើនតែមានអាការប្រហែល

ដូចកិរិយាវិសេសនៈ ឧ. ជានាតិ ដឹង ស្គាល់, ចេះ", វិជានាតិ "ដឹងច្បាស់, ស្គាល់ជាក់, ចេះប្រាកដ, ចេះប្លែក" ។ ប្រើនាំមុខនិបាតសព្ទ មានអាការដូចជាបទវិសេសនៈរបស់និបាតសព្ទនោះក៏មាន ឧ. សាយំ "ល្ងាច", អតិសាយំ "ល្ងាចពេក. ល្ងាចណាស់" ។ ជួនណា ឧបសគ្គ អាចបំបែរសព្ទដែលខ្លួននាំមុខនោះ ព្រមទាំងខ្លួនឯង ឲ្យមានសេចក្ដីងាកឃ្លាតបាត់ស្រឡះចាកលំនាំដើម ឲ្យក្លាយជាសេចក្ដីផ្សេងទៅវិញក៏មាន, កាលបើមានអាការយ៉ាងនេះ ហៅថា "ឧបសគ្គបំបែរធាតុ" ឬ "ឧបសគ្គបំបែរសព្ទ" ឧ. ភវតិ "កើត, មាន ចម្រើន", អនុភវតិ "សោយ, រង ទទួលរង...", អភិភវតិ "គ្របសង្កត់, បំពាន, រំលោភ, គម្រាម,..." ។ គច្ឆតិ "ទៅ ដល់", អាគច្ឆតិ "មក" ។ ភវោ "សេចក្ដីចម្រើន" បរាភវោ "សេចក្ដីវិនាស, កិរិយាលាញ" ។ ជួនណាបង្វែរនាមសព្ទ ដែលខ្លួននាំមុខនោះ ឲ្យក្លាយទៅជានិបាតសព្ទ ហើយបំបែរសេចក្ដីឲ្យងាកចេញផ្សេងអំពីដំណើរដើមទៅវិញក៏មាន ឧ. ខណោ "ខណៈ (ស្របក់, រំពេច)" អភិក្ខណំ "រឿយ ៗ, ញឹកញយ" ។

# ឧទាហរណ៍សង្ខេប

[១២៥] សព្ទប្រែចេញអំពីឧបសគ្គទាំង ២០ ដែលបានប្រែមកហើយត្រង់លេខ ១២៣ នោះ គ្រាន់តែជាគោលឲ្យអ្នកសិក្សាចំណាំក្នុងវិធីប្រែសព្ទ មិនមែនអស់ហើយតែប៉ុណ្ណោះទេ ពីព្រោះឧបសគ្គទាំងនោះមានន័យឲ្យប្រែច្រើនបែបណាស់ គឺឲ្យប្រែតម្រូវតាមដំណើរសេចក្ដី ។

នឹងសម្ដែងឧទាហរណ៍សង្ខេប ឲ្យល្មមដល់អធ្យាស្រ័យអ្នករៀនថ្មី ដូចមានរបៀបតទៅនេះ :

## អតិ

(នាម) អតិចរណំ "កិរិយាប្រព្រឹត្តកន្លង, -ល្មើស, -ផិត -ក្បត់" ។ (គុណ) អតិទីឃោ "វែងពេក, វែងណាស់" ។ (កិរិយា) អតិសោភតិ "ល្អកន្លង, ល្អពេក, ល្អណាស់, រុងរឿង" ។ (និបាត) អតិប្បគោ "ព្រឹកពេក, ព្រឹកណាស់, ព្រឹកណាស់ពេក" ។

អធិ

(ន.) ករណំ "អំពើ", អធិករណំ "វិវាទ, ជម្លោះ, ក្ដី" ។ (គុ.) អធិវរោ "ប្រសើរក្រៃពេក, ប្រសើរលើសលប់" ។ (កិ.), វសតិ "នៅ", អធិវសតិ "នៅអាស្រ័យ,...", អធិវាសេតិ អត់សង្កត់, ខំទ្រាំ, ទទួល, ទទួលនិមន្ត, ទទួលអញ្ជើញ" ។

អនុ

(ន.) អនុចរោ "អ្នកដើរតាម, អ្នកដោយសារ,...", អនុ-ថេរោ "ព្រះថេរៈបន្ទាប់, ព្រះថេរៈតូច" ។ (កិ.) អនុករោតិ "ធ្វើតាម, យកតម្រាប់, ត្រាប់" ។

អប

(ន.) គមនំ "កិរិយាទៅ", អបគមនំ "កិរិយាជៀសចេញទៅ, កិរិយាគេចចេញ..." ។ (កិ.) នេតិ "នាំ, នាំទៅ" អបនេតិ "នាំចេញ, បម្រាស, ផ្លាស់..." ។

## អបិ ឬ បិ

(ន.) អបិកច្ឆោ "ជិតក្លៀក", អបិធានំ ឬ បិធានំ "វត្ថុសម្រាប់ដាក់ខាងលើ, - សម្រាប់គ្រប (គ្រប)", អបិហារោ "កិរិយានាំមកខាងលើ, កិរិយាយោងឡើង,..." ។ (កិ.) ទហតិ "ដុត, ឆេះ, កម្ដៅ,...", បិទហតិ "បិទ, គ្រប, ខ្ទប់, ស្លង់, ភ្ជិត... ។

## អភិ

(ន.) អភិរតិ "សេចក្ដីរីករាយក្រៃពេក", អភិវាទនំ "កិរិ-យាសំពះ, - ថ្វាយបង្គំ ដោយគោរព" ។ (គុ.) អភិនវោ "ថ្មីក្រៃពេក (ថ្មីសន្លាង)" ។ (កិ.) អភិក្កមតិ "ឈានទៅខាងមុខ,..." ។

## អវ ឬ ឱ

(ន.) ធារណំ "កិរិយាទ្រទ្រង់", អវធារណំ "កិរិយាទទួលបន្ទុក, កិរិយាឃាត់,..." តរណំ "កិរិយាឆ្លង", ឱតរណំ "កិរិ-យាស្ទង់..." ។ (គុ.) អវំសិរោ "មានក្បាលចុះក្រោម" ។ (កិ.) មញ្ញតិ "ដឹង, ស្មាន", អវមញ្ញតិ, អវមញ្ញេតិ "មើលងាយ", វទតិ "ពោល, ស្ដី, និយាយ, ថា" , ឱវទតិ "ទូន្មាន" ។

(ន.) ការោ "អ្នកធ្វើ, ការ (អំពើ, របរ) អាការោ "ដំណើរលំនាំ (អាការ)", រតិ "សេចក្ដីត្រេកអរ, តម្រេក", អារតិ "កិរិយាវៀរ, - លះលែង, - តម" ។ (កិ.) បូរតិ "ពេញ", អាបូរតិ "ពេញកំពុង, ពេញព្រៀប..." ។

## ឧ

(ន.) បថោ "ផ្លូវ", ឧបថោ "ផ្លូវខុស, ក្រៅគន្លង" ។ (កិ.) គច្ឆតិ "ទៅ, ដល់", ឧគ្គច្ឆតិ "ឡើងទៅលើ, ហោះឡើង, រះឡើង,...", ធរតិ "ទ្រទ្រង់", ឧទ្ធរតិ "រើ, រើឡើង, លើកឡើង, គាស់ឡើង,..." ។

## ឧប

(ន.) វនំ "ព្រៃ", ឧបវនំ "សួន, សួនច្បារ, ។ (កិ.) ធារេតិ "ទ្រទ្រង់, បាំង...", ឧបធារេតិ "ពិចារណា, រំពឹង", និសីទតិ "អង្គុយ" ឧបនិសីទតិ "អង្គុយជិត" ។

ទុ

(ន.) វុឌ្ឍិ "ភ្លៀង", ទុព្វុឌ្ឍិ "ភ្លៀងមិនស្រួល" ។ (គុ.), បញ្ញោ "មានប្រាជ្ញា", ទុប្បញ្ញោ "ឥតប្រាជ្ញា" ។ (កិ.) លភតិ បាន", ទុល្លភតិ "បានដោយក្រ, ពិបាកបាន" ។

និ(១)

(ន.) ទស្សនំ "កិរិយាឃើញ", និទស្សនំ "កិរិយាសម្តែងចេញ, ចង្អុលបង្ហាញ, សេចក្តីពន្យល់, ឧទាហរណ៍" ។ (គុ.) និទ្ទោសោ "ឥតទោស" ។ (កិ.) វារេតិ "ប្រាថ្នា...", និវារេតិ "ឃាត់, ហាម, រារាំង..." ។

នី(១)

(ន.) នីវរណំ "កិរិយារាំង ធម្មជាតជាគ្រឿងរារាំង..." ។ (គុ.) និយានិកំ ឬ និយ្យានិកំ (សត្ថុ សាសនំ សាសនា របស់

---

១ និ និង នី ទាំង ២ សព្ទនេះ មានទំនងពិបាកសង្កេតជាបំផុត ពីព្រោះជួនណា និ ទីឃៈជា នី ក៏មាន នី រស្សៈជា និ ក៏មាន គួរនឹងឲ្យចូលចិត្តថាឧបសគ្គ ទាំង ២ នេះ មានរូបតែមួយគឺមានតែ "និ" មួយប៉ុណ្ណោះ កាលបើទីឃៈក៏ក្លាយជា "នី" ទៅ, ប៉ុន្តែបើនឹងសម្រេចសេចក្តីចូលចិត្តយ៉ាងនេះទៅ នឹងខុសអំពីន័យក្នុងគម្ពីរសព្ទសាស្ត្រទាំងពួង ខាងភាសាបាឡី មានគម្ពីរអភិធានប្បទីបិកាជាដើម ដែលវេយ្យាករណបណ្ឌិតទាំងឡាយលោកបានសម្រេចជា ២ សព្ទស្រេចមកហើយ ព្រោះហេតុនោះ សាស្ត្រាចារ្យគួរនាំយកឧទាហរណ៍អំពីគម្ពីរទាំងពួងមកអធិប្បាយពន្យល់សិស្សផងចុះ ។

ព្រះសាស្តា) "ជាហេតុនាំសត្វឲ្យចេញ (ចាកវដ្តទុក្ខ)" ។ (កិ.) នីហរតិ "នាំចេញ..." ។

ប

(ន.) ហារោ "កិរិយានាំ, - ប្រកាន់, កងក, ខ្សែក" បហារោ "កិរិយាវាយ, - ទះ, - សម្លាប់..." ។ (គុ.) បមុខោ "ដែលនាំមុខ, - ជាប្រធាន..." ។ (កិ.) ជានាតិ "ដឹង, ស្គាល់, ចេះ", បជានាតិ "ដឹងសព្វ..." ។

បដិ ឬ បតិ

(ន.) បដិវចនំ "ពាក្យតប. ពាក្យត" ។ (កិ.) បតិដ្ឋាតិ "តម្កល់ចំពោះ, ដាក់ចំ,..." ។

បរា

(ន.) ជយោ "កិរិយាឈ្នះ (ជម្នះ)", បរាជយោ កិរិយាចាញ់" ។ (កិ.) ភវតិ "កើត, មាន, ចម្រើន", បរាភវតិ "វិនាស, លាញ" ។

## បរិ

(ន.) ភាសនំ "កិរិយាពោល, - និយាយ, - ស្តី, បរិ-ភាសនំ "កិរិយាជេរ, ពាក្យប្រទេច..." ។ (កិ.) ចរតិ "ប្រព្រឹត្ត, ដើរ...", បរិចរតិ "បម្រើ, ចៅ" ។

## វិ

(ន.) មតិ "គំនិត, ប្រាជ្ញា", វិមតិ "សេចក្តីសង្ស័យ" ។ (កិ.) រមតិ "ត្រេកអរ, រីករាយ", វិរមតិ "វៀរលែង, ជៀសវាង, តម" ។

## សំ

(ន.) ឋានំ "ទី, ទីតាំង, ទីតម្កល់...", សណ្ឋានំ "ទ្រង់, ទ្រង់ទ្រាយ, រាង" ។ (កិ.), ខុភតិ, ខោភេតិ "កម្រើក", សំខុ-ភតិ, សំខោភេតិ "កម្រើកព្រម, រំជួល, ជ្រួល, ផ្អើល..." ។

## សុ

(ន.) សុបថោ "ផ្លូវល្អ, ផ្លូវស្រួល, ផ្លូវត្រូវ" ។ (គុ.) សុករំ "ងាយធ្វើ, ស្រួលធ្វើ, ស្រណុកធ្វើ" ។ (កិ.) សុជាយតេ

"កើតដោយងាយ..." ។ (និ.) ចិរំ "យូរ", សុចិរំ យូរណាស់ យូរពេក" ។

## និបាត

[១២៦] សេចក្ដីដែលបាននិយាយមកហើយក្នុងខាងដើម ត្រង់លេខ ១២២ ថា ពួកនិបាតសម្រាប់រៀងដាច់ដោយខ្លួនត្រង់ចន្លោះ ឬ ត្រង់សង្កាត់ពាក្យក្នុងឃ្លាសេចក្ដីមួយ ៗ នោះ គឺដាក់រៀងត្រង់ចន្លោះនៃនាមសព្ទនិងនាមសព្ទផងគ្នា ឬ កិរិយាសព្ទនិងកិរិយាសព្ទផងគ្នា ឬ ក៏នាមសព្ទនិងកិរិយាសព្ទតគ្នា ពុំនោះដាក់រៀងមុនបំផុត ឬក្រោយបំផុតក្នុងខាងដើម ឬខាងចុងប្រយោគក៏បាន រៀងភ្ជាប់ជាមួយនឹងនាមសព្ទដែលរួមជាបទសមាសក៏បានខ្លះ ។

និបាតសព្ទនោះមានច្រើនណាស់, ក្នុងទីនេះ នឹងនាំយកមកសម្ដែងគ្រាន់តែជាបុព្វភាគនៃការសិក្សា ឲ្យល្មមដល់អធ្យាស្រ័យនៃអ្នកសិក្សាដំបូង ។ ម្យ៉ាងទៀត និបាតទាំងនោះ ជា

សព្ទសម្រាប់ប្រើប្រាប់សេចក្ដីផ្សេង ៗ ជាអនេកមាន អាលបនត្ថវាចកៈ, កាលត្ថវាចកៈ, ឋានត្ថវាចកៈ, បរិច្ឆេទត្ថវាចកៈ, ឧបមានុបមេយ្យត្ថវាចកៈ, បការត្ថវាចកៈ, បដិសេធនត្ថវាចកៈ, អនុស្សវនត្ថវាចកៈ បរិកប្បត្ថវាចកៈ, បុច្ឆនត្ថវាចកៈ, សម្បដិច្ឆនត្ថវាចកៈ, ឧយ្យោជនត្ថវាចកៈ អនេកត្ថវាចកៈ, បទបូរណត្ថវាចកៈ នានត្ថវាចកៈ ជាដើម ដូចមានរបៀបរៀបរៀងដោយសង្ខេបតទៅនេះ

## អាលបនត្ថវាចកៈ

"និបាតប្រាប់សេចក្ដីជាអាលបនៈ"

និបាតពួកនេះមាន ១២ សព្ទ គឺ យគ្ឃេ ភន្តេ ភទន្តេ, ភណេ, អម្ភោ, អាវុសោ, រេ, អរេ, ហរេ, ហេ, អហេ, ជេ ។

## យគ្ឃេ

យគ្ឃេប្រែថា "សូមព្រះរាជតេជះ, សូមព្រះរាជតេជះតម្កល់លើត្បូង, សូមទ្រង់មេត្តាប្រោស, សូមទានមេត្តាប្រោស, ទានប្រោស" ។ សព្ទនេះ សម្រាប់និយាយបានតែចំពោះឥស្សរជន

មានក្សត្រទ្រង់រាជ្យជាដើម ដែលមានអានុភាពច្រើនជាងខ្លួនអ្នកនិយាយ ឬ គ្រហស្ថនិយាយចំពោះជំនុំសង្ឃ ដោយគ្រហស្ថអ្នកនិយាយនោះមានសេចក្ដីគោរពច្រើន ឧ. យគ្ឃេ ទេវ ជានេយ្យាសិ... "សូមព្រះរាជតេជះតម្កល់លើត្បូង, បពិត្រព្រះសម្មតិទេព, សូមព្រះអង្គទ្រង់ជ្រាប..." ។ យគ្ឃេ ភន្តេ ភិក្ខុសង្ឃោ ឥទំ មេ បច្ឆិមទានំ បដិគ្គណ្ហាតុ "សូមទានមេត្តាប្រោស, បពិត្រព្រះសង្ឃដ៏ចម្រើន, សូមព្រះភិក្ខុសង្ឃ-ទទួលនូវទាននេះ ដែលជាអំណោយចុងក្រោយបំផុត របស់ខ្ញុំព្រះករុណា..." ។

## ភន្តេ

ភន្តេ ប្រែថា "បពិត្រព្រះអង្គ-ព្រះករុណា-លោកដ៏ចម្រើន" ជាសព្ទសម្រាប់និយាយចំពោះព្រះសម្មាសម្ពុទ្ធជាម្ចាស់ ឬគ្រហស្ថនិយាយចំពោះបព្វជិត ឬក៏បព្វជិតដែលមានវស្សាខ្ចីជាងនិយាយទៅរកបព្វជិតផងគ្នាដែលមានវស្សាចាស់ជាង ។

## ភទន្តេ

ភទន្តេ ប្រែថា "បពិត្រព្រះអង្គដ៏ចម្រើន" ជាសព្ទសម្រាប់ភិក្ខុទាំងឡាយ ឆ្លើយទទួលព្រះបន្ទូលព្រះសម្ពុទ្ធជាម្ចាស់ ក្នុងកាលដែលទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា, "ភិក្ខវេ" ឬ "ភិក្ខវោ" ប្រែថា "ម្នាលភិក្ខុទាំងឡាយ" ឬថា "ភិក្ខុទាំងឡាយ", ភិក្ខុទាំងនោះក៏ឆ្លើយទទួលព្រះបន្ទូលថា "ភទន្តេ" ប្រែថា "បពិត្រព្រះអង្គដ៏ចម្រើន" ឬថា "ព្រះអង្គដ៏ចម្រើន" បើប្រែតម្រូវតាមលំនាំសម្ដីយើងដែលប្រើសព្វថ្ងៃនេះ ភទន្តេ គួរប្រែថា "ព្រះករុណាថ្លៃវិសេស" ពីព្រោះសព្ទនេះប្រើចេញអាការប្រហែលគ្នានឹងនិបាត-សព្ទថា "អាម" ឬ "អាម ភន្តេ" ដែរ ។

## ភណេ

ភណេ ប្រែថា "នែនាយ, - ចៅ, - ប្រស្ដែង, - វ៉ឺ, - វ៉ឺយ" ជាសព្ទសម្រាប់អ្នកធំនិយាយទៅរកមនុស្សប្រុសអ្នកតូចដែលមានអានុភាពតិចទាបជាងហើយដែលនៅក្នុងបង្គាប់ខ្លួន ។

## អម្ភោ

អម្ភោ ប្រែថា "នៃអ្នកដ៏ចម្រើនទាំងឡាយ, - អស់លោក-អ្នកទាំងឡាយ" ជាពាក្យសម្រាប់អ្នកផងនិយាយទៅរកមនុស្សច្រើននាក់ដោយលំអុតលំឱន, បើនិយាយទៅរកកូនក្មេង, ត្រូវនឹងភាសាយើងថា "នាង, អានាង, វ៉ី, វ៉ីយ..." ។

## អាវុសោ

អាវុសោ ប្រែថា "ម្នាលលោក-អ្នកដ៏មានអាយុ" ជាពាក្យលំអុត សម្រាប់បព្វជិតនិយាយទៅរកគ្រហស្ថសាមញ្ញ ឬ បព្វជិតដែលមានវស្សាចាស់និយាយទៅរកបព្វជិតផងគ្នា ដែលមានវស្សាខ្ចីជាង ។

## រេ, អរេ, ហារេ

ទាំង ៣ សព្ទនេះ ប្រែដូចគ្នាថា "វ៉ី, វ៉ីយ, អាខូច, មេខូច អាចង្រៃ, មេចង្រៃ" ឬថា "ហឺយអានេះ, ហឺយមេនេះ..." ជាពាក្យទ្រគោះ, មាក់ងាយ (ប៉ុន្តែ ហារេ មិនសូវមានប្រើ) ។

ហោ. អហោ

ទាំងពីរសព្ទនេះ ប្រែដូចគ្នាថា "...អស់លោក-អ្នកទាំង-ឡាយ" ឬថា "ហើយ, រ៉ឺយ" ជាពាក្យសម្រាប់និយាយទៅរកមនុស្សច្រើននាក់ដោយសេចក្តីគួរសមក៏បាន, និយាយទៅរកមនុស្សច្រើននាក់ ឬ មនុស្សតែម្នាក់ដោយទ្រគោះក៏បាន ប្រើបានទាំងពីរយ៉ាងតាមលំនាំសេចក្តី (ប៉ុន្តែ អហោ មិនសូវមានប្រើ) ។

ជេ

ជេ ប្រែថា "នែហង, នែមេ" ជាពាក្យសម្រាប់ចៅហ្វាយនាយនិយាយដោយលំអុតទៅរកស្រីជាបាវព្រាវ ឬ ស្រីអ្នកបម្រើដែលមានអានុភាពតូចទាបស្មើបាវព្រាវ ។

គាថាសម្រាប់ជន្ទេញឲ្យជាំយចាំ

យគ្ឃេ ភន្តេ ភទន្តេ (ច) ភណេ អម្ភោ-វុំសោ អរេ

រេ ហរេ ហេ អហេ ជេ (តិ អាលបនត្ថវាចកា) ។

## កាលត្ថវាចកៈ

"និបាតប្រាប់កាល, ប្រាប់ពេល"

| | |
|---|---|
| អថ គ្រានោះ, លំដាប់នោះ... | ស្វេ ស្អែក, ក្នុងថ្ងៃស្អែក |
| បាតោ ព្រឹក, អំពីព្រឹក | បរសុវេ ខានស្អែក, ក្នុងថ្ងៃខានស្អែក |
| ទិវា ថ្ងៃ, ក្នុងវេលាថ្ងៃ | បរស្វេ ខានស្អែក,ក្នុងថ្ងៃខានស្អែក |
| សាយំ ល្ងាច, ក្នុងវេលាល្ងាច | សម្បតិ អម្បាញ់មិញ... |
| សុវេ ថ្ងៃ, ក្នុងវេលាថ្ងៃ | អាយតឹ តទៅ, ក្នុងខាងមុខ |
| ហិយ្យោឬហីយោ ម្សិលមិញ, អំពីម្សិល | |

មួយគាថាគន្លឹះសម្រាប់ងងេញឲ្យងាយចាំ

អថ បាតោ ទិវា សាយំ សុវេ ហិយ្យោ (ច) អាយតឹ
បរស្វេ សម្បតិ (ចេវ) បរសុវេ (ច) ស្វេ (ឥតិ
ឯកាទសយិមេ សទ្ទា សព្វេ កាលត្ថវាចកា) ។

## ឋានត្ថវាចកៈ

"និបាតប្រាប់ទី"

| | |
|---|---|
| ឧទ្ធំ ខាងលើ | អធោ ខាងក្រោម |
| ឧបរិ ខាងលើ | ហេដ្ឋា ខាងក្រោម, ខាងក្រោយ |

| | | | |
|---|---|---|---|
| អន្តរា | ចន្លោះ, រវាង | ឱរំ | ត្រើយអាយ, ខាងអាយ |
| អន្តោ | ខាងក្នុង | បារំ | ត្រើយនាយ, ខាងនាយ |
| តិរោ | ខាងក្រៅ | ហុរំ | លោកដទៃ,លោកឯមុខ |
| ពហិ | ខាងក្រៅ | សម្មុខា | ចំពោះមុខ, នៅមុខ |
| ពហិទ្ធា | ខាងក្រៅ | បរម្មុខា | កំបាំង, កំបាំងពីមុខ |
| ពាហិរំ, ពាហិរា | ខាងក្រៅ | រហោ | ស្ងាត់, ទីស្ងាត់ |

## មួយគាថាកន្លះសម្រាប់ជង្ហេញឲ្យងាយចាំ

ឧទ្ធំ អធោ-បរិ ហេដ្ឋា    អន្តរា-ន្តោ   តិរោ   ពហិ
ពហិទ្ធា  ពាហិរំ  ឱរំ    បារំ  ហុរំ  (ច)  សម្មុខា
បរម្មុខា រហោ (ចាតិ    ឥមេ  ឋានត្ថវាចកា)  ។

## បរិច្ឆេទត្ថវាចកា:

"និបាតប្រាប់សេចក្ដីកំណត់"

| | | | |
|---|---|---|---|
| កីវ | ប៉ុន្មាន, ប៉ុនណា | យាវទេវ | កំណត់ត្រឹមណា,ត្រឹមតែប៉ុនណា |
| យាវ | ដរាបណា, ត្រឹមណា | តាវទេវ | កំណត់ត្រឹមនោះ,ត្រឹមតែប៉ុណ្ណោះ |
| តាវ | ដរាបនោះ, ត្រឹមនោះ | យាវតា | មានប្រមាណប៉ុនណា... |

| | |
|---|---|
| តាវតា មានប្រមាណប៉ុណ្ណោះ... | ឯត្តាវតា មានប្រមាណប៉ុណ្ណេះ... |
| កិត្តាវតា មានប្រមាណប៉ុន្មាន... | សមន្តា ជុំវិញ |

## មួយគាថាគន្លះសម្រាប់ងន្ទេញឲ្យជាំយចាំ

ឯត្តាវតា សមន្តា កី- វ តាវ យាវទេវ តា-
វទេវ យាវតា យាវ កិត្តាវតា (ច) តាវតា
(ឥតិ សព្វេ ឥមេ សទ្ទា បរិច្ឆេទត្ថវាចកា) ។

## ឧបមានុបមេយ្យត្ថវាចកៈ

"និបាតប្រាប់សេចក្តីប្រៀប-ប្រដូច"

| | |
|---|---|
| វិយ បីដូច, ដូច, ដូចជា, ហាក់ដូច ហាក់ដូចជា,ប្រហែលដូច,ប្រហែលដូចជា | សេយ្យថា យ៉ាងណា,យ៉ាង-ណាមិញ,ដូចម្តេចមិញ,ដូចជា |
| ឥវ ប្រដូច, ដូចជា, ដូច | តថា យ៉ាងនោះ, ដូច្នោះ,... |
| យថា ដូចជា, យ៉ាងណា,យ៉ាងណាមិញ... | ឯវំ យ៉ាងនេះ,យ៉ាងនោះ,ដូច្នោះ... |

## គាថាសម្រាប់ងន្ទេញឲ្យជាំយចាំ

វិយិ វ សេយ្យថា យថា តថា ឯវំ (ឥមេ ឥមេ
ឧបមានុបមេយ្យត្ថេ សព្វេ សទ្ទា វ ហោន្តិ ឆ) ។

## បការត្ថវាចកៈ

"និបាតប្រាប់ប្រការ"

ឯវំ ដោយប្រការដូច្នេះ, ដោយប្រការដូច្នោះ...

តថា ដោយប្រការនោះ, ដោយប្រការដូច្នោះ

កថំ ដោយប្រការដូចម្តេច, ម្តេច, ដូចម្តេច

## កន្ទះគាថាសម្រាប់ទន្ទេញឲ្យជាំយចាំ

ឯវំ តថា កថំ (សព្វេ បការត្ថេវ ហោន្តិ-មេ)។

## បដិសេធនត្ថវាចកៈ

"និបាតប្រាប់សេចក្តីឃាត់, ហាម, ដាច់ខាត"

| | |
|---|---|
| ន មិន, មិនមែន, ពុំ, ឥត, ខាន | គ្រាន់តែ, ភ្លាមក៏.... |
| នោ មិន,មិនមែន,ពុំ,ឥត,ខាន | ឯវ មែន, មែនពិត,... |
| មា កុំ | វិនា វៀរលែង,វៀរតែ,លើកលែងតែ... |
| វ ពិត, មែន, តែប៉ុណ្ណោះ,គ្រាន់តែ | អលំកុំ,កុំឡើយ,ល្មើយ,ល្មមហើយ |

## កន្ទះគាថាសម្រាប់ទន្ទេញឲ្យជាំយចាំ

ន នោ មា វ វិនា ឯវ អល (ន្តិ បដិសេធនេ)។

## អនុស្សវនត្ថវាចកៈ

"និបាតប្រាប់សេចក្ដីតាមដែលបានឮ"

កិរ, ខលុ, សុទំ ទាំង ៣ សព្ទ ប្រែដូចគ្នា "ឮថាបានឮថា" ឬ "មានសេក្ដីតំណាលថា" ។

## កាព្ទះគាថាសម្រាប់ងន្ទេញឲ្យង៉ាយចាំ

កិរ ខលុ សុទំ (សទ្ទា ឥមេ វត្តន្ត្យ-នុស្សវេ ។

## បរិកប្បត្ថវាចកៈ

"និបាតប្រាប់សេចក្ដីជញ្ជឹង, ប្រមើល, ស្មាន, ណាត់, សម្រេច"

| | |
|---|---|
| ចេ បើ | អថ បើ, បើថា,.... |
| យទិ បើ, ប្រសិនបើ, ប្រសិនជា, ទោះបី, ល្គឹកតែ, បើថា | អប្បេវនាម ធ្វើម្ដេចហ្ន, គិតដូចម្ដេចហ្ន, ធ្វើយ៉ាងណាអេះ... |
| សចេ បើ, ប្រសិនបើ | យន្នូន បើដូច្នោះ, បើដូច្នោះមានតែ, ដូចម្ដេចហ្ន,... |

## គាថាសម្រាប់ងន្ទេញឲ្យង៉ាយចាំ

សចេ ចេ យទិ យន្នូន អថ អប្បេវនាម (ច

ឥតិ សព្វេ ឥមេ សទ្ទា បរិកប្បត្ថវាចកា) ។

## បុច្ឆនត្ថវាចកៈ

"និបាតប្រាប់សេចក្ដីសួរ, ដណ្ដឹង"

| | | | |
|---|---|---|---|
| កឹ | ឬ, អ្វី, ដូចម្ដេច... | ននុ | មិនមែនឬ,ក្រែង,-ទេដឹង.. |
| កថំ | យ៉ាងណា, ដូចម្ដេច,... | ឧទាហុ | ឬថា, ឬក៏ |
| កច្ចិ | ឬ, ដែរឬ, ខ្លះដែរ,... | អាទុ | ឬថា, ឬក៏ |
| នុ | ...ហ្ន...,អេះ,... ហ៏, ទេដឹង... | សេយ្យថីទំ | ដូចម្ដេចនេះ, យ៉ាងណានេះ, ដូចម្ដេច... |

### គាថាសម្រាប់ចង្អុលឲ្យងាយចាំ

ននុ កឹ នុ កថំ កច្ចិ អាទុ ឧទាហុ (កេវលំ)
សេយ្យថីទំ (ឥមេ សព្វេ សទ្ទា វត្តន្តិ បុច្ឆនេ) ។

## សម្បដិច្ឆនត្ថវាចកៈ

"និបាតប្រាប់សេចក្ដីទទួល, ឆ្លើយ"

អាម, អាមន្ដា ទាំងពីរសព្ទ ប្រែដូចគ្នាថា "អើ[១]...

### កន្លះគាថាសម្រាប់ចង្អុលឲ្យងាយចាំ

អាមា-មន្តា (ឥតិ សទ្ទា វត្តន្តិ សម្បដិច្ឆនេ) ។

---

១ ត្រូវប្រែតាមដំណើរពាក្យឆ្លើយ តាមសមគួរដល់សេចក្ដីដែលប្រើក្នុងភាសាយើង ។

## ឧយ្យោជនត្ថវាចកៈ

"និបាតប្រាប់សេចក្តីតឿន"

| | |
|---|---|
| ឥង្ឃ ដូចជាតឿន,ហ៎,ហ៎ចុះ,ចុះ... | ហន្ទ ហ៎, បើដូច្នោះ... |
| តគ្ឃ ហ៎, ហ៎ចុះ, ចុះ,... | តេនហិ ហ៎, បើដូច្នោះ... |

## កាព្យគាថាសម្រាប់ទន្ទេញឲ្យងាយចាំ

តេនហិ-ង្ឃ តគ្ឃ ហន្ទ (ឧយ្យោជនត្ថវាចកា) ។

## អនេកត្ថវាចកៈ

"និបាតប្រាប់សេចក្តីច្រើនយ៉ាង"

| | |
|---|---|
| ច ផង, ក្តី, ក៏, មួយវិញទៀត, មែនពិត, មួយ,.... | បន ក៏, ឯ, ចំណែកខាង, ប៉ុន្តែ, ប៉ុន្តែថា,.... |
| វា ឬ, ខ្លះ, ក្តី, ក៏ដោយ, ក៏បាន, ពុំនោះសោត... | អបិ,បិ ដែរ, ខ្លះ, ក៏បាន, ក៏មាន, ក៏ដោយ,ថ្វីបើ,ក្រែង,ជួនជា... |
| ហិ ក៏, ពិត, មែន, ព្រោះ, ពីព្រោះ, ដ្បិត,... | អបិច មួយវិញទៀត, អើក៏, ពុំនោះសោត,... |
| តុ ក៏,ឯ,ចំណែកខាង,មួយវិញទៀត... | អថវា មួយវិញទៀត, ម្យ៉ាងទៀតថា... |

# គាថាសម្រាប់ជន្ទេញឲ្យជាំយចាំ

ច វា ហិ តុ បនា-បិ បិ អបិច អថវា (ឥតិ អនេកត្ថា ឥមេ សទ្ទា សទ្ទប្បយោគពន្ធនា) ។

## បទបូរណត្ថវាចកា:

"និបាតប្រាប់សេចក្តីថាគ្រាន់តែបំពេញបទ"

| | |
|---|---|
| នុ ហ្ន, ហ៎, ហឹះ, ហ្ន៎ះ.... | សេ ហ្ន៎ះ,... |
| សុ ហ៎, ហិះ, ហ្ន៎ះ,... | ខោ ឯង,... |
| វេ ហើយ, ហិះ... | វត ឱ. ហ្ន. អើហ្ន. យី. យីអើ... |
| វោ ហ្ន៎ះ, យី, យើ,... | ហវេ ហើយ, យី, យើ, ហ៎ះ, ហ្ន៎ះ,.. |

## កង្វះគាថាសម្រាប់ជន្ទេញឲ្យជាំយចាំ

នុ សុ វេ វោ ហវេ ខោ សេ វតា- (តិ បទបូរណេ) ។

## នានត្ថវាចកា:

"និបាតប្រាប់សេចក្តីផ្សេង ៗ"

| | |
|---|---|
| អញ្ញទត្ថុ ដោយពិត, ប្រាកដ,... | អទ្ធា ដោយពិត, ប្រាកដ... |
| អថោ មួយវិញទៀត... | អវស្សំ ដោយពិត, មែន,... |

អហោ ឱ, ក្រៃពេក...

អារា ឆ្ងាយ, ពីចម្ងាយ,...

អារាំ ច្បាស់, ប្រាកដ, ជាក់

ឥតិ ដូច្នេះ, ព្រោះហេតុដូច្នោះ

ឧច្ចំ ខ្ពស់

កិញ្ចាបិ ក៏មែនហើយ,ប្រាកដមែនហើយ, សូម្បីតិចតួច,...

ក្វចិ ខ្លះ

នានា ផ្សេងៗ , ទីទៃ ៗ,...

នីចំ ទាប

នូន ដោយពិត,ពិត, ប្រាកដ, មែន

បច្ឆា ខាងក្រោយ

បដ្ឋាយ ចាប់ដើម, តាំងពី, ពីដូច

បភូតិ ចាប់ដើម, តាំងពី,...

បុន ទៀត, វិញ

បុនប្បុនំ រឿយៗ, ញឹកញយ,...

ភិយ្យោ ក្រៃលែង

ភិយ្យោសោ ក្រៃលែង

មិច្ឆា ខុស

មុធា ទទេ

មុសា កុហក, មិនពិត

សកឹ មួយគ្រា, ម្តង

សណិកំ តិចៗ,សន្សឹមៗ,សំរៀមៗ ថ្នមៗ, លបៗ, ញើបៗ...

សតក្ខត្តុំ[១] មួយរយដង,មួយរយលើក

សទ្ធឹ មួយអន្លើ, ជាមួយ

សយំ ខ្លួនឯង, ឯង

សហ មួយអន្លើ, ជាមួយ

សាមំ ខ្លួនឯង, ឯង

---

១ ឯកក្ខត្តុំ "ម្តង, មួយលើក", ទ្វិក្ខត្តុំ "ពីរដង, ពីរលើក" ។ល។ ក៏រាប់បញ្ចូលក្នុងនិបាតនេះដែរ ។

## ពីរគាថាគន្ធៈសម្រាប់ឧទ្ទេញឲ្យជាយចាំ

អញ្ញទត្ថុ អថោ អទ្ធា អវស្សំ នូន អារ-ហោ
នីចំ ឧច្ចំ បុន បច្ឆា សណិកា-វិ បុនប្បុនំ
បភូតិ ភិយ្យោ ភិយ្យោសោ មិច្ឆា នានា មុធា មុសា
សតក្ខត្តុំ សកឹ សទ្ធឹ សហ សាមំ សយំ ឥតិ
ក្វចិ កិញ្ចាបិ បដ្ឋាយ (ឥតិ នានត្ថវាចកា) ។

## បច្ច័យ

[១២៧] ដែលបាននិយាយក្នុងខាងដើមត្រង់លេខ ១២២ ខ្លះមកហើយថា, "ពួកបច្ច័យសម្រាប់ចុះត្រង់ខាងចុងធាតុជាកិរិយាសព្ទក៏បាន ចុះក្នុងខាងចុងនាមសព្ទក៏បាន" នោះ អ្នកសិក្សាត្រូវកំណត់ដឹងដូច្នេះថា, អព្យយបច្ច័យនោះ ខ្លះចុះបានតែក្នុងខាងចុងនាមសព្ទពីរយ៉ាង គឺនាមនាមនិងសព្វនាម មិនចំពោះដល់កិរិយាសព្ទផងទេ, ខ្លះចុះបានតែក្នុងខាងចុងកិរិយាសព្ទ មិនចំពោះដល់នាមនាមនិងសព្វនាមផងទេ, ឯគុណនាម នឹងយកបច្ច័យពួកនោះមកចុះខាងចុងពុំបានឡើយ, ដូចមានរបៀបរៀបរៀងតទៅនេះ

## តួបច្ច័យនិងឧទាហរណ៍

អព្យយបច្ច័យ មាន ២២ គឺ តោ, ត្រ, ត្ថ, ហ, ធ, ធិ, ហឹ, ហំ, ហិញ្ចនំ, វ, ទា, ទានិ, រហិ, ធុនា, ទាចនំ, ជ្ជ, ជ្ជុ, តវេ, តុំ, ត្វា, ត្វាន, តូន ។

បច្ច័យទាំង ២២ នេះចែកចេញជា ៤ ពួកតាមដំណើរដែលប្រើគឺ តោ មួយនេះទុកដូចជាពួកមួយ, ត្រ, ត្ថ, ហ, ធ, ធិ, ហឹ, ហំ, ហិញ្ចនំ, វ ៩ នេះជាពួកមួយ, ទា, ទានិ, រហិ, ធុនា, ទាចនំ, ជ្ជ, ជ្ជុ ៧ នេះជាពួកមួយ, តវេ, តុំ, ត្វា, ត្វាន, តូន ៥ នេះជាពួកមួយ ។

### ពួកទី ១

តោ-បច្ច័យ សម្រាប់ចុះបានតែក្នុងខាងចុងនាមនាមនិងសព្វនាម នឹងប្រើចុះក្នុងខាងចុងកិរិយាសព្ទពុំបានឡើយ ។ កាលបើចុះតោបច្ច័យហើយ តោបច្ច័យនោះជាគ្រឿងសម្គាល់ជំនួសវិភត្តិតតិយានិងបញ្ចមី ឬជាជំនួសវិភត្តិសត្តមីក៏បានខ្លះ។ បើជំនួសតតិយាវិភត្តិ ច្រើនមានសេចក្តីឲ្យប្រែថា "ខាង, តាម",

បើជំនួសវិភត្តិបញ្ចមីនិងសត្តមី ប្រែតាមអត្ថរបស់អាយតនិបាត សម្រាប់វិភត្តិទាំងពីរនោះ ។ បើចុះខាងចុងសព្វនាម ប្រើជាបទវិសេសនៈរបស់នាមនាមបានទាំង ៣ លិង្គ, ទាំងពីរវចនៈ ឬប្រើផ្ទាល់តាមទំនើងខ្លួនឯងក៏បានខ្លះ ហៅថា "អព្យយសព្វនាម" ។

| សព្ទដើម | បច្ច័យ | សម្រេចរូបជា | សព្ទប្រែ |
|---|---|---|---|
| សព្វ | តោ | សព្វតោ[១] | អំពី-ទាំងពួង,.. |
| អញ្ញ | តោ | អញ្ញតោ | អំពី-ដទៃ,-ឯទៀត... |
| អញ្ញតរ | តោ | អញ្ញតរតោ | អំពី-ណាមួយ... |
| ឥតរ | តោ | ឥតរតោ | អំពី-ក្រៅនេះ... |
| ឯក | តោ | ឯកតោ | ខាងម្ខាង,ក្នុង-ជាមួយគ្នា,ព្រមគ្នា.. |
| ឧភ | តោ | ឧភតោ | តាមខាងទាំងពីរ... |
| បរ | តោ | បរតោ | តាមខាងដទៃ... |
| ត | តោ | តតោ | អំពី-នោះ |
| ឯត | តោ | ឯតោ,អតោ | អំពី-នុ៎ះ, ខាងហ្នឹង... |
| ឥម | តោ | ឥតោ | អំពី-នេះ, ខាងនេះ... |

១ អ្នករៀនត្រូវទន្ទេញដូច្នេះថា "សព្វ និង តោ ជា សព្វតោ អំពី-ទាំងពួង" ។

| សព្ទដើម | បច្ច័យ | សម្រេចរូបជា | សព្ទប្រែ |
|---|---|---|---|
| អបរ | តោ | អបរតោ | អំពី-ដទៃទៀត... |
| បុរ | តោ | បុរតោ | ខាងមុខ... |
| បច្ឆា | តោ | បច្ឆតោ | ខាងក្រោយ... |
| ទក្ខិណ | តោ | ទក្ខិណតោ | ខាងស្តាំ... |
| វាម | តោ | វាមតោ | ខាងឆ្វេង... |
| ឧត្តរ | តោ | ឧត្តរតោ | ខាងលើ... |
| អធរ | តោ | អធរតោ | ខាងក្រោម... |
| យ | តោ | យតោ | អំពី-ឯណា... |
| អមុ | តោ | អមុតោ | អំពី-ឯណោះ... |
| កតរ | តោ | កតរតោ | អំពី-ណា... |
| កឹ | តោ | កុតោ | អំពី-ណា... |
| អត្ថ | តោ | អត្ថតោ | ដោយសេចក្តី... |
| សំខេប | តោ | សំខេបតោ | ដោយសង្ខេប |
| វិត្ថារ | តោ | វិត្ថារតោ | ដោយពិស្តារ |
| វិសេស | តោ | វិសេសតោ | ដោយសេចក្តីប្លែក |

| សព្ទដើម | បច្ច័យ | សម្រេចរូបជា | សព្ទប្រែ |
|---|---|---|---|
| បិតុ | តោ | បិតិតោ | ខាងបិតា... |
| មាតុ | តោ | មាតិតោ | ខាងមាតា... |

ពួកទី ២

បច្ច័យគឺ ត្រ, ត្ថ, ហ, ធ, ធិ, ហឹ, ហំ, ហិញ្ចនំ, វ ទាំង ៩ នេះ សម្រាប់ចុះបានតែក្នុងខាងចុងសព្វនាមតែម្យ៉ាងប៉ុណ្ណោះ នឹងចុះក្នុងខាងចុងនាមនាមនិងកិរិយាសព្ទពុំបានឡើយ ។ បច្ច័យទាំងនោះជាគ្រឿងសម្គាល់ជំនួសសត្តមីវិភត្តិ ប្រើជាបទវិ-សេសនៈរបស់នាមនាមបានទាំង ៣ លិង្គ, ទាំងពីរវចនៈ ហៅថា "អព្យយសព្វនាម" ។

| សព្ទដើម | បច្ច័យ | សម្រេចរូបជា | សព្ទប្រែ |
|---|---|---|---|
| សព្វ | ត្រ | សព្វត្រ | ក្នុង-ទាំងពួង,-ទាំងអស់,ទាំងមូល |
| សព្វ | ត្ថ | សព្វត្ថ | ក្នុង-ទាំងពួង,-ទាំងអស់,ទាំងមូល |
| សព្វ | ធិ | សព្វធិ | ក្នុង-ទាំងពួង,-ទាំងអស់,ទាំងមូល |
| អញ្ញ | ត្រ | អញ្ញត្រ | ក្នុង-ដទៃ,-ឯទៀត |

| សព្ទដើម | បច្ច័យ | សម្រេចរូបជា | សព្ទប្រែ |
|---|---|---|---|
| អញ្ញ | ត្ថ | អញ្ញត្ថ | ក្នុង-ដទៃ,-ឯទៀត |
| យ | ត្រ | យត្រ | ក្នុង-ឯណា,ត្រង់-ណា |
| យ | ត្ថ | យត្ថ | ក្នុង-ឯណា,ត្រង់-ណា |
| យ | ហឹ | យហឹ | ក្នុង-ឯណា,ត្រង់-ណា |
| យ | ហំ | យហំ | ក្នុង-ឯណា,ត្រង់-ណា |
| ត | ត្រ | តត្រ | ក្នុង-នោះ,ត្រង់-នោះ |
| ត | ត្ថ | តត្ថ | ក្នុង-នោះ,ត្រង់-នោះ |
| ត | ហឹ | តហឹ | ក្នុង-នោះ,ត្រង់-នោះ |
| ត | ហំ | តហំ | ក្នុង-នោះ,ត្រង់-នោះ |
| ឯត | ត្រ | អត្រ | ក្នុង-នុ៎ះ,-ហ្នឹង,ត្រង់-ហ្នឹង... |
| ឯត | ត្ថ | ឯត្ថ, អត្ថ | ក្នុង-នុ៎ះ,-ហ្នឹង,ត្រង់-ហ្នឹង... |
| ឯក | ត្រ | ឯកត្រ | ក្នុង-មួយ,ត្រង់-ម្ខាង |
| ឯក | ត្ថ | ឯកត្ថ | ក្នុង-មួយ,ត្រង់-ម្ខាង |
| ឧភយ | ត្រ | ឧភយត្រ | ក្នុង-ទាំងពីរ |
| ឧភយ | ត្ថ | ឧភយត្ថ | ក្នុង-ទាំងពីរ |

| សព្ទដើម | បច្ច័យ | សម្រេចរូបជា | សព្ទប្រែ |
|---|---|---|---|
| ឥម | ធ | ឥធ | ក្នុង-នេះ,ត្រង់-នេះ |
| ឥម | ហ | ឥហ | ក្នុង-នេះ,ត្រង់-នេះ |
| កឹ | ត្រ | កុត្រ | ក្នុង-ណា,ត្រង់-ណា |
| កឹ | ត្ថ | កត្ថ | ក្នុង-ណា,ត្រង់-ណា |
| កឹ | ហឹ | កុហឹ | ក្នុង-ណា,ត្រង់-ណា |
| កឹ | ហំ | កុហំ, កហំ | ក្នុង-ណា,ត្រង់-ណា |
| កឹ | ហិញ្ចនំ | កុហិញ្ចនំ | ក្នុង-ណា,ត្រង់-ណា |
| កឹ | វ | ក្វ | ក្នុង-ណា,ត្រង់-ណា |

## ពួកទី ៣

បច្ច័យ គឺ ទា, ទានិ, រហិ, ធុនា, ទាចនំ, ជ្ជ, ជ្ជុ ទាំង ៧ នេះ សម្រាប់ចុះបានតែក្នុងខាងចុងសព្វនាមតែម្យ៉ាងប៉ុណ្ណោះ នឹងចុះក្នុងខាងចុងនាមនាមឬកិរិយាសព្ទពុំបានឡើយ ។ បច្ច័យទាំងនោះជាគ្រឿងសម្គាល់ជំនួសសត្តមីវិភត្តិ ប៉ុន្តែមានដំណើរប្រើខុសគ្នាអំពីអព្យយបច្ច័យពួកទី ២ ដ្បិតអព្យយបច្ច័យពួកទី ២

ប្រើជាបទវិសេសនៈរបស់នាមនាម ឯបច្ច័យពួកទី ៣ នេះ ពិតជាប្រើជំនួសសត្តមីវិភត្តិមែន ប៉ុន្តែមិនប្រើជាបទវិសេសនៈរបស់នាមនាមទេ ប្រើប្រាប់សេចក្តីតាមទំនើងខ្លួនឯងតែម្តង ជាបច្ច័យប្រាប់កាលវេលា ហៅថា "កាលសត្តមី" ។

| សព្ទដើម | បច្ច័យ | សម្រេចរូបជា | សព្ទប្រែ |
|---|---|---|---|
| សព្វ | ទា | សព្វទា,សទា | ក្នុងកាលទាំងពួង,សព្វកាល,រាល់ដង |
| ឯក | ទា | ឯកទា | ក្នុងកាល១,ក្នុងកាលខ្លះ,ក្នុងកាលម្តង |
| យ | ទា | យទា | ក្នុងកាលឯណា,អង្កាល់ដែល,គ្រាណា |
| ត | ទា | តទា | ក្នុងកាលនោះ,គ្រានោះ,អង្កាល់នោះ |
| កឹ | ទា | កទា | ក្នុងកាលណា, អង្កាល់ |
| កឹ | ទា+ចិ[១] | កទាចិ | ក្នុងកាលណាៗ,ក្នុងកាលខ្លះ,ជួនណា |
| កឹ | រហិ+ចិ[២] | ករហិចិ | ក្នុងកាលណាៗ, ជួនកាល,... |
| កឹ | ទាចនំ | កុទាចនំ | ក្នុងកាលខ្លះ, ជួនកាល, ជួនណា,... |

១,២ ចិ ជាអសាកល្យត្ថវាចកនិបាត គឺនិបាតសព្ទប្រាប់សេចក្តីថា "ជួនណា,ជួនកាល,ខ្លះ" ជានិបាតសម្រាប់ចុះផ្សំជាមួយនឹងកឹសព្ទ (មើលកឹសព្ទក្នុងខាងដើមត្រង់លេខ ១១៧) ។

| សព្ទដើម | បច្ច័យ | សម្រេចរូបជា | សព្ទប្រែ |
|---|---|---|---|
| ឥម | ទានិ | ឥទានិ | ក្នុងកាលនេះ...ឥឡូវនេះ... |
| ឥម | ធុនា | អធុនា | ក្នុងកាលនេះ...អម្បាញ់មិញ.. |
| ឥម | ជ្ជ | អជ្ជ | ក្នុងកាលនេះ... ថ្ងៃនេះ |
| ឥម | ជ្ជុ | សជ្ជុ | ក្នុងថ្ងៃនេះ... |
| ឯត | រហិ | ឯតរហិ | ក្នុងកាលឥឡូវនេះ |
| បរ | ជ្ជុ | បរជ្ជុ | ក្នុងកាលដទៃ, ក្នុងថ្ងៃឯទៀត |
| អបរ | ជ្ជុ | អបរជ្ជុ | ក្នុងថ្ងៃដទៃទៀត |

## ពួកទី ៤

បច្ច័យគឺ តវេ, តុំ, ត្វា, ត្វាន, តូន ទាំង ៥ នេះសម្រាប់ចុះបានតែក្នុងខាងចុងធាតុជាកិរិយាសព្ទតែម្យ៉ាងប៉ុណ្ណោះ នឹងចុះខាងចុងនាមនាម ឬ សព្វនាមពុំបានឡើយ ជាបច្ច័យអាចនាំកិរិយាសព្ទដែលខ្លួនអាស្រ័យផងនោះឲ្យមានឈ្មោះថា "អព្យយសព្ទ" ជាពួកផ្សេងទីទៃអំពីកិរិយាសព្ទទាំងពួង (ចូរមើលក្នុងកិតកនិទ្ទេសខាងមុខត្រង់លេខ ១៧៣ និងលេខ ១៨១)។

| ធាតុ | បច្ច័យ | សម្រេចរូបជា | សព្ទប្រែ |
|---|---|---|---|
| ករ | តវេ | កាតវេ | ដើម្បីធ្វើ, ធ្វើ |
| ករ | តុំ | កត្តុំ, កាតុំ | ដើម្បីធ្វើ, ធ្វើ, រីកិរិយាធ្វើ |
| ករ | ត្វា | ករិត្វា, កត្វា | ធ្វើហើយ.... |
| ករ | ត្វាន | ករិត្វាន,កត្វាន | ធ្វើហើយ.... |
| ករ | តូន | កត្តូន, កាតូន | ធ្វើហើយ.... |

មួយគាថាកន្លុះសម្រាប់ឧទ្ទេញឲ្យដាំយចាំ

ឈ្មោះអព្យយបច្ច័យចាំង ២២

តោ ត្រ ត្ថ ហ ហឹ ហំ ធ ធិ ហិញ្ចនំ វ (ភុម្មិកា)

ទានិ-ជ្ជុ ទាចនំ ទា-ជ្ជ រហិ ធុនា (តិ កាលិកា)

តូន ត្វាន តវេ ត្វា តុំ (ឥតិ ធាតុន្និយោជនា) ។

នាមនិទ្ទេសទី ២ ចប់ដោយសង្ខេបតែប៉ុណ្ណោះ

---

## រៀបចំវាយអក្សរឡើងវិញនិងពិនិត្យតាមច្បាប់ដើមដោយ

## គណៈកម្មការពុទ្ធិកវប្បធម៌អង្គការមូលនិធិវត្តបញ្ញាធំ

ការវាយអក្សរ និងបោះពុម្ពសាឡើងវិញនូវសៀវភៅធម៌ដែលជាស្នាដៃចាស់ៗ របស់អ្នកនិពន្ធជំនាន់មុនគឺអាស្រ័យ ដោយការមើលឃើញ នូវកត្តាចាំបាច់មួយចំនួន ដូចខាងក្រោម ៖

- ឯកសារដើម ត្រូវបានថតចម្លងច្រើនសា ធ្វើឲ្យមានលក្ខណៈមិនច្បាស់ ពិបាកក្នុងការអាន
- រក្សាស្នាដៃវប្បធម៌ព្រះពុទ្ធសាសនាឲ្យគង់វង្សស្ថិតស្ថេរ
- តម្រូវការរបស់សិក្ខាកាមអ្នកប្រាថ្នាចង់យល់ដឹងនូវខ្លឹមសារពុទ្ធសាសនា
- ផ្សាយនូវធម្មទាន ធ្វើឲ្យព្រះពុទ្ធសាសនាកាន់តែមានភាពរីកចម្រើនរុងរឿងក្នុងលោក

ក្នុងករណីដែលលោកអ្នកអានបានពើបប្រទះនូវកំហុសឆ្គងណាមួយ
ចង់ឲ្យយើងកែតម្រូវ ឬចង់បានសៀវភៅធម៌យកទៅអាន
សូមទាក់ទងមកយើងខ្ញុំតាមអាសយដ្ឋានដូចខាងក្រោមៈ
វត្តបញ្ញា សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
លេខទូរស័ព្ទ: (៨៥៥) ១២ ៩៦១ ៩២៩, (៨៥៥) ៨៨៧ ៩៦១ ៩២៩
អ៊ីមែល: maha.panna@gmail.com
គេហទំព័រ: http://www.mahapanna.org

## Taking Refuge with a mind of Bodhichitta

**In the Buddha, the Dharma and the Sangha,**
**I shall always take refuge**
**Until the attainment of full awakening.**

**Through the merit of practicing generosity**
**and other perfections,**
**May I swiftly accomplish Buddhahood,**
**And benefit of all sentient beings.**

## The Prayers of the Bodhisattvas

**With a wish to awaken all beings,**
**I shall always go for refuge**
**To the Buddha, Dharma, and Sangha,**
**Until I attain full enlightenment.**

**Possessing compassion and wisdom,**
**Today, in the Buddha's presence,**
**I sincerely generate**
**the supreme mind of Bodhichitta**
**For the benefit of all sentient beings.**

"As long as space endures,
As long as sentient beings dwell,
Until then, may I too remain
To dispel the miseries of all sentient beings."

With bad advisors forever left behind,
From paths of evil he departs for eternity,
Soon to see the Buddha of Limitless Light
And perfect Samantabhadra's Supreme Vows.

The supreme and endless blessings
of Samantabhadra's deeds,
I now universally transfer.
May every living being, drowning and adrift,
Soon return to the Pure Land of Limitless Light!

**✻ The Vows of Samantabhadra ✻**

I vow that when my life approaches its end,
All obstructions will be swept away;
I will see Amitabha Buddha,
And be born in His Western Pure Land of
Ultimate Bliss and Peace.

When reborn in the Western Pure Land,
I will perfect and completely fulfill
Without exception these Great Vows,
To delight and benefit all beings.

**✻ The Vows of Samantabhadra Avatamsaka Sutra ✻**

*"Wherever the Buddha's teachings have flourished,*

*either in cities or countrysides,*

*people would gain inconceivable benefits.*

*The land and people would be enveloped in peace.*

*The sun and moon will shine clear and bright.*

*Wind and rain would appear accordingly,*

*and there will be no disasters.*

*Nations would be prosperous*

*and there would be no use for soldiers or weapons.*

*People would abide by morality and accord with laws.*

*They would be courteous and humble,*

*and everyone would be content without injustices.*

*There would be no thefts or violence.*

*The strong would not dominate the weak*

*and everyone would get their fair share."*

~THE BUDDHA SPEAKS OF
THE INFINITE LIFE SUTRA OF
ADORNMENT, PURITY, EQUALITY
AND ENLIGHTENMENT OF
THE MAHAYANA SCHOOL~

# NAME OF SPONSOR
# 助 印 功 德 芳 名

**Book's Title: Tool to support Kaccāyana Vol. 1**

**書 名：柬埔寨文：Tool to support Kaccāyana Vol. 1，**

**巴利文文法工具書 第一冊**

**Book Serial No., 書 號：CA044**

N.T. Dollars：

**101,789：AMITABHA BUDDHIST SOCIETY OF USA**

美國淨宗學會

**Amount：** N.T. Dollars **101,789；Print 5,000 copies**

**以上合計：新台幣 101,789 元；恭印伍千冊。**

**Dedication of Merits:**

Wherever the Buddha's teachings have flourished, either in cities or countrysides,
People would gain inconceivable benefits.
The land and people would be enveloped in peace.
The sun and moon will shine clear and bright.
Wind and rain would appear accordingly, and there will be no disasters.
Nations would be prosperous and there would be no use for soldiers or weapons.
People would abide by morality and accord with laws.
They would be courteous and humble, and everyone would be content without injustices.
There would be no thefts or violence.
The strong would not dominate the weak and everyone would get their fair share.

**回向：**天下和順，日月清明，風雨以時，災厲不起，國豐民安，兵戈無用，
崇德興仁，務修禮讓，國無盜賊，無有怨枉，強不凌弱，各得其所。
法界一切有情，所有六道四生，宿世冤親，現世業債，咸憑法力，悉得解脫。
現世者增福延壽，發菩提心，常隨佛學，勤修精進，利濟群生。
已故者往生淨土，同出苦輪，共登覺岸，直證阿鞞跋致，圓滿無上菩提。

**附記：**本會接受善信發心印贈經書，其必要之費用，皆經本會審慎評估；
若有結餘，均續作本會之印(購)經書及運費使用，為施主廣積陰德。

# DEDICATION OF MERIT

May the merit and virtue
accrued from this work
adorn Amitabha Buddha's Pure Land,
repay the four great kindnesses above,
and relieve the suffering of
those on the three paths below.
May those who see or hear of these efforts
generate Bodhi-mind,
spend their lives devoted to the Buddha Dharma,
and finally be reborn together in
the Land of Ultimate Bliss.
Homage to Amita Buddha!

**NAMO AMITABHA**
**南無阿彌陀佛**

《東埔寨巴利文：Tool to support Kaccāyana Vol. 1，
巴利文文法工具書 第一冊》

財團法人佛陀教育基金會 印贈
台北市杭州南路一段五十五號十一樓
Printed and donated for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org
Website:http://www.budaedu.org
Mobile Web: m.budaedu.org
**This book is strictly for free distribution, it is not to be sold.**
សម្រាប់ចែកជាធម្មទាន
Printed in Taiwan
5,000 copies; March 2015
CA044 - 13025